# បុញ្ញកិរិយាវត្ថុ១០

រៀបរៀងដោយ

ភិក្ខុ សុវណ្ណជោតោ គួង~សុវណ្ណ

ពុទ្ធសករាជ ២៥៤៧

(សម្រាប់ជាធម្មទាន)

# បុណ្យកិរិយាវត្ថុ១០

រៀបរៀងដោយ

ភិក្ខុ សុវណ្ណជោតោ គួង-សុវណ្ណ

វត្តនិគ្រោធវ័ន

ពុទ្ធសករាជ ២៥៤៧

(សម្រាប់ជាធម្មទាន)

~សៀវភៅ **បុញ្ញកិរិយាវត្ថុ១០**

~រៀបរៀងដោយធម្មាចារ្យ **សុវណ្ណជោតោ ឆួន~សុវណ្ណ**

~អ្នកពិនិត្យ ធម្មាចារ្យ **ធម្មបាលោ សាន~សប្បាយ**

ធម្មាចារ្យ **អគ្គធីរោ គង់~សុមិត្ត**

សាមណេរ **អាន~វណ្ណះ** សាមណេរ **ទ្រី~ចៅណៃ**

សាមណេរ **សេង~វ៉ុន** សាមណេរ **រី~សារ៉ែន**

~អ្នកមានឧបការៈ លោកម្ចាស់គ្រូ មេត្តាបាលោ ទឹម សឿត

បានអនុញ្ញាតឱ្យប្រើប្រាស់កុំព្យូទ័ររបស់សង្ឃ ។

ភិក្ខុអគ្គធីរោ គង់ សុមិត្ត អ្នកវាយអត្ថបទ

ព្រះសង្ឃ និង ពុទ្ធបរិស័ទ វត្តនិគ្រោធវ័ន "គល់ទទឹង"

ឧបាសិកា ហុង ចេង ជាវេយ្យាវច្ចករ ។

~ទីកន្លែងធ្វើ វត្តនិគ្រោធវ័ន "គល់ទទឹង" ។

~ធម្មទានដោយ ពុទ្ធបរិស័ទទូទៅ

~ពុទ្ធសករាជ ២៥៤៧

# អារម្ភកថា

សៀវភៅ **បុញ្ញកិរិយាវត្ថុ ១០** នេះ កើតឡើងដោយអាស្រ័យហេតុខាងក្រោមនេះ ៖

១-ខ្ញុំព្រះករុណា អាត្មាភាព បានសិក្សារៀនសូត្រព្រះធម៌តាមរយៈគម្ពីរព្រះត្រៃបិដក និងអដ្ឋកថាជាដើម បានឃើញព្រះពុទ្ធដីកាពីរោះៗ ដែលទាក់ទងក្នុងកិច្ចការបុណ្យកុសល និងកិច្ចបដិបត្តិផ្សេងៗ ក្នុងបុញ្ញកិរិយាវត្ថុទាំង ១០ យ៉ាង ដែលជាសេចក្តីល្អគួរធ្វើ ព្រោះជាហេតុ ជាទីតាំងនៃផលល្អកើតឡើងដែលសម្រាប់ជម្រះសេចក្តីសៅហ្មងក្នុងសន្តានចិត្ត និងជាហេតុជាទីតាំងនៃផលល្អ ដែលសប្បុរសទាំងឡាយ គួរធ្វើ គួរបដិបត្តិ គួរបម្រើន... ។

២-ដោយមានសេចក្តីសង្វេគក្នុងជីវិត ព្រោះបានឃើញព្រះពុទ្ធដីកាមួយកន្លែងដែលព្រះមានព្រះភាគ ត្រាស់ថា ៖

"ឧបនីយតិ ជីវិតមប្បមាយុំ ជរូបនីតស្ស ន សន្តិ តាណា ឯតំ ភយំ មរណេ បេក្ខមានោ លោកាមិសំ បជហេ សន្តិបេក្ខោ : ជីវិតគឺអាយុ (របស់សត្វទាំងឡាយ) តិចតួចពេកណាស់ ជ្បិតជរាតែងនាំចូលទៅរក (សេចក្តីស្លាប់)

កាលបើសត្វដែលត្រូវជរានាំចូលទៅជិត (សេចក្តីស្លាប់)ហើយ នឹងរកអ្វីជ្រកកោនពុំមានឡើយ កាលបើបុគ្គលសំឡឹងឃើញភ័យនុ៎ះ ក្នុងសេចក្តីស្លាប់ហើយ ជាអ្នកប្រាថ្នាសេចក្តីស្ងប់ ត្រូវតែលះបង់អាមិសៈ ក្នុងលោកចេញ " ។

ព្រោះហេតុនោះ បានជាខ្ញុំព្រះករុណា អាត្មាភាព ខំប្រឹងសិក្សាស្រាវជ្រាវ ដកស្រង់ព្រះពុទ្ធដីកាខ្លះ ដែលមាននៅក្នុងគម្ពីរព្រះត្រៃបិដក និងប្រែសេចក្តីក្នុងអដ្ឋកថានិងបរមត្ថជោតិកៈជាដើម ដែលទាក់ទងក្នុងបុញ្ញកិរិយាវត្ថុ រៀបរៀងឲ្យកើតជាសៀវភៅនេះឡើង ដើម្បីបានជាប្រយោជន៍ សម្រាប់ពុទ្ធបរិស័ទសិក្សារៀនសូត្រ និងគោរពប្រតិបត្តិ នៅក្នុងព្រះពុទ្ធសាសនា នឹងបាននូវសេចក្តីចម្រើនតទៅ ។

សៀវភៅនេះ គង់មានខុសដោយអត្ថនិងព្យញ្ជនៈ និងអក្ខរាវិរុទ្ធខ្លះ ឬ មានការខុសឆ្គងដោយប្រការណាមួយពុំខានជួនកាលខុសដោយសេចក្តីភ្លាំងភ្លាត់ ជួនកាលខុសដោយចេះមិនដល់ ការខុសទាំងអស់នេះ សូមអភ័យទោស និង សូមអ្នកប្រាជ្ញទាំងជួយកែសម្រួល តាមព្រះពុទ្ធឱវាទ ដោយកុសលចេតនាផងចុះ ។

*ដោយមហាកុសលចេតនាណា ដែលកើតអំពីធម្មទាន សូមឧទ្ទិសនូវសៀវភៅនេះ ជាសក្ការបូជាថ្វាយចំពោះព្រះរតនត្រ័យ សូមបុណ្យកុសល បានសម្រេចដល់ញាតិមួយអន្លើដល់សព្វសត្វទាំងពួងទាំងឡាយ ព្រមទាំងអ្នកដែលកំពុងកាន់អាននូវសៀវភៅនេះ ចូរបានសេចក្ដីសុខ ឲ្យមានសេចក្ដីក្សេម ចូរជាអ្នកសោយរសនៃព្រះសទ្ធម្ម របស់ព្រះមានព្រះភាគចុះ ។*

*សូមអនុមោទនា !!!*

**ពុទ្ធមណ្ឌលមហាសតិប្បដ្ឋាន**

**វត្តនិគ្រោធវ័ន "គល់ទទឹង"**

ថ្ងៃ ១១ កើត ខែផល្គុន ឆ្នាំមមែ ព.ស.២៥៤៧

**ភិក្ខុ សុវណ្ណជោតោ ភួង-សុវណ្ណ**

# សេចក្តីបញ្ជាក់

សៀវភៅ **បុញ្ញកិរិយាវត្ថុ១០** នេះ ខ្ញុំបាន រៀបរៀងឡើង និងបានបោះពុម្ព ក្នុងពុទ្ធសករាជ ២៥៤៧ កាលនោះដាក់ឈ្មោះសៀវភៅ **ទសបុញ្ញ-កិរិយាវត្ថុ** រហូតមកដល់ពុទ្ធសករាជ ២៥៥៤ នេះ ដោយ មានព្រះករុណាជាច្រើនរូប និងពុទ្ធបរិស័ទជាច្រើន ផងដែរ ចេះតែមកសួររកសៀវភៅនេះ ខ្ញុំព្រះកុណា ក៏បានចាត់ចែងយកទៅបោះពុម្ពជាថ្មី ប៉ុន្តែចំពោះការ បោះពុម្ពថ្មីនេះ ខ្ញុំព្រះកុណា បានកែសម្រួល និងថែម សេចក្តីខ្លះទៀត ដើម្បីឱ្យសៀវភៅនេះ មានលក្ខណៈ កាន់តែល្អប្រសើរ ។

សូមពុទ្ធបរិស័ទ ត្រេកអរអនុមោទនានូវកុសល-ធម្មទានគ្រប់យ៉ាង សូមបានសេចក្តីសុខ រួចផុតចាកទុក្ខ ទាំងពួង សូមអនុមោទនា !!!

# សន្លឹកប្រាប់មាតិកា

**មាតិកា** **ទំព័រ**

អារម្ភកថា ........................................................ ក

សន្លឹកប្រាប់មាតិកា ........................................... ង

I. អធិប្បាយកិច្ចការបុណ្យផ្សេងៗ ................................ ១

II. ពាក្យបុញ្ញកិរិយាវត្ថុ ១០ ........................................ ៥

III. បុញ្ញកិរិយាវត្ថុ ១០ សម្ដែងជាពីរន័យ ...................... ៧

IV. វចនត្ថរបស់បុញ្ញកិរិយាវត្ថុ ១០ ប្រការ

ព្រមទាំងពាក្យអធិប្បាយ និងប្រភេទ .................... ៩

**១-ទានមយៈ ៩**

១.១ ទានវត្ថុក្នុងព្រះវិន័យ ៤ យ៉ាង ...................... ១៥

១.២ ទានពួកពីរ ............................................. ១៥

១.៣ ទានពួក ៣ (តិកទាន) ............................... ១៨

១.៤ ទានពួក ៥ អសប្បុរិសទាន ៥ យ៉ាង ............ ២៤

សប្បុរិសទាន ៥ យ៉ាង ................................ ២៥

សប្បុរិសទាន ៥ យ៉ាង ព្រមទាំងអានិសង្ស ...... ២៦

កាលទាន ៥ យ៉ាង .................................... ២៩

១.៥ ឆឡង្គទាន ............................................... ៣០

១.៦ ទានមាន ៨ យ៉ាង .................................... ៣៩

១.៧ ទានវត្ថុ ៨ យ៉ាង ...................................... ៤២

១.៨ សប្បុរិសទាន ៨ យ៉ាង ................................ ៤៤

១.៩ ទាន ២១ យ៉ាង ........................................ ៤៥

បាដិបុគ្គលិកទាន មាន ១៤ ........................... ៤៦

សង្ឃគតាទក្ខិណាទាន មាន ៧ ...................... ៤៨

អធិប្បាយបាដិបុគ្គលិកទាន .......................... ៤៩

អធិប្បាយសង្ឃគតាទក្ខិណាទាន ................... ៥៩

១.១០ សរុបទាន ............................................ ៦៦

១.១១ បាលីសម្តែងការសរុបទានទាំង ៤ យ៉ាង ...... ៦៦

១.១២ លក្ខណៈជាដើមរបស់ទានកុសល .............. ៦៨

១.១៣ បដិក្ខេបធមិជាដើមរបស់ទានកុសល ......... ៦៨

១.១៤ អានិសង្សទាន ៥ យ៉ាង .......................... ៦៩

១.១៥ ការកើតឡើងនៃទានមាន ៨ យ៉ាង ........... ៧០

១.១៦ បុព្វយោគរបស់ព្រះបាទមហាសុទស្សន ....... ៧៦

ផលនៃកុសល ........................................ ៧៩
១.១៧ រឿងព្រះបាទនន្ទរាជ .............................. ៨២
១.១៨ រឿងព្រះទេវីព្រះនាមគោបាលមាតា .......... ៨៧
**២-សីលមយៈ** ................................................... ៩០
២.១ សីលប្បភេទកថា ..................................... ៩៥
ក្រុមសីល២ (ចែកជា ៧ ពួក) .................... ៩៦
ក្រុមសីល៣ (ចែកជា ៥ ពួក) .................... ៩៧
ក្រុមសីល៤ (ចែកជា ៤ ពួក) ..................... ៩៧
ក្រុមសីល៥ (ចែកជា ២ ពួក) .................... ៩៨
២.២ ប្រភេទនៃសីល ....................................... ៩៩
២.៣ ភាពជាអ្នកទ្រុស្តសីលនិងអលជ្ជីនៃភិក្ខុនិងភិក្ខុនី ១០២
២.៤ អ្នកទ្រុស្តសីលនិងអលជ្ជី សម្រាប់សាមណេរ ... ១០៤
២.៥ អ្នកទ្រុស្តសីលនិងអលជ្ជីសម្រាប់គ្រហស្ថ ........ ១០៧
២.៦ ពាក្យថាទ្រុសសីល .................................... ១០៨
២.៧ ការសមាទានសីលរបស់គ្រហស្ថ ២ ប្រភេទ ... ១០៩
ការសមាទានសីល ៥ ជាឯកជ្ឈសមាទាន ...... ១១៣

ការសមាទានសីល ៥ ជាបច្ចេកសមាទាន ...... ១១៤
ការសមាទានឧបោសថសីលជាឯកជ្ឈសមាទាន ១១៥
ការសមាទានឧបោសថសីលជាបច្ចេកសមាទាន ១១៥
សេចក្ដីខុសប្លែកគ្នានៃការសមាទាន ............ ១១៦
២.៨ បាដិហារិយបក្ខឧបោសថ .......................... ១១៧
២.៩ សីលវិសេសរបស់ឃរាវាសទាំងឡាយ ........... ១១៩
២.១០ ឈ្មោះនៃអាជីវដ្ឋមកសីល និងការផ្សេងគ្នា
របស់អ្នករក្សាបញ្ចសីលនិងអាជីវដ្ឋមកសីល .... ១២០
២.១១ ការចែកសីលដោយនិច្ចសីលនិងអនិច្ចសីល ... ១២១
២.១២ ការចែកសីលដោយចារិត្តសីលនិងវារិត្តសីល ១២២
២.១៣ វិធីសមាទានព្រមទាំងពុទ្ធប្រណាម
ត្រៃសរណគមន៍និងសិក្ខាបទ ........................ ១២៣
២.១៤ វិធីសមាទានអាជីវដ្ឋមកសីល .................... ១២៣
២.១៥ វិធីសមាទាននវង្គុបោសថសីល .................. ១១៦
២.១៦ វិធីសមាទានទសង្គសីល .......................... ១១៩
២.១៧ ភស្តុតាងដែលទទួលបាន ក្រោយពីរក្សាសីល ១៣៣
២.១៨ លក្ខណជាដើមរបស់សីលកុសល ................ ១៣៥

២.១៩ បដិក្ខេបធម៌ជាដើមរបស់សីលកុសល .......... ១៣៦

២.២០ អានិសង្សឧបោសថសីល .......................... ១៣៧

២.២១ អានិសង្សសីល ....................................... ១៣៩

២.២២ សីលវត្ថេរគាថា ...................................... ១៤៧

២.២៣ សីលវិមំសជាតក .................................... ១៥១

**៣-ភាវនាមយៈ** ........................................................ ១៥៤

៣.១ លក្ខណជាដើមរបស់ភាវនាកុសល ............... ១៥៦

៣.២ បដិក្ខេបធម៌ជាដើមរបស់ភាវនាកុសល ......... ១៥៧

**៤-អបចាយនមយៈ** .................................................. ១៥៨

៤.១ អបចាយនៈមាន ២ យ៉ាង ......................... ១៥៩

៤.២ បុគ្គលដែលគួរគោរពឱនលំទោន ៣ ប្រភេទ ... ១៦០

៤.៣ សេចក្តីគោរពនិងមិនគោរព ........................ ១៦២

៤.៤ គាថាសម្តែងអានិសង្សរបស់អបចាយនៈ ........ ១៦៧

**៥-វេយ្យាវច្ចមយៈ** .................................................. ១៧០

៥.១ បុញ្ញកម្មរបស់ឧត្តរមាណព ......................... ១៧២

៥.២ បុញ្ញកម្មរបស់ព្រះរាជាចណ្ឌបជ្ជោត ................ ១៧៣

**៦-បត្តិទានមយៈ** ........................................ ១៧៨

**៧-បត្តានុមោទានមយៈ** ........................................ ១៨០

៧.១ ការអនុមោទនាបុណ្យដែលមិនឈ្មោះថា

បត្តានុមោទនាដោយត្រង់ ........................... ១៨២

៧.២ ចំណែកបុណ្យដែលគេឧទ្ទិសឱ្យ ២ ប្រការ ........ ១៨៣

៧.៣ វិធីចែកបុណ្យប្រភេទឧទ្ទិស្សិកបត្តិ ............... ១៨៧

៧.៤ វិធីចែកបុណ្យប្រភេទអនុទ្ទិស្សិកបត្តិ ............. ១៨៨

៧.៥ រឿងឧបាសកម្នាក់ ..................................... ១៨៨

៧.៦ រឿងសង្ខព្រាហ្មណ៍ .................................... ១៩០

៧.៧ វិហារវិមាន ............................................ ១៩២

៧.៨ រឿងប្រេតជាមាតានៃព្រះសារីបុត្ត ................ ១៩៥

៧.៩ ការអនុមោទនាបុណ្យជាការប្រដៅចិត្តមួយផ្នែក ២០២

**៨-ធម្មស្សវនមយៈ** ........................................ ២០៤

៨.១ ការស្តាប់ធមិតាមកាលជាមង្គល .................. ២០៦

៨.២ អានិសង្សទាំងឡាយ ៤ ប្រការ នៃធមិ

ដែលចូលទៅកាន់ត្រចៀករឿយៗ ................ ២១០

៨.៣ រឿងកុក្កុដី ធម្មស្សវនកថា ......................... ២១៩

**៩-ធម្មទេសនាមយៈ** .................................................... ២២២

៩.១ អានិសង្សធម្មទេសនាកុសល ........................ ២២៣

៩.២ ធម្មទាន .................................................... ២២៦

៩.៣ ធម្មកថិកអ្នកសម្តែងធម៌មាន ៥ យ៉ាង ........... ២៣៥

៩.៤ គាថាក្នុងកិន្ទទសូត្រ ....................................... ២៣៦

១០-ទិដ្ឋុជុកម្ម .................................................... ១៣៨

១០.១ បច្ច័យនៃកម្មស្សកតាញាណ ៣ .................. ១៤២

១០.២ សម្មាទិដ្ឋិ ១០ ប្រការ .............................. ១៤៣

១០.៣ អង្គធម៌របស់ទិដ្ឋុជុកម្ម ក្នុងខណៈទាំង ៣
របស់ចេតនា .................................................... ២៤៦

១០.៤ សរុបបុញ្ញកិរិយាវត្ថុ ៧ ប្រការ ចូលក្នុងទាន
សីល ភាវនា .................................................... ២៥០

១០.៥ អធិប្បាយធម៌ជាបដិបក្ខនឹងទានជាដើម ....... ២៥២

១០.៦ ការសង្គ្រោះធម្មទេសនានិងទិដ្ឋុជុកម្ម ន័យមួយទៀត
តាមអដ្ឋកថា អធិប្បាយពុទ្ធភាសិត ................ ២៥៦

១១-និធិកណ្ឌសូត្រ ............................................ ២៥៩

# ព្រះគាថាគាថាព័ន្ធ

*(សុត្តន្តបិដក លេខ៥៣ ទំព័រ៦៩)*

បុញ្ញមេវ សោ សិក្ខេយ្យ អាយតគ្គំ សុខិន្ទ្រិយំ
ទានញ្ច សមចរិយញ្ច មេត្តចិត្តញ្ច ភាវយេ
ឯតេ ធម្មេ ភាវយិត្វា តយោ សុខសមុទ្ទយេ
អព្យាបជ្ឈំ សុខំ លោកំ បណ្ឌិតោ ឧបបជ្ជតិ ។

*កុលបុត្រអ្នកប្រាថ្នាប្រយោជន៍ គួរសិក្សានូវបុណ្យ ដែលមានផលបរិបូរណ៍ មានវិបាកជាសុខ គឺគួរចម្រើនទានផង ការប្រព្រឹត្តិស្មើ គឺសីលផង មេត្តាចិត្តផង លុះចម្រើនធម៌ទាំង ៣ នេះ ដែលមានអានិសង្សជាសុខហើយ រមែងចូលទៅកាន់លោកដែលជាសុខ ឥតមានការបៀតបៀន ។*

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ*

*អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

# ទសបុញ្ញកិរិយាវត្ថុ

## I. អធិប្បាយកិច្ចការបុណ្យផ្សេងៗ

"ចិត្តុប្បាទវសេន បណេតំ អដ្ឋវិធំ ហោតិ"

*ការធ្វើកិច្ចការបុណ្យផ្សេងៗ ដោយកាយ វាចា ចិត្ត ដែលជាសេចក្តីល្អ របស់បុគ្គលក្នុងលោក ដែលសប្បុរសទាំងឡាយបានទទួលស្គាល់ថា "ជាសេចក្តីល្អ" ព្រោះមិនមានការជំទាស់នឹងឱវាទ ពាក្យទូន្មានរបស់ព្រះសម្មាសម្ពុទ្ធ ដែលបុគ្គលទាំងឡាយបានប្រព្រឹត្តបដិបត្តិតមក រហូតដល់សព្វថ្ងៃនេះនោះ សុទ្ធតែជាកាមាវចរកុសលទាំងអស់ ។ ការងារដែលជាសេចក្តីល្អផ្សេងៗ ទាំងអស់នោះ កាលពណ៌នាតាមវោហារ (ការពោល)ហើយ ក៏មានច្រើនជាទីបំផុត ដែលមិនអាចពណ៌នាឲ្យអស់បាន ។ ទោះបីជាយ៉ាងនោះក៏ដោយ សេចក្តីល្អ*

ផ្សេងៗទាំងនោះ មិនមែនជាការធ្វើល្អអ្វីដទៃក្រៅអំពីកុសល-កម្មបថ ១០ និង បុញ្ញកិរិយាវត្ថុ ១០ នេះទេ ។

ដូច្នោះ ការសម្តែងការងារបុណ្យកុសល ដែលជាសេចក្តីល្អ មានកុសលកម្មបថ ១០ និងបុញ្ញកិរិយាវត្ថុ ១០នេះជាការពោលតាមផ្នែកសុត្តន្តន័យ ។ តែបើពោលតាមសភាវន័យហើយ ក៏បានដល់ការកើតឡើងរបស់មហាកុសល-ចិត្តុប្បាទ ៨ ដួងនោះប៉ុណ្ណោះ ។

មួយទៀត ការងារដែលមនុស្សទាំងឡាយ បាននាំគ្នាធ្វើមកនេះ បើពោលតាមសេចក្តីពិតហើយ ក៏បានដល់រូបនិងនាម គឺ កាយនិងចិត្តទាំងពីរប៉ុណ្ណោះ ដែលជាអ្នកធ្វើឡើង ។ ពោលគឺ **កាយ** មាននាទីធ្វើ, ចិត្តមាននាទីបញ្ជា ដូចអ្នកធ្វើការជាមួយមេការ ឬ ដូចតួរថនិងអ្នកបររថ ព្រោះហេតុនោះអ្នកដែលមិនចូលចិត្តក្នុងនាមធម៌ គឺ **ចិត្ត** ត្រឹមតែយល់ចូលចិត្តក្នុងរូបធម៌ គឺ រាងកាយតែម្យ៉ាង, កាលខ្លួនឯងធ្វើមិនល្អ ឬឃើញអ្នកដទៃធ្វើមិនល្អ ក៏មិនអាចដោះស្រាយកែខៃឲ្យត្រឡប់ជាល្អឡើងវិញបាន ត្រឹមតែធ្វើការដោះស្រាយ កែលំអដោយវិធីពក់ៗ បន្តិចបន្តួច កាលខ្លួនឯងធ្វើល្អ ឬ ឃើញអ្នកដទៃធ្វើល្អ នឹងធ្វើការគាំទ្រ លើកទឹកចិត្តឲ្យល្អក្រៃលែងឡើង

ទៅ ក៏ធ្វើមិនបានដូចគ្នា ។ បើបានក៏ត្រឹមតែបន្តិចបន្តួច មិនអាចគាំទ្រ លើកទឹកចិត្ត ឲ្យជ្រួតជ្រាបដល់ចិត្តពិតបាន ។ ការជាដូច្នេះ ក៏ព្រោះការដោះស្រាយកែលំអ និងការគាំទ្រ លើកទឹកចិត្តរបស់មនុស្សយើងនេះ ធ្វើបានជាយ៉ាងល្អបំផុត ត្រឹមតែរូបរាងកាយដែលជារបស់ខាងក្រៅម្យ៉ាង ។ ចំណែក អ្នកដែលមានសេចក្តីចូលចិត្តល្អទាំងរូប និង នាមនោះ បើធ្វើ ការដោះស្រាយកែលំអ ការធ្វើផ្លូវកាយ វាចា ចិត្ត ដែល មិនល្អរបស់ខ្លួនឯង ឬបុគ្គលដទៃ ក៏ធ្វើការដោះស្រាយឲ្យ សម្រេចបាន ការមានឱកាសធ្វើការលើកទឹកចិត្ត ការធ្វើតាម ផ្លូវកាយ វាចា ចិត្ត ដែលល្អរបស់ខ្លួនឯង ឬបុគ្គលដទៃហើយ ក៏អាច(លើកទឹកចិត្ត) ឲ្យជ្រួតជ្រាបដល់ចិត្តបានយ៉ាងល្អ ។

ការប្រព្រឹត្តិទៅដូច្នេះ ក៏ព្រោះជាប់មកអំពីសេចក្តី សម្គាល់របស់រូបនិងនាម គឺ កាយ ចិត្ត មានសេចក្តីសម្គាល់ ផ្សេងៗគ្នានោះឯង គឺ កាយមាននាទីធ្វើតាមពាក្យបង្គាប់របស់ ចិត្ត, ចិត្តមាននាទីនឹកគិត ពិចារណា ត្រិះរិះ ចាត់ចែង បង្គាប់ ឲ្យកាយវាចា ដែលជារូប ធ្វើការងារតាមចិត្តបង្គាប់ ។ ដោយហេតុនេះ ការងារដែលល្អ ដែលជាកុសលកម្មបថ ១០

និង បុញ្ញកិរិយាវត្ថុ ១០ ដែលប្រាកដប្រព្រឹត្តទៅក្នុងប្រជុំជនគ្រប់ថ្នាក់ គ្រប់ជាតិសាសន៍បាននោះ ក៏ព្រោះដោយសារហេតុជាប់មកអំពីមហាកុសលចិត្តុប្បាទ ៨ ដួង ដែលជានាមធម៌ គឺ ចិត្តនោះឯង ។

បើវៀរចាកមហាកុសលចិត្តុប្បាទ ៨ ដួង នេះចេញហើយ ការធ្វើល្អ មានកុសលកម្មបថ ១០ និង បុញ្ញកិរិយាវត្ថុ ១០ ក៏ត្រូវសាបសូន្យទៅអំពីពួកមនុស្សទាំងស្រុង នៅមានតែការធ្វើដែលជាទុច្ចរិត (អំពើអាក្រក់តាមផ្លូវកាយវាចានិងចិត្ត) ទុរាជីព (មានការចិញ្ចឹមជីវិតអាក្រក់) តែម្យ៉ាង មានប្រាកដនៅក្នុងមនុស្សលោក ដែលជាប់មកអំពីអកុសលចិត្តុប្បាទ ជាអ្នកបញ្ជា កាលជាដូច្នេះ មនុស្សលោកនេះ ក៏មិនផ្សេងអ្វីពីសត្វ-តិរច្ឆាន បើនឹងនិយាយយ៉ាងខ្លីហើយ ពេលណាមហាកុសលចិត្តុប្បាទ ៨ ដួង ជាអ្នកបញ្ជា កាយ វាចា ធ្វើល្អ ពេលនោះការធ្វើរបស់ជនទាំងឡាយ ក៏តាំងនៅក្នុងកុសលកម្មបថ បុញ្ញកិរិយាវត្ថុ ១០ ។ ពេលណា អកុសលចិត្តុប្បាទ ១២ ដួង ជាអ្នកបញ្ជា ពេលនោះ ការធ្វើក៏ជាទុច្ចរិត ទុរាជីពទៅ ។

*ហេតុនោះឯង ព្រះអនុរុទ្ធាចារ្យ ទើបមានសេចក្តីប្រាថ្នាចង់ឲ្យដឹងមូលហេតុ ដែលជាអង្គធម៌នៃការធ្វើកុសលកម្មបថ ១០ និង បុញ្ញកិរិយាវត្ថុ ១០ តទៅដោយបាលីថា ៖*

"ចិត្តុប្បាទវសេន បនេតំ អដ្ឋវិធំ ហោតិ *ប្រែថា កាមាវចរកុសលកម្មនេះ កាលពោលដោយការកើតឡើងរបស់ចិត្តហើយ រមែងមាន ៨ " ។*

## II. ពាក្យថាបុញ្ញកិរិយាវត្ថុ

*នៅក្នុងគម្ពីរបរមត្ថទីបនី-អដ្ឋកថា ពន្យល់ថា ពាក្យថា* ***បុញ្ញកិរិយាវត្ថុ*** *នេះ សេចក្តីថា កុសលទាំងឡាយដែលឲ្យកើតផលក្នុងភពដែលគួរបូជា ឬ ជម្រះសន្តានរបស់ខ្លួន ព្រោះដូច្នោះ ទើបឈ្មោះថា បុញ្ញ បុញ្ញទាំងនោះផង ឈ្មោះថា ជាកិរិយា ព្រោះត្រូវធ្វើដោយហេតុ ដោយបច្ច័យទាំងឡាយផង ព្រោះហេតុនោះ ទើបឈ្មោះថា* ***បុញ្ញកិរិយា,*** *បុញ្ញកិរិយានោះឯង ឈ្មោះថា បុញ្ញកិរិយាវត្ថុ ព្រោះជាទីតាំងនៃអានិសង្សនោះៗ ។*

ក្នុងគម្ពីរបរមត្ថជោតិកៈ ថា ពាក្យថា បុញ្ញកិរិយាវត្ថុ នេះ ជាភាសាបាលី ប្រែថា សេចក្ដីល្អដែលគួរធ្វើ ព្រោះជាហេតុ ជាទីតាំងនៃអានិសង្ស (គុណប្រយោជន៍ ឬសេចក្ដីសុខ-ចម្រើន) ។ កាលបែកបទហើយ បាន ៣ បទ គឺ

បុញ្ញ + ក្រិយ + វត្ថុ, បុញ្ញ មានន័យថា ការងារដែលល្អ ដែលសម្រាប់ជម្រះសេចក្ដីសៅហ្មង ក្ដៅក្រហាយ ក្រិយ មានន័យថា គួរធ្វើ, វត្ថុ មានន័យថា ជាហេតុជាទីតាំងនៃអានិសង្ស ។

ដូចសម្ដែងវចនត្ថៈថា ៖

អត្តនោ សន្តានំ បុនាតិ សោធេតីតិ = បុញ្ញំ ការធ្វើណា រមែងជម្រះសន្ដានចិត្តរបស់ខ្លួនឲ្យស្អាតបរិសុទ្ធ ដូច្នោះការធ្វើនោះ ឈ្មោះថា បុណ្យ បានដល់ ការបរិច្ចាគទាន រក្សាសីល ចម្រើនភាវនាជាដើម ។

សប្បុរិសេហិ កាតព្វន្តិ កិរិយំ ការធ្វើណា ដែលសប្បុរសទាំងឡាយគួរធ្វើ គួរចម្រើន ដូច្នោះ ការធ្វើនោះឈ្មោះថា **កិរិយ** បានដល់ ការបរិច្ចាគទាន រក្សាសីល ចម្រើនភាវនាជាដើម ។

**តេ តេ អានិសំសា វសន្តិ តិដ្ឋន្តិ ឯត្ថាតិ** = *វត្ថុ អានិសង្ស (ផលនៃកុសល) ផ្សេងៗ រមែងតាំងនៅក្នុងការធ្វើណា ដូច្នោះ ការធ្វើនោះឈ្មោះថា* ***វត្ថុ*** *បានដល់ការបរិច្ចាគទាន រក្សាសីល ចម្រើនភាវនាជាដើម ។*

**កត្តព្វំ បុញ្ញំ** = **បុញ្ញកិរិយំ** *សេចក្តីល្អដែលសប្បុរសទាំងឡាយគួរធ្វើ ឈ្មោះថា បុញ្ញកិរិយា ។*

**បុញ្ញកិរិយញ្ច តំ វត្ថុចាតិ** = **បុញ្ញកិរិយវត្ថុ** *ការធ្វើដែលជាសេចក្តីល្អ ដែលសប្បុរសទាំងឡាយគួរធ្វើ និងជាទីតាំងនៃអានិសង្ស ដូច្នោះ ការធ្វើនោះ ឈ្មោះថា* ***បុញ្ញកិរិយាវត្ថុ*** *បានដល់ ការបរិច្ចាគទាន រក្សាសីល ចម្រើនភាវនាជាដើម ។*

## III. បុញ្ញកិរិយាវត្ថុ ១០ សម្តែងជាពីរន័យ

***សម្តែងជាសុត្តន្តន័យ*** *បុញ្ញកិរិយាវត្ថុ ១០ មានចំនួន ៣០ បានដល់ កាយកម្មទាន វចីកម្មទាន មនោកម្មទាន ជាដើម ដូចដែលបានពោលមកហើយ ។*

***សម្តែងដោយអភិធម្មន័យ*** *បុញ្ញកិរិយាវត្ថុ១០ មានចំនួន ១១ ឬ ២៣ គឺ*

***ទាន*** *មាន ១ បានដល់ មនោកម្មទាន ដែលជាអនភិជ្ឈា,*

***សីល*** *មាន ២ បានដល់ កាយកម្មសីល វចីកម្មសីល ដែលជាកាយកម្ម ៣ វចីកម្ម ៤,*

***ភាវនា អបចាយនៈ វេយ្យាវច្ចៈ*** *ទាំងបីនេះ មាន ១ បានដល់ មនោកម្ម ដែលជាអព្យាបាទៈ និង សម្មាទិដ្ឋិ,*

***បត្តិទាន បត្តានុមោទនា*** *ទាំងពីរនេះ មាន ១ បានដល់ មនោកម្មដែលជាអនភិជ្ឈា និង សម្មាទិដ្ឋិ,*

***ធម្មស្សវនៈ*** *មាន ១ បានដល់ មនោកម្មដែលជាសម្មាទិដ្ឋិ,*

***ធម្មទេសនា*** *មាន ១ បានដល់ មនោកម្មដែលជាអនភិជ្ឈា អព្យាបាទៈ សម្មាទិដ្ឋិ,*

***ទិដ្ឋុជុកម្ម*** *មាន ១ បានដល់ មនោកម្មដែលជាសម្មាទិដ្ឋិ ។*

## IV. វចនត្ថរបស់បុញ្ញកិរិយាវត្ថុ ១០ ប្រការ ព្រមទាំងពាក្យអធិប្បាយនិងប្រភេទ

### ១_ទានមយៈ

*នៅក្នុងគម្ពីរបរមត្ថទីបនី-អដ្ឋកថា ពន្យល់ថា ៖*

*ពាក្យថា* **ទានមយំ** *បានដល់ ចេតនាជាគ្រឿងបរិច្ចាគ ទេយ្យធម៌របស់ខ្លួនដល់អ្នកដទៃ ដោយអំណាចនៃការអនុគ្រោះ ឬដោយអំណាចនៃការបូជា របស់អ្នកដែលកាត់ឫសគល់ គឺកពនៅមិនទាន់ដាច់ ឈ្មោះថា* **ទាន** *ព្រោះជាហេតុនៃការឲ្យ ។ ទាននោះឯង ឈ្មោះថា* **ទានមយ** *។ ចេតនាដែលប្រព្រឹត្តទៅហើយ ក្នុងកាលទាំង ៣ គឺ ក្នុងកាលដែលជាចំណែកខាងដើម តាំងអំពីការឲ្យបច្ច័យ ៤ ទាំងនោះកើតឡើង ១ ក្នុងវេលាបរិច្ចាគ ១ ក្នុងការសោមនស្សចិត្ត រលឹកដល់ខាងក្រោយ (អំពីទីឲ្យហើយ) ១ របស់អ្នកឲ្យវត្ថុនោះៗ ក្នុងបណ្ដាបច្ច័យ ៤ មានចីវរជាដើម ឬក្នុងបណ្ដាទានវត្ថុ ១០ យ៉ាង មានបាយជាដើម ឬបណ្ដាអារម្មណ៍ ៦ មានរូបជាដើម ឈ្មោះថា បុញ្ញកិរិយាវត្ថុ ដែលសម្រេចដោយការឲ្យទាន ។*

ម្យ៉ាងទៀត ក្នុងវេលាដែលអ្នកឲ្យបាយជាដើម ឲ្យ(ទាន) ដោយគិតថា "យើងនឹងឲ្យបាយ និងទឹកជាដើម" ក្តី ដោយរលឹកដល់ទានបារមី ក្តី បុញ្ញកិរិយាវត្ថុ **ជាទានមយៈ** ។

នៅក្នុងបរមត្ថជោតិកៈ អធិប្បាយថា ៖

**ទានំ** សម្តែងវចនត្ថៈថា **ទីយតិ ឯតេនាតិ = ទានំ** ជនទាំងឡាយ គប្បីឲ្យដោយចេតនានេះ ដូច្នេះ ចេតនាដែលជាហេតុនៃការឲ្យ ឈ្មោះថា **ទាន** ។

ពាក្យថា **ទាន** តាមវចនត្ថៈនេះ បានដល់ តួចេតនាដែលជាហេតុនៃការឲ្យទានសម្រេចបាន ។

ន័យមួយទៀត **ទាតព្វន្តិ = ទានំ** វត្ថុយ៉ាងណាដែលជនទាំងឡាយគប្បីឲ្យ ដូច្នោះ វត្ថុយ៉ាងនោះ ឈ្មោះថា **ទាន** បានដល់ វត្ថុដែលគប្បីឲ្យ (**ទាតព្វវត្ថុ** ឬ **ទេយ្យធម្ម**) ។

វចនត្ថៈទាំងពីរនេះ ជាគ្រឿងចង្អុលបង្ហាញឲ្យដឹងថា **ទាន** មាន ២ យ៉ាង គឺ ចេតនាទាន និង វត្ថុទាន ។ ទាំង ២ យ៉ាងនេះ ចេតនាទាន មាន ៣ យ៉ាង ពោលដោយកាល គឺ **បុព្វចេតនាទាន** (ចេតនាដែលកើតឡើងមុនអំពីកាលឲ្យ) តាំងអំពីកាលដែលបានគិតថា នឹងធ្វើបុណ្យឲ្យទាន ឬ តាំងអំពី

*កាលស្វែងរកវត្ថុដែលជាទេយ្យធម៌;* ***មុញ្ចនចេតនា*** *(ចេតនាដែលកើតឡើង ក្នុងខណៈដែលកំពុងឲ្យ);* ***អបរចេតនាទាន*** *(ចេតនាដែលកើតឡើង ក្រោយអំពីកាលឲ្យទានរួចហើយ) ។ ភាពនៃបីតិ ឆ្អែតចិត្តក្នុងការឲ្យនោះ ចេតនាទាំង ៣ មានបុព្វចេតនាទានជាដើមនេះ បើបានឱកាស ក៏នឹងអាចឲ្យផលក្នុងបដិសន្ធិកាល ឲ្យកើតជាមនុស្សទេវតាបាន ដូចមានសម្តែងទុកក្នុងព្រះបាលីអបទានថា "***ឯកបុប្ផំ យជិត្វាន អសីតិកប្បកោដិយោ ទុគ្គតឹ នាភិជានាមិ ឯក-បុប្ផស្សិទំ ផលំ*** *ការបូជាដោយផ្កាឈើមួយទង ធ្វើឲ្យខ្ញុំម្ចាស់មិនស្គាល់ទុគ្គតិភព មាននរកជាដើម រហូតដល់វេលា ៨០ កោដិអាយុកប្ប ឬ រហូតដល់វេលា ៨០ កោដិជាតិ នេះឯងជាផលដែលបានទទួលអំពីការថ្វាយផ្កាឈើត្រឹមតែមួយទង" ។*

*តាមព្រះបាលីនេះ មិនមែនថា នឹងបញ្ចេញផលឲ្យកើតជាមនុស្សទេវតាជាប់តគ្នារឿយៗរហូត ៨០ កោដិអាយុកប្ប ឬ ៨០ កោដិភពជាតិ បានដោយត្រង់តែម្តងនុ៎ះទេ គឺត្រឹមតែជាដើមហេតុ ជួយឲ្យកើតជាមនុស្សទេវតា ក្នុងភពទី ២ ពេលបានកើតមកជាមនុស្ស ទេវតា ក្នុងភពទី ២ ហើយ ក៏បាន*

ចម្រើនកុសលផ្សេងៗ ថែមថ្មីទៀតតទៅ កុសលថ្មីក្នុងភពទី ២ នោះ ក៏ជួយឲ្យកើតជាមនុស្សទេវតា ក្នុងភពទី ៣ តទៅ កាលបានកើតមកជាមនុស្ស ទេវតា ក្នុងភពទី ៣ ហើយ ក៏បានសាង ចម្រើនកុសលផ្សេងៗ ឡើងថ្មីទៀតតទៅ កុសលដែលបានកើតថ្មី ក្នុងភពទី ៣ នោះ ក៏ជួយឲ្យកើតជាមនុស្ស ទេវតា ក្នុងភពទី ៤ តទៅ យ៉ាងនេះទៅរឿយៗ មិនដាច់រយៈរហូតដល់ ៨០ កោដិកពជាតិ ដូច្នោះ លោកទើបពោលថា អានិសង្សនៃការបូជាដោយផ្កាឈើត្រឹមតែមួយទង នោះ អាចជួយឲ្យផុតបាកទុគ្គតិភព បានអស់កាលជាយូរអង្វែង ។

មួយទៀត ចេតនាទាំង ៣ មានបុព្វចេតនាជាដើមនេះ មិនមែនមានបរិបូរណ៍គ្រប់កាលទាំង ៣ ជានិច្ចទៅទេ ពោលគឺ ពេលខ្លះ **មុញ្ចនចេតនាមាន** តែបុព្វចេតនា អបរចេតនា មិនមាន, **បុព្វចេតនាមាន** តែមុញ្ចនចេតនា អបរចេតនា មិនមាន, **អបរចេតនាមាន** តែបុព្វចេតនា មុញ្ចនចេតនា មិនមាន, ពេលខ្លះ មុញ្ចនចេតនា បុព្វចេតនា ទាំង ២ មាន តែអបរចេតនា មិនមាន, មុញ្ចនចេតនា អបរចេតនាមាន

តែបុព្វចេតនា មិនមាន, បុព្វចេតនា អបរចេតនាមាន តែមុញ្ចនចេតនា មិនមាន, ពេលខ្លះ ក៏មិនមានទាំង ៣ កាល ។

ក្នុងចេតនាទាំង ៣ នេះ កាលពោលដោយការកើតងាយស្រួល ឬលំបាកហើយ មុញ្ចនចេតនាកើតងាយស្រួល អបរចេតនា កើតបានលំបាក ដូច្នោះ បើចេតនាកើតមិនគ្រប់ទាំង ៣ កាល ដូចបានពោលមកហើយ ការធ្វើទានដូច្នេះរមែងមានអានិសង្សមិនចម្រើន ដូច្នោះ គួរព្យាយាមធ្វើទានឲ្យព្រមដោយចេតនាទាំង ៣ បើចេតនាកើតឡើងព្រមទាំង ៣ កាលដោយល្អ ការធ្វើទានយ៉ាងនេះ រមែងមានអានិសង្សច្រើនដ៏ធំទូលាយ ដូចដែលនឹងគប្បីឃើញ គប្បីដឹងបានដោយសេចក្តីផ្សេងៗគ្នា របស់ទេវតាទាំង ៦ ជាន់ និងជនទាំងឡាយក្នុងលោកនេះ ទាំងដែលជាអតីត និង បច្ចុប្បន្ន ដែលមានការប្រព្រឹត្តិទៅផ្សេងៗគ្នា យ៉ាងណា ពោលគឺ ផ្សេងគ្នាដោយជាតិត្រកូល ឋានៈ ទ្រព្យសម្បត្តិ បរិវារ ដែលប្រព្រឹត្តទៅដូច្នេះក៏បរិសុទ្ធហើយជាប់មកអំពីទាន សីល ភាវនា ដែលដល់ព្រមដោយចេតនាទាំង ៣ កាល ឬមិនដល់ព្រមទាំង ៣ កាលខ្លះទៅយ៉ាងណាមួយ ឬមិនមានបាត់ទៅនោះឯងជាហេតុ ព្រោះ

ហេតុនេះ ព្រះមានព្រះភាគជាម្ចាស់ ទើបទ្រង់សម្តែងទុកក្នុងព្រះបាលី ឆឡង្គុត្តរ ថា ៖

បុព្វេវ ទានា សុមនោ ទទំ ចិត្តំ បសាទយេ
ទត្វា អត្តមនោ ហោតិ ឯសា យញ្ញស្ស សម្បទា។

ទាយកមានចិត្តរីករាយ ក្នុងវេលាមុនអំពីកាលឲ្យ កំពុងឲ្យធ្វើចិត្តឲ្យជ្រះថ្លា លុះឲ្យហើយ ក៏មានចិត្តត្រេកអរ (តាមក្រោយ) នេះជាសេចក្តីបរិបូរណ៍របស់ទាន[១] ។

ព្រះមហាពុទ្ធឃោសាចារ្យ បានសម្តែងទុកក្នុងសត្តនិបាត នៃអង្គុត្តរនិកាយ អដ្ឋកថាថា :

ទានញ្ហិនាម តិស្សោ ចេតនា បរិបុណ្ណំ
កាតុំ សក្កោន្តស្សេវ មហប្ផលំ ហោតិ

ការឲ្យដែលបានឈ្មោះថា ទាននោះ ត្រូវតែជាទានដែលដល់ព្រមដោយចេតនាទាំង ៣ កាលដែលអ្នកធ្វើអាចធ្វើឲ្យកើតឡើងបានយ៉ាងបរិបូរណ៍ប៉ុណ្ណោះ ទាននោះ ទើបមានផលយ៉ាងច្រើន ។

---

១ សុត្តន្ត. អង្គុត្តរនិកាយ លេខ ៤៦ ទំព័រ ១១៦ ។

## ១.១ ទានវត្ថុក្នុងព្រះវិន័យ ៤ យ៉ាង

**១-ចីវរទាន** *ការឲ្យសំពត់ចីវរ ដល់ភិក្ខុសាមណេរ ឬការឲ្យសំពត់ ខោអាវ គ្រឿងស្លៀកដណ្តប់ដល់អ្នកដទៃ*

**២-បិណ្ឌបាតទាន** *ការឲ្យចង្ហាន់បិណ្ឌបាត ដូចជា បាយ ត្រី សាច់ នំស្រស់ នំក្រៀម ឬផ្លែឈើ ដល់អ្នកដទៃ*

**៣-សេនាសនទាន** *ការឲ្យទីនៅអាស្រ័យ ដូចជា កសាងកុដិ សាលា ព្រះវិហារ ឬ រោងឧបោសថជាដើម និងការឲ្យទីស្នាក់នៅដល់អ្នកដំណើរ ឬអ្នកទាល់ក្រ*

**៤-ភេសជ្ជទាន** *ការឲ្យភេសជ្ជៈ គឺថ្នាំព្យាបាលរោគ ។*

*ការបរិច្ចាគទាន មានច្រើនប្រភេទផ្សេងគ្នា នឹងសម្តែងដោយសង្ខេប ល្មមដល់ការយល់ដឹងខ្លះៗ ដូចតទៅ ៖*

## ១.២ ទានពួកពីរ

*១-អាមិសទាន ការឲ្យវត្ថុបច្ច័យ ៤ ឬរបស់ផ្សេងៗ*

*២-ធម្មទាន ការឲ្យធម៌ជាទាន គឺការសម្តែងធម៌ ការបង្រៀនធម៌ និងការរចនា ការកសាងសៀវភៅធម៌ផ្សេងៗ ហៅថាធម្មទាន ។*

*ក្នុងទាន ២ យ៉ាងនេះ ធម្មទានជាទានដែលប្រណីតជាង អាមិសទាន ដូចព្រះបាលីថា "**សព្វទានំ ធម្មទានំ ជិនាតិ** ធម្មទាន ឈ្នះអស់ទានទាំងពួង" ។*

*អាមិសទាន ឲ្យផល គឺ កាលកើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន បរិបូណ៌ដោយសម្បត្តិ, ធម្មទាន ឲ្យផល គឺ កើតបញ្ញា ។*

## នំយមួយទៀត

*១-**សាហត្ថិកទាន** ការឲ្យទានដោយដៃខ្លួនឯង ។*

*២-**អាណត្តិកទាន** ប្រើអ្នកដទៃឲ្យធ្វើទានជំនួស ។*

***សាហត្ថិកទាន** ប្រណីតជាង **អាណត្តិកទាន***

***សាហត្ថិកទាន** កាលបញ្ចេញផល ក៏ឲ្យជាបុគ្គលស្តុកស្តម្ភ ជាអ្នកបរិបូណ៌ដោយសម្បត្តិ ព្រមដោយបរិវារ,*

***អាណត្តិកទាន** សូម្បីបញ្ចេញផល ឲ្យជាអ្នកបរិបូណ៌ដោយសម្បត្តិ ក៏ពិតមែនហើយ តែបរិវារមិនសូវមានទេ ។*

## ន័យមួយទៀត

*១-សម្បជានទាន* ការធ្វើបុណ្យ ដែលប្រកបដោយការយល់ដឹង គឺ ដឹងនូវផលនៃការឲ្យទាននោះជាដើម ។

*២-អសម្បជានទាន* ការធ្វើបុណ្យ ដោយមិនមានការយល់ដឹង ការចូលចិត្ត ក្នុងរឿងកម្មនិងផលរបស់កម្មជាដើម,

*សម្បជានទាន* កាលបញ្ចេញផល រមែងជាអ្នកបរិបូណ៌ដោយសម្បត្តិ និង ព្រមដោយបញ្ញា,

*អសម្បជានទាន* កាលបញ្ចេញផល រមែងឲ្យជាអ្នកបរិបូណ៌ដោយសម្បត្តិ ប៉ុន្តែខ្វះសតិបញ្ញា ។

## ន័យមួយទៀត

*១-វដ្តនិស្សិតទាន* ការធ្វើបុណ្យ ដោយការប្រាថ្នាភោគសម្ប័ទ បរិវារសម្ប័ទ គឺប្រាថ្នាឲ្យមានទ្រព្យជាសេដ្ឋី មហាសេដ្ឋី និងប្រាថ្នាភវសម្បត្តិ គឺ ត្រូវការឲ្យកើតជាមនុស្ស ជាទេវតា ជាព្រហ្ម ។

*២-វិវដ្តនិស្សិតទាន* ការធ្វើបុណ្យ ដែលមិនមានសេចក្តីប្រាថ្នាក្នុងភោគសម្ប័ទ បរិវារសម្ប័ទ និងភវសម្បត្តិទេ ប្រាថ្នា

តែសម្មាសម្ពោធិញ្ញាណ បច្ចេកពោធិញ្ញាណ អគ្គសាវកពោធិញ្ញាណ មហាសាវកពោធិញ្ញាណ និងប្រកតីសាវកពោធិញ្ញាណ យ៉ាងណាមួយប៉ុណ្ណោះ ។

វដ្តនិស្សិតទាន មិនហៅថា ទានបារមីទេ ជាទានកុសលសាមញ្ញ កាលបញ្ចេញផល ក៏ឲ្យមានសេចក្តីសុខត្រឹមតែមនុស្ស និងទេវតាប៉ុណ្ណោះ មិនអាចឲ្យបានសម្រេចមគ្គផលដោយឆាប់រហ័សទេ ។

ចំណែកវិវដ្តនិស្សិតទាន ហៅថា ទានបារមី កាលបញ្ចេញផល ឲ្យមានសេចក្តីសុខក្នុងមនុស្ស និងទេវតា និងអាចឲ្យបានសម្រេចមគ្គផល ដោយឆាប់រហ័ស ។

## ១.៣ ទានពួក ៣ (តិកទាន)

ក្នុងទានពួកបីនេះ **ហីនទាន** ១ **មជ្ឈិមទាន** ១ **បណីតទាន** ១ មាន ៣ ន័យ គឺ ៖

<u>ន័យទី១</u> **ហីនទាន** ការធ្វើទានថ្នាក់ទាប បានដល់ការធ្វើទានដែលមានសេចក្តីប្រាថ្នាលាភ យស ការសរសើរ, **មជ្ឈិមទាន** ការធ្វើទានថ្នាក់កណ្តាល បានដល់ ការធ្វើទាន

ដែលមានសេចក្ដីប្រាថ្នា មនុស្សសម្បត្តិ ទេវតាសម្បត្តិ, បណីតទាន ការធ្វើទានថ្នាក់ខ្ពស់ បានដល់ ការធ្វើទានតាមដំណើរផ្លូវរបស់ព្រះអរិយ និងព្រះពោធិសត្វទាំងឡាយ គឺសេចក្ដីប្រាថ្នាព្រះនិព្វាននោះឯង ។

ន័យទី២ ហីនទាន ការធ្វើទានថ្នាក់ទាប បានដល់ ការធ្វើទានដែលមានសេចក្ដីប្រាថ្នា មនុស្សសម្បត្តិ ទេវតា-សម្បត្តិ, មជ្ឈិមទាន ការធ្វើទានថ្នាក់កណ្ដាល បានដល់ ការធ្វើទានដែលមានសេចក្ដីប្រាថ្នាសាវកពោធិញាណ បច្ចេក-ពោធិញាណ, បណីតទាន ការធ្វើទានថ្នាក់ខ្ពស់ បានដល់ ការធ្វើទានដែលមានសេចក្ដីប្រាថ្នា ឲ្យបានសម្រេចសម្មា-សម្ពោធិញាណ ។

ន័យទី៣ ហីនទាន ការធ្វើទានថ្នាក់ទាប បានដល់ ការធ្វើទានដែលប្រកបដោយឆន្ទៈ វិរិយៈ ចិត្តៈ បញ្ញា តិចតួច ពោលគឺមានការពេញចិត្ត ព្យាយាម ចូលចិត្ត យល់ដឹងក្នុងការធ្វើទាននោះ ត្រឹមតែបន្តិចបន្តួច, មជ្ឈិមទាន ការធ្វើទានថ្នាក់កណ្ដាល បានដល់ ការធ្វើទានដែលប្រកបដោយឆន្ទៈ វិរិយៈ ចិត្តៈ បញ្ញា ល្មមប្រមាណ ពោលគឺមានការពេញចិត្ត

*ព្យាយាម ចូលចិត្ត យល់ដឹង ក្នុងការធ្វើទាននោះយ៉ាងល្អ សាមញ្ញទៅ, បណីតទាន ការធ្វើទានថ្នាក់ខ្ពស់ បានដល់ ការធ្វើទានដែលប្រកបដោយឆន្ទៈ វីរិយៈ ចិត្តៈ បញ្ញា យ៉ាង ក្រៃលែង ពោលគឺមានការពេញចិត្ត ព្យាយាម ចូលចិត្ត យល់ដឹងក្នុងការធ្វើទាននោះ យ៉ាងល្អក្រៃលែង តាមដំណើរ ផ្លូវរបស់សប្បុរសទាំងឡាយ ។*

## ន័យមួយទៀត ទានមាន ៣ គឺ

***១-ទាសទាន*** *ការធ្វើបុណ្យ ដោយគ្រឿងឧបភោគ បរិភោគ ដែលអាក្រក់ជាងវត្ថុដែលខ្លួនប្រើ ខ្លួនបរិភោគ,*

***២-សហាយទាន*** *ការធ្វើបុណ្យ ដោយគ្រឿងឧបភោគ បរិភោគ ដែលស្មើនឹងវត្ថុដែលខ្លួនប្រើ ខ្លួនបរិភោគ,*

***៣-សាមិទាន*** *ការធ្វើបុណ្យ ដោយគ្រឿងឧបភោគ បរិភោគ ដែលល្អជាងវត្ថុដែលខ្លួនប្រើ ខ្លួនបរិភោគ ។*

**ទាន ៣ ប្រភេទនេះ ក្នុងមង្គលត្ថទីបនីមានសម្ដែងថា :**

<u>ទី១</u> : ទាសោ ហុត្វា ទេតិ តណ្ហាទាសព្យស្ស ឧបគតត្តា *បុគ្គលអ្នកឲ្យទាន មានសភាពជាខ្ញុំនៃទាន ព្រោះ*

ការៈនៃបុគ្គលនោះ ចូលទៅជិតកាន់យកជាខ្ញុំនៃតណ្ហា ។ គឺ ឲ្យវត្ថុថោកទាប បរិភោគខ្លួនឯងដ៏ថ្លៃថ្លា ទាសោ ឝិយ ហោតិ ទុកដូចជាបុគ្គលជាខ្ញុំនៃទាន, មនុស្សខ្ញុំគេ ជាមនុស្ស ថោកទាប (បើបានសោយរាជ្យជាស្តេចៗ អង្គនោះ នឹងនៅ ក្រោមបង្គាប់គេ) ។

**ទី២** : សហាយោ ហុត្វា ទេតិ តស្ស អប្បិយ- ភាវវិសជ្ជនតោ បុគ្គលអ្នកឲ្យទាន មានសភាពជាសម្លាញ់ (នោះ) ព្រោះភាពនៃខ្លួនបានលះបង់នូវទេយ្យវត្ថុ មិនជាទី ស្រឡាញ់របស់ខ្លួន, (បើបានសោយរាជ្យជាស្តេចៗអង្គនោះ ឯករាជ្យ) ។

**ទី៣** : សាមិ ហុត្វា ទេតិ តត្ថ តណ្ហាទាសព្យតោ អត្តានំ មោចេត្វា អភិភុយ្យ បវត្តនតោ ។ បុគ្គលអ្នក ឲ្យទានមានសភាពជាម្ចាស់ ព្រោះបានដោះខ្លួន អំពីខ្ញុំនៃតណ្ហា ក្នុងទេយ្យវត្ថុនោះ ព្រោះបានគ្របសង្កត់លើតណ្ហា, ព្រោះ ជាម្ចាស់នៃទេយ្យវត្ថុ គឺបរិភោគខ្លួនឯងទាបថោក ដល់ឲ្យទាន មានវត្ថុដ៏ថ្លៃថ្លា ឬមានចិត្តគ្របសង្កត់លើលោភៈ មិនឲ្យតណ្ហា

*ជិះជាន់បាន លះបង់មច្ឆរិយៈ មិនមានចិត្តមន្ទិល ។ (បើបាន សោយរាជ្យជាស្តេច គឺ បានត្រួតត្រាលើនគរជនទៃ) ។*

**ន័យមួយទៀត ទានមាន៣ គឺ**

***១-លោកាធិបតេយ្យទាន*** *ការធ្វើទានដែលប្រារព្ធមនុស្សចំណែកច្រើនជាធំ គឺខ្លួនឯងមិនមានសេចក្តីពេញចិត្តនឹងធ្វើទេ តែខ្លាចអ្នកដទៃតិះដៀល មើលងាយ ទើបបានធ្វើ ។*

***២-អត្តាធិបតេយ្យទាន*** *ការធ្វើទានប្រារព្ធខ្លួនឯងជាធំ គឺគិតថា យើងជាមនុស្ស ជាអ្នកមានទ្រព្យសម្បត្តិច្រើន បើមិនបរិច្ចាគទ្រព្យជួយសង្គ្រោះ ក្នុងកិច្ចការនោះៗខ្លះហើយ ក៏ជាការមិនសមគួរ គួរស្អប់ ដូច្នោះទើបធ្វើ ។*

***៣-ធម្មាធិបតេយ្យទាន*** *ការធ្វើទានដែលប្រារព្ធធម៌ជាធំ គឺពិចារណាថា ការបរិច្ចាគទាននេះ ជាធម៌គឺសប្បុរសទាំងឡាយនិយមធ្វើ សូម្បីព្រះពោធិសត្វទាំងឡាយ កាលនៅបំពេញបារមីនោះ ក៏បានបំពេញទានបារមី ជាដំបូង ជាគន្លងធំ និងសូម្បីសាវកផ្សេងៗ របស់ព្រះសម្មាសម្ពុទ្ធទាំងឡាយ ក៏*

ពេញចិត្តក្នុងការកសាងទាននេះដូចគ្នា, ការពិចារណាឃើញជាប្រយោជន៍ដូច្នេះហើយ ក៏ធ្វើតាមឱកាស តាមកាលវេលា ។

## ទាន ៣ យ៉ាងមានសទ្ធាជាដើម

(សុត្តន្តបិដក ៤៨ / ១៦០)

១-សទ្ធាយ ទានំ ទេតិ បុគ្គលឲ្យទានដោយសទ្ធា

២-ហិរិយា ទានំ ទេតិ បុគ្គលឲ្យទានដោយហិរិ

៣-កុសលញ្ច ទានំ កុសលទាន ។

(ទានដែលរកទោស មិនបាន) ។

សទ្ធាទាន ហិរិទាន កុសលទាន ធម៌ទាំងនេះ ជាធម៌តាំងនៅក្នុងពួកសប្បុរស, សប្បុរសទាំងឡាយ តែងពោលនូវធម៌នេះថា ជាផ្លូវទៅកាន់ទេវលោក ព្រោះថា បុគ្គលតែងទៅកាន់ទេវលោកបាន ដោយធម៌នេះ ។

ក្នុងអដ្ឋកថា មនោរថបូរណី ពន្យល់ថា ៖

បុគ្គលរមែងឲ្យទានដោយសទ្ធាណា សទ្ធានោះ លោកប្រាថ្នាយកថា សទ្ធា ។ បុគ្គលរមែងឲ្យទានដោយហិរិណា ហិរិនោះ លោកប្រាថ្នាយកថា ហិរិ ។

# ១.៤ ទានពួក ៥

## អសប្បុរិសទាន ៥ យ៉ាង

(អង្គុត្តរនិកាយ បញ្ចកនិបាត ៤៥ / ៨៧)

១–អសក្កច្ចំ ទេតិ ឲ្យទានដោយមិនគោរព (ក្នុងទេយ្យធម៌ បានដល់ មិនគោរព គឺធ្វើចិត្តឲ្យស្អាតឲ្យទានទេ)

២–អចិត្តីកត្វា ទេតិ ឲ្យទានដោយមិនធ្វើនូវសេចក្ដីគោរព (ក្នុងបដិគ្គាហកៈ បានដល់ ឲ្យដោយអាការៈមិនកោតក្រែង ដោយសេចក្ដីមិនគោរព)

៣–អសហត្ថា ទេតិ មិនឲ្យដោយដៃខ្លួនឯង

៤–អបវិទ្ធំ ទេតិ ឲ្យទានដូចជាបោះចោល

៥–អនាគមនទិដ្ឋិកោ ទេតិ ឲ្យទានដោយឃើញថាមិនឲ្យផល (បានដល់ មិនធ្វើសេចក្ដីឃើញផលកម្ម នឹងមកយ៉ាងនេះថា ផលនៃកម្មដែលធ្វើ នឹងមកដល់ដូច្នេះ ឲ្យកើតឡើងទេ) ។

# សប្បុរិសទាន ៥ យ៉ាង

(អង្គុត្តរនិកាយ បញ្ចកនិបាត ៤៥ / ៨៧)

១-សក្កច្ចំ ទេតិ ឲ្យទានដោយគោរព (ក្នុងទេយ្យធម៌)

២-ចិត្តី កត្វា ទេតិ ឲ្យទានដោយធ្វើនូវសេចក្តីគោរព (ក្នុងបដិគ្គាហកៈ)

៣-សហត្ថា ទេតិ ឲ្យដោយដៃខ្លួនឯង

៤-អនបវិទ្ធំ ទេតិ ឲ្យទានមិនដូចជាបោះចោល

៥-អាគមនទិដ្ឋិកោ ទេតិ ឲ្យទានដោយឃើញថាឲ្យផល (គឺជឿកម្ម និងវិបាក) ។

ក្នុងអដ្ឋកថា-មនោរថបូរណី ពន្យល់ថា ៖

បទថា ចិត្តី កត្វា ទេតិ បានដល់ ចូលទៅតាំងសេចក្តីកោតក្រែងក្នុងទេយ្យធម៌ និង ទក្ខិណេយ្យបុគ្គលហើយឲ្យ ។ ក្នុងពីរយ៉ាងនោះ បុគ្គលធ្វើទេយ្យធម៌ឲ្យប្រណីតមានរសឆ្ងាញ់ហើយឲ្យ ឈ្មោះថា ចូលទៅតាំងសេចក្តីកោតក្រែងក្នុងទេយ្យធម៌ ។ បុគ្គលជ្រើសរើសបុគ្គលហើយឲ្យឈ្មោះថា តាំងសេចក្តីកោតក្រែងក្នុងទក្ខិណេយ្យបុគ្គល ។

បទថា សហត្ថា ទេតិ សេចក្តីថា មិនប្រើដៃរបស់អ្នកដទៃ ឲ្យដោយពាក្យបញ្ជា គឺឲ្យដោយដៃខ្លួនឯងប៉ុណ្ណោះ ដោយគិតថា ឈ្មោះថា កាលដែលយើងត្រាច់រង្គាត់ទៅក្នុងសង្សារវដ្តដែលមិនមានខាងដើម និងខាងចុងហើយ បានប្រើដៃនិងជើងនោះ មិនមានប្រមាណឡើយ យើងនឹងធ្វើសេចក្តីរួចផុតទៅអំពីវដ្តៈ ការចេញចាកភពដូច្នោះ ។

បទថា អាគមនទិដ្ឋិកោ បានដល់ ជឿកម្មនិងវិបាកថា នឹងជាបច្ច័យនៃភព ក្នុងអនាគតហើយឲ្យ ដូច្នេះ ។

## សប្បុរិសទាន ៥ យ៉ាង ព្រមទាំងអានិសង្ស

*(សុត្តន្តបិដក លេខ ៤៥ ទំព័រ ៨៨)*

បញ្ចិមានិ ភិក្ខវេ សប្បុរិសទានានិ : ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាននេះ មាន ៥ យ៉ាង ។

កតមានិ បញ្ច សប្បុរិសទាន ៥ យ៉ាង ដូចម្តេចខ្លះ ?

១-សទ្ធាយ ទានំ ទេតិ ឲ្យទានដោយសទ្ធា

២-សក្កច្ចំ ទានំ ទេតិ ឲ្យទានដោយគោរព

៣-កាលេន ទានំ ទេតិ ឲ្យទានតាមកាលដ៏សមគួរ

**៤-អនុគ្គហិតចិត្តោ ទានំ ទេតិ** *ឲ្យទានដោយចិត្តអនុគ្រោះ*

**៥-អត្តានញ្ច បរញ្ច អនុបហច្ច ទានំ ទេតិ** *ឲ្យទានដោយមិនបានបៀតបៀនខ្លួនឯង និងអ្នកដទៃ ។*

**សទ្ធាទាន** *“ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយសទ្ធា ដោយផលទាននេះ កាលកើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគច្រើន ជាបុគ្គលមានរូបល្អគួរមិលមើល ជាទីជ្រះថ្លា ប្រកបដោយភាពជាអ្នកមានសម្បុរល្អដ៏ក្រៃលែងផង” ។*

**សក្កច្ចទាន** *“ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយគោរព ដោយផលទាននេះ កាលកើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន ពួកជនណា ទោះកូនក្តី ប្រពន្ធក្តី ខ្ញុំបម្រើក្តី អ្នកធ្វើការងារក្តី របស់បុគ្គលនោះ ជនទាំងនោះស្តាប់ដោយល្អ ផ្ទៀងសោតតាំងចិត្តស្តាប់ ដើម្បីដឹងផង” ។ (រមែងជឿសំដីគ្រប់ពាក្យពេចន៍ យកចិត្ត មិនឲ្យខកចិត្តក្នុងការងារ) ។*

**កាលទាន** *“ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានតាមកាលដ៏សមគួរដោយផលទាននេះ កាលកើតក្នុងទីណាៗ ជាបុគ្គល*

*ស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើន ប្រយោជន៍ គឺភោគៈដ៏ពោរពេញ រមែងមកតាមកាលដ៏គួរ ដល់បុគ្គលនោះផង” ។ (នៅក្នុងបរមត្ថជោតិកៈថា មានសេចក្តីចម្រើនរុងរឿងតាំងពីបឋមវ័យ ដែលជាវ័យកំលោះ ក្រមុំ មានផលប្រយោជន៍ ដែលគប្បីបានយ៉ាងបរិបូរណ៍) ។*

**អនុគ្គហិតទាន** *“ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយចិត្តអនុគ្រោះ ដោយផលទាននេះ កាលកើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគច្រើនផង រមែងបង្អោនចិត្តទៅដើម្បីបរិភោគក្នុងកាមគុណ៥ ដ៏លើសលប់ផង”។*

**អនុបហច្ចទាន** *“ម្នាលភិក្ខុទាំងឡាយ បុគ្គលឲ្យទានដោយមិនបានបៀតបៀនខ្លួនឯង និងអ្នកដទៃ ដោយផលទាននេះ កាលកើតក្នុងទីណាៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគច្រើនផង សេចក្តីអន្តរាយនៃភោគទាំងឡាយ មិនមានមកអំពីទីណាមួយ គឺអំពីភ្លើង អំពីទឹក អំពីស្តេច អំពីចោរ អំពីហេតុមិនជាទីស្រឡាញ់ និងអំពីមនុស្សជាទាយាទ” ។*

*ម្នាលភិក្ខុទាំងឡាយ សប្បុរិសទានមាន៥ យ៉ាងនេះឯង ។*

# កាលទាន ៥ យ៉ាង

*(សុត្តន្តបិដក អង្គុត្តរនិកាយ លេខ ៤៤ ទំព័រ ៨១)*

១-អាគន្តុកស្ស ទានំ ទេតិ *ឲ្យទានដល់អ្នកមកថ្មី*

២-គមិកស្ស ទានំ ទេតិ *ឲ្យទានដល់អ្នកដំណើរ*

៣-គិលានស្ស ទានំ ទេតិ *ឲ្យទានដល់អ្នកមានជម្ងឺ*

៤-ទុព្ភិក្ខេ ទានំ ទេតិ *ឲ្យទានក្នុងពេលអត់បាយ*

៥-យានិ តានិ នវសស្សានិ នវផលានិ តានិ បឋមំ សីលវន្តេសុ បតិដ្ឋាបេតិ : *បានតម្កល់ស្រូវថ្មី ផ្លែឈើដំបូង ដល់បុគ្គលមានសីលទាំងឡាយជាដំបូង ។*

*(ព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះគាថានេះថា)*

*ពួកជនមានបញ្ញា ដឹងភាសិតរបស់អ្នកប្រាជ្ញ មានសេចក្តីកំណាញ់ប្រាសចេញហើយ មានចិត្តជ្រះថ្លាហើយ រមែងឲ្យទានក្នុងកាលគួរ ទានដែលបុគ្គលឲ្យតាមកាលសមគួរចំពោះព្រះអរិយបុគ្គលទាំងឡាយ ដែលជាបុគ្គលមានកាយនិងចិត្តប្រកបដោយតាទិគុណ ទក្ខិណាទានរបស់បុគ្គលនោះ ជាទានមានផលបរិបូរណ៍ ។ ពួកជនណា អនុមោទនា*

*ឬធ្វើនូវសេចក្តីខ្វល់ខ្វាយ ក្នុងទក្ខិណាទាននោះ ទក្ខិណា-ទានរបស់អ្នកទាំងនោះ នឹងបានឈ្មោះថា ថយថោក ព្រោះតែអនុមោទនា ឬធ្វើការខ្វល់ខ្វាយនោះ ក៏ទេ ពួកជនទាំងនោះ ជាអ្នកបានចំណែកបុណ្យដែរ ។ ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ដល់បុគ្គលណា ជាទានមានផលច្រើន បុគ្គលមានចិត្តមិនបានរួញរា គប្បីឲ្យទានចំពោះបុគ្គលនោះ ព្រោះថា បុណ្យទាំងឡាយ រមែងជាទីពឹងនៃពួកសត្វក្នុងលោកខាងមុខ ។*

## ១.៥ ឆឡង្គទាន

*(សុត្តន្តបិដក លេខ៤៦ ទំព័រ១១៤)*

***អង្គរបស់ទាយក មាន ៣***

១-បុព្វេវ ទានា សុមនោ ហោតិ : *ទាយកជាអ្នកមានចិត្តត្រេកអរមុនអំពីកាលឲ្យ*

២-ទទំ ចិត្តំ បសាទេតិ : *កំពុងតែឲ្យធ្វើចិត្តឲ្យជ្រះថ្លា*

៣-ទត្វា អត្តមនោ ហោតិ *លុះឲ្យហើយមានចិត្តរីករាយ*

***អង្គរបស់បដិគ្គាហកៈទាំងឡាយ មាន ៣***

១-វីតរាគា វា ហោន្តិ រាគវិនយាយ វា បដិបន្នា : *ពួកបដិគ្គាហកៈ ជាអ្នកប្រាសចាករាគៈ ឬប្រតិបត្តិដើម្បីបន្ទោបង់រាគៈ*

២-វីតទោសា វា ហោន្តិ ទោសវិនយាយ វា បដិបន្នា : *ពួកបដិគ្គាហកៈ ជាអ្នកប្រាសចាកទោសៈ ឬប្រតិបត្តិដើម្បីបន្ទោបង់ទោសៈ*

៣-វីតមោហា វា ហោន្តិ មោហវិនយាយ វា បដិបន្នា : *ពួកបដិគ្គាហកៈ ជាអ្នកប្រាសចាកមោហៈ ឬប្រតិបត្តិដើម្បីបន្ទោបង់មោហៈ*

*អង្គរបស់ទាយកមាន ៣ អង្គរបស់បដិគ្គាហកៈ មាន ៣ ដូច្នេះ យ៉ាងនេះឯង ជាទានប្រកបដោយអង្គ ៦ ។*

*ព្រះអង្គទ្រង់ត្រាស់ដូច្នេះថា “ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយកំណត់នូវប្រមាណនៃបុណ្យរបស់ទាន ដែលប្រកបដោយអង្គ ៦ យ៉ាងនេះថា គំនរបុណ្យ គំនរកុសល ជាគ្រឿងនាំមកនូវសេចក្តីសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខ*

ជាវិបាក ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ប៉ុណ្ណោះ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាត្រេកអរ គាប់ចិត្ត ជាប្រយោជន៍ ជាសុខបានឡើយ ។ ដោយពិតនោះថា រាប់មិនបាន ប្រមាណមិនកើត គ្រាន់តែរាប់ថា ជាគំនរបុណ្យច្រើនប៉ុណ្ណោះបាន ។ ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលដែលមិនងាយកំណត់ប្រមាណនូវទឹកក្នុងមហាសមុទ្រថា ទឹកប៉ុណ្ណោះអាឡ្ហកៈក្ដី ទឹកប៉ុណ្ណោះរយអាឡ្ហកៈក្ដី ទឹកប៉ុណ្ណោះពាន់អាឡ្ហកៈក្ដី ទឹកប៉ុណ្ណោះសែនអាឡ្ហកៈក្ដី បានឡើយ ។ ដោយពិតនោះថា រាប់មិនបាន ប្រមាណមិនកើត គ្រាន់តែរាប់ថា ជាគំនរទឹកដ៏ច្រើនប៉ុណ្ណោះបាន យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលដែលមិនងាយកំណត់ប្រមាណនូវបុណ្យ នូវទានប្រកបដោយអង្គ ៦ យ៉ាង យ៉ាងនេះថា គំនរបុណ្យ គំនរកុសល ជាគ្រឿងនាំមកនូវសេចក្ដីសុខ ឲ្យនូវអារម្មណ៍ដ៏ល្អ មានសុខជាវិបាក ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ប៉ុណ្ណោះ ប្រព្រឹត្តទៅដើម្បីសេចក្ដីប្រាថ្នាត្រេកអរ គាប់ចិត្តជាប្រយោជន៍ ជាសុខបានឡើយ ។ ដោយពិតនោះថា រាប់មិនបានប្រមាណមិនកើត គ្រាន់តែរាប់ថា ជាគំនរបុណ្យ ដ៏ច្រើនប៉ុណ្ណោះបាន ក៏យ៉ាងនោះដែរ ។

*ព្រះមានព្រះភាគ បានត្រាស់សូត្រនេះហើយ ព្រះសុគត ជាសាស្តា លុះទ្រង់ត្រាស់សូត្រនេះរួចហើយ ទើបត្រាស់គាថាព័ន្ធនេះទៀតថា ៖*

*ទាយកមានចិត្តរីករាយ ក្នុងវេលាមុនអំពីការឲ្យ កំពុងឲ្យធ្វើចិត្តឲ្យជ្រះថ្លា លុះឲ្យហើយ ក៏មានចិត្តត្រេកអរ(តាមក្រោយ) នេះជាសេចក្តីបរិបូរណ៍របស់ទាន ។ បុគ្គលអ្នកប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនមានអាសវៈ ជាព្រហ្មចារី មានសេចក្តីសង្រួម ឈ្មោះថា ជាខេត្តនៃទានដ៏បរិបូរណ៍ (ដោយគុណ) ។ បុគ្គលខ្វល់ខ្វាយដោយខ្លួនឯងឲ្យទានដោយដៃរបស់ខ្លួន ។ ទានទុំះ ជាទានមានផលច្រើន ព្រោះខ្លួនផង ព្រោះបុគ្គលដទៃផង ។ អ្នកប្រាជ្ញ ជាបណ្ឌិត អ្នកមានសទ្ធា មានចិត្តផុតស្រឡះ (ចាកសេចក្តីកំណាញ់) លុះឲ្យទានយ៉ាងនេះហើយ ក៏រមែងទៅកើតក្នុងទេវលោកជាសុខ ឥតមានទុក្ខ ។*

***<u>អដ្ឋកថា ឆឡង្គសូត្រ ថា</u> :***

*បទថា ឆឡង្គសមន្នាគតា ប្រែថា ប្រកបដោយអង្គនៃគុណ ៦ ។ **ទាន** ឈ្មោះថា ទក្ខិណា ។*

ច្រើនបទថា បុព្វេ ធាជា សុមនោ មានសេចក្តីថា រមែងជាអ្នកដល់ហើយនូវសោមនស្ស តាំងអំពី ១ ខែ និង កន្លះខែមកថា អញនឹងឲ្យទាន ដូច្នេះ ។ ក៏បណ្តាចេតនាទាំង ៣ យ៉ាងនេះ បុព្វចេតនា បានដល់ ទាយកអ្នកគិតចាប់ផ្តើម អំពីចង់ស្រែថា អញនឹងឲ្យទាន ដោយផលដែលបានសម្រេច មកអំពីស្រែនេះ ដូច្នេះ តាំងពីវេលាដែលកើតឡើងនៃចិត្តថា អញនឹងឲ្យទាន ដូច្នេះ ។ ចំណែកមុញ្ចនចេតនា ដែលព្រះ មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ទាយកកំពុងឲ្យ រមែង ញ៉ាំងចិត្តឲ្យជ្រះថ្លា រមែងបានក្នុងពេលដែលឲ្យទានទុំះឯង ។ ចំណែកអបរាបរចេតនានោះថា លុះឲ្យទានរួចហើយ ក៏រមែង មានចិត្តត្រេកអរ ដូច្នេះ រមែងបានដល់ ទាយកអ្នកនឹករលឹក តាមជាបន្តបន្ទាប់មក ។

បទថា វីតរាគា គឺមានរាគៈទៅប្រាសហើយ បានដល់ អស់អាសវៈហើយ ។

ពីរបទថា រាគវិនយាយ វា បដិបន្នា មានសេចក្តី ថា ប្រតិបត្តិនូវបដិបទា គ្រឿងកំចាត់បង់នូវរាគៈ ។

ក៏ទេសនានេះ សម្តែងបដិគ្គាហកៈយ៉ាងឧក្រិដ្ឋ ។ ក៏ទក្ខិណា ដែលឲ្យដល់ព្រះខីណាស្រពទាំងឡាយតែមួយពួក ទើបជាទក្ខិណាប្រកបដោយអង្គ ៦ ក៏មិនមែនទេ, ទក្ខិណា ដែលឲ្យសូម្បីដល់ព្រះអនាគាមី ព្រះសកទាគាមី និង ព្រះសោតាបន្នទាំងឡាយ ដោយហោចទៅសូម្បីដល់សាមណេរ អ្នកកាន់នូវភណ្ឌៈ ដែលបួសក្នុងថ្ងៃនោះ ក៏ប្រកបដោយអង្គ ៦ ដូចគ្នាដែរ ។ ព្រោះថា សូម្បីសាមណេរនោះ ឈ្មោះថា បួសហើយដើម្បីសោតាបត្តិមគ្គ មែនពិត ។

<u>ដីកា ឆឡង្គសូត្រ ថា</u> ៖

បទថា បុព្វេវ ទានា មានសេចក្តីថា ក្នុងពេលមុនអំពីមុញ្ចនចេតនា គឺ ចាប់ផ្តើមអំពីការចាត់ចែងឧបករណ៍នៃទាន ។

បទថា សុមនោ មានសេចក្តីថា គប្បីជាអ្នកដល់នូវសោមនស្សថា អាត្មាអញនឹងកប់នូវកំណាប់ទ្រព្យ ដែលជាហេតុនៃសម្បត្តិ មានប្រក្រតីជាប់តាម (ខ្លួន) ទៅបាន ។

បាទគាថាថា ទទំ ចិត្តំ បសាទយេ មានសេចក្តីថា ទាយកកំពុងឲ្យ ដាក់នូវទេយ្យធម៌ចំពោះក្នុងដៃនៃទក្ខិណេយ្យ-

បុគ្គល គប្បីធ្វើចិត្តរបស់ខ្លួនឲ្យជ្រះថ្លាថា អាត្មាអញកំពុងធ្វើនូវការកាន់យកខ្លឹមសារអំពីទ្រព្យដែលមិនមានខ្លឹមសារ ដូច្នេះ ។

បាទគាថា ឧត្វា អត្តមនោ ហោតិ មានសេចក្តីថា ទាយកបរិច្ចាគទេយ្យធម៌ ដល់ទក្ខិណេយ្យបុគ្គលទាំងឡាយហើយ ជាអ្នកមានចិត្តត្រេកអរ រីករាយសប្បាយ គឺ កើតបីតិសោមនស្សថា "ទាន ឈ្មោះថា បណ្ឌិតបញ្ញត្តិទុកហើយ អាត្មាអញ ក៏បានតម្កល់ទុកហើយ, ឱ ! ទានរបស់អាត្មាអញ សម្រេចប្រយោជន៍ ដោយល្អហើយហ្ន៎" ។

បទថា ឯសា មានសេចក្តីថា សេចក្តីបរិបូរណ៍នៃចេតនាទាំង ៣ យ៉ាង ដែលទៅតាមនូវការជឿកម្មនិងផល ដែលសោមនស្សកាន់កាប់ទាំងនេះ គឺ បុព្វចេតនា មុញ្ចនចេតនា អបរាបរចេតនា នេះឯណា សេចក្តីបរិបូរណ៍នៃចេតនានេះ ។

<u>ក្នុងគម្ពីរមង្គលត្ថទីបនី ថា</u> ៖

បទវិគ្គហៈថា ៖ ឧធំ ចិត្តំ បសាទយេតិ ឧឧន្តោ ទេយ្យធម្មំ ឧក្ខិណេយ្យស្ស ហត្ថេ បតិដ្ឋាបេន្តោ អសារតោ ធនតោ សារាទានំ ករោមិ ៖ បុគ្គលមាន

*ចេតនាកាលញ៉ាំងទេយ្យធម៌ ឲ្យតម្កល់នៅចំពោះក្នុងដៃខាងស្តាំថា អញនឹងធ្វើនូវទ្រព្យមិនមានខ្លឹម ឲ្យទៅជាទ្រព្យមានខ្លឹម, ឈ្មោះថា* ឧទំ ចិត្តំ បសាទយេ *គឺ ញ៉ាំងចិត្តឲ្យជ្រះថ្លា ។*

ឧត្វា អត្តមនោ ហោតីតិ ឧក្ខិណេយ្យានំ ទេយ្យធម្មំ បរិច្ចជិត្វា បណ្ឌិតប្បញ្ញត្តំ ឆាម មយា អនុដ្ឋិតំ អហោ សាធុ សុដ្ឋូតិ អត្តមនោ បមុទិតោ បីតិសោមនស្សជាតោ ហោតិ : *បុគ្គលលះបង់នូវទេយ្យធម៌ដល់ទក្ខិណេយ្យបុគ្គល ជាអ្នកមានចិត្តត្រេកអរផង មានចិត្តរីករាយផង ជាអ្នកមានបីតិនិងសោមនស្សកើតឡើងដោយគិតថា ទាននេះ គឺ អញបានតម្កល់នៅល្អហើយ ឈ្មោះថា គឺបណ្ឌិតលោកបញ្ញត្តិហើយថា ជាទានញ៉ាំងប្រយោជន៍ឲ្យសម្រេចដោយប្រពៃ ឈ្មោះថា* ឧត្វា អត្តមនោ ហោតិ *គឺ ឲ្យរួចហើយមានចិត្តជ្រះថ្លាថែមខាងក្រោយទៀត ។*

<u>*សេចក្តីតំណាលថា*</u> *អបុត្តកសេដ្ឋីនោះ កាលពីព្រេង-នាយមក កើតជាសេដ្ឋី ក្នុងក្រុងពារាណសី ថ្ងៃមួយក្រោកអំពីព្រលឹម បរិភោគរួចហើយ ទៅគាល់បម្រើស្តេច ឃើញព្រះបច្ចេកពុទ្ធព្រះនាម*តគរសិខី *ញ៉ាំងបុគ្គលឲ្យយកចង្ហាន់*

បិណ្ឌបាតប្រគេនដល់ព្រះបច្ចេកពុទ្ធអង្គនោះថា អ្នកទាំងឡាយ ចូរឲ្យនូវដុំបាយដល់សមណៈដូច្នេះ លុះពោលរួចហើយ ក៏ក្រោកពីអាសនៈចៀសចេញទៅ ។ លុះសេដ្ឋីគហបតីនោះឲ្យរួចហើយ ជាអ្នកមានសេចក្ដីក្ដៅក្រហាយ ក្នុងពេលជាខាងក្រោយថា ទាសៈទាំងឡាយក្ដី កម្មករទាំងឡាយក្ដី គប្បីបរិភោគនូវបិណ្ឌបាតនេះប្រសើរជាង ។

សេដ្ឋីគហបតីនោះ បានឲ្យគេប្រតិបត្តិព្រះ**តគរសិខី**-បច្ចេកពុទ្ធ ដោយបិណ្ឌបាតហើយ បានទៅកាន់សុគតិសួគ៌ទេវលោក អស់វារៈ ៧ ដង ដោយវិបាករបស់កម្មនោះឯង បានដំណែងជាសេដ្ឋីក្នុងក្រុងសាវត្ថីនេះឯង អស់វារៈ ៧ ដង ដោយសេសសល់ផលកម្មនោះឯង ។

លុះសេដ្ឋីគហបតីនោះឲ្យរួចហើយ ជាអ្នកមានសេចក្ដីក្ដៅក្រហាយក្នុងពេលជាខាងក្រោយថា ទាសៈទាំងឡាយក្ដី កម្មករទាំងឡាយក្ដី គប្បីបរិភោគនូវបិណ្ឌបាតនេះប្រសើរជាង ដោយវិបាកនៃកម្មនោះ បានជាសេដ្ឋីគហបតីនោះ មិនបង្អោនចិត្តទៅ ដើម្បីបរិភោគនូវភត្តឆ្ងាញ់ពិសា មិនបង្អោនចិត្តទៅ ដើម្បីប្រើប្រាស់សំពត់ល្អថ្លៃថ្លា មិនបង្អោនចិត្តទៅ ដើម្បី

ប្រើប្រាស់យានល្អ មិនបង្អោនចិត្តទៅ ដើម្បីបរិភោគបញ្ចកាមគុណដ៏ថ្លៃថ្លា ។

ព្រោះថា ចេតនាតែមួយពិតក្នុងបិណ្ឌបាតទានតែមួយដែរ គឺមិនឲ្យនូវបដិសន្ធិ ២ ទេ សម្រេចនូវប្រយោជន៍ ជវនចិត្តតែមួយ កាលពោលថា អ្នកទាំងឡាយចូរឲ្យបិណ្ឌបាតដល់សមណៈនេះ ត្រង់ជវនចិត្តកណ្តាលក៏គ្មាន និងខាងចុងក៏គ្មាន ជវនចិត្តមិនស្ទុះទៅកាន់គ្រប់ទាំង ៣ កាល គឺ ចេតនា ៣ មិនគ្រប់គ្រាន់ ។ (មង្គលត្ថទីបនី. ៣,១៣; សុត្តន្ត. ២៩,២៥០)

## ១.៦ ទានមាន ៨ យ៉ាង

(អង្គុត្តរនិកាយ លេខ៤៨ ទំព័រ១៦០)

១-អាសជ្ជ ទានំ ទេតិ : គឺបុគ្គលឲ្យទានព្រោះបានបាត់បែងទុកស្រេច

២-ភយា ទានំ ទេតិ : ឲ្យទានព្រោះភ័យ

៣-អទាសិ មេតិ ទានំ ទេតិ : ឲ្យទានដោយគិតថា គេបានឲ្យដល់អញ (ក្នុងកាលមុន)

៤-ទស្សតិ មេតិ ទានំ ទេតិ : ឲ្យទានដោយ

*គិតថា គេនឹងឲ្យដល់អញវិញ (ក្នុងអនាគត)*

៥-សាហុ ទានន្តិ ទានំ ទេតិ : *ឲ្យទានដោយគិតថា ទានជាការប្រពៃ*

៦-អហំ បចាមិ ឥមេ ន បចន្តិ នារហាមិ បចន្តោ អបចន្តានំ ទានំ ន ទាតុន្តិ ទានំ ទេតិ : *ឲ្យទានដោយគិតថា អញចំអិន បុគ្គលទាំងឡាយនេះ មិនទាន់ចំអិន អញកាលចំអិន មិនគួរដើម្បីមិនឲ្យទានដល់ បុគ្គលមិនទាន់ចំអិន*

៧-ឥមំ មេ ទានំ ទទតោ កល្យាណោ កិត្តិ-សទ្ទោ អព្ភុគ្គច្ឆតីតិ ទានំ ទេតិ : *ឲ្យទានដោយគិតថា កាលបើអញឲ្យនូវទាននេះ កិត្តិស័ព្ទដ៏ពីរោះ រមែងខ្ចរខ្ចាយទៅ*

៨-ចិត្តាលង្ការចិត្តបរិក្ខារត្ថំ ទានំ ទេតិ: *ឲ្យទានដើម្បីជាគ្រឿងប្រដាប់នៃចិត្ត និង ជាបរិក្ខានៃចិត្ត ។*

*<u>អដ្ឋកថា ពន្យល់ថា</u>* ៖

*បទថា* អាសជ្ជ ទានំ ទេតិ *សេចក្តីថា បុគ្គលខ្លះឲ្យទាន ព្រោះបានចាត់ចែងទុកស្រេច គឺល្មមឃើញ បដិគ្គា-*

*ហាក:មកដល់ និមន្តឲ្យទាន អង្គុយមួយរំពេចធ្វើសក្ការ:ហើយទើបឲ្យទាន រមែងមិនលំបាកចិត្តថា នឹងឲ្យ ។*

*បទថា* **ភយា** *បានដល់ ព្រោះភ័យខ្លាច (គេ)រិះគន់ថា អ្នកនេះ ជាអ្នកមិនឲ្យ ជាអ្នកមិនធ្វើ ឬព្រោះភ័យខ្លាចអបាយភូមិ ។*

*បទថា* **សាហុ** **ទានំ** *សេចក្តីថា ឲ្យដោយគិតថា ឈ្មោះថា* **ទាន** *ញុំាងប្រយោជន៍ឲ្យសម្រេច គឺ ល្អ បានដល់ដែលបណ្ឌិតមានព្រះពុទ្ធជាម្ចាស់ជាដើមសរសើរហើយ ។*

*បទថា* **ចិត្តាលង្ការចិត្តបរិក្ខារត្ថំ** **ទានំ** **ទេតិ** *សេចក្តីថា ឲ្យដើម្បីជាគ្រឿងប្រដាប់នៃចិត្ត និងជាបរិក្ខារនៃចិត្តក្នុងសមថ:និងវិបស្សនា ។ ព្រោះថា ទានរមែងធ្វើចិត្តឲ្យទន់ភ្លន់ បុគ្គលអ្នកបានទទួលទាន រមែងមានចិត្តទន់ភ្លន់ល្អថា យើងបានហើយ សូម្បីបុគ្គលអ្នកឲ្យទាននោះ ក៏រមែងមានចិត្តទន់ភ្លន់ថា យើងឲ្យទានហើយ ។ ព្រោះដូច្នោះ ទាននោះ ឈ្មោះថា រមែងធ្វើចិត្តរបស់បុគ្គលទាំងពីរផ្នែកឲ្យទន់ភ្លន់ ព្រោះហេតុនោះឯង ទើបទ្រង់ត្រាស់ថា* **អទន្តទមនំ** *ការទូន្មានចិត្តដែលនៅមិនទាន់បានទូន្មាន ដូចព្រះមានព្រះភាគ ត្រាស់ទុកថា ៖*

**អទន្តទមនំ ទានំ អទានំ ទន្តទូសកំ**

**អនេន បិយវាចេន ឱណមន្តិ នមន្តិ ច ។**

*ការឲ្យទានជាគ្រឿងទូន្មានចិត្ត ដែលនៅមិនទាន់ទូន្មាន ការមិនឲ្យទានជាគ្រឿងប្រទូសរ៉ាយចិត្ត ដែលទូន្មានហើយ ជនទាំងឡាយមានចិត្តទន់ភ្លន់ នឹងគោរពឱនចុះដោយបិយវាចានេះ ។*

*ក៏បណ្ដាការឲ្យទាន ៨ ប្រការនេះ ការឲ្យដើម្បីជាគ្រឿងប្រដាប់ចិត្តប៉ុណ្ណោះ ជាការខ្ពស់បំផុត ។*

*(ចាកមនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ ៣៧ / ៤៧២)*

## ១.៧ ទានវត្ថុ ៨ យ៉ាង

១-ឆន្ទា ទានំ ទេតិ *ឲ្យទានព្រោះសេចក្ដីស្រឡាញ់*

២-ទោសា ទានំ ទេតិ *ឲ្យទានព្រោះសេចក្ដីខឹង*

៣-មោហា ទានំ ទេតិ *ឲ្យទានព្រោះសេចក្ដីល្ងង់*

៤-ភយា ទានំ ទេតិ *ឲ្យទានព្រោះសេចក្ដីភ័យ*

៥-ទិន្នបុព្វំ កតបុព្វំ បិតុបិតាមហេហិ ននាហាសិ ពោរាណំ កុលវំសំ ហាបេតុន្តិ ទានំ ទេតិ : *ឲ្យទាន*

*ព្រោះគិតថា ជីដូនជីតាទាំងឡាយ (របស់អញ) ធ្លាប់ឲ្យធ្លាប់ធ្វើមក អញមិនគួរញ៉ាំងវង្សត្រកូលពីបូរាណនោះឲ្យវិនាស*

**៦-ឥមាហំ ទានំ ទត្វា កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជិស្សាមីតិ ទានំ ទេតិ** : *ឲ្យទានព្រោះគិតថា អញបានឲ្យទាននេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិសួគ៌ទេវលោក*

**៧-ឥមំ មេ ទានំ ទទតោ ចិត្តំ បសីទតិ អត្តមនតា សោមនស្សំ ឧបជាយតីតិ ទានំ ទេតិ** : *ឲ្យទាន ព្រោះគិតថា កាលអញឲ្យទាននេះ ចិត្តរមែងជ្រះថ្លា ទាំងសេចក្តីពេញចិត្តនិងសោមនស្ស ក៏រមែងកើតឡើង*

**៨-ចិត្តាលង្ការចិត្តបរិក្ខារត្ថំ ទានំ ទេតិ** : *ឲ្យទានដើម្បីជាគ្រឿងប្រដាប់នៃចិត្ត និងជាបរិក្ខារនៃចិត្ត ។*

*ក្នុងអដ្ឋកថា ទានវត្ថុសូត្រ ពន្យល់ថា ៖*

*បទថា* ទានវត្ថូនិ *បានដល់ ហេតុនៃការឲ្យទាន ។*

*បទថា* ឆន្ទា ទានំ ទេតិ *សេចក្តីថា បុគ្គលឲ្យទានព្រោះសេចក្តីស្រឡាញ់ ។ បទថា* ទោសា *សេចក្តីថា ជា*

អ្នកក្រោធហើយ វត្ថុណាមាន ប្រញាប់ចាប់យកវត្ថុនោះឲ្យទៅ ព្រោះទោសៈ ។ បទថា មោហេន សេចក្តីថា ជាអ្នកល្ងង់ ឲ្យទៅ ព្រោះមោហៈ ។ បទថា ភយា សេចក្តីថា ព្រោះខ្លាច(ពាក្យ)រិះគន់ ឬព្រោះខ្លាចអបាយភូមិ ឬព្រោះភ័យខ្លាច(ពាក្យ)រិះគន់និងអបាយភូមិនោះឯងពិតៗ ទើបឲ្យទៅ ។

បទថា កុលវំសំ បានដល់ ជាប្រវេណីរបស់ត្រកូល ។

(ចាកមនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ អដ្ឋកនិបាត)

## ១.៨ សប្បុរិសទាន ៨ យ៉ាង

(សុត្តន្តបិដក អង្គុត្តរនិកាយ លេខ ៤៨ ទំព័រ ១៧៣)

១-សុចឹ ទេតិ បុគ្គលឲ្យវត្ថុស្អាត

២-បណីតំ ទេតិ ឲ្យវត្ថុថ្លៃថ្លា

៣-កាលេន ទេតិ ឲ្យតាមកាល

៤-កប្បិយំ ទេតិ ឲ្យវត្ថុគួរ

៥-វិចេយ្យ ទេតិ ជ្រើសរើសហើយ ទើបឲ្យ

៦-អភិណ្ហំ ទេតិ ឲ្យទានរឿយៗ

៧-ទទំ ចិត្តំ បសាទេតិ កំពុងឲ្យញ៉ាំងចិត្តឲ្យជ្រះថ្លា

៨-ឧត្វា អត្តមនោ ហោតិ *លុះឲ្យហើយ រមែង មានសេចក្តីពេញចិត្ត ។*

*បុគ្គលរមែងឲ្យនូវទានទាំងឡាយ គឺទឹកនិងភោជនដ៏ស្អាត ថ្លៃថ្លាតាមកាល វត្ថុដ៏គួររឿយៗ ចំពោះព្រហ្មចារីបុគ្គល ទាំងឡាយ ដូចជាស្រែដ៏ល្អ ពួកអ្នកប្រាជ្ញ រមែងសរសើរនូវទានទាំងឡាយ ដែលបុគ្គលលះបង់នូវអាមិសៈ ជាច្រើន ដែលមិនគួរឲ្យកើតសេចក្តីក្តៅក្រហាយ ហើយ ឲ្យយ៉ាងនេះ អ្នកប្រាជ្ញ មានបញ្ញា ជាអ្នកមានសទ្ធា បានបូជាយ៉ាងនេះហើយ មានចិត្តរួចស្រឡះ រមែងចូល ទៅកាន់ទេវលោក ដែលមិនមានសេចក្តីទុក្ខ មានតែ សេចក្តីសុខ ។*

## ១.៩ ទាន ២១ យ៉ាង

*ក៏ក្នុងទក្ខិណាវិភង្គសូត្រ ក្នុងចតុត្ថវគ្គ ឧបរិបណ្ណាសក ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទាន ២១ យ៉ាង ។*

## *បាដិបុគ្គលិកទាន មាន ១៤*

*(សុត្តន្តបិដក លេខ២៨ ទំព័រ២២០-២២៦)*

១-តថាគតេ អរហន្តេ សម្មាសម្ពុទ្ធេ ទានំ ទេតិ *ឲ្យទានចំពោះព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។*

២-បច្ចេកសម្ពុទ្ធេ ទានំ ទេតិ *ឲ្យទានចំពោះព្រះបច្ចេកសម្ពុទ្ធ*

៣-តថាគតសាវកេ អរហន្តេ ទានំ ទេតិ *ឲ្យទានចំពោះព្រះអរហន្ត ជាសាវករបស់តថាគត ។*

៤-អរហត្តផលសច្ឆិកិរិយាយ បដិបន្នេ ទានំ ទេតិ *ឲ្យទានចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល*

៥-អនាគាមិស្ស ទានំ ទេតិ *ឲ្យទានចំពោះអនាគាមិបុគ្គល*

៦-អនាគាមិផលសច្ឆិកិរិយាយ បដិបន្នេ ទានំ ទេតិ *ឲ្យទានចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល*

៧-សកទាគាមិស្ស ទានំ ទេតិ *ឲ្យទានចំពោះសកទាគាមិបុគ្គល*

៨-សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នេ ទានំ ទេតិ *ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល*

៩-សោតាបន្នេ ទានំ ទេតិ *ឲ្យទានចំពោះសោតាបន្នបុគ្គល*

១០-សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នេ ទានំ ទេតិ *ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឲ្យជាក់ ច្បាស់នូវសោតាបត្តិផល*

១១-ពាហិរកេ កាមេសុ វីតរាគេ ទានំ ទេតិ *ឲ្យទានចំពោះអ្នកបួសខាងក្រៅ (ពុទ្ធសាសនា) ដែលប្រាសចាកតម្រេក ក្នុងកាមទាំងឡាយ*

១២-បុថុជ្ជនសីលវន្តេ ទានំ ទេតិ *ឲ្យទានចំពោះបុថុជ្ជនមានសីល*

១៣–បុថុជ្ជនទុស្សីលេ ទានំ ទេតិ *ឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល*

១៤–តិរច្ឆានគតេ ទានំ ទេតិ *ឲ្យទានចំពោះសត្វតិរច្ឆាន ។*

## *សង្ឃគតាទក្ខិណាទាន មាន ៧*

១–ពុទ្ធប្បមុខេ ឧភតោសង្ឃេ ទានំ ទេតិ *បុគ្គលឲ្យទានចំពោះសង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រធាន*

២–តថាគតេ បរិនិព្វុតេ ឧភតោសង្ឃេ ទានំ ទេតិ *កាលបើព្រះតថាគតបរិនិព្វានទៅ បុគ្គលឲ្យទានចំពោះសង្ឃទាំងពីរចំណែក ។*

៣–ភិក្ខុសង្ឃេ ទានំ ទេតិ *ឲ្យទានចំពោះតែភិក្ខុសង្ឃ*

៤–ភិក្ខុនីសង្ឃេ ទានំ ទេតិ *ឲ្យទានចំពោះតែភិក្ខុនីសង្ឃ ។*

៥–ឯត្តកេ មេ ភិក្ខូ ច ភិក្ខុនិយោ ច សង្ឃតោ ឧទ្ទិស្សថាតិ ទានំ ទេតិ *បុគ្គល (ទៅនិមន្ត*

*អំពីភិក្ខុសង្ឃ) ថា សូមលោកម្ចាស់ទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណេះ ពួកភិក្ខុនីប៉ុណ្ណេះ អំពីសង្ឃដើម្បីខ្ញុំ ហើយទើបឲ្យទាន*

៦-ឯត្តកេ មេ ភិក្ខូ សង្ឃតោ ឧទ្ទិស្សជាតិ ធានំ ទេតិ *បុគ្គល (ទៅនិមន្តអំពីសំណាក់សង្ឃ) ថា សូមលោកម្ចាស់ទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណេះអំពីសង្ឃ ដើម្បីខ្ញុំ ហើយទើបឲ្យទាន ។*

៧-ឯត្តកា មេ ភិក្ខុនិយោ សង្ឃតោ ឧទ្ទិស្ស-ជាតិ ធានំ ទេតិ *បុគ្គល (ទៅនិមន្តអំពីសំណាក់សង្ឃ) ថា សូមលោកម្ចាស់ទាំងឡាយ ចាត់ពួកភិក្ខុនីប៉ុណ្ណេះ អំពីសង្ឃ ដើម្បីខ្ញុំ ហើយទើបឲ្យទាន ។*

## អធិប្បាយបាដិបុគ្គលិកទាន

*ក៏បណ្ដាទាន ២១ យ៉ាងនោះ ទានណា ដែលបុគ្គលឲ្យហើយ ដល់សត្វតិរច្ឆាន ដើម្បីនឹងចិញ្ចឹម ដោយអំណាចនៃគុណ មានការដល់ព្រមដោយលក្ខណៈជាដើម និងដោយអំណាចឧបការៈ មានការបានទឹកដោះនិងការចាំថែរក្សា ជា*

*ដើម, ទាននោះ ព្រះអង្គទ្រង់មិនកំណត់យកទេ ព្រោះមិនប្រកប ដោយលក្ខណៈនៃទាន ។ មែនពិត ការបរិច្ចាគដោយវត្ថុដែល គប្បីឲ្យរបស់ខ្លួន* ***ដោយអំណាចសេចក្តីប្រាថ្នា ដើម្បីសេចក្តី អនុគ្រោះ*** *និង* ***ការបូជា*** *ឈ្មោះថា* **ទាន** *។ ការបរិច្ចាគវត្ថុ ដែលគប្បីឲ្យដោយអំណាចការភ័យខ្លាច សេចក្តីស្រឡាញ់ និង ប្រាថ្នាការសូកប៉ាន់ជាដើម មិនឈ្មោះថាទានទេ ព្រោះជាទាន ដែលមានទោស ។ វត្ថុសូម្បីត្រឹមតែពំនូតបាយកន្ទះពំនូត ឯណា ដែលបុគ្គលឲ្យហើយ សូម្បីវត្ថុនោះ ព្រះអង្គក៏មិនបាន កំណត់យកដែរ ព្រោះមិនអាចក្នុងការឲ្យផលបានតាមដែល ប្រាថ្នាចង់បាន ព្រោះភាវនៃទានដែលល្មមដល់សេចក្តីត្រូវការ នូវមិនទាន់បានបរិបូរណ៍ ។ ក៏ទានណា ដែលបុគ្គលប្រាថ្នា ចំពោះផល ដោយន័យជាដើមថា “****បុណ្យដែលសម្រេចដោយ ទាននេះឯង ចូរមានដើម្បីសេចក្តីចម្រើន នៃប្រយោជន៍សុខ តទៅ****” ដូច្នេះ បានឲ្យដល់បណ្តាសត្វតិរច្ឆាន មានសុនខ ជ្រូក មាន់ និងក្អែកជាដើម សត្វឯណាមួយ ដែលខ្លួនបានជួបប្រទះ ហើយ ល្មមដល់សេចក្តីត្រូវការ ទាននោះ ព្រះអង្គទ្រង់ កំណត់យកហើយថា “ទានក្នុងសត្វតិរច្ឆាន” ។*

ទានក្នុងសត្វតិរច្ឆាននោះ ឈ្មោះថា មានអានិសង្ស ១០០ ដង ព្រោះឲ្យអានិសង្ស ៥០០ គឺ ឲ្យអាយុក្នុង ១០០ អត្តភាព, ឲ្យពណ៌សម្បុរ ឲ្យសេចក្តីសុខ ឲ្យកម្លាំង ឲ្យបដិភាណ ក្នុង ១០០ អត្តភាព ។ គប្បីជ្រាបន័យ សូម្បីក្នុងទានដែលខ្ពស់ឡើងៗទៅ យ៉ាងដូច្នេះដែរ ។

មួយទៀត ជនទាំងឡាយ មានព្រានសំណាញ់ និង អ្នកចាប់ត្រីជាដើម ដែលចិញ្ចឹមជីវិតដោយការបៀតបៀន សត្វដទៃ ឈ្មោះថា បុថុជ្ជនទ្រុស្តសីល **ទាន** ដែលគេឲ្យហើយ ដល់បុថុជ្ជនទ្រុស្តសីលនោះ មានអានិសង្ស ១០០០ ដង ។

ម្យ៉ាងទៀត បុគ្គលអ្នកមានសីល ដូចជាអ្នកមានសីល ជាអ្នកមិនអួតអាង មិនមានមាយា មិនបៀតបៀននូវសត្វដទៃ ចិញ្ចឹមជីវិតដោយកសិកម្ម ឬពាណិជ្ជកម្ម ដោយធម៌ស្មើ ឈ្មោះថា បុថុជ្ជនមានសីល ។ **ទាន**ដែលគេឲ្យហើយ ដល់ បុថុជ្ជនមានសីលនោះ មានអានិសង្ស ១ សែនដង ។

មួយទៀត អ្នកមានអភិញ្ញា ៥ ដែលជាលោកិយ មានប្រក្រតី ពោលកម្ម ជាអ្នកបួសខាងក្រៅ (ពុទ្ធសាសនា) ឈ្មោះថា ជាអ្នកគ្មានសេចក្តីត្រេកអរក្នុងកាមទាំងឡាយ **ទាន**

ដែលគេឲ្យហើយដល់តាបស អ្នកមិនមានសេចក្តីត្រេកអរក្នុងកាមទាំងឡាយនោះ មានអានិសង្ស ១ សែនកោដិ ។

ទានដែលគេឲ្យហើយ ដល់អ្នកទទួលទាំងឡាយ ១០ នេះ គឺ ដល់បុគ្គលដែលប្រតិបត្តិដើម្បីសោតាបត្តិផល ដល់ព្រះសោតាបន្ន ដល់បុគ្គលដែលប្រតិបត្តិ ដើម្បីសកទាគាមិ-ផល ដល់ព្រះសកទាគាមី ដល់បុគ្គលដែលប្រតិបត្តិដើម្បីអនាគាមិផល ដល់ព្រះអនាគាមី ដល់បុគ្គលដែលប្រតិបត្តិដើម្បីអរហត្តផល ដល់ព្រះអរហន្ត ដល់ព្រះបច្ចេកពុទ្ធ ដល់ព្រះសម្មាសម្ពុទ្ធ ជាទានដែលរាប់មិនបានដោយផល ។

សួរថា សេចក្តីប្លែកផ្សេងគ្នានៃទានដែលគេឲ្យហើយដល់បដិគ្គាហកៈទាំង ១០ ពួកនោះ តើដូចម្តេចខ្លះ ?

ឆ្លើយថា ភាវៈនៃទានដែលគេឲ្យហើយ ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីប្រយោជន៍ដល់សោតាបត្តិផល មានផលរាប់មិនបាន គប្បីជ្រាបដូចជាទឹកក្នុងចង្អូរ ជារបស់ដែលរាប់មិនបានដូច្នោះ ។ ភាវៈនៃទានដែលបុគ្គលថ្វាយហើយ ចំពោះព្រះអរិយបុគ្គលទាំងឡាយ មានព្រះសោតាបន្នជាដើម ជាទានមានផលរាប់មិនបាន ដោយអំណាចគុណខ្ពស់ក្រៃលែងជាង

គ្មាន គប្បីជ្រាបដូចជាទឹកក្នុងមហានទី និងក្នុងមហាសមុទ្រនោះៗ ជារបស់ដែលរាប់មិនបានដូច្នោះ ។ សេចក្តីនេះគប្បីជ្រាបសូម្បីក្នុងភាវៈនៃអាចម៍ដី ចាប់ដើមអំពីអាចម៍ដីក្នុងប្រទេស ដែលមានទំហំស្មើនឹងមណ្ឌលលាននៃផែនដី រហូតដល់អាចម៍ដីពេញទាំងផែនដី ប្រមាណមិនបាន ។ មែនពិតសូម្បីកាលបើមានភាវៈនៃទានទាំងនោះ ជាទានស្មើគ្នាដោយភាវៈជាទានមានផលរាប់មិនបាន, ភាវៈនៃទានជារបស់តិច និងច្រើន រមែងមានដូចគ្នា គប្បីជ្រាបដូចជាសំវដ្តកប្បជាដើមជារបស់រាប់មិនបាន និង ជាភាវៈនៃមហាកប្ប ក៏ជារបស់ដែលរាប់មិនបានដូច្នោះ ។

បណ្តាអ្នកទទួលទាំងនោះ អ្នកទទួលទាំង ៨ នេះ គឺ ឧបាសកអ្នកដល់នូវព្រះត្រៃសរណៈ, ឧបាសកអ្នកតាំងនៅក្នុងសីល ៥, ឧបាសកអ្នកតាំងនៅក្នុងសីល ១០, សាមណេរដែលបួសក្នុងថ្ងៃនោះ, ភិក្ខុអ្នកគ្រាន់តែបួសហើយភ្លាម, ភិក្ខុអ្នកដល់ព្រមដោយវត្ត, ភិក្ខុអ្នកប្រារព្ធវិបស្សនា, ភិក្ខុអ្នកតាំងនៅក្នុងបឋមមគ្គ ឈ្មោះថា ជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ដល់សោតាបត្តិផល ។ មែនពិត ការចុះកាន់ព្រះ

សាសនា ក៏ត្រឹមតែដើម្បីរលាស់ចេញនូវទុក្ខក្នុងវដ្តសង្សារ និង ត្រឹមតែដើម្បីបាក់ផ្ចុះនូវមគ្គតែប៉ុណ្ណោះ, ព្រោះហេតុនោះ កិរិយាដល់នូវសរណៈ ការសមាទានសិក្ខាបទ បព្វជ្ជា ឧបសម្បទ ការញ៉ាំងសីលឲ្យបរិបូរណ៍ ការប្រកបរឿយៗ នូវអធិចិត្តសិក្ខា វិបស្សនាដែលជាចំណែកនៃការត្រាស់ដឹង សរុបទៅ បដិបទាទាំងនេះ ជាការបដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ដោយពិត ។

ប្រៀបដូចជាសមាធិភាវនា ដែលជាចំណែកនៃកិរិយាត្រាស់ដឹង រមែងជាឧបនិស្ស័យ ដោយភាវៈជាបច្ច័យនៃការសម្រេចនូវអរិយមគ្គ ជាបន្តបន្ទាប់គ្នាទៅ យ៉ាងណាមិញ ការធ្វើសីលឲ្យបរិបូរណ៍ឧបសម្បទ បព្វជ្ជា កិរិយាតាំងនៅក្នុងសីល ១០ ឬសីល ៥ របស់ឧបាសក ដែលជាចំណែកនៃការត្រាស់ដឹង ដោយហោចទៅ សូម្បីការដល់នូវសរណៈដែលជាចំណែកនៃការត្រាស់ដឹង រមែងជាឧបនិស្ស័យ នៃការបាននូវអរិយមគ្គ ក៏យ៉ាងដូច្នោះដែរ ព្រោះហេតុនោះ បដិបទាទាំងអស់នេះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ថា

“ជាសេចក្តីបដិបត្តិ ដើម្បីប្រយោជន៍ដល់សោតាបត្តិផល” ដូច្នេះ ។

បណ្តាបដិគ្គាហកៈទាំង ៨ ពួកនោះ សូម្បីទានដែលបុគ្គលឲ្យហើយ ដល់ឧបាសកអ្នកដល់នូវត្រៃសរណៈ ក៏រមែងមានផលរាប់មិនបាន សេចក្តីជ្រះថ្លាដែលញាណជម្រះហើយ ដែលសង្គ្រោះដោយសេចក្តីរាប់អាន និងសេចក្តីគោរពដ៏ច្រើន ក្នុងព្រះមានព្រះភាគជាម្ចាស់ ក្នុងព្រះធម៌ ក្នុងព្រះសង្ឃ ដោយអាការៈយ៉ាងប្រសើរក្រៃលែង ដែលប្រព្រឹត្តទៅហើយ ដោយអាការៈថា ភាវៈជាអ្នកមានព្រះរតនត្រ័យនោះជាខាងដើម ជាអាទិថា “ព្រះមានព្រះភាគជាម្ចាស់ ទ្រង់បានត្រាស់ដឹងដោយប្រពៃ ចំពោះព្រះអង្គឯង ព្រះធម៌ គឺ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្តែងហើយដោយល្អ, ព្រះសង្ឃជាអ្នកប្រតិបត្តិហើយដោយល្អ” ដូច្នេះ ឈ្មោះថា សរណគមន៍ ។ បុណ្យដែលបុគ្គលធ្វើហើយ ក្នុងសន្តានដែលខ្លួនអប់រំហើយដោយសេចក្តីជ្រះថ្លា ដែលប្រព្រឹត្តទៅក្នុងវត្ថុ (ព្រះរតនត្រ័យ) នោះ រមែងជាទានមានផលច្រើន ព្រោះកិរិយាដល់ព្រមនៃខេត្ត ដោយប្រការដូច្នេះឯង ។

**ទាន** ដែលបុគ្គលឲ្យហើយ ដល់ឧបាសកអ្នកមានសីល៥ ជាទានមានផលច្រើនជាងទាននោះ ។ ព្រោះថា សរណគមន៍ គឺ កិរិយាដល់ព្រមនៃអធ្យាស្រ័យ ព្រោះមានសេចក្តីជ្រះថ្លាក្នុងវត្ថុ ៣ យ៉ាង (ព្រះរតនត្រ័យ) សរុបសេចក្តីទៅសីល ៥ របស់ឧបាសកអ្នកប្រាកដដូច្នោះនោះ ក៏គឺសេចក្តីសង្រួមកាយវាចា ដែលកិរិយាដល់ព្រមនៃអធ្យាស្រ័យឧបត្ថម្ភហើយ ។ ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ចំពោះឧបាសកអ្នកមានសីល ៥ នោះ ទើបឈ្មោះថា មានផលច្រើន យ៉ាងដូច្នេះ ។ **ទាន** ដែលបុគ្គលឲ្យហើយ ចំពោះឧបាសកអ្នកមានសីល ១០ នោះ ជាទានមានផលច្រើនជាងទានដែលគេឲ្យដល់ឧបាសកអ្នកមានសីល ៥ នោះ ។ មែនពិត សីល ១០ ឈ្មោះថា សីលរបស់ឧបាសកយ៉ាងបរិបូរណ៍ ព្រោះហេតុនោះ ទានដែលបុគ្គលឲ្យហើយ ចំពោះឧបាសកអ្នកមានសីល ១០ នោះ ទើបមានផលច្រើនដូច្នេះ ។ **ទាន** ដែលបុគ្គលប្រគេនហើយដល់សាមណេរមានផលច្រើនជាងទាននោះ ។ **ទាន** ដែលបុគ្គលប្រគេនហើយ ដល់ភិក្ខុអ្នកគ្រាន់តែបួសស្រេចហើយភ្លាម មានផលច្រើនជាងទាននោះ ។ **ទាន** ដែលបុគ្គលប្រគេន

ហើយដល់ភិក្ខុអ្នកដល់ព្រមដោយវត្ត មានផលច្រើនជាងទាននោះ ។ **ទាន** ដែលបុគ្គលប្រគេនហើយ ដល់ភិក្ខុអ្នកប្រារព្ធវិបស្សនា មានផលច្រើនជាងទាននោះ ។

ក៏ភាវៈនៃទាន ដែលបុគ្គលឲ្យហើយចំពោះបដិគ្គាហកៈនោះៗ ជាទានមានផលច្រើនប្លែកផ្សេងៗគ្នា ។ ព្រោះភាវៈនៃគុណ មានសីលរបស់សាមណេរជាដើម ប្រសើរជាងគ្នាជាដើម ព្រោះគុណដែលប្រសើរខ្ពង់ខ្ពស់ជាងគ្នា ដូច្នេះ ។ ក៏ភាវៈនៃលោកអ្នកដែលដល់ព្រមដោយមគ្គ ឈ្មោះថា ជាអ្នកមានគុណមិនទាន់ពេញបរិបូរណ៍ ព្រោះលោកជាអ្នកមិនទាន់បានសម្រេចកិច្ច ព្រោះសង្កិលេសធម៌ទាំងឡាយ លោកកំពុងតែលះបង់ និងព្រោះវោទានធម៌ទាំងឡាយ គឺ លោកកំពុងតែចម្រើនដោយចំណែកនោះៗ, ក៏ភាវៈនៃលោកអ្នកដែលដល់ព្រមដោយផលទាំងឡាយ ឈ្មោះថា ជាអ្នកមានគុណបរិបូណ៌ហើយ ព្រោះលោកជាអ្នកមានកិច្ចសម្រេចហើយ ព្រោះហេតុនោះ គប្បីជ្រាបភាវៈនៃលោកអ្នកដែលតាំងនៅក្នុងផល ជាខេត្តដ៏ខ្ពង់ខ្ពស់ជាងអ្នកដែលតាំងនៅក្នុងមគ្គនោះៗ ។

មួយទៀត ការៈនៃលោកអ្នកដែលតាំងនៅក្នុងមគ្គខាងលើ ជាអ្នកមានគុណខ្ពង់ខ្ពស់ជាងលោកអ្នកដែលតាំងនៅក្នុងមគ្គខាងក្រោម និងការៈនៃលោកអ្នកដែលតាំងនៅក្នុងផលខាងលើ ជាអ្នកមានគុណខ្ពង់ខ្ពស់ ជាងលោកអ្នកដែលតាំងនៅក្នុងផលខាងក្រោម, ប្រាកដហើយមែនពិត ។ មែនពិតដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ការៈនៃទានដែលបុគ្គលប្រគេនហើយ ដល់ព្រះអរិយបុគ្គល អ្នកមានគុណខ្ពង់ខ្ពស់ទាំងឡាយ ជាទានមានផលច្រើន ។

សួរថា ឈ្មោះថា ការៈនៃលោកអ្នកដែលព្រមព្រៀងដោយមគ្គ ដែលធម្មតាកំណត់ហើយ ដោយលក្ខណៈនៃមគ្គចិត្ត, ក៏ក្នុងខណៈនោះ ការប្រគេនទានក្តី ការទទួលទានក្តី នឹងមានព្រមយ៉ាងដូចម្តេច ?

ឆ្លើយថា ភិក្ខុអ្នកប្រារព្ធវិបស្សនា ជាអ្នកឈរនៅត្រង់មាត់ទ្វារផ្ទះ ឬអង្គុយនៅក្នុងវិហារនិងសាលាឆាន់, ទាយកទទួលបាត្ររបស់លោកហើយ ក៏ដាក់នូវរបស់ដែលគួរឆាន់គួរបរិភោគចូលទៅ, ក្នុងខណៈនោះ ការចេញ(ចាកកិលេស)

ដោយមគ្គ រមែងមានដល់ភិក្ខុ ទាននេះឈ្មោះថា ជាទានដែលប្រគេនហើយ ដល់លោកអ្នកដែលព្រមព្រៀងដោយមគ្គ ។

**ទាន ១៤ យ៉ាងនេះ** ឈ្មោះថា បាដិបុគ្គលិកទាន ព្រោះធ្វើវិគ្រោះថា "ចំពោះបុគ្គល គឺចំពោះបុគ្គលម្នាក់ ឈ្មោះថាចំពោះបុគ្គល, ទានដែលឈ្មោះថា បាដិបុគ្គលិកទាន ព្រោះអត្ថថា គឺ គេឲ្យដល់បុគ្គលចំពោះនោះ" ។

## អធិប្បាយសង្ឃគតាទក្ខិណាទាន

ក៏ទានដែលបុគ្គលប្រគេនហើយ ដល់បុគ្គលទាំង ៧ ពួកនេះ គឺ បុគ្គលឲ្យទានចំពោះសង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រធាន ។ល។ បុគ្គល (ទៅនិមន្តអំពីសំណាក់សង្ឃ) ថាសូមលោកទាំងឡាយ ចាត់ពួកភិក្ខុនីប៉ុណ្ណេះអំពីសង្ឃ ដើម្បីខ្ញុំហើយទើបឲ្យទាន ឈ្មោះថា ទានដែលប្រព្រឹត្តទៅក្នុងសង្ឃ ។ ទានដែលប្រព្រឹត្តទៅក្នុងសង្ឃទាំងអស់នោះ មានផលរាប់មិនបាន ។ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ចំពោះព្រះអានន្ទ ដូច្នេះថា "ម្នាលអានន្ទ ក្នុងកាលអនាគត នឹងមានគោត្រភូសង្ឃ (សង្ឃមានតែឈ្មោះ) មានតែសំពត់កាសាវៈ

ចង្កក ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ជនទាំងនោះឧទ្ទិសចំពោះសង្ឃ ហើយនឹងឲ្យទានដល់បុគ្គលទ្រុស្តសីលទាំងនោះ ម្នាលអានន្ទ សូម្បីក្នុងកាលនោះ ក៏តថាគតពោលថា សង្ឃគតាទក្ខិណាទានមានអានិសង្សរាប់មិនបាន ប្រមាណមិនកើតដែរ ម្នាលអានន្ទ តថាគតមិនដែលពោលនូវបាដិបុគ្គលិកទានថា មានអានិសង្សច្រើនជាង សង្ឃគតា-ទក្ខិណាទាន ដោយបរិយាយណាមួយឡើយ” ។

ដោយហេតុនោះ ក្នុងអដ្ឋកថា ទក្ខិណាវិភង្គសូត្រ ទើបលោកពោលថា “សូម្បីទក្ខិណា ដែលបុគ្គលប្រគេនហើយចំពោះព្រះសង្ឃមានព្រះពុទ្ធជាប្រធាន ព្រះមានព្រះភាគទ្រង់ត្រាស់ថា ឈ្មោះថា ទានមានផលរាប់មិនបាន ព្រោះការរាប់ដោយគុណ” ដូច្នេះ ។ មែនពិត ទក្ខិណាដែលប្រព្រឹត្តទៅក្នុងព្រះសង្ឃ រមែងមានដល់បុគ្គលដែលអាច ដើម្បីនឹងធ្វើនូវសេចក្ដីគោរពកោតក្រែងចំពោះព្រះសង្ឃ ។ តែកិរិយាធ្វើនូវសេចក្ដីគោរពកោតក្រែងចំពោះព្រះសង្ឃ ជាកិច្ចដែលធ្វើបានដោយកម្រ ។ ក៏បុគ្គលណា ចាត់ចែងនូវទេយ្យធម៌ដោយគិតថា “អាត្មាអញនឹងប្រគេននូវទាន ដែលប្រព្រឹត្តទៅក្នុង

ព្រះសង្ឃ” ដូច្នេះ ទៅកាន់វត្តពោលថា “បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន សូមព្រះគុណម្ចាស់ឲ្យនូវព្រះថេរៈ១រូប ចាកអំពីព្រះសង្ឃ” ដូច្នេះ, លុះដល់បានសាមណេរអំពីព្រះសង្ឃហើយ ក៏រមែងដល់នូវភាពជាដទៃ (អន់ចិត្ត) ថា “អាត្មាអញ បានសាមណេរ” ដូច្នេះ, ទក្ខិណារបស់បុគ្គលនោះ រមែងមិនឈ្មោះថា ប្រព្រឹត្តទៅក្នុងព្រះសង្ឃទេ ។ សូម្បីកាលបើបានព្រះមហាថេរៈហើយ ទោះជាធ្វើសេចក្តីសោមនស្សឲ្យកើតឡើងថា “អាត្មាអញ បានព្រះមហាថេរៈ” ដូច្នេះ, ទក្ខិណានោះក៏មិនឈ្មោះថា ប្រព្រឹត្តទៅក្នុងព្រះសង្ឃដូចគ្នាដែរ ។ ចំណែកបុគ្គលណា បានបដិគ្គាហកៈជាសាមណេរ ឬ ឧបសម្បន្នជាកំលោះ ឬ ព្រះថេរៈ ជាពាល ឬ បណ្ឌិតរូបណាមួយចាកពីព្រះសង្ឃ ជាអ្នកមិនមានសេចក្តីសង្ស័យ រមែងអាចដើម្បីនឹងធ្វើនូវសេចក្តីគោរពកោតក្រែង ក្នុងព្រះសង្ឃថា “អាត្មាអញប្រគេនដល់ព្រះសង្ឃ” ដូច្នេះ, ទក្ខិណារបស់បុគ្គលនោះ រមែងឈ្មោះថា ជាទានដែលប្រព្រឹត្តទៅក្នុងព្រះសង្ឃ ។ សមណៈដែលទាយកនិមន្តចំពោះចាកព្រះសង្ឃ ជាបុថុជ្ជន, បាដិបុគ្គលិកជាព្រះសោតាបន្ន, កាលបើបុគ្គលអាចធ្វើសេចក្តី

គោរពកោតក្រែងក្នុងព្រះសង្ឃ, ទានដែលបុគ្គលប្រគេនហើយ ចំពោះសមណៈដែលជាបុថុជ្ជន ក៏ជាទានមានផលច្រើនជាង ។ សូម្បីក្នុងពាក្យជាដើមថា “សមណៈដែលទាយកនិមន្តចំពោះ (ចាកសង្ឃ) ជាព្រះសង្ឃ បដិគ្គាហកៈជាព្រះសកទាគាមី” ក៏ន័យនេះដូចគ្នាដែរ ។ មែនពិត កាលបើបុគ្គលអាចដើម្បី នឹងធ្វើនូវសេចក្តីគោរពកោតក្រែងចំពោះព្រះសង្ឃ, ទានដែល បុគ្គលប្រគេនហើយ សូម្បីចំពោះសមណៈទ្រុស្តសីល ដែល គេនិមន្តចំពោះ (ចាកសង្ឃ) ក៏ជាទានមានផលច្រើនជាង ទានដែលប្រគេនចំពោះព្រះខីណាស្រពដោយពិត ។ ក៏ព្រះ តម្រាស់ណាដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បពិត្រ ព្រះមហារាជ ទានដែលបុគ្គលប្រគេនហើយ ដល់សមណៈ អ្នកមានសីល ជាទានមានផលច្រើន, ដែលប្រគេនហើយ ដល់សមណៈដែលទ្រុស្តសីល មិនមានផលច្រើន យ៉ាង ដូច្នោះទេ ដូច្នេះ, ព្រះតម្រាស់នោះ ព្រះអង្គទ្រង់ត្រាស់ លះន័យនេះចោល” ។

***ដីកាទក្ខិណាវិភង្គសូត្រនោះថា***

*បទថា គុណសង្ខ្យា សេចក្តីថា ព្រោះការគណនារាប់ដោយផល អានិសង្ស គឺព្រោះភាវៈនៃទានមានផលច្រើន ។ ទក្ខិណាព្រះមានព្រះភាគ ទ្រង់ត្រាស់ថា មានផលរាប់មិនបាន ក៏ព្រោះភាវៈនៃទក្ខិណានោះ គឺ បុគ្គលប្រគេនហើយចំពោះសង្ឃ ។ ក៏ការប្រគេនចំពោះព្រះសង្ឃ រមែងមានដោយវិធីណា, ដើម្បីនឹងសម្តែងនូវវិធីនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យជាដើមថា "សង្ឃគតា ទក្ខិណា ហិ ដូច្នេះ ។*

*បណ្តាបទទាំងនោះ បទថា ចិត្តិការំ បានដល់សេចក្តីគោរព ។ ចាកពីព្រះសង្ឃ មិនមែនចាកបុគ្គល ។ បទថា អញ្ញថត្តំ មានសេចក្តីថា មិនញ៉ាំងចិត្តឲ្យកើតឡើងយ៉ាងនេះថា "ទាន ជាទាន គឺអាត្មាអញឲ្យហើយដល់បុគ្គលនេះ" ដូច្នេះ ហើយចាត់ចែងនូវទេយ្យធម៌ ដោយគិតថា "អាត្មាអញនឹងប្រគេនដល់ព្រះសង្ឃ" ដូច្នេះ រមែងដល់នូវភាវៈជាអ្នកមានចិត្តផ្សេង) អន់ចិត្តថា* **ទាន** *ឈ្មោះថា ជាទានដែលអាត្មាអញគប្បីប្រគេនដល់សាមណេរ ដូច្នេះ, ព្រោះហេតុនោះ ទក្ខិណារបស់បុគ្គលនោះ រមែងមិនឈ្មោះថា*

ជាទានដែលប្រព្រឹត្តទៅក្នុងព្រះសង្ឃឡើយ ទក្ខិណា រមែងមិនឈ្មោះថា ប្រព្រឹត្តទៅក្នុងព្រះសង្ឃបាន ក៏ព្រោះធ្វើចិត្តឲ្យប្រែប្រួលទៅដោយអំណាចនៃបុគ្គល ។

ពីរបទថា **និព្វេមតិកោ ហុត្វា** មានសេចក្តីថា មិនញុំាងសេចក្តីសង្ស័យឲ្យកើតឡើងថា **ទាន** ជាទានដែលអាត្មាអញឲ្យហើយដល់បុគ្គលនេះ ឬក៏មិនបានឲ្យហើយឬទេហ្ន៎ ។

ពីរបទថា **សង្ឃេ ចិត្តិការំ** មានសេចក្តីថា កាលបើបុគ្គលនឹករឭកដល់គុណនៃព្រះសង្ឃ មានភាវៈជាអ្នកប្រតិបត្តិប្រពៃជាដើម ប្រគេនដោយអំណាចសេចក្តីគោរព ដែលកើតឡើងហើយ ក្នុងបុគ្គលនោះ ប្រៀបដូចជាប្រគេនទូវចំពោះមុខនៃព្រះសង្ឃ ដោយសេចក្តីគោរពក្នុងសង្ឃគុណ, ទានដែលបុគ្គលប្រគេនហើយចំពោះគណៈជាបុថុជ្ជន ក៏រមែងមានផលច្រើនជាង ។ ទានដែលបុគ្គលប្រគេនហើយចំពោះគណៈអ្នកទ្រុស្តសីល ក៏រមែងមានផលច្រើនជាង (ទានដែលគេប្រគេនចំពោះព្រះខីណាស្រព) ដោយពិត ព្រោះសមណៈនោះ គេនិមន្តចំពោះអំពីព្រះសង្ឃ និងព្រោះគេប្រគេនហើយ ដោយគិតយ៉ាងនេះថា អាត្មាអញនឹងប្រគេនដល់ព្រះសង្ឃ ដូច្នេះ ។ ព្រោះ

ហេតុនោះ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ថា “ម្នាលអានន្ទ តថាគតមិនដែលពោលនូវបាដិបុគ្គលិកទានថា មានអានិសង្ស ច្រើនជាងសង្ឃគតាទក្ខិណាទាន ដោយបរិយាយណាមួយ ឡើយ” ដូច្នេះ ។ ព្រះអដ្ឋកថាចារ្យ ចោទសួរថា ប្រសិនបើ ទានដែលគេប្រគេនហើយ សូម្បីចំពោះសមណៈអ្នកទ្រុស្តសីល ដែលគេនិមន្តចំពោះអំពីព្រះសង្ឃ រមែងជាទានមានផលច្រើន ជាង ទានដែលបុគ្គលប្រគេនហើយចំពោះព្រះខីណាស្រព, កាលបើមានយ៉ាង ដូច្នេះ, ពាក្យថា បពិត្រមហារាជ ទាន ដែលបុគ្គលប្រគេនហើយ ដល់បុគ្គលអ្នកមានសីលទុ៎ះឯង ជា ទានមានផលច្រើន, ដែលប្រគេនដល់បុគ្គលទ្រុស្តសីល មិន មានផលច្រើនយ៉ាង ដូច្នោះទេ ដូច្នេះនេះ តើយ៉ាងដូចម្តេចហ្ន៎ ! ដូច្នេះហើយ ទើបពោលថា ពាក្យនោះ ព្រះមានព្រះភាគ ត្រាស់ហើយ លះបង់នូវន័យនេះចោល” ដូច្នេះ ។

ឆ្លើយថា ពាក្យនោះ ព្រះអង្គទ្រង់លះចោលនូវវិធីនិមន្ត ចំពោះអំពីព្រះសង្ឃ ហើយត្រាស់ដោយអំណាចការនិមន្ត សមណៈអ្នកទ្រុស្តសីល តែម្យ៉ាងដូច្នេះ ។ (មង្គលត្ថទីបនី) ។

## ១.១០ សរុបទាន

*កាលសរុបមក ទាននេះមាន ៤ យ៉ាង គឺ*

*១-**ចេតនាទាន** បានដល់ ចេតនាចេតសិក ដែលប្រកបជាមួយមហាកុសល ដែលជាហេតុនៃការឲ្យទាន*

*២-**វត្ថុទាន** បានដល់ បច្ច័យ ៤ ដែលជាទេយ្យធម៌*

*៣-**អលោភទាន** បានដល់ អលោភចេតសិក ដែលប្រកបជាមួយចេតនាចេតសិក ដែលជាហេតុនៃការឲ្យទាន*

*៤-**វិរតិទាន** បានដល់ វិរតិចេតសិក ៣ ដែលមានការវៀរចាកអកុសលទុច្ចរិត ដែលជាហេតុឲ្យសត្វទាំងឡាយមិនត្រូវទុក្ខព្រួយចិត្ត ក្នុងការដែលនឹងមានភ័យកើតឡើង ជាអភ័យទាន ទាំងខាងក្នុងនិងខាងក្រៅ ។*

## ១.១១ បាលីសម្តែងការសរុបទានទាំង ៤ យ៉ាង

១-ចេតសិកោ ធម្មោ ទានន្តិ ? អាមន្តា *ចេតនាចេតសិក ដែលប្រកបជាមួយមហាកុសល ឈ្មោះថា **ទាន** មែនទេ ? ឆ្លើយថា មែន ។*

*(មកក្នុងព្រះបាលីទានកថា សត្តមវគ្គ គម្ពីរកថាវត្ថុ)*

២–ទេយ្យធម្មោ ទានន្តិ ? អាមន្តា ***វត្ថុ*** *ឈ្មោះថា* ***ទាន*** *មែនទេ ?  ឆ្លើយថា មែន ។*

*(មកក្នុងព្រះបាលីទានកថា សត្តមវគ្គ គម្ពីរកថាវត្ថុ)*

៣–តំ សម្បយុត្តោ អលោភោបិ ទានំ នាម ***អលោភចេតសិក*** *ដែលប្រកបជាមួយចេតសិក ដែលជាហេតុនៃការឲ្យ ក៏ឈ្មោះថា* ***ទាន*** *។*

*(មកក្នុងសុត្ត សង្គហៈ អដ្ឋកថា និងមូលដីកា)*

៤–អភយំ ទេតីតិ អាគតដ្ឋានេ វិរតិ ទានំ ។ *កាលដែលពោលពាក្យឲ្យអភ័យគ្នានោះ ការដែលឲ្យអភ័យនេះ ឈ្មោះថា* ***វិរតិទាន*** *។ (មកក្នុងព្រះបាលី កថាវត្ថុ)*

៥–បាណាតិបាតា បដិវិរតោ ភិក្ខវេ អរិយសាវកោ អបរិមាណានំ សត្តានំ អភយំ ទេតិ ។ល។ ឥទំ ភិក្ខវេ បឋមំ ទានំ មហាទានំ ។ *ព្រះអរិយសាវកបានវៀរហើយ ចាកបាណាតិបាតនោះ រមែងឲ្យអភ័យដល់សត្វទាំងឡាយ មិនមានប្រមាណ ការឲ្យអភ័យដល់សត្វទាំងឡាយនេះ បានឈ្មោះថា មហាទានទី ១ ។*

*(មកក្នុងអភិសន្ទសូត្រ ទានវគ្គ អដ្ឋកនិបាត នៃព្រះបាលីអង្គុត្តរ)*

## ១.១២ លក្ខណៈជាដើមរបស់ទានកុសល

១-បរិច្ចាគលក្ខណំ មានការបរិច្ចាគ ជាលក្ខណៈ

២-លោភវិទ្ធំសនរសំ មានការកំចាត់បង់នូវសេចក្តី
លោភជាកិច្ច

៣-ភវវិភវសម្បត្តិបច្ចុប្បដ្ឋានំ មានការដល់ព្រមនៃភពជាតិ និងផុតចាកភពជាតិ ជាអាការប្រាកដ

៤-សទ្ធេយ្យបទដ្ឋានំ សទ្ធាចេតសិកដែលមានសភាពជ្រះថ្លាក្នុងវត្ថុដែលគួរជ្រះថ្លា ជាហេតុជិត ។

## ១.១៣ បដិក្ខេបធម៌ជាដើមរបស់ទានកុសល

១-បដិក្ខេបធម្ម ធម៌ដែលត្រូវហាមឃាត់ដោយ
ទានកុសល បានដល់ លោភៈ

២-អនុញ្ញាតធម្ម ធម៌ដែលបានទទួលអនុញ្ញាតអំពី
ទានកុសលឲ្យកើតឡើងនោះ បានដល់ អលោភៈ

៣-ឧប្បាទេតព្វធម្ម ធម៌ដែលទានកុសលធ្វើឲ្យកើតឡើង បានដល់ មគ្គខាងក្រោម៣ ផលខាងក្រោម ៣ សំដៅដល់ អំណាចរបស់ទានកុសលដែលជាឧបត្ថម្ភកសត្តិ ។

## ១.១៤ អានិសង្សទាន ៥ យ៉ាង

*(សុត្តន្តបិដក អង្គុត្តរនិកាយ បញ្ចមភាគ ៤៤ ទំព័រ៨០)*

១-ពហុនោ ជនស្ស បិយោ ហោតិ មនាបោ *គឺ ជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃជនច្រើន*

២-សន្តោ សប្បុរិសា ភជន្តិ *ពួកសប្បុរសអ្នកស្ងប់ រមែងគប់រក*

៣-កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ *មានកិត្តិស័ព្ទដ៏ពីរោះ ខ្ចរខ្ចាយទៅ*

៤-គិហិធម្មា អនបគតោ ហោតិ *មិនបានប្រាស-ចាកធម៌របស់គ្រហស្ថ*

៥-កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ *លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងកើតក្នុងសុគតិសួគ៌ទេវលោក ។*

*បុគ្គលកាលឲ្យទាន រមែងជាទីស្រឡាញ់ ជាអ្នកអនុកូលទៅតាមធម៌របស់ពួកសប្បុរស ពួកសព្រហ្មចារី អ្នកសង្រួមមានចិត្តស្ងប់រម្ងាប់ រមែងរាប់រកបុគ្គលនោះសព្វៗកាល ពួក*

សព្រហ្មចារីនោះ រមែងសម្ដែងធម៌ ជាគ្រឿងបន្ទោបង់នូវទុក្ខទាំងអស់ ដល់បុគ្គលនោះ ទាំងបុគ្គលនោះដឹងនូវធម៌ហើយ ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វានក្នុងលោកនេះ ។

## ១.១៥ ការកើតឡើងនៃទានមាន ៨ យ៉ាង

(សុត្តន្តបិដក អង្គុត្តរនិកាយ លេខ ៤៨ ទំព័រ១៦៤-១៦៨)

១-បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទានគឺ បាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ និងប្រទីប ជាទានដល់សមណ ឬព្រាហ្មណ៍ បុគ្គលនោះឲ្យនូវវត្ថុណា ក៏ប្រាថ្នានូវវត្ថុនោះ បុគ្គលនោះ ឃើញពួកខត្តិយមហាសាលក្ដី ព្រាហ្មណ-មហាសាលក្ដី គហបតិមហាសាលក្ដី ដែលកំពុងឆ្អែតស្កប់ស្កល់ មូលមិត្រ បម្រើដោយកាមគុណទាំង ៥ ។ បុគ្គលនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ ! អញលុះតែបែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកខត្តិយមហាសាលក្ដី ព្រាហ្មណមហាសាលក្ដី គហបតិមហា-សាលក្ដី បុគ្គលនោះ ក៏តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ

ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនបានចម្រើនគុណធម៌ដ៏លើសលប់ឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកខត្តិយមហាសាលខ្លះ ព្រាហ្មណមហាសាលខ្លះ គហបតិ-មហាសាលខ្លះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ សេចក្តីប្រាថ្នាដោយចិត្ត របស់បុគ្គលមានសីល រមែងសម្រេចព្រោះចិត្តដ៏បរិសុទ្ធ ។

២-ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះឲ្យទានគឺ បាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ ប្រទីបជាទាន ដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះ ឲ្យនូវវត្ថុណាក៏ប្រាថ្នានូវវត្ថុនោះ បុគ្គលនោះ បានឮថា ពួកទេវតាចាតុម្មហា-រាជិកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាង នេះថា “ឱហ្ន៎ ! អាត្មាអញលុះបែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យទៅកើត ជាមួយនឹងពួកទេវតាចាតុម្មហារាជិកៈ” បុគ្គលនោះ ក៏តម្កល់ចិត្តនោះ

អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនបានចម្រើនគុណធម៌ ដ៏លើសលប់ឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាចាតុម្មហារាជិកៈ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្ត របស់បុគ្គលមានសីលរមែងសម្រេច ព្រោះចិត្តដ៏បរិសុទ្ធិ ។

៣-៧-ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទានគឺ បាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ និងប្រទីបជាទានដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះឲ្យនូវវត្ថុណាក៏ប្រាថ្នានូវវត្ថុនោះ បុគ្គលនោះបានឮថា ពួកទេវតាតាវត្តិង្ស ។បេ។ ពួកទេវតាយាម... ពួកទេវតាតុសិត... ពួកទេវតានិម្មានរតី... ពួកទេវតាបរនិម្មិតវសវត្តី... មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ ! អាត្មាអញ លុះបែកធ្លាយរាងកាយ

*ស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកទេវតា បរនិម្មិត-វសវត្តី... បុគ្គលនោះ ក៏តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនបានចម្រើនគុណធម៌ដ៏លើសលប់ឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាបរនិម្មិតវសវត្តី... ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេច ព្រោះចិត្តដ៏បរិសុទ្ធ ។*

*៨-ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទានគឺ បាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ ប្រទីប ជាទានដល់សមណៈ ឬព្រាហ្មណ៍ បុគ្គលនោះឲ្យនូវវត្ថុណា ក៏ប្រាថ្នានូវវត្ថុនោះ បុគ្គលនោះបានឮថា ពួកទេវតា ព្រហ្មកា-យិកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា "ឱហ្ន៎ ! អាត្មាអញ*

លុះបែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកទេវតាព្រហ្មកាយិកៈ បុគ្គលនោះ ក៏តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនបានចម្រើនគុណធម៌ដ៏លើសលប់ឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតា ព្រហ្មកាយិកៈ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ ទានចំពោះបុគ្គលប្រាសចាករាគៈ មិនចំពោះបុគ្គលប្រកបដោយរាគៈទេ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្ត របស់បុគ្គលមានសីល រមែងសម្រេច ព្រោះប្រាសចាករាគៈ ។

**អដ្ឋកថា មនោរថបូរណី ទានូបបត្តិសូត្រ ពន្យល់ថា**

បទថា ទានូបបត្តិយោ បានដល់ ឧបបត្តិ (ការកើតឡើង) មានទានជាបច្ច័យ ។ បទថា ទហតិ ប្រែថា "តាំងទុក" ។ បទថា អធិដ្ឋាតិ ជាវេវចនៈ របស់ពាក្យថា ទហតិ នោះឯង ។ បទថា ភាវេតិ "ឲ្យចម្រើន" ។

បទថា ហីនេធិមុត្តំ បានដល់ ឱនទៅក្នុងចំណែកទាប គឺកាមគុណ ៥ ។ បទថា ឧត្តរឹ អភាវិតំ បានដល់ មិនបានអប់រំដើម្បីជាប្រយោជន៍ដល់មគ្គ និងផល ខ្ពស់ជាងនោះ ។ បទថា តត្រូបបត្តិយា សំវត្តតិ សេចក្តីថា រមែងប្រព្រឹត្តទៅដើម្បីត្រូវការកើតក្នុងឋានដែលខ្លួនប្រាថ្នាហើយ ធ្វើកុសល ។ បទថា វីតរាគស្ស បានដល់ អ្នកដករាគៈដោយមគ្គ ឬអ្នកគ្របសង្កត់រាគៈដោយសមាបត្តិ ។ ពិតមែន ត្រឹមតែទានប៉ុណ្ណោះ មិនអាចនឹងកើតក្នុងព្រហ្មលោកបាន តែទានរមែងជាគ្រឿងប្រដាប់ជុំវិញរបស់ចិត្ត ដែលប្រកបដោយសមាធិ និងវិបស្សនា តាំងអំពីនោះ បុគ្គលអ្នកមានចិត្តទន់ដោយការឲ្យទាន ចម្រើនព្រហ្មវិហារ កើតក្នុងព្រហ្មលោក ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា វីតរាគស្ស នោសរាគស្ស ដូច្នេះ ។

**<u>សេចក្តីបញ្ជាក់</u>** :

ការបរិច្ចាគទាន និង ការកើតឡើងនៃទាន នៅមានច្រើនប្រភេទណាស់ តែក្នុងទីនេះ មិនបានសម្តែងឲ្យគ្រប់

ប្រភេទទេ គ្រាន់តែនាំមកសម្តែងដោយសង្ខេបទាំងនេះ ក៏ដើម្បីឲ្យពុទ្ធបរិស័ទយល់ដឹងខ្លះប៉ុណ្ណោះ ក្នុងការកសាងនូវទានកុសល ។

❁ ទីបំផុតនៃពាក្យថា **ទាន** នេះ ខ្ញុំនឹងលើកយកនូវបុព្វយោគរបស់ព្រះបាទមហាសុទស្សន និងផលនៃទាន និងរឿងពីរ មកសម្តែងជាសាធកតទៅ ៖

ក្នុងអដ្ឋកថា មហាសុទស្សនសូត្រ បានសម្តែងអំពីបុព្វយោគរបស់ព្រះបាទមហាសុទស្សនទុកថា ៖

## ១.១៦ បុព្វយោគរបស់ព្រះបាទមហាសុទស្សន

បានឮថា ក្នុងកាលមុន ព្រះរាជាទ្រង់កើតក្នុងត្រកូលគហបតី ។ សម័យនោះ ព្រះថេរៈមួយរូប ក្នុងសាសនារបស់ព្រះពុទ្ធកស្សបៈ ទ្រង់នៅមានព្រះជន្ម ចាំវស្សាក្នុងព្រៃ ។ ព្រះពោធិសត្វចូលព្រៃដោយការងាររបស់ខ្លួន ឃើញព្រះថេរៈហើយចូលទៅគាល់ថ្វាយបង្គំហើយ ក្រឡេកមើលទីអង្គុយនិងទីចង្រ្កមជាដើម របស់ព្រះថេរៈ ទើបសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់នៅក្នុងទីនោះឬ ។ បានស្តាប់ថា យ៉ាងនោះឧបាសក

ទើបគិតថា "សមគួរនឹងសាងបណ្ណសាលា ប្រគេនលោកម្ចាស់ក្នុងទីនេះ" ហើយលើកការងាររបស់ខ្លួនជញ្ជូនសម្ភារៈ ធ្វើបណ្ណ-សាលា បូកលាបជញ្ជាំងដោយដីស្អិត ភ្ជាប់ទ្វារ ធ្វើបង្អែកអង្គុយ អង្គុយក្នុងទីសមគួរមួយ ដោយគិតថា លោកម្ចាស់នឹងធ្វើការបរិភោគ ឬទេហ្ន៎ ។ ព្រះថេរៈមកពីខាងក្នុងស្រុក ចូលទៅកាន់បណ្ណសាលា ហើយអង្គុយត្រង់បង្អែក ។ សូម្បីឧបាសកមកហើយថ្វាយបង្គំ អង្គុយក្នុងទីជិតហើយ សួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន បណ្ណសាលាផាសុកទេ ។ (ព្រះថេរៈប្រាប់ថា) ផាសុក សមគួរដល់បព្វជិត ។ (ឧបាសក) លោកនឹងនៅទីនេះឬ ។ (ព្រះថេរៈ) យ៉ាងនោះឧបាសក ។ ឧបាសកនោះដឹងហើយថា ព្រះថេរៈនឹងនៅដោយអាការទទួល ឲ្យព្រះថេរៈជ្រាបថា លោកគប្បីទៅកាន់ទ្វារផ្ទះរបស់ខ្ញុំជានិច្ច ហើយប្រាប់ថា បពិត្រលោកដ៏ចម្រើន សូមលោកចូរឲ្យពរម្យ៉ាងដល់ខ្ញុំចុះ ។ (ព្រះថេរៈ) ម្នាលឧបាសក បព្វជិតមានពរកន្លងហើយ ។ (ឧបាសក) បពិត្រលោកម្ចាស់ដ៏ចម្រើន ជាពរដែលគួរ និងមិនមានទោស ។ (ព្រះថេរៈ) ឧបាសក ចូរប្រាប់មក ។ (ឧបាសក) "បពិត្រលោកម្ចាស់ដ៏ចម្រើន មនុស្សទាំងឡាយក្នុងទីជាទីនៅ

ជាប្រចាំ រមែងប្រាថ្នាការមកក្នុងមណ្ឌល ឬអមណ្ឌល រមែងក្រោធដល់ព្រះថេរៈអ្នកមិនមក ព្រោះដូច្នោះ លោកម្ចាស់សូមរឿទៅកាន់ទីនិមន្តដទៃហើយ ចូលទៅកាន់ផ្ទះរបស់ខ្ញុំហើយ គប្បីធ្វើភត្តកិច្ច" ។ ព្រះថេរៈ ទទួលហើយ ។

ក៏ពោធិសត្វនោះ ក្រាលកន្ទេលផែនក្នុងសាលា រៀបចំគ្រែតាំង ដាក់បង្អែក ដាក់ទីជូតជើង ជីកស្រះ ធ្វើទីចង្ក្រម ចាក់ពោយខ្សាច់ ឃើញសត្វមកទម្លាយជញ្ជាំង ធ្វើដីស្អិតឲ្យធ្លាក់ ក៏លោមព័ទ្ធរបងបន្លា ឃើញសត្វចុះស្រះ ធ្វើទឹកឲ្យល្អក់ ក៏កសាងជណ្តើរខាងក្នុង លោមព័ទ្ធរបងបន្លាខាងក្រៅ ដាំជួរត្នោតក្នុងទីបំផុតរបងខាងក្នុង ឃើញសត្វធ្វើស្មោកគ្រោកកន្លែងដែលសមគួរក្នុងមហាចង្ក្រម ក៏លោមព័ទ្ធទីចង្ក្រមដោយរបង ដាំជួរត្នោត ក្នុងទីបំផុតរបងខាងក្នុង ញុំាងអាវាសឲ្យសម្រេចយ៉ាងនេះថ្វាយត្រៃចីវរ បិណ្ឌបាត ថ្នាំ ភាជនបរិភោគ ក្អមទឹក កន្ត្រៃកាំបិតកាត់ក្រចក ម្ជុល ឈើច្រត់ ស្បែកជើង ពាងទឹក ឆត្រគប់ភ្លើង ឈើកង្វារអាចម៍ត្រចៀក បាត្រ ស្មោកបាត្រ សំពត់តម្រងទឹក ទីតម្រងទឹក ឬក៏ វត្ថុដែលបព្វជិតគួរបរិភោគដទៃចំពោះព្រះថេរៈ ឈ្មោះថា បរិក្ខារដែលព្រះពោធិសត្វមិនថ្វាយ

ដល់ព្រះថេរៈមិនមាន ។ ព្រះពោធិសត្វនោះ រក្សាសីល រក្សាឧបោសថ ទំនុកបម្រុងព្រះថេរៈរហូតដល់អស់ជីវិត ។ ព្រះថេរៈនៅក្នុងអាវាសនោះឯង សម្រេចព្រះអរហត្តហើយនិព្វាន ។

ចំណែកព្រះពោធិសត្វ ធ្វើបុណ្យរហូតដល់អស់អាយុ ហើយទៅកើតក្នុងទេវលោក ចុតិអំពីទេវលោកនោះ មកកាន់មនុស្សលោក កើតជាព្រះបាទមហាសុទស្សនចក្រពត្តិ ក្នុងរាជធានី ឈ្មោះថា កុសវតី ។

> ឯវំ ឆាតិមហន្តម្បិ បុញ្ញំ អាយតនេ កតំ
> មហាវិចាកំ ហោតីតិ កត្តព្វំ តំ វិភាវិនា ។
>
> បុណ្យសូម្បីដែលមិនធំក្រៃលែងទេ បានធ្វើហើយក្នុងសាសនា របស់លោកយ៉ាងនេះ មហាវិបាក (ផលដ៏ច្រើនក្រៃលែង) ទើបមាន ព្រោះដូច្នោះ អ្នកមានបញ្ញា (ប្រកបដោយសទ្ធា) គប្បីធ្វើបុណ្យនោះ ។

## ផលនៃកុសល

បានឮថា ព្រះនគរ ៨៤,០០០ នគរ ប្រាសាទ ១ ពាន់ខ្នង និងកូដាគារមួយពាន់ កើតឡើង ព្រោះផលបុណ្យហូរមកនៃ

បណ្ណសាលាមួយខ្នង ។ បល្ល័ង្ក ៨៤,០០០ កើតឡើង ដោយផលបុណ្យហូរមកនៃគ្រែដែលថ្វាយ ដើម្បីប្រយោជន៍ដល់ការដេក ។ ដំរី ៨៤,០០០ សេះ ១,០០០ រថ ១,០០០ កើតឡើងដោយផលបុណ្យដែលហូរមកនៃតាំងដែលថ្វាយ ដើម្បីប្រយោជន៍ ដល់ការអង្គុយ ។ កែវមណី ៨៤,០០០ កើតឡើងដោយផលបុណ្យដែលហូរមកនៃប្រទីបមួយ ។ ស្រះបោក្ខរណី ៨៤,០០០ កើតឡើង ដោយផលបុណ្យដែលហូរមកនៃស្រះបោក្ខរណីមួយ ។ ស្ត្រី ៨៤,០០០ បុត្រ ១,០០០ នាក់ គហបតី ១,០០០ នាក់ កើតឡើង ដោយផលបុណ្យដែលហូរមកនៃការថ្វាយបរិភោគភាជនៈ បាត្រ ស្បោកបាត្រ ធម្មក្រក សំពត់តម្រងទឹក ឆ្នាំងទឹក កន្ត្រៃ កាំបិតកាត់ក្រចក ម្ជុល សោរឈើកន្លាស់អាចម៍ត្រចៀក សំពត់ជូតជើង ស្រែកជើង ឆត្រនិងឈើប្រត់ ។ មេគោ ៨៤,០០០ កើតឡើង ដោយផលបុណ្យដែលហូរមកនៃទានគោរស ។ សំពត់ ៨៤,០០០ កោដិ កើតឡើង ដោយផលបុណ្យដែលហូរមកនៃទានសំពត់ស្បៀក សំពត់ដណ្តប់ ។ សម្រាប់ដាក់ព្រះក្រយាហារ ៨៤,០០០ គប្បីជ្រាបថាកើតឡើង ដោយផលបុណ្យដែលហូរមកនៃទានភោជនា ។

ព្រះមានព្រះភាគ ត្រាស់ដល់សម្បត្តិរបស់ព្រះបាទមហា-សុទស្សនចក្រពត្តិ តាំងពីដើមដោយពិស្តារ ដូច្នេះហើយ កាលនឹងទ្រង់សម្តែងសម្បត្តិនោះទាំងអស់ ដូចសម្តែងរោងលេងធូលីដល់ក្មេងទាំងឡាយ ផ្ដុំលើព្រះទេនជាទីរំលត់ខន្ធបរិនិព្វាន ហើយត្រាស់ថា ម្នាលអានន្ទ អ្នកចូរមើល ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា **វិបរិណតា** (ប្រែប្រួលទៅហើយ) សេចក្ដីថា ដល់នូវសេចក្ដីប្រែប្រួលដូចប្រទីបរលត់ដោយលះប្រក្រតីទៅ ដូច្នោះ ។ បទថា **ឯវំ អនិច្ចា ខោ អានន្ទ សង្ខារា** (ម្នាលអានន្ទ សង្ខារទាំងឡាយ មិនទៀងយ៉ាងនេះឯង) សេចក្ដីថា ឈ្មោះថា មិនទៀង ព្រោះអត្ថថាមានហើយត្រឡប់ជាមិនមានយ៉ាងនេះ ។ បុរសចងបង្អោងក្នុងដើមឈើចម្បាកម្ពស់ ១០០ ហត្ថ ឡើងហើយ កាន់យកផ្កាឈើចម្បា ស្រាយបង្អោងចុះមកយ៉ាងណា ព្រះមានព្រះភាគ ក៏ដូច្នោះដែរ ទ្រង់លើកនូវសម្បត្តិរបស់ស្តេចមហាសុទស្សនចក្រពត្តិខ្ពស់ដល់សែនកោដិឆ្នាំ មិនមែនតិច ដូចចងបង្អោង, ទ្រង់កាន់យកអនិច្ចលក្ខណៈ ដែលតាំងនៅក្នុងទីបំផុតនៃសម្បត្តិ ឈានចុះដូចស្រាយបង្អោង ដោយប្រការដូច្នេះ ។ ដោយហេតុនោះ

ក្នុងកាលមុន ព្រះបាទ**វសភៈ** ទ្រង់ស្តាប់ព្រះសូត្រនេះ ដែលព្រះទីឃភាណត្ថេរ ស្វាធ្យាយក្នុងអម្ពលដ្ឋិកា ផ្នែកទិសខាងកើតនៃលោហៈប្រាសាទ ហើយទ្រង់គិតថា លោកម្ចាស់របស់យើងពោលអ្វីក្នុងទីនេះ លោកម្ចាស់ពោលចំពោះសម្បត្តិក្នុងឋានដែលខ្លួនបានស៊ី បានផឹកប៉ុណ្ណោះ ទ្រង់ទម្រេតព្រះហស្តឆ្វេងផ្គុំដោយព្រះហស្តស្តាំ ថា លោកមានចក្ខុដោយចក្ខុ ៥ ប្រការឃើញសូត្រនេះហើយ ពោលយ៉ាងនេះ ក្នុងកាលដែលព្រះមានព្រះភាគត្រាស់ថា "ម្នាលអានន្ទ សង្ខារទាំងឡាយមិនទៀងយ៉ាងនេះឯង" ។ ទ្រង់មានព្រះហឫទ័យត្រេកអរថា **សាធុ សាធុ** ទ្រង់ឲ្យសាធុការ ។

## ១.១៧ រឿងព្រះបាទនន្ទរាជ

ក្នុងអតីតកាល កុដុម្ពិកម្នាក់ ជាអ្នកនៅក្នុងទីក្រុងពារាណសី ត្រាច់ទៅក្នុងព្រៃ បានឃើញសំពត់អនុវាតរបស់ព្រះបច្ចេកពុទ្ធលោកកំពុងធ្វើចីវរ មិនគ្រប់គ្រាន់ ទើបបានប្រគេនសំពត់ដណ្តប់របស់ខ្លួន ។ កុដុម្ពិកនោះ បានទៅកើតក្នុងភពតាវត្តិង្ស ព្រោះកម្មនោះ សោយនូវទិព្វសម្បត្តិ

ច្យុតចាកកពតាវត្តិង្សនោះហើយ ក៏បានមកកើតក្នុងត្រកូលនៃអមាត្យក្នុងទីប្រមាណមួយយោជន៍ អំពីក្រុងពារាណសី បានចម្រើនពេញវ័យហើយ ក្នុងថ្ងៃនក្ខត្តឫក្សបានពោលថា "បពិត្រអ្នកម្តាយ សូមអ្នកម្តាយឲ្យសំពត់សាដកដល់ខ្ញុំ, ខ្ញុំនឹងលេងនក្ខត្តឫក្ស" ។ មាតានោះ បានឲ្យសំពត់ស, (ប៉ុន្តែ) កាលកូននោះពោលថា "សំពត់នេះសាច់មិនល្អទេ" ដូច្នេះ, ទើបបានឲ្យសំពត់ផ្សេងទៀត ។ កូននោះ ហាមនូវសំពត់នោះទៀត ។ ម្តាយនោះពោលថា "ក្នុងផ្ទះរបស់យើង គ្មានសំពត់ល្អជាងនេះទេ" ។ កូននោះពោលថា "បពិត្រអ្នកម្តាយ ខ្ញុំនឹងទៅកន្លែងដែលបាន" ។ ម្តាយនោះ បានពោលថា "នែកូន ម្តាយប្រាថ្នាចង់ឲ្យកូនឯង បាននូវរាជសម្បត្តិក្នុងក្រុងពារាណសីក្នុងថ្ងៃនេះទៀតផង" ។ កូននោះពោលថា "បពិត្រអ្នកម្តាយប្រពៃហើយ" ដូច្នេះ ថ្វាយបង្គំមាតា ត្រូវនិយាមនៃបុណ្យជាស់តឿនហើយ ក៏ទៅកាន់ក្រុងពារាណសី ដេកដណ្តប់(គ្រប)នូវអវយវៈព្រមទាំងក្បាល លើផ្ទាំងសិលាដែលជាមង្គលក្នុងឧទ្យាន ក៏ថ្ងៃនោះ ជាថ្ងៃទី ៧ នៃព្រះរាជា ក្រុងពារាណសីទ្រង់បានទីវង្គតទៅ ។ ជនទាំងឡាយ មានអមាត្យ

ជាដើម បានបូជានូវព្រះសរីរៈកិច្ចរបស់ព្រះរាជាហើយ ទើបប្រឹក្សាគ្នាថា "ព្រះរាជា ទ្រង់មានព្រះរាជធីតាតែមួយព្រះអង្គប៉ុណ្ណោះ, គ្មានព្រះរាជឱរសទេ រាជសម្បត្តិដែលប្រាសចាកព្រះរាជានឹងតាំងនៅពុំបានឡើយ" ដូច្នេះហើយ កាលនឹងលែងបុស្សរថ (រថមានពណ៌ស)ទៅ បានទឹមសេះសិន្ធព ៤ ដែលមានសម្បុរដូចជាផ្កាកុមុទ ហើយបានតាំងរាជកុកុធភ័ណ្ឌ ៥ ប្រការ លើរថស្រេចហើយ ក៏លែងរថទៅ រថបានចេញទៅតាមមាត់ទ្វារទិសខាងកើត ចូលកាន់ឧទ្យាន ធ្វើប្រទក្សិណកុមារនោះមិនទៅណា ។ បុរោហិត បានបើកជាយសំពត់ដែលដណ្តប់ ហើយត្រួតពិនិត្យមើលផ្ទៃនៃបាទជើង ពោលថា "កុមារនេះ សមគួរហើយ ដើម្បីគ្រប់គ្រងរាជសម្បត្តិ" ដូច្នេះហើយ ឲ្យគេប្រគំនូវដូរតន្ត្រីអស់វារៈ ៣ ដង ។ គ្រានោះកុមារបានបើកមុខឡើងហើយ ពោលថា "បពិត្រលោកឪពុកតើមានហេតុអ្វី ? " ។ បុរោហិតពោលថា "បពិត្រលោកម្ចាស់រាជសម្បត្តិ រមែងសម្រេចដល់លោកម្ចាស់" ។ កុមារសួរថា "ចុះព្រះរាជារបស់អ្នកទាំងឡាយ ស្តេចយាងទៅណា ? " ។ បុរោហិតពោលថា "បពិត្រលោកម្ចាស់ ព្រះអង្គទ្រង់ស្តេច

ទីវង្គតទៅហើយ” ។ កន្លងទៅបានប៉ុន្មានថ្ងៃហើយ ? ។ បុរោហិតពោលថា “ថ្ងៃនេះ ជាថ្ងៃទី៧” ។ កុមារសួរថា ព្រះរាជឱរសក្តី ព្រះរាជធីតាក្តី មិនមានទេឬ ? ។ បុរោហិតពោលថា “បពិត្រលោកម្ចាស់ មានតែព្រះរាជធីតា (តែ) ព្រះរាជឱរសមិនមានទេ” ។ កុមារពោលថា បើដូច្នោះខ្ញុំនឹងគ្រប់គ្រងនូវរាជសម្បត្តិ ពួកអមាត្យទាំងនោះ នាំគ្នាធ្វើមណ្ឌបសម្រាប់អភិសេក ក្នុងពេលនោះភ្លាម ហើយក៏បានអភិសេកក្នុងមណ្ឌបនោះ រួចហើយបានបង្អោនសំពត់ដែលមានតម្លៃ ១ ពាន់ ចូលទៅថ្វាយ ។ ព្រះរាជាអង្គនោះ មានព្រះរាជឱង្ការថា “សំពត់នេះ មានសាច់មិនល្អ អ្នកទាំងឡាយចូរនាំយកកុន្ទីទឹកមាសមក ខ្ញុំនឹងបាននូវសំពត់ ដូច្នេះហើយស្តេចក្រោកឡើងទ្រង់យកព្រះហស្តក្បង់ទឹក ហើយទ្រង់សាចទៅទិសខាងកើត ។ ដើមកប្បព្រឹក្ស ៨ ដើម បានទំលាយផែនដីដ៏ក្រាសផុសឡើងហើយ ក្នុងពេលនោះភ្លាម ។ ដើមកប្បព្រឹក្ស ៨ ដើម ផុសឡើងហើយត្រង់ទិសទក្សិណ, ៨ ដើម ផុសឡើងហើយត្រង់ទិសបស្ចិម, ៨ ដើម ផុសឡើងហើយត្រង់ទិសឧត្តរ, ដោយឧបាយនេះ ។ ដើមកប្បព្រឹក្សទាំងអស់មាន ៣២ ដើម

ដុះឡើងហើយ ដោយប្រការដូច្នេះ ។ ព្រះរាជាអង្គនោះ ទ្រង់ស្លៀកសំពត់ទិព្វមួយ ទ្រង់បានដណ្តប់សំពត់ទិព្វ ១ ទ្រង់ត្រាស់បញ្ជាឲ្យពួកអមាត្យ វាយស្គរជ័យឃោសនា ក្នុងរាជ-ធានីរបស់ព្រះបាទនន្ទរាជថា "ស្រីទាំងឡាយ កុំត្បាញសូត្រឡើយ" ហើយទ្រង់ត្រាស់បញ្ជាឲ្យលើកឆត្រឡើង ។ ឲ្យស្តេចឡើងលើកដំរីដ៏ប្រសើរ ទ្រង់យាងចូលទៅព្រះនគរ ស្តេចឡើងលើប្រាសាទ ទ្រង់សោយនូវមហាសម្បត្តិ គ្រប់គ្រងរជ្ជធានីរបស់ព្រះអង្គទាំងអស់ ប្រៀបដូចជាឧត្តរកុរុទ្វីប ទ្រង់បានព្រះរាជទានសំពត់ទិព្វទាំងឡាយ ដល់មនុស្សទាំងឡាយដែលបានមកហើយៗ ក្រោយមក ទ្រង់បានសាងព្រះផ្នួសព្រមទាំងព្រះទេវី នៅក្នុងព្រះឧទ្យាន ញ៉ាំងឈានឲ្យកើតឡើងហើយមានឈានមិនសាបសូន្យ ហើយបានទៅកើតក្នុងព្រហ្មលោក។ ក្នុងពេលនេះ (ពុទ្ធកាល) ព្រះរាជាអង្គនោះ បានកើតជាព្រះមហាកស្សបត្ថេរៈ ព្រះទេវី បានមកកើតជានាងភទ្ទកាបិលានីដូច្នេះឯង ។

(រឿងព្រះបាទនន្ទរាជ មកក្នុងអដ្ឋកថា បរមត្ថទីបនី) ។

## ១.១៨ រឿងព្រះទេវីព្រះនាមគោបាលមាតា

ក្នុងចន្លោះផ្លូវទៅកាន់នគរឧជ្ជេនី មាននិគមមួយឈ្មោះតេលនាឡិ ។ ក្នុងនិគមនោះ មានធីតារបស់សេដ្ឋីពីរនាក់, ធីតាម្នាក់ជាអ្នកក្រីក្រ ដោយកាលកន្លងទៅនៃមាតាបិតាអាស្រ័យនូវស្រីមេទំ ចិញ្ចឹមជីវិត ជាអ្នកមានខ្លួនស្អាត ស្រស់មានសក់វែងជាងពួកស្រីឯទៀត, ធីតាម្នាក់ជាអ្នកស្តុកស្តម្ភ (តែ) មិនមានសក់ ។ ក្នុងគ្រានោះ ព្រះមហាកច្ចាយនត្ថេរៈព្រមទាំងភិក្ខុ ៧ រូប មានប្រាថ្នានឹងក្រាបទូលនូវការកើតឡើងនៃព្រះពុទ្ធ ដល់ព្រះរាជាព្រះនាមចណ្ឌបជ្ជោត ទើបនិមន្តទៅកាន់ក្រុងឧជ្ជេនី ដល់និគមនោះហើយ ក៏ចូលទៅបិណ្ឌបាតក្នុងនិគមនោះ (តែ) ឥតបានវត្ថុអ្វីឡើយ។ សេដ្ឋីធីតាដែលមានសក់វែងដឹងរឿងនោះហើយ ក៏បញ្ជូនស្រីមេទំទៅ ដោយប្រាប់ថា ចូរនាងនិមន្តព្រះថេរៈទាំងឡាយ ហើយឲ្យគង់ក្នុងផ្ទះ” ។ ស្រីនោះបានធ្វើយ៉ាងដូច្នោះ ។ សេដ្ឋីធីតា បានចូលទៅកាន់បន្ទប់ ហើយឲ្យស្រីមេទំកាត់សក់របស់ខ្លួន បញ្ជូនទៅហើយដោយប្រាប់ថា “នែនាង ចូរនាងឲ្យសក់ទាំងនេះ ដល់សេដ្ឋីធីតាដែលមិនមានសក់ ឈ្មោះនុ៎ះ, ធីតារបស់សេដ្ឋីនោះ ឲ្យនូវ

វត្ថុអ្វី, ចូរនាំយកវត្ថុនោះមក, ពួកយើងនឹងប្រគេនបិណ្ឌបាត ដល់ព្រះគុណម្ចាស់ទាំងឡាយ ដោយវត្ថុនោះ” ។ នាងបាន ធ្វើយ៉ាងដូច្នោះហើយ បានទទួលយកទ្រព្យ ៨ កហាបណៈ មកឲ្យហើយ ដល់សេដ្ឋីធីតាដែលមានសក់ ។ សេដ្ឋីធីតានោះ បានធ្វើបិណ្ឌបាតមួយៗ ឲ្យទៅជាមួយៗកហាបណៈ ហើយ ញ៉ាំងបុគ្គលឲ្យប្រគេនហើយ ដល់ព្រះថេរៈទាំងឡាយ ខ្លួនឯង នៅក្នុងបន្ទប់ ។ ព្រះមហាកច្ចាយនត្ថេរៈ ដឹងហេតុការណ៍នោះ ហើយ បានឲ្យបុគ្គលទៅហៅសេដ្ឋីធីតានោះមក ។ សេដ្ឋីធីតា នោះ បានមកហើយ ព្រោះសេចក្ដីគោរពចំពោះព្រះថេរៈ ថ្វាយ បង្គំព្រះថេរៈហើយ ក៏បានញ៉ាំងសទ្ធាជ្រះថ្លាដ៏មានកម្លាំងឲ្យ កើតឡើងហើយ ។ ឈ្មោះថា **ទាន** ដែលនាងប្រគេនហើយ ក្នុងខេត្តដ៏ល្អ រមែងឲ្យនូវវិបាកក្នុងបច្ចុប្បន្នទាន់ភ្នែក ព្រោះ ហេតុនោះ សក់ទាំងឡាយរបស់នាងបានដុះឡើងវិញហើយ ក្នុងការៈតាមប្រក្រតីភ្លាម ជាមួយគ្នានឹងការថ្វាយបង្គំព្រះថេរៈ។ ព្រះថេរៈទាំងឡាយ ទទួលបិណ្ឌបាតហើយ, កាលសេដ្ឋីធីតា នោះ ឃើញទុំះឯង, ក៏ហោះឡើងទៅកាន់អាកាសវេហាស៍ បាន ចុះក្នុងឧទ្យាន ឈ្មោះកាញ្ចនវ័ន ហើយធ្វើនូវភត្តកិច្ច ។ បុគ្គល

*អ្នករក្សាឧទ្យាន ឃើញព្រះថេរៈទាំងឡាយហើយ ក៏បានក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាស្តេចយាងទៅកាន់ព្រះរាជឧទ្យាន ទ្រង់ទតព្រះនេត្រឃើញព្រះថេរៈទាំងឡាយ ហើយទ្រង់បានត្រាស់សួរថា "បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ក្នុងថ្ងៃនេះ ព្រះគុណម្ចាស់ទាំងឡាយ បានហើយនូវភិក្ខាក្នុងទីឯណា ? " ដូច្នេះ ទ្រង់ព្រះសណ្តាប់រឿងនោះហើយ ទ្រង់ស្តេចយាងទៅដំណាក់ ត្រាស់ឲ្យនាំសេដ្ឋីធីតានោះមក ក្នុងថ្ងៃនោះឯង ហើយទ្រង់បានអភិសេក(នាង) ជាអគ្គមហេសី ។ ក្នុងកាលក្រោយមក ព្រះនាងទ្រង់បានប្រសូតព្រះរាជបុត្របានយកឈ្មោះរបស់សេដ្ឋី ដែលជាអយ្យការបស់ព្រះរាជឱរសេ ថ្វាយព្រះនាមថា* ***គោបាល*** *(ចំណែកព្រះនាង) ប្រាកដនាមថា* ***"គោបាលមាតាទេវី)*** *ដោយអំណាចព្រះនាមរបស់ព្រះរាជឱរសេ ទ្រង់ជ្រះថ្លាហើយយ៉ាងក្រៃលែងចំពោះព្រះថេរៈ ទ្រង់បានឲ្យបុគ្គលកសាងព្រះវិហារថ្វាយព្រះថេរៈហើយ ក្នុងព្រះរាជឧទ្យាន ឈ្មោះកាញ្ចនវ័ន ដូច្នេះឯង ។*

*(រឿងព្រះនាងគោបាលទេវី មកក្នុងអដ្ឋកថាឯកនិបាត អង្គុត្តរនិកាយ) ។*

# ២_សីលមយ:

ក្នុងអដ្ឋកថា បរមត្ថទីបនី ថា :

*ពាក្យថា **សីលមយ** បានដល់ ចេតនាដែលប្រព្រឹត្តទៅហើយ ដល់បុគ្គលអ្នក សមាទានសីល ៥ សីល ៨ ឬសីល ១០ ដោយអំណាចនៃការកំណត់ឲ្យជានិច្ចសីល និងឧបោសថ-សីលជាដើម ឬអ្នកគិតថា យើងនឹងបួសដើម្បីបំពេញសីលឲ្យបរិបូរណ៍ ហើយទៅកាន់វិហារបួស នឹងញ៉ាំងមនោរថឲ្យដល់ទីបំផុត រលឹកថា យើងបួសហើយជាការល្អ ហើយអប់រំបំពេញបាតិមោក្ខសំវរសីលឲ្យបរិបូរណ៍ដោយសទ្ធា ពិចារណាបច្ច័យ ៤ មានចីវរជាដើមដោយបញ្ញា សង្រួមចក្ខុទ្វារជាដើមក្នុងរូបជាដើម ដែលមកកាន់កន្ទងដោយសតិ និងជម្រះអាជីវបារិសុទ្ធិសីល ដោយសេចក្ដីព្យាយាម រមែងតាំងមាំព្រោះដូច្នោះ ចេតនានោះ ទើបឈ្មោះថា **បុញ្ញកិរិយាវត្ថុសម្រេចដោយសីល** ។*

*(ម្យ៉ាងទៀត) កាលឲ្យទាន ដោយតាំងនៅក្នុងវត្ត-បដិបត្តិ បុញ្ញកិរិយាវត្ថុ ជាសីលមយ: ។*

ក្នុងបរមត្ថជោតិក ថា :

*សីល សម្តែងវចនត្ថៈថា* **សីលយតិ កាយវចីកម្មានិ សម្មា ធបាតីតិ** = **សីលំ** *ធម្មជាតិណា រមែងធ្វើឲ្យកាយកម្ម និងវចីកម្មតាំងទុកដោយល្អ ដូច្នោះ ធម្មជាតិនោះឈ្មោះថា* **សីល,** *បានដល់ កិរិយារួបរួមទុកនូវកម្មទាំងឡាយមានកាយកម្មជាដើម មិនរាត់រាយ ដោយអំណាចការៈនៃបុគ្គលអ្នកមានសីល ឬកិរិយាចូលទៅទ្រទ្រង់ទូទៅ ដោយអំណាចនៃកិរិយាប្រតិស្ឋាននៃធម៌ទាំងឡាយជាកុសលម្យ៉ាង ដើម្បីឲ្យកុសលកើត, ទានចេតនា គឺចេតនាដែលទាក់ទងនឹងការបរិច្ចាគទាន សីលចេតនា គឺចេតនាដែលទាក់ទងនឹងការរក្សាសីល ទាំងនេះកើតឡើងដល់ព្រះអរហន្តទាំងឡាយ ក៏មានតែចេតនាទាំងនេះ នៅក្នុងមហាកិរិយាចិត្តុប្បាទទាំងអស់ ។*

*សេចក្តីនេះ អធិប្បាយថា ពាក្យថា សីលនោះ ជាតួចេតនាដែលមានការជំរុញនូវកាយវាចា ឲ្យតាំងនៅក្នុងកិរិយាមារយាទដែលល្អ ទាំងបិទចន្លោះមិនឲ្យអកុសលផ្សេងៗ ដោយអំណាចកាយទុច្ចរិត វចីទុច្ចរិត ប្រាកដឡើងបាន សេចក្តីនេះសម្តែងឲ្យដឹងបានថា សីលនោះ មាននាទីរក្សាកាយវាចា មិន*

ឲ្យប្រព្រឹត្តទៅក្នុងទុច្ចរិត ដែលកើតមកអំពីអកុសលផ្សេងៗប៉ុណ្ណោះ, ចំណែកការរក្សាផ្លូវចិត្ត ដើម្បីមិនឲ្យមានទុច្ចរិតផ្សេងៗ កើតឡើងនោះ ជានាទីរបស់ភាវនាដោយចំពោះ ។

វចនត្ថៈមួយទៀតថា ៖ **សីលយតិ កុសលធម្មេ ឧបធារេតីតិ = សីលំ** : ធម្មជាតិណា រមែងទ្រទ្រង់ទុកនូវកុសលធម៌ (មានសមាធិ បញ្ញានិងវិមុត្តិជាដើម) ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **សីល** ។

អធិប្បាយថា សីលចេតនា គឺការរក្សាសិក្ខាបទផ្សេងៗ មានបាណាតិបាតវិរតិជាដើមទាំងនេះ អាចឲ្យសមាធិ បញ្ញា និងមគ្គផលកើតឡើងបាន ឧបមាដូចជាផ្ទៃផែនដី ដែលជាទីអាស្រ័យរបស់វត្ថុផ្សេងៗ ទាំងមានជីវិត និងមិនមានជីវិត បើខ្វះផែនដី ដែលជាទីអាស្រ័យហើយ វត្ថុផ្សេងៗ ទាំងមានជីវិត និងមិនមានជីវិតទាំងឡាយនោះ ក៏រមែងកើតឡើង និងចម្រើនឡើងមិនបាន សេចក្តីឧបមានេះយ៉ាងណា សមាធិ បញ្ញា មគ្គ ផល ទាំងនេះ រមែងអាស្រ័យ កើតឡើង បើវៀរចាកសីលកុសលចេញហើយ វត្ថុ(ធម៌)ទាំងនេះ រមែងកើតឡើងមិនបាន ។

ដូច្នេះ ព្រះមានព្រះភាគជាម្ចាស់ ទើបវិសជ្ជនាសេចក្ដីសម្គាល់របស់សីល ក្នុងការបដិបត្តិដើម្បីផុតចាកទុក្ខ ដែលមានសេចក្ដីវិលវល់ដោយលំបាក ទាំងខាងក្នុងទាំងខាងក្រៅ ហើយចូលកាន់ព្រះនិព្វាននោះថា ៖

**សីលេ បតិដ្ឋាយ នរោ សបញ្ញោ**
**ចិត្តំ បញ្ញញ្ច ភាវយំ**
**អាតាបី និបកោ ភិក្ខុ**
**សោ ឥមំ វិជដយេ ជដំ ។**

នរជន មានប្រាជ្ញា បានតាំងមាំក្នុងសីលហើយ ចម្រើននូវសមាធិចិត្តនិងវិបស្សនាបញ្ញា ជាអ្នកមានព្យាយាមដុតកំដៅកិលេស ប្រកបដោយបារិហារិយប្បញ្ញា ជាអ្នកឃើញភ័យក្នុងសង្សារ បុគ្គលនោះ ទើបកាប់ឆ្កានូវតណ្ហាជាគ្រឿងចាក់ស្រែះនេះបាន ។

ក្នុងគាថានេះ សម្ដែងអំពីធម៌ ៦ យ៉ាង គឺ សីល ១ សមាធិ ១ បញ្ញា ៣ អាតប: គឺសេចក្ដីព្យាយាម ១ ។

បញ្ញា ៣ គឺ **សជាតិប្បញ្ញា** បញ្ញាជាប់មកជាមួយនឹងបដិសន្ធិជាត្រៃហេតុ កើតអំពីកម្មចាស់ ដែលបានកសាងទុកមក ក្នុងអតីតជាតិ ១ ,

**វិបស្សនាបញ្ញា** បញ្ញាសម្រេចមកអំពីការពិចារណាឃើញតាមការណ៍ពិត ក្នុងបច្ចុប្បន្ន ១ ,

**នេបកប្បញ្ញា** បញ្ញាដែលរក្សាខ្លួនទុក ចាកធម៌ដែលជាសត្រូវ ឬ**បារិហារិកប្បញ្ញា** បញ្ញាដែលអាចកំណត់នូវកិច្ចទាំងពួង មានកិរិយាឈានចូល និងឈានថយជាដើម ហើយនាំទៅកាន់តែអំពើដែលមានប្រយោជន៍ តែងប្រកបមិនដាច់ ក្នុងកិរិយារក្សាទុកនូវកម្មដ្ឋាន ១ ។

ក្នុងគាថានោះ នរជននេះ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សម្ដែងថា ប្រកបដោយបញ្ញា ដូច្នេះ ដោយបញ្ញាញាណកិច្ចដែលនរជននោះគប្បីធ្វើ មិនមានក្នុងបញ្ញានោះ ។ ព្រោះថា បញ្ញានោះ សម្រេចហើយដល់បុគ្គលនោះ ដោយអានុភាពនៃកម្មដែលមានមក ក្នុងកាលមុនតែម្យ៉ាង ។ ក៏នរជននោះដែលជាអ្នកធ្វើរឿយៗ និងជាអ្នកធ្វើនូវការដឹងខ្លួន ដោយអំណាចនៃវីរិយៈ ដោយអំណាចនៃបញ្ញា ដែលព្រះអង្គទ្រង់

សម្ដែងត្រង់បទនេះថា "អ្នកមានអាតបៈ គឺ ព្យាយាម មាននេបកៈ គឺ បញ្ញាចាស់ក្លា" ដូច្នេះ គប្បីប្រតិស្ឋានក្នុងសីល ហើយចម្រើននូវសមថៈ និងវិបស្សនា ដែលព្រះអង្គទ្រង់សម្ដែង ដោយអំណាចនៃចិត្តនិងបញ្ញា ។ ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់សម្ដែងនូវផ្លូវនៃព្រះនិព្វាននេះ ដោយប្រធាននៃសីល សមាធិ និងបញ្ញា ។

## ២.១ សីលប្បភេទកថា

*សីល* បើចែកតាមប្រភេទ មានច្រើនជាអនេក តែបើ ចាត់ទុកជាក្រុមៗ តាំងអំពីទី ១ ដល់ក្រុមទី ៥ ។ ហើយក្រុម នីមួយៗ មានចែកចេញជាប្រភេទច្រើនតទៅទៀត ដូចន័យ ដែលនឹងវិសជ្ជនា តទៅនេះ ៖

ក៏បណ្ដាក្រុមរបស់សីលទាំងឡាយនោះ ក្រុមទី ១ ដើម ដំបូង មានតែចែកតាមលក្ខណៈរបស់សីលទាំងអស់ ដែល រួបរួមមកហៅថា **សីលនលក្ខណៈ** បានដល់ លក្ខណៈដែល ផ្ទុកទុកនូវកាយកម្មជាដើម និង ទ្រទុកនូវកុសលទាំងពួង ។

ឯក្រុមទី ២ មាន ៧ ពួក, ក្រុមទី ៣ មាន ៥ ពួក, ក្រុមទី ៤ មាន ៤ ពួក, ក្រុមទី ៥ មាន ២ ពួក ។

ក្រុមសីលទី១ សីលទាំងអស់នេះឯង បើតាមប្រក្រតីជាលក្ខណៈរបស់ខ្លួន មានបការតែមួយដោយពិត ។

## ក្រុមសីល២ (ចែកជា ៧ ពួក)

ពួកទី១ ដោយអំណាចនៃចារិត្តសីល និង វារិត្តសីល

ពួកទី២ ដោយអំណាចនៃអភិសមាចារិកសីល និង អាទិព្រហ្មចរិយកសីល ។

ពួកទី៣ ដោយអំណាចនៃវិរតិសីល និង អវិរតិសីល

ពួកទី៤ ដោយអំណាចនៃនិស្សិតសីល និងអនិស្សិតសីល

ពួកទី៥ ដោយអំណាចនៃកាលបរិយន្តសីល និង អាបាណកោដិកសីល

ពួកទី៦ ដោយអំណាចនៃសបរិយន្តសីល និងអបរិយន្តសីល

ពួកទី៧ ដោយអំណាចនៃលោកិយសីល និងលោកុត្តរសីល

## ក្រុមសីល៣ (ចែកជា ៥ ពួក)

ពួកទី ១ *ដោយអំណាចនៃហីនសីល ១ មជ្ឈិមសីល ១ បណីតសីល ១*

ពួកទី ២ *ដោយអំណាចនៃអត្តាធិបតេយ្យសីល ១ លោកាធិបតេយ្យសីល១ ធម្មាធិបតេយ្យសីល១*

ពួកទី ៣ *ដោយអំណាចនៃបរាមដ្ឋសីល ១ អបរាមដ្ឋសីល ១ បដិបស្សទ្ធិសីល ១*

ពួកទី ៤ *ដោយអំណាចនៃវិសុទ្ធិសីល ១ អវិសុទ្ធិសីល ១ វេមតិកសីល ១*

ពួកទី ៥ *ដោយអំណាចនៃសេក្ខសីល ១ អសេក្ខសីល ១ នេវសេក្ខានាសេក្ខសីល ១*

## ក្រុមសីល៤ (ចែកជា ៤ ពួក)

ពួកទី ១ *ដោយអំណាចនៃហានភាគិយសីល ១ ឋិតិភាគិយសីល ១ វិសេសភាគិយសីល ១ និព្វេធភាគិយសីល ១*

ពួកទី ២ *ដោយអំណាចនៃកិក្ខុសីល ១ កិក្ខុនីសីល ១ អនុបសម្បន្នសីល ១ គហដ្ឋសីល ១*

ពួកទី ៣ *ដោយអំណាចនៃបកតិសីល ១ អាចារសីល ១ ធម្មតាសីល ១ បុព្វហេតុកសីល ១*

ពួកទី៤ *ដោយអំណាចនៃបាតិមោក្ខសំវរសីល ១ ឥន្ទ្រិយសំវរសីល ១ អាជីវបារិសុទ្ធិសីល ១ បច្ចយសន្និស្សិតសីល ១ ។*

## ក្រុមសីល៥ (ចែកជា ២ ពួក)

ពួកទី១ *ដោយអំណាចនៃសីលមាន បរិយន្តបារិសុទ្ធិ-សីល ១ អបរិយន្តបារិសុទ្ធិសីល ១ បរិបុណ្ណបារិសុទ្ធិសីល ១ អបរាមដ្ឋបារិសុទ្ធិសីល ១ បដិបស្សទ្ធិបារិសុទ្ធិសីល ១ ,*

ពួកទី២ *ដោយអំណាចនៃបហានសីល ១ វេរមណី-សីល ១ ចេតនាសីល ១ សំវរសីល ១ អវីតិក្កមសីល ១ ។*

*ក្នុងសីលទាំង* **៥** *ក្រុម ខ្ញុំមិនបានលើកយកមកអធិប្បាយទាំងអស់ទេ ខ្ញុំនឹងស្រង់យកក្រុមសីលណាមួយអំពីប្រភេទនៃសីលទាំងនោះ មកអធិប្បាយ ក៏បណ្ដាសីល*

*ទាំងនោះ ខ្ញុំនឹងស្រង់យកតែសីលមួយក្រុម ក្នុងប្រភេទនៃសីល ៤ ដែលមាននាមថា ភិក្ខុសីល ១ ភិក្ខុនីសីល ១ អនុបសម្បន្នសីល ១ គហដ្ឋសីល ១ មកអធិប្បាយដោយសង្ខេបតទៅ ។*

## ២.២ ប្រភេទនៃសីល

**១-ភិក្ខុសីល** *សីលរបស់ភិក្ខុ បានដល់ សិក្ខាបទដែលព្រះសម្ពុទ្ធទ្រង់បញ្ញត្តចំពោះតែភិក្ខុ គឺ សិក្ខាបទដែលជាអសាធារណប្បញ្ញត្តិ ផ្នែកខាងភិក្ខុ*[២] *ព្រមទាំងសិក្ខាបទដែលជាសាធារណប្បញ្ញត្តិ*[៣] *ដែលភិក្ខុត្រូវរក្សាក្រៅអំពីអសាធារណប្បញ្ញត្តិផង និងខន្ធកវត្ត ។*

---

[២] សិក្ខាបទ ដែលព្រះសម្ពុទ្ធ ទ្រង់បញ្ញត្តិចំពោះភិក្ខុ ហើយត្រូវប្រព្រឹត្តតាមតែពួកភិក្ខុ ហៅថា អសាធារណប្បញ្ញត្តិផ្នែកខាងភិក្ខុ ។

[៣] សិក្ខាបទ ដែលព្រះសម្ពុទ្ធ ទ្រង់បញ្ញត្តិដល់ភិក្ខុនិងភិក្ខុនី ហើយត្រូវប្រព្រឹត្តតាមស្មើគ្នា ទាំងភិក្ខុទាំងភិក្ខុនី ហៅថា សាធារណប្បញាត្តិ ។

**២-ភិក្ខុនីសីល** *សីលរបស់ភិក្ខុនី បានដល់ សិក្ខាបទដែលព្រះសម្ពុទ្ធ ទ្រង់បញ្ញត្តចំពោះតែភិក្ខុនី គឺ សិក្ខាបទ ជាអសាធារណប្បញ្ញត្តិផ្នែកភិក្ខុនី* [៤] *ព្រមទាំងសិក្ខាបទដែលជាសាធារណប្បញ្ញត្តិ ដែលភិក្ខុនីត្រូវរក្សាក្រៅអំពីអសាធារណប្បញ្ញត្តិផង ។*

**៣-អនុបសម្បន្នសីល** *សីលរបស់អនុបសម្បន្ន បានដល់ សីល ១០ របស់សាមណេរនិងសាមណេរីទាំងឡាយ ។*

**៤-គហដ្ឋសីល** *សីលរបស់គ្រហស្ថ បានដល់ និច្ចសីលមានសិក្ខាបទ ៥ សិក្ខាបទ ១០* [៥] *ដោយមានឧស្សាហ៍*

---

[៤] សិក្ខាបទ ដែលព្រះសម្ពុទ្ធ ទ្រង់បញ្ញត្តិចំពោះភិក្ខុនី ហើយត្រូវប្រព្រឹត្តតាមតែពួកភិក្ខុនី ហៅថា អសាធារណប្បញ្ញត្តិផ្នែកខាងភិក្ខុនី ។

[៥] ក្នុងគម្ពីរវិសុទ្ធិមគ្គ លោកពោលថា "សីលរបស់គ្រហស្ថយ៉ាងនេះ គឺ សម្រាប់ពួកឧបាសកនិងឧបាសិកា មានសិក្ខាបទ ៥ ដោយអំណាចនិច្ចសីល ឬកាលបើមានសេចក្ដីព្យាយាម ក៏គប្បីរក្សាទាំង ១០ សិក្ខាបទ មានសិក្ខាបទ ៨ ដោយអំណាចជាអង្គឧបោសថ ។ (សីល ១០ ឈ្មោះថា ជានិច្ចសីល ព្រោះតែសមាទានហើយត្រូវរក្សា ជាប់ជានិច្ច មិនមានកំណត់កាល ដូចជាសិក្ខាបទ ៥ ដែរ) ។

កើតឡើងទៀត និងឧបោសថសីល មានសិក្ខាបទ ៨ របស់ឧបាសកនិងឧបាសិកាទាំងឡាយ ។

ក្នុងសីល ៤ យ៉ាងនេះ ភិក្ខុសីល និងភិក្ខុនីសីល មិនត្រូវសមាទាន ព្រោះក្រោយពីសូត្រកម្មវាចាត្រឹមត្រូវតាមច្បាប់ព្រះវិន័យ ដោយវៀរចាកវិបត្តិ ៥ យ៉ាងមាន វត្ថុ ១ ញត្តិ ១ អនុស្សាវនា ១ សីមា ១ បរិស័ទ ១, ដល់ព្រមដោយសម្បត្តិ ៥ យ៉ាងគឺ បរិបូរណ៍ដោយវត្ថុ ១ ការៈនៃឧបសម្បទាបេក្ខៈនោះ បរិសុទ្ធផុតស្រឡះចាកអន្តរាយិកធម៌ទាំងឡាយ១ បរិបូរណ៍ដោយសីមា ១ បរិបូរណ៍ដោយបរិស័ទ ១ ញ៉ាំងកិច្ចជាខាងដើមឲ្យសម្រេច ១ ហើយសីលទាំងនោះ ក៏សម្រេចផង ។

សម្រាប់សាមណេរសីលនោះ ក៏ដូចគ្នា មិនត្រូវមានការសមាទានដោយចំពោះ ក្រោយអំពីសរណគមន៍ ៣ ដែលឧបជ្ឈាយ៍ និងបព្វជ្ជាបេក្ខៈ ពោលត្រឹមត្រូវតាមវិនយ បរិសុទ្ធទាំងពីរចំណែក គឺទាំងអ្នកឲ្យនិងអ្នកទទួល មិនឲ្យខូច ឲ្យដល់ព្រមដោយឋាននិងករណៈរបស់ព្យញ្ជនៈទាំងឡាយ មាន ពុ អក្សរ និង ធ អក្សរជាដើមហើយ សីលទាំងនេះ ក៏សម្រេចផង ។

ពាក្យថា គ្រហស្ថ ប្រែថា អ្នកគ្រប់គ្រងផ្ទះ ដូចវចនត្ថៈថា គេហោ តិដ្ឋតីតិ គហដ្ឋោ : អ្នកណានៅក្នុងផ្ទះ ដូច្នោះ អ្នកនោះ ឈ្មោះថា **គហដ្ឋ** ។

សម្រាប់គ្រហស្ថសីលនោះ ត្រូវមានការសមាទានដោយចំពោះ ត្រឹមតែសមាទានត្រៃសរណគមន៍ នៅមិនទាន់ហៅថា ជាអ្នកមានគហដ្ឋសីលទេ ហៅបានត្រឹមតែជាអ្នកដល់ត្រៃសរណគមន៍ប៉ុណ្ណោះ ដូច្នេះ ត្រូវសមាទានសិក្ខាបទទៀត ទើបមានគហដ្ឋសីល ។

## ២.៣ ភាពជាអ្នកទ្រុស្តសីលនិងអលជ្ជីនៃភិក្ខុនិងភិក្ខុនី

អ្នកទ្រុស្តសីលសម្រាប់ភិក្ខុ ភិក្ខុនី គឺ ភិក្ខុ ឬភិក្ខុនីរូបណា ក្រោយអំពីបានសូត្រញត្តិចតុត្ថកម្មវាចា ដោយត្រឹមត្រូវខាងក្នុងសីមារៀបរយហើយ ភិក្ខុឬភិក្ខុនីនោះ ក៏បានឈ្មោះថាជាអ្នកមានសីលរបស់ភិក្ខុ ឬភិក្ខុនី តាំងនៅហើយ ដោយមិនត្រូវមានការសមាទានដោយចំពោះទៀត រហូតដល់វេលាដែលមិនទាន់បានពោលពាក្យលាសិក្ខា ឬនៅមិនបានដល់ភាពជាអ្នកត្រូវអាបត្តិបារាជិក ក៏ពោលបានថា អ្នកនោះ ក៏តាំងនៅ

ក្នុងភិក្ខុសីល ឬភិក្ខុនីសីល ដោយត្រឹមត្រូវ ។ តែបើពោល លាសិក្ខាហើយ ឬចូលដល់ភាពជាអ្នកត្រូវអាបត្តិបារាជិកហើយ ភិក្ខុ ឬភិក្ខុនីសីលទាំងនោះ ឈ្មោះថា ជាការបែកធ្លាយ ក៏ផុត អស់ទៅ ព្រោះដូច្នោះ ភិក្ខុ ឬភិក្ខុនីរូបនោះ បើនៅមិនបាន ប្តូរភេទទៅជាឃរាវាស ឬជាសាមណេរ សាមណេរី នៅតែ ប្តេជ្ញាខ្លួនថា ជាភិក្ខុ ឬភិក្ខុនី ក៏ពោលបានថា អ្នកនោះ ជាអ្នកទ្រុស្តសីល ។

មួយទៀត ពាក្យថា **ទ្រុស្តសីល** បានដល់ គ្មានសីល ។ គ្មានសីល ដោយមិនបានសមាទាន ឬសមាទានហើយ ធ្វើឲ្យ បែកធ្លាយទៅវិញ ។

បុគ្គលជាអលជ្ជី សម្រាប់ភិក្ខុ ឬភិក្ខុនី គឺ បើភិក្ខុ ភិក្ខុនី រូបណា មានចេតនាប្រព្រឹត្តកន្លងសិក្ខាបទដទៃៗ ដែលក្រៅ អំពីអាបត្តិបារាជិក មានសង្ឃាទិសេស ឬសុទ្ធិកបាចិត្តិយ ជាដើម ទាំងមិនបានរក្សាអាបត្តិនោះៗ ឲ្យត្រឹមត្រូវតាម ព្រះវិន័យ គឺបើជាអាបត្តិសង្ឃាទិសេស មិនបានធ្វើវុដ្ឋានកម្ម បានដល់ ការនៅបរិវាសនិងមានត្ត, បើជាអាបត្តិដទៃៗ មាន សុទ្ធិកបាចិត្តិយជាដើម មិនបានធ្វើទេសនាកម្ម គឺការសម្តែង

អាបត្តិនោះចេញ ជាមួយសព្រហ្មចារី ដូច្នេះហើយ ក៏ពោលបានថា អ្នកនោះជាអលជ្ជី (អ្នកមិនមានខ្មាស) ។

ម្យ៉ាងទៀត អលជ្ជីដោយហេតុ ៣ យ៉ាងគឺ ក្លែងត្រូវអាបត្តិ ១ បិទបាំងអាបត្តិ ១ ដល់ការលុះអគតិ ១ បុគ្គលប្រាកដដូច្នេះ ទ្រង់ហៅថា អលជ្ជីបុគ្គល ។

ក្នុងបុគ្គលទាំង ២ ប្រភេទនេះ បុគ្គលអ្នកទ្រុស្តសីលមានការៈធ្ងន់ជាង ចំណែកអ្នកជាអលជ្ជីនោះ មានការៈស្រាលជាង ។

## ២.៤ អ្នកទ្រុស្តសីលនិងអលជ្ជី សម្រាប់សាមណេរ

សេចក្តីពិត សាមណេរនោះ បើក្នុងពេលបព្វជ្ជាឧបជ្ឈាយ៍ឲ្យសរណគមន៍ ៣ និងខ្លួនឯងដែលជាបព្វជ្ជាបេក្ខៈបានទទួលសរណគមន៍ ៣ ពោលតាមត្រឹមត្រូវ បរិសុទ្ធទាំងពីរចំណែក អស់វារៈ ៣ ដងហើយ សូម្បីមិនសមាទានសិក្ខាបទ ១០ មានបាណាតិបាតា វេរមណី ជាដើម ដោយចំពោះៗ ទៀត ក៏ឈ្មោះថា បានសម្រេចជាសាមណេរហើយ ក៏មានសាមណេរសីលព្រមបរិបូរណ៍ ដោយត្រឹមត្រូវតាំងពី

ពេលនោះទៅ រហូតដល់នៅមិនទាន់បានបួរកេទ ឬនៅមិនទាន់បានប្រព្រឹត្តខុសក្នុងលិង្គនាសនៈទាំង ១០ យ៉ាង ណាមួយ ក៏តាំងនៅក្នុងភាវៈជាសាមណេរដរាបនោះ, ដូច្នេះ ការសម្ដែងសិក្ខាបទ ១០ មានបាណាតិបាតា វេរមណី ជាដើម រហូតដល់ជាតរូបរជតប្បដិគ្គហណា វេរមណី ជាទីបំផុត ក្រោយអំពីការទទួលសរណគមន៍ ៣ ផងនោះ ត្រឹមតែដើម្បីឲ្យសាមណេរដឹងក្នុងសិក្ខាបទ ដែលខ្លួនទឹងគប្បីសង្រួមតទៅប៉ុណ្ណោះ សមដូចព្រះមានព្រះភាគ ទ្រង់សម្ដែងទុក ក្នុងព្រះបាលីសិក្ខាបទវិនយមហាវគ្គថា "អនុជានាមិ ភិក្ខវេ សាមណេរានំ ទស សិក្ខាបទានិ តេសុ ច សាមណេរេហិ សិក្ខិតុំ ចាណាតិចាតា វេរមណី ។ល។ ជាតរូបរជតប្ប-ដិគ្គហណា វេរមណី" ដូច្នេះ ។

បណ្ដាសិក្ខាបទ ១០ កាលសាមណេរប្រព្រឹត្តកន្លងសិក្ខាបទ ៥ ខាងដើមណាមួយ គឺតាំងពីបាណាតិបាតា វេរមណី ជាដើម រហូតដល់សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី ជាទីបំផុតហើយ ជាអ្នកគួរដល់លិង្គនាសនៈ ។ សិក្ខាបទដែលនៅសល់ ៥ ទៀត តាំងពី វិកាលភោជនា វេរមណី ជាដើម

វហូតដល់ជាតួរូបវជតប្បដិគ្គហណា វេរមណី ជាទីបំផុតនោះ ត្រឹមតែទទួលទោសទណ្ឌកម្មប៉ុណ្ណោះ ។ ដូច្នោះ សាមណេររូបណាប្រព្រឹត្តកន្លងសិក្ខាបទ ដែលទាក់ទងជាមួយនឹងលិង្គនាសនៈ ក៏ត្រូវសឹកចាកភេទសាមណេរទៅ ឬមិនប្រាថ្នានឹងសឹកទេ ក៏ត្រូវទទួលត្រៃសរណគមន៍ថ្មី ។ បើប្រព្រឹត្តកន្លងសិក្ខាបទដែលទាក់ទងជាមួយនឹងទណ្ឌកម្ម ក៏ត្រូវសូមទទួលទោសអំពីឧបជ្ឈាយ៍ ឬអាចារ្យ ឲ្យដាក់ទោស ដើម្បីសេចក្ដីសង្រួមរបស់ខ្លួនតទៅ ។ ព្រោះដូច្នោះ សាមណេររូបណាមានការប្រព្រឹត្តិខុសសិក្ខាបទ ដែលទាក់ទងជាមួយលិង្គនាសនៈ ១០ ណាមួយហើយ មិនព្រមសឹកចាកភេទសាមណេរ ឬមិនព្រមទទួលត្រៃសរណគមន៍ថ្មី ក៏ហៅសាមណេររូបនោះថា ជាអ្នកទ្រុស្តសីល ។ បើសាមណេររូបណា ធ្វើខុសសិក្ខាបទដែលទាក់ទងជាមួយទណ្ឌកម្ម ១០ ណាមួយ តែមិនទទួលទោសអំពីឧបជ្ឈាយ៍ ឬអាចារ្យ មិនតាំងនៅក្នុងសំវរៈ ក៏ហៅសាមណេររូបនោះថា ជាអលជ្ជី ។

## ២.៥ អ្នកទ្រុស្តសីលនិងអលជ្ជីសម្រាប់គ្រហស្ថ

*សីល ៥ មានការវៀរចាកការសម្លាប់សត្វជាដើម រហូតដល់ការវៀរចាកការផឹកទឹកស្រវឹង គឺសុរានិងមេរ័យ ជាទីបំផុត ទាំងនេះ ជានិច្ចសីលរបស់គ្រហស្ថទូទៅ ដូច្នោះ បើអ្នកណាមានការវៀរចាក មិនប្រព្រឹត្តកន្លង ក៏បានឈ្មោះថា អ្នកនោះបានតាំងនៅហើយក្នុងគហដ្ឋសីល បើអ្នកណា មិនមាន ការវៀរចាកប្រព្រឹត្តកន្លងក្នុងសិក្ខាបទណាមួយ ឬទាំង ៥ អ្នកនោះក៏ពោលបានថា ជាអ្នកទ្រុស្តសីល ។*

*គ្រហស្ថ ជាអលជ្ជី គឺគ្រហស្ថណា ចូលចិត្ត ឬពេញចិត្តនិយាយពាក្យញុះញង់ ស៊ិកសៀត បំបែកបំបាក់អ្នកដទៃ (**បិសុណាវាចា**) ។ ពោលនូវពាក្យអាក្រក់ មានពាក្យទ្រគោះបោះបោក ជេរប្រទេច អ្នកដទៃជាដើម (**ផរុសវាចា**) ។ ពោលនូវពាក្យរោយរាយឥតប្រយោជន៍ (**សម្ផប្បលាប**) និងគិតសំឡឹងរំពៃទ្រព្យរបស់អ្នកដទៃ ដោយគិតបំរុងនឹងឲ្យបានមកជាទ្រព្យរបស់ខ្លួន (**អភិជ្ឈា**) មានចិត្តចងគំនុំគុំគួន គិតប៉ងនឹងឲ្យអ្នកដទៃដល់នូវសេចក្តីវិនាស (**ព្យាបាទ**) ទាំងនេះក្តី នឹងជាអ្នកមិនពេញចិត្តបដិបត្តិតាមតួនាទីរបស់ខ្លួន តាមពាក្យប្រៀន*

ប្រដៅរបស់ព្រះមានព្រះភាគជាម្ចាស់ ដែលព្រះអង្គសម្ដែងទុកក្នុងសង្គាលកសូត្រ គឺ មិនបដិបត្តិតាមតួនាទី រវាងមាតាបិតាជាមួយនឹងបុត្រ ស្វាមីជាមួយនឹងភរិយា គ្រូអាចារ្យជាមួយនឹងសិស្ស ចៅហ្វាយនាយជាមួយនឹងទាសៈកម្មករ មិត្តចំពោះមិត្ត និងរវាងសាសនាណាក៏ដោយ កាលជាដូច្នេះហើយ ក៏ពោលបានថា អ្នកនោះ ជាអលជ្ជី ។ បើគ្រហស្ថណា មិនចូលចិត្តនិយាយរឿងបិសុណាវាចា ផរុសវាចា សម្ផប្បលាប មិនចូលចិត្តគិតរឿងអភិជ្ឈា ព្យាបាទ មានសេចក្ដីត្រេកអរ បដិបត្តិតាមតួនាទី រវាងមាតាបិតាជាមួយនឹងបុត្រ ស្វាមីជាមួយនឹងភរិយាជាដើម គ្រហស្ថនោះ ឈ្មោះថា ជាលជ្ជីបុគ្គល (បុគ្គលមានខ្មាស) ។

## ២.៦ ពាក្យថាទុស្សីល

ក្នុងអដ្ឋកថា គម្ពីរឧទាន លោកពន្យល់ថា ៖

បណ្ដាបទទាំងនោះ បទថា ទុស្សីលោ បានដល់ អ្នកគ្មានសីល ។ បទថា សីលវិបន្នោ បានដល់ អ្នកមានសីលវិបត្តិ គឺអ្នកទម្លាយសំវរៈ ។ ក៏ក្នុងបទទាំងនេះដោយបទថា

*ទុស្សីលោ ត្រាស់ដល់បុគ្គលដែលមិនមានសីល ។*

សោ បនស្ស សីលាភាវោ ទុវិធោ អសមាទា-នេន វា សមាទិន្នស្ស ភេទេន វាតិ ។ តេសុ បុរិមោ ន តថា សាវជ្ជោ, យថា ទុតិយោ សាវជ្ជតរោ ។ *ក៏បុគ្គលដែលមិនមានសីលនោះមាន ២ យ៉ាង គឺ ព្រោះមិនសមាទាន ឬទម្លាយសីលដែលសមាទានហើយ ។ ក្នុង ២ យ៉ាងនោះ ទីដើមមិនមានទោសដូចទីទី២ ដែលមានទោសខ្លាំងជាង ។ ដើម្បីនឹងសម្ដែងសេចក្ដីមិនមានសីល ដែលមានទោសតាមដែលប្រាថ្នាជាហេតុ ដោយទេសនាជាបុគ្គលា-ធិដ្ឋាន ទើបត្រាស់ថា សីលវិបន្នោ ដូច្នេះ ។ ដោយហេតុនោះ ព្រះអង្គទើបទ្រង់សម្ដែងអត្ថនៃបទថា "ទុស្សីលោ" ដូច្នេះ ។*

## ២.៧ ការសមាទានសីលរបស់គ្រហស្ថ ២ ប្រភេទ

១-ឯកជ្ឈសមាទាន *សមាទានរួមគ្នា*

២-បច្ចេកសមាទាន *សមាទានចំពោះសិក្ខាបទមួយៗ ។*

ឧបាសក (និងឧបាសិកា) សមាទានរួមគ្នាក្តី ចំពោះសិក្ខាបទមួយៗក្តី ដោយខ្លួនឯង ឬក្នុងសំណាក់នៃបុគ្គលដទៃ ក៏ជាសិក្ខាបទដែលបានសមាទានហើយ ។

សួរថា ក៏(ការសមាទានរួមគ្នា និងការសមាទានចំពោះសិក្ខាបទមួយៗ) មានការប្លែកគ្នាយ៉ាងដូចម្តេច ?

ឆ្លើយថា កាលបើឧបាសក(ឧបាសិកា) សមាទានរួមគ្នា វិរតិក្តី ចេតនាក្តី ដូចគ្នាតែម្តង តែសភាវៈនៃវិរតិ និងចេតនាទាំងឡាយនោះ មាន ៥ យ៉ាង ព្រះមានព្រះភាគ ទ្រង់បញ្ញត្តិដោយអំណាចនៃកិច្ច ។ កាលបើឧបាសក (ឧបាសិកា) សមាទានចំពោះសិក្ខាបទមួយៗ វិរតិក្តី ចេតនាក្តី ក៏(បែកចេញ)ជា ៥ ផងដែរ ។

ក៏បណ្តាសិក្ខាបទទាំង ៥ ខាងដើមនេះ របស់ពួកសាមណេរទាំងឡាយ កាលបើសិក្ខាបទមួយដាច់ហើយ សិក្ខាបទសព្វទាំងអស់ ក៏ជាសិក្ខាបទដាច់ហើយដែរ ។ ព្រោះសិក្ខាបទទាំង ៥ នោះ តាំងនៅក្នុងឋានៈនៃបារាជិក ។ សិក្ខាបទនោះឯណាមួយ ជាវីតិក្កម ដែលសាមណេរទាំងឡាយនោះ ល្មើសបញ្ញត្តិហើយ កម្មពន្ធ រមែងមាន ព្រោះសិក្ខាបទនោះប៉ុណ្ណោះ ។

ចំណែកពួកគ្រហស្ថ កាលបើសិក្ខាបទមួយដាច់ហើយ ក៏តែង ដាច់ហើយតែសិក្ខាបទមួយប៉ុណ្ណោះ ព្រោះហេតុដែលសីលប្រកប ដោយអង្គ ៥ រមែងសម្រេចដល់គ្រហស្ថទាំងឡាយនោះបាន ម្តងទៀត ក៏ដោយការសមាទាននូវសិក្ខាបទទាំងនោះនុ៎ះឯង ។ សិក្ខាបទនោះ ឯណាមួយ សូម្បីដែលពួកគ្រហស្ថទាំងឡាយ នោះ បានប្រព្រឹត្តកន្លងហើយ កម្មពន្ធ រមែងមាន ព្រោះ សិក្ខាបទនោះតែប៉ុណ្ណោះ ។

ចំណែកអាចារ្យមួយពួកទៀតពោលថា "បណ្តាសិក្ខាបទ ទាំងឡាយ ដែលពួកគ្រហស្ថទាំងនោះ បានសមាទានហើយ ផ្សេងៗ គ្នា កាលបើសិក្ខាបទមួយដាច់ហើយ ក៏រមែងដាច់ ហើយ តែសិក្ខាបទមួយប៉ុណ្ណោះ ។ ប៉ុន្តែកាលបើពួកគ្រហស្ថ ទាំងនោះ សមាទានរួមជាមួយគ្នា យ៉ាងដូច្នេះថា "**បញ្ចង្គ-សមន្នាគតំ សីលំ សមាទិយាមិ** : ខ្ញុំសូមសមាទាននូវ សីលដែលប្រកបដោយអង្គ ៥" ដូច្នេះ កាលបើសិក្ខាបទមួយ ដាច់ហើយ សិក្ខាបទសូម្បីទាំងអស់ ក៏រមែងដាច់ហើយដែរ ។ ព្រោះហេតុអ្វី ? ព្រោះការសមាទាន មិនញែកចេញពីគ្នា" ។

ក៏ពាក្យថា បរេ នុ៎ះ ព្រះអដ្ឋកថាចារ្យ ពោលសំដៅយក អាចារ្យអ្នកសម្ដែងគម្ពីរទីឃនិកាយ ។ ពិតដូច្នោះ ក្នុងអដ្ឋកថាកូដទន្តសូត្រ ព្រះអដ្ឋកថាចារ្យ ពោលហើយថា “អ្នកណាទទួលសិក្ខាបទទាំង ៥ រួមជាមួយគ្នា កាលបើសិក្ខាបទមួយរបស់អ្នកនោះ បែកធ្លាយហើយ សិក្ខាបទសូម្បីទាំងអស់ ក៏រមែងបែកធ្លាយហើយដែរ, អ្នកណាទទួលយកចំពោះអង្គមួយៗ អ្នកនោះ រមែងប្រព្រឹត្តកន្លងនូវសិក្ខាបទណាមួយ សិក្ខាបទនោះតែប៉ុណ្ណោះ រមែងបែកធ្លាយ ។

ដីកានៃកូដទន្តសូត្រនោះថា “សិក្ខាបទសូម្បីទាំងអស់ ឈ្មោះថា រមែងបែកធ្លាយហើយ ព្រោះភាវៈនៃសិក្ខាបទដែលបានសមាទានរួមជាមួយគ្នា ។ សិក្ខាបទនោះប៉ុណ្ណោះ ឈ្មោះថា រមែងបែកធ្លាយ ព្រោះភាវៈនៃសិក្ខាបទដែលបានសមាទានផ្សេងគ្នា ។ ក៏ពិធីនុ៎ះ លោកបានពោលហើយដោយអំណាចគ្រហស្ថ ។ (បាកមង្គលត្ថទីបនី ៣ / ២២២-២២៤)

## ការសមាទានសីល ៥ ជាឯកជ្ឈសមាទាន

*ការសមាទានសិក្ខាបទ ៥ រួមគ្នា ដូច្នេះ ៖*

*អ្នកសមាទានពោលថា* "**បញ្ចង្គសមន្នាគតំ សីលំ សមាទិយាមិ** *: ខ្ញុំសូមសមាទាននូវសីលដែលប្រកបដោយអង្គ ៥*" *ឬថា* "**បញ្ចសិក្ខាបទំ សមាទិយាមិ** *: ខ្ញុំព្រះករុណាសូមសមាទានសិក្ខាបទទាំង ៥, (មានបាណាតិបាតវិរតិជាដើម រហូតដល់សុរាមេរយមជ្ជប្បមាទដ្ឋានវិរតិ ជាទីបំផុត) ។*

*ការសមាទានសីលជាឯកជ្ឈសមាទាន ដែលពោលមកនេះ បើប្រព្រឹត្តកន្លងសិក្ខាបទណាមួយ ក៏ជាការដាច់ទាំងអស់ព្រមគ្នាផង, ត្រូវសមាទានថ្មីទាំងអស់ ។ ចំណែកអ្នក សមាទានសិក្ខាបទដោយចំពោះសិក្ខាបទមួយៗ នោះ បើប្រព្រឹត្តកន្លងសិក្ខាបទណាមួយ ក៏ជាការដាច់ចំពោះសិក្ខាបទនោះៗ ប៉ុណ្ណោះ សិក្ខាបទដទៃៗ តាំងនៅប្រក្រតីមិនដាច់ទេ គ្រាន់តែសមាទានថ្មីចំពោះសិក្ខាបទដែលដាច់ប៉ុណ្ណោះ ។*

*ការសមាទានឧបោសថសីល ក៏មានន័យដូចគ្នា ។*

## ការសមាទានសីល ៥ ជាបច្ចេកសមាទាន

*សមាទានសិក្ខាបទ ៥ ដោយចំពោះសិក្ខាបទមួយៗ ថា ៖*

*១-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ*

*២-អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ*

*៣-កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ*

*៤-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ*

*៥-សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ ដូច្នេះ ។*

*❁ សីល ៥ ជានិច្ចសីលរបស់យាវាសទាំងឡាយ ដូច្នេះសូមឲ្យអ្នកដែលសមាទានក្តី មិនបានសមាទានក្តី ត្រូវរក្សាជាប្រក្រតី ដើម្បីខ្លួនផ្ទាល់ជាអ្នកមានសីល បើថានឹងមានអ្នកអាងថា ខ្ញុំម្ចាស់មិនសមាទាន ដូច្នោះ មិនរក្សា ក៏មិនមានទោស ក្នុងពាក្យនិយាយដូច្នោះ ត្រឹមតែជាការសម្តែងឲ្យអ្នកដទៃដឹងថា ខ្លួនមិនចូលចិត្តសីល ៥ ថា ជានិច្ចសីលរបស់យាវាសទាំងឡាយប៉ុណ្ណោះ តែអ្នកនោះ មិនបានជាបុគ្គលផុតពីភាពជាអ្នកទ្រុស្តសីលទេ ។ សម្រាប់អ្នកមានការសមាទានសីល ៥ ហើយរក្សានោះ បានប្រយោជន៍ច្រើនឡើងតទៅទៀត*

ពេលគឺ ក្រៅអំពីបានជាអ្នកមានបញ្ចសីលកុសលហើយ នៅមានសមាទានកុសលកើតឡើងទៀត ដោយហេតុនេះ ពុទ្ធមាមកជនទាំងឡាយ មានការនិយមសមាទានសីល ៥ រឿយៗ រហូតមក ទាំងប្រាកដនៅក្នុងពេលឥឡូវនេះ ។

## ការសមាទានឧបោសថសីលជាឯកជ្ឈសមាទាន

បើសមាទានសិក្ខាបទ ៨ រួមគ្នា ក៏ឲ្យពោលដូច្នេះថា "ឧបោសថសីលំ សមាទិយាមិ" ឬសមាទានថា "អដ្ឋង្គសីលំ សមាទិយាមិ" ប្រែថា "ខ្ញុំព្រះករុណា សូមសមាទានឧបោសថសីលមានអង្គ ៨ ប្រការ" ដូច្នេះ ។

## ការសមាទានឧបោសថសីលជាបច្ចេកសមាទាន

សមាទានសិក្ខាបទ ៨ ដោយចំពោះសិក្ខាបទមួយៗ ថា

១-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ ។ល។

៦. វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ

៧. នច្ចគីតវាទិតវិសូកទស្សន-មាលាគន្ធវិលេបនធារណ-មណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ

*៨. ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ ដូច្នេះ ។*

## សេចក្ដីខុសប្លែកគ្នានៃការសមាទាន

*សួរថា សេចក្ដីខុសប្លែកអំពីគ្នានឹងគ្នា (នៃការមាទានជាឯកជ្ឈសមាទាន និងបច្ចេកសមាទាន) មានយ៉ាងដូចម្ដេច ?*

*ឆ្លើយថា បើបុគ្គលសមាទានជាឯកជ្ឈសមាទាន វិរតិក៏ដូចគ្នាតែមួយប៉ុណ្ណោះ, ចេតនា ក៏មានមួយដួងដូចគ្នាដែរ ។ ប៉ុន្តែ វិរតិនិងចេតនាទាំង ២ នោះ ធ្វើកិច្ចនៃវិរតិនិងចេតនាគ្រប់បែបយ៉ាង ព្រោះហេតុនោះ សិក្ខាបទទាំងអស់ចាត់ទុកថា គឺបុគ្គលអ្នករក្សាឧបោសថ បានសមាទានហើយដោយពិត ។ ដោយការសមាទានរួមគ្នានោះឯង ។*

*ម្យ៉ាងទៀត បើបុគ្គលសមាទានជាបច្ចេកសមាទាន វិរតិនិងចេតនាដែលផ្សេងៗគ្នា រមែងកើតឡើងតាមនាទីរបស់ខ្លួនដោយអំណាចនៃកិច្ច ។*

សព្វសមាទានេ បន វចីភេទោ កាតព្វោយេវ :

*ក៏ក្នុងការសមាទានគ្រប់យ៉ាង គប្បីធ្វើការបញ្ចេញវាចា ដោយ*

*ពិត ។ (ចាកមង្គលត្ថទីបនី ៣, ១៦៥-១៦៧)*

## ២.៨ បាដិហារិយបក្ខឧបោសថ

*ក្នុងធម្មិកសូត្រ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ៖*

*ព្រោះហេតុនោះ អ្នកចូរមានចិត្តជ្រះថ្លា រក្សាឧបោសថ ដែលប្រកបដោយអង្គប្រាំបី ឲ្យមានសភាពពេញលេញល្អ អស់ថ្ងៃទី ១៤ ទី ១៥ និងថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ។*

***ក្នុងអដ្ឋកថា បរមត្ថជោតិកា ពន្យល់ថា ៖***

*គប្បីប្រកបនឹងបទដទៃ យ៉ាងនេះថា* បក្ខស្ស ឧបវស្ស-ឧបោសថំ *សេចក្តីថា គប្បីចាំរក្សាឧបោសថគ្រប់ ៣ ថ្ងៃទាំងនេះ គឺរហូតអស់ថ្ងៃទី ១៤ ទី ១៥ និងថ្ងៃទី ៨ នៃបក្ខ គប្បីចាំរក្សាឧបោសថប្រកបដោយអង្គ ៨ នេះឯង ។ ក៏ក្នុងបទថា* បាដិហារិយបក្ខញ្ច *(អស់បាដិហារិយបក្ខផង) នេះ ប្រាំខែទាំងនេះគឺ (អាសាឡ្ហ) ខែ ៨ ដើម ជិតថ្ងៃចូលវស្សា បីខែក្នុងវស្សា និងខែកត្តិក (ខែ ១២) លោកហៅថា* ***បាដិហារិយបក្ខ*** *។*

អាចារ្យពួកដទៃ ពោលថា បាដិហារិយបក្ខ មានបីខែប៉ុណ្ណោះគឺ ខែអាសាឍ ខែកត្តិក ខែផល្គុន (ខែ ៨ ខែ ១២ និងខែ ៤) ។ អាចារ្យមួយពួកទៀត ពោលថា មាន ៤ ថ្ងៃគឺ ថ្ងៃទី ១៣ ថ្ងៃទី ១ (ថ្ងៃបាដិបទ) ថ្ងៃទី ៧ និងថ្ងៃទី ៩ ក្នុងគ្រប់ៗ បក្ខ ដោយថ្ងៃមុន និងថ្ងៃក្រោយ របស់ថ្ងៃឧបោសថនៃបក្ខ ។

យំ រុច្ចតិ តំ គហេតព្វំ : អ្នកសិក្សាគាប់ចិត្ត យ៉ាងណា ក៏គប្បីកាន់យកយ៉ាងនោះ ។

សព្វំ វា បន បុញ្ញកាមីនំ ភាសិតព្វំ : ក៏បុគ្គល អ្នកប្រាថ្នាបុណ្យទាំងឡាយ គប្បីធ្វើឲ្យបានគ្រប់យ៉ាង ។

គប្បីចងចិត្តទុកថា អ្នកមានចិត្តជ្រះថ្លា **បាដិហារិយបក្ខ** នេះ ដោយប្រការដូច្នេះ មិនវៀរស្ទួម្បីតែមួយថ្ងៃ ចូលដល់អង្គ ៨ ធ្វើឲ្យពេញលេញដោយល្អ បរិបូរណ៍ដោយល្អ គប្បីចាំរក្សា ឧបោសថដែលប្រកបដោយអង្គ ៨ ។

**ក្នុងអដ្ឋកថា មនោរថបូរណី ពន្យល់ថា ៖**

ក្នុងបទថា បាដិហារិយបក្ខញ្ច នេះ គប្បីជ្រាបវិនិច្ឆ័យ ដូចតទៅនេះ ឧបោសថដែលរក្សាជាប់តគ្នា រហូតដល់អស់ ត្រៃមាសខាងក្នុងវស្សា ឈ្មោះថា **បាដិហារិយបក្ខឧបោសថ** ។

*កាលមិនអាច (រក្សា)ឧបោសថរហូតដល់អស់ត្រៃមាសនោះបាន ឧបោសថដែលរក្សាប្រចាំរហូតដល់អស់ខែមួយ ក្នុងចន្លោះថ្ងៃបវារណាទាំង ២ ខ្ទះ, កាលមិនអាច (រក្សា)ឧបោសថប្រចាំរហូតដល់អស់ខែមួយនោះបាន (ឧបោសថ)កន្លះខែមួយ តាំងពីថ្ងៃបវារណាដំបូងខ្ទះ, ក៏ឈ្មោះថា* **បាដិហារិយបក្ខឧបោសថ** *ដូចគ្នា ។*

## ២.៩ សីលវិសេសរបស់ឃរាវាសទាំងឡាយ

*ការរក្សាសីលរបស់យរាវាសនោះ ក្រៅអំពីសីល ៥ សីល ៨ ហើយ នៅមានសីលដទៃៗ ទៀត ដែលនឹងរក្សាបានដូចជា ៖*

**១-អាជីវដ្ឋមកសីល** *បានដល់ វៀរចាកកាយទុច្ចរិត ៣ វចីទុច្ចរិត ៤ និង* ***មិច្ឆាជីវា វេរមណី*** *ជាគំរប់ ៨ ។*

**២-នវង្គឧបោសថសីល** *បានដល់ ឧបោសថសីលនោះឯង តែបន្ថែម “****យថាពលំ មេត្តាសហគតេន ចេតសា សព្វាវន្តំ លោកំ ផរិត្វា វិហរាមិ :*** *ខ្ញុំព្រះករុណា សូមផ្សាយទៅកាន់លោកទាំងពួង ដោយចិត្តដែលប្រកបដោយមេត្តា តាមសមគួរដល់កម្លាំង ហើយនៅគ្រប់ឥរិយាបថទាំង ៤ ។*

**៣-ឧសន្តសីល** *បានដល់ សិក្ខាបទ ១០ ប្រការ ដែលសាមណេររក្សានោះឯង ។*

## ២.១០ ឈ្មោះនៃអាជីវដ្ឋមកសីល និងការផ្សេងគ្នារបស់អ្នករក្សាបញ្ចសីលនិងអាជីវដ្ឋមកសីល

*អាជីវដ្ឋមកសីលនេះ ក្នុងវិសុទ្ធិមគ្គ លោកហៅថា អាទិព្រហ្មចរិយសីល សីលដែលជាខាងដើមរបស់មគ្គព្រហ្មចរិយ សំដៅសេចក្ដីថា អាជីវដ្ឋមកសីលនេះ ជាបាទដែលនឹងឲ្យបានសម្រេចមគ្គផល ។*

*មួយទៀត យកវាសទាំងឡាយនឹងសមាទានអាជីវដ្ឋមកសីល ឬមិនសមាទានក៏ដោយ បើប្រព្រឹត្តកន្លងសិក្ខាបទណាមួយហើយ ក៏រមែងមានទោស ដូចគ្នានឹងការប្រព្រឹត្តិកន្លងបញ្ចសីល ។ ក្នុងសីល ២ យ៉ាងនោះ បើអ្នកណារក្សាបញ្ចសីលនៅជានិច្ច អ្នកនោះក៏បានឈ្មោះថា ជាសប្បុរសធម្មតា បើរក្សាអាជីវដ្ឋមកសីលនៅជានិច្ច អ្នកនោះក៏បានឈ្មោះថា ជាសប្បុរសដ៏វិសេស ។*

## ២.១១ ការចែកសីលដោយនិច្ចសីលនិងអនិច្ចសីល

និច្ចសីល សំដៅសេចក្តីថា សីលណាកាលពិធីកម្មនោះសម្រេចហើយ ក៏ដល់ព្រមដោយសីលនោះទៅផង ដោយមិនត្រូវមានការសមាទានទៀត និងអ្នកនោះ ក៏ត្រូវរក្សាសីលនោះជានិច្ច តាំងអំពីពេលនោះជាដើមទៅ បើមិនរក្សា រមែងមានទោស សីលនោះឈ្មោះថា **និច្ចសីល** ។

អនិច្ចសីល សំដៅសេចក្តីថា សីលណា មិនរក្សាក៏មិនមានទោស ប្រសិនបើមានសេចក្តីប្រាថ្នានឹងរក្សា ក៏ត្រូវមានការសមាទានសីលនោះ ដូច្នេះ សីលនោះ ឈ្មោះថា **អនិច្ចសីល** ។

**និច្ចសីល** គឺ សិក្ខាបទវិភង្គសម្រាប់ភិក្ខុ ២២០ សិក្ខាបទនិងខន្ធកវត្ត និងសិក្ខាបទ ៣០៤ របស់ភិក្ខុនី ដែលព្រះមានព្រះភាគ ទ្រង់សម្តែងទុកក្នុងភិក្ខុបាតិមោក្ខ និងភិក្ខុនីបាតិ-មោក្ខនោះ ជានិច្ចសីលរបស់ភិក្ខុ ភិក្ខុនី ។ ទសង្គសីលសេខិយវត្ត សិក្ខាបទទាំងឡាយឯទៀតដែលជាលោកវជ្ជៈ មានសុក្កវិស្សដ្ឋិសិក្ខាបទជាដើម ទាំងនោះ ជានិច្ចសីល របស់សាមណេរ ។ សីល ៥ នោះ ជានិច្ចសីល របស់គ្រហស្ថ

ទាំងឡាយ ។

**អនិច្ចសីល** គឺការប្រព្រឹត្តិធុតង្គ ក្នុងធុតង្គ ១៣ សម្រាប់ភិក្ខុ, ធុតង្គ ៨ សម្រាប់ភិក្ខុនី, ធុតង្គ ១២ សម្រាប់សាមណេរ, ធុតង្គ ៧ សម្រាប់សិក្ខមានា និងសាមណេរីនេះ ជាអនិច្ចសីលរបស់ភិក្ខុ ភិក្ខុនី សាមណេរ សិក្ខមានា និងសាមណេរី ។

ឧបោសថសីល នវង្គុបោសថសីល ទសង្គសីល និងប្រព្រឹត្តធុតង្គយ៉ាងណាមួយ បណ្តាធុតង្គ ២ យ៉ាងគឺ ឯកាសនិកង្គធុតង្គ បត្តបិណ្ឌិកង្គធុតង្គ ទាំងនេះ ជាអនិច្ចសីលរបស់យាវាសទាំងឡាយ ។

## ២.១២ ការចែកសីលដោយចារិត្តសីលនិងវារិត្តសីល

ចារិត្តសីល សំដៅសេចក្តីថា មិនប្រព្រឹត្តក៏មិនមានទោស បើប្រព្រឹត្តបាន ក៏ល្អ មានប្រយោជន៍ច្រើន បានដល់អនិច្ចសីល ដូចដែលបានពោលហើយនោះឯង ។

វារិត្តសីល សំដៅសេចក្តីថា សីលនោះ ត្រូវមានការប្រព្រឹត្តិជាប្រចាំ បើមិនប្រព្រឹត្ត រមែងមានទោស បានដល់និច្ចសីលនោះឯង ។

## ២.១៣ វិធីសមាទានព្រមទាំងពុទ្ធប្រណាម ត្រៃសរណគមន៍និងសិក្ខាបទ

*វិធីសមាទានបញ្ចសីល និងឧបោសថសីលនោះ រមែងជាការយល់ចូលចិត្ត ដឹងល្អទូទៅហើយ ដូច្នោះ នឹងមិននាំមកពោលទីនេះទៀតទេ ។ សម្រាប់វិធីសមាទាន* ***អាជីវដ្ឋមកសីល*** *នវង្គុបោសថសីល និង* ***ទសង្គសីល****នោះ មានសម្ដែងដូច្នេះ ៖*

## ២.១៤ វិធីសមាទានអាជីវដ្ឋមកសីល

*អ្នកសមាទានសីល ពោលសមាទានថា ៖*

***ឱកាស / អហំ / មយំ / ភន្តេ តិសរណេន សហ អាជីវដ្ឋមកសីលំ ធម្មំ / យាចាមិ / យាចាម / អនុគ្គហំ កត្វា សីលំ ទេថ / មេ / នោ / ភន្តេ ;***

***ទុតិយម្បិ ។ល។ តតិយម្បិ ។ល។***

*សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវធម៌ គឺ អាជីវដ្ឋមកសីល មួយអន្លើដោយព្រះត្រៃសរណគមន៍ បពិត្រព្រះករុណាដ៏ចម្រើន*

*សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ឲ្យនូវសីលដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ ;*

*។ល។ ជាគម្រប់ពីរដងផង, ។ល។ ជាគម្រប់បីដងផង ។*

អ្នកឱ្យសីលពោលនាំមុន អ្នកសមាទានពោលតាមថា

*នមោ តស្ស ។ល។ (ពោល៣ចប់)*

*ពុទ្ធំ សរណំ គច្ឆាមិ ។ល។*

*ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ។ល។*

*តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ។ល។*

## សិក្ខាបទ

*១-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ*

*២-អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ*

*៣-កាមេសុមិច្ឆាចារា វេរមណី សិក្ខាបទំ សមាទិយាមិ*

*៤-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ*

*៥-បិសុណាវាចា វេរមណី សិក្ខាបទំ សមាទិយាមិ*

*ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនាជាហេតុវៀរចាកកិរិយាពោលពាក្យញុះញង់*

**៦-ផរុសវាចា វេរមណី សិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាពោលពាក្យអាក្រក់

**៧-សម្ផប្បលាបា វេរមណី សិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាពោលពាក្យឥតប្រយោជន៍

**៨-មិច្ឆាជីវា វេរមណី សិក្ខាបទំ សមាទិយាមិ**

ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺចេតនា ជាហេតុវៀរចាកកិរិយាចិញ្ចឹមជីវិតខុស ។

☆ ចាប់ពី **នមោ តស្ស ។ល។** រហូតមកដល់សិក្ខាបទទី ៨ អ្នកឲ្យសីលសូត្រនាំមុន. អ្នកសមាទានសីលពោលតាមទៅ ។

អ្នកឲ្យសីលសូត្រថា "**តិសរណេន សហ អាជីវដ្ឋមកសីលំ សាធុកំ កត្វា អប្បមាទេន សម្បាទេហិ / សម្បាទេថ** ប្រែថា : អ្នក / អ្នកទាំងឡាយ គប្បីធ្វើនូវសីល មានអាជីវៈជាគម្រប់ ៨ ព្រមទាំងព្រះត្រៃសរណគមន៍ឲ្យប្រពៃ ត្រូវរក្សាឲ្យល្អ ដោយសេចក្តីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានសីលទទួលថា **អាម ភន្តេ** .

*អ្នកឲ្យសីលសម្តែងអានិសង្សសីលថា ៖*

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។

*អ្នកទទួលសីលពោលថា **សាធុ សាធុ សាធុ** ។*

## ២.១៥ វិធីសមាទាននវង្គឧបោសថសីល

*អ្នកសមាទានសីល ពោលសមាទានថា ៖*

ឱកាស / អហំ / មយំ / ភន្តេ តិសរណេន សហ នវង្គសមន្នាគតំ ឧបោសថសីលំ ធម្មំ យាចាមិ / យាចាម / អនុគ្គហំ កត្វា សីលំ ទេថ / មេ / នោ / ភន្តេ ។ ទុតិយម្បិ ។ល។ តតិយម្បិ ។ល។

*សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវធម៌ គឺ ឧបោសថសីល ដែលប្រកបដោយអង្គ ៩ មួយអន្លើដោយព្រះត្រៃសរណគមន៍ សូមព្រះករុណា មេត្តាធ្វើនូវសេចក្តីអនុគ្រោះដល់ខ្ញុំព្រះករុណា*

/ ខ្ញុំព្រះករុណាទាំងឡាយ ;

ៗលៗ ជាគម្រប់ពីរដងផង, ៗលៗ ជាគម្រប់បីដងផង ។

អ្នកឱ្យសីលពោលនាំមុន អ្នកសមាទានពោលតាមថា

*នមោ តស្ស ៗលៗ (ពោល ៣ ចប់)*

*ពុទ្ធំ សរណំ គច្ឆាមិ ៗលៗ*

*ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ៗលៗ*

*តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ៗលៗ*

**<u>សិក្ខាបទ</u>**

*១-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ*

*២-អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ*

*៣-អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ*

*៤-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ*

*៥-សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ*

*៦-វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ*

*៧-នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណ-*

មណ្ឌនវិភូសនដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ

៨-ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ សមាទិយាមិ

៩-យថាពលំ មេត្តា សហគតេន ចេតសា សព្វាវន្តំ លោកំ ផរិត្វា វិហរាមិ ខ្ញុំព្រះករុណា សូមផ្សាយទៅកាន់លោកទាំងពួង ដោយចិត្តដែលប្រកបដោយមេត្តា តាមសមគួរដល់កម្លាំង ហើយនៅគ្រប់ឥរិយាបថទាំង ៤ ,

ឬថា មេត្តាសហគតេន ចេតសា សព្វបាណភូតេសុ ផរិត្វា វិហរណំ សមាទិយាមិ ខ្ញុំព្រះករុណា សូមផ្សាយទៅចំពោះពួកសត្វនិងពួកភូតទាំងឡាយ ដោយចិត្តដែលប្រកបដោយការរាប់អាន សមាទានគ្រប់ឥរិយាបថទាំង ៤ ,

☆ (ចាប់ពី នមោ តស្ស ។ល។ រហូតមកដល់សិក្ខាបទទី ៩ អ្នកឲ្យសីលសូធ្យនាំមុន. អ្នកសមាទានសីលពោលតាម ។

អ្នកឲ្យសីលសូធ្យថា តិសរណេន សហ នវង្គសមន្នាគតំ ឧបោសថសីលំ សាធុកំ កត្វា អប្បមាទេន សម្បាទេហិ / សម្បាទេថ, អ្នក / អ្នកទាំងឡាយ គប្បីធ្វើនូវឧបោសថសីលដែលប្រកបដោយអង្គ ៩ មួយអន្លើដោយព្រះត្រៃសរណគមន៍

ឲ្យប្រពៃ ដោយសេចក្ដីមិនប្រមាទ គឺថាកុំបីធ្វេសប្រហែសឡើយ ។

អ្នកសមាទានសីលទទួលថា អាម ភន្តេ ។

**អ្នកឱ្យសីលពោលពីអានិសង្សសីលថា**

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។

អ្នកសមាទានសីលទទួលថា សាធុ សាធុ សាធុ ។

## ២.១៦ វិធីសមាទានទសង្គសីល

អ្នកសមាទានសីលពោលថា ៖

ឧកាស / អហំ / មយំ / ភន្តេ តិសរណេន សហ ទសង្គសមន្នាគតំ សីលំ ធម្មំ / យាចាមិ / យាចាម / អនុគ្គហំ កត្វា សីលំ ទេថ / មេ / នោ / ភន្តេ ;

ទុតិយម្បិ ។ល។ តតិយម្បិ ។ល។

សូមគោរព បពិត្រព្រះករុណាដ៏ចម្រើន ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ / សូមនូវធម៌ គឺទសង្គសីល

មួយអន្លើដោយព្រះត្រៃសរណគមន៍ សូមព្រះករុណា មេត្តាធ្វើនូវសេចក្ដីអនុគ្រោះ ដល់ខ្ញុំព្រះករុណា / ខ្ញុំព្រះករុណាទាំងឡាយ ; ។ល។ ជាគម្រប់ពីរដងផង, ។ល។ ជាគម្រប់បីដងផង ។

**អ្នកឱ្យសីលពោលនាំមុន អ្នកសមាទានពោលតាមថា**

នមោ តស្ស ។ល។ (ពោល៣ចប់)

ពុទ្ធំ សរណំ គច្ឆាមិ ។ល។

ទុតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ។ល។

តតិយម្បិ ពុទ្ធំ សរណំ គច្ឆាមិ ។ល។

**សិក្ខាបទ**

១-បាណាតិបាតា វេរមណី សិក្ខាបទំ សមាទិយាមិ

២-អទិន្នាទានា វេរមណី សិក្ខាបទំ សមាទិយាមិ

៣-អព្រហ្មចរិយា វេរមណី សិក្ខាបទំ សមាទិយាមិ

៤-មុសាវាទា វេរមណី សិក្ខាបទំ សមាទិយាមិ

៥-សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី សិក្ខាបទំ សមាទិយាមិ

៦-វិកាលភោជនា វេរមណី សិក្ខាបទំ សមាទិយាមិ

៧-នច្ចគីតវាទិតវិសូកទស្សនា វេរមណី សិក្ខាបទំ
សមាទិយាមិ

៨-មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា
វេរមណី សិក្ខាបទំ សមាទិយាមិ

៩-ឧច្ចាសយនមហាសយនា វេរមណី សិក្ខាបទំ
សមាទិយាមិ

១០-ជាតរូបរជតប្បដិគ្គហណា វេរមណី សិក្ខាបទំ សមាទិយាមិ ខ្ញុំព្រះករុណា សូមសមាទាននូវសិក្ខាបទ គឺ ចេតនាជាហេតុវៀរចាក កិរិយាទទួលកាន់យកនូវមាស និង ប្រាក់ដោយខ្លួនឯង ឬ ប្រើអ្នកដទៃឲ្យទទួលកាន់យក ឬ ត្រេកអរចំពោះមាស និងប្រាក់នោះ ។

☆ <u>បញ្ជាក់</u> ចាប់ពី **នមោ តស្ស** ។ល។ រហូតមកដល់ សិក្ខាបទទី ១០ អ្នកឲ្យសីលសូធ្យនាំមុន. អ្នកសមាទានសីល ពោលតាម ។

អ្នកឲ្យសីលសូត្រថា "តិសរណេន សហ ទសគហដ្ឋសីលំ សាធុកំ កត្វា អប្បមាទេន សម្បាទេហិ / សម្បាទេថ," អ្នក /

*អ្នកទាំងឡាយ គប្បីធ្វើនូវទសគហដ្ឋសីលដែលប្រកបដោយអង្គ ១០ មួយអន្លើដោយព្រះត្រៃសរណគមន៍ឲ្យប្រពៃ ដោយសេចក្ដីមិនប្រមាទ គឺ ថាកុំបីធ្វេសប្រហែសឡើយ ។*

*អ្នកទទួលសីលពោលថា **អាម ភន្តេ** ។*

**អ្នកឱ្យសីលពោលពីអានិសង្សសីលថា**

សីលេន សុគតឹ យន្តិ សីលេន ភោគសម្បទា
សីលេន និព្វុតឹ យន្តិ តស្មា សីលំ វិសោធយេ ។

*អ្នកទទួលសីលថា **សាធុ សាធុ សាធុ** ៕*

☆ *<u>កំណត់សម្គាល់</u> អ្នកឲ្យសីលពោលថា* "យមហំ វទាមិ តំ វទេហិ / វទេថ" *ក្រោយអំពីពាក្យអារាធនា, អ្នកទទួលសមាទានសីល ពោលព្រមគ្នាថា* "អាម ភន្តេ"; និងអ្នក*ឲ្យសីលពោលថា* "តិសរណគ្គមនំ បរិបុណ្ណំ ឬ តិសរណ-គ្គហណំ បរិបុណ្ណំ" *ក្រោយពីអ្នកទទួលត្រៃសរណគមន៍ចប់ហើយ, អ្នកទទួលសីលទាំងឡាយ ពោលព្រមគ្នាថា* "អាម ភន្តេ" *ដូច្នេះ ។*

*ពាក្យពោលទាំងនេះ ជាពាក្យពោលដែលបុរាណាចារ្យទាំងឡាយ និយមប្រើ និងទទួលមត៌កជាប់តមករហូតដល់ឥឡូវនេះ ដូច្នោះ ទើបមិនគួរនឹងចោលរបស់ដែលល្អទាំងនេះឲ្យសាបសូន្យទៅឡើយ ។*

## ២.១៧ ភស្តុតាងដែលទទួលបាន ក្រោយពីរក្សាសីល

១-និច្ចសីលវសេន បញ្ចសិក្ខាបទានិ, សតិ វា ឧស្សាហេ ទស, ឧបោសថង្គវសេន អដ្ឋាតិ ឥទំ គហដ្ឋសីលំ ។ *សិក្ខាបទទាំង ៥ ពោលដោយនិច្ចសីលក្តី សិក្ខាបទទាំង ១០ កាលមានសេចក្តីព្យាយាមក្តី, សិក្ខាបទទាំង ៨ កាលពោលដោយអង្គនៃឧបោសថសីលក្តី, សីល ៥ សីល ៨ សីល ១០ ដូចពោលមកហើយនេះឈ្មោះថា **គ្រហស្ថសីល** (មកក្នុងវិសុទ្ធិមគ្គអដ្ឋកថា) ។*

២-ទសាតិ សាមណេរេហិ រក្ខិតព្វសីលមាហ ។ *ពាក្យថា "**ទសសីល**" នោះ ពោលគឺសីល ១០ ដែលសាមណេរទាំងឡាយរក្សានោះឯង (មកក្នុងវិសុទ្ធិមគ្គមហាដីកា) ។*

៣-សិក្ខាតិ ឧបាសកឧបាសិកាហិ សិក្ខិតព្វ-សិក្ខា, សាបិ បញ្ចសីលទសសីលវសេន វេទិតព្វា ។ *ពាក្យថា “**សិក្ខា**” គឺប្រព្រឹត្តនោះ បានដល់ សិក្ខាបទដែលឧបាសក ឧបាសិកាទាំងឡាយ គប្បីប្រព្រឹត្តនោះឯង សិក្ខាបទដែលឧបាសក ឧបាសិកាទាំងឡាយ គប្បីប្រព្រឹត្តនោះគឺ សីល ៥ សីល ១០ ក៏មិនជំទាស់ (មកក្នុងសម្មោហវិនោទនីអដ្ឋកថា) ។*

៤-សីលវន្តោតិ ឧបាសកត្តេ បតិដ្ឋាយ បញ្ចហិ ទសហិ សីលេហិ សមន្នាគតោ ។ *អ្នកដែលតាំងនៅក្នុងភាពជាឧបាសក ឧបាសិកា នឹងបរិបូរណ៍ដោយសីល ៥ សីល ១០ នេះ ទើបបានឈ្មោះថា “**សីលវន្តោ**” គឺអ្នកមានសីល (មកក្នុងសគាថវគ្គសំយុត្តអដ្ឋកថា) ។*

៥-គិហិនោបិ បញ្ចសីលំ ទសសីលំ បច្ចវេក្ខ-ន្តស្ស : *គ្រហស្ថអ្នកដែលពិចារណាសីល ៥ ឬសីល ១០ ដែលខ្លួនបានរក្សា (មកក្នុងសម្មោហវិនោទនីអដ្ឋកថា) ។*

៦-សរណាគមនេ កិញ្ចិ និវេសេតិ តថាគតោ, កិញ្ចិ បញ្ចសុ សីលេសុ, សីលេ ទសវិធេ បរំ ។

*ព្រះតថាគតទ្រង់ណែនាំទាយក ទាយិកាទាំងពួង (ពួកខ្លះ) ឲ្យតាំងនៅក្នុងត្រៃសរណគមន៍, ពួកខ្លះក៏ឲ្យតាំងនៅក្នុងសីល ៥, ពួកខ្លះក៏ឲ្យតាំងនៅក្នុងសីល ១០ ដូច្នេះ (មកក្នុងពុទ្ធវង្ស-អដ្ឋកថា) ។*

## ២.១៨ លក្ខណជាដើមរបស់សីលកុសល

១-បតិដ្ឋានលក្ខណំ *ជាទីតាំងនៃកុសលធម៌ទាំងពួងជាលក្ខណៈ*

២-ទុស្សីល្យវិទ្ធំសនរសំ *មានការកំចាត់បង់នូវភាពនៃបុគ្គលទ្រុស្តសីលជាកិច្ច*

៣-សោចេយ្យបច្ចុប្បដ្ឋានំ *មានសេចក្តីបរិសុទ្ធិនៃកាយ និងវាចាជាអាការប្រាកដ*

៤-ហិរិឱត្តប្បបទដ្ឋានំ *មានហិរិ និង ឱត្តប្បៈជាហេតុជិតឲ្យកើតឡើង ។*

## ២.១៩ បដិក្ខេបធម៌ជាដើមរបស់សីលកុសល

១–បដិក្ខេបធម្ម ធម៌ដែលត្រូវលះបង់ដោយសីលកុសល បានដល់ ទោសដែលទាក់ទងដោយការប្រទូសរ៉ាយ

២–អនុញ្ញាតធម្ម ធម៌ដែលបានអនុញ្ញាត អំពីសីលកុសល ឲ្យកើតឡើងនោះ បានដល់ អទោសៈ គឺសេចក្តីមិនប្រទូសរ៉ាយ

៣–ឧប្បាទេតព្វធម្ម ធម៌ដែលសីលកុសលធ្វើឲ្យកើតឡើង បានដល់ មគ្គខាងក្រោម ៣ ផលខាងក្រោម ៣ (សំដៅដល់អំណាចរបស់សីលកុសលដែលជាឧបត្ថម្ភកសត្តិ) សមដូចព្រះមហាពុទ្ធឃោសាចារ្យ សម្តែងទុកក្នុងខន្ធកៈវគ្គសំយុត្តអដ្ឋកថាថា "ទានសីលុបនិស្សយា ហិ តយោ មគ្គេ ច ផលានិ ច ទាបេន្តិ, ភាវនុបនិស្សយោ អរហត្តំ ទាបេតិ" "មហាកុសលដែលមានទានសីល ជាឧបនិស្ស័យឲ្យបានមគ្គខាងក្រោម ៣ ផលខាងក្រោម

*៣, មហាកុសលដែលមានការនាជាឧបនិស្ស័យ រមែងបាន អរហត្តមគ្គ អរហត្តផល” ។*

## ២.២០ អានិសង្សឧបោសថសីល

*(សុត្តន្តបិដក អង្គុត្តរនិកាយ លេខ៤៨ ទំព័រ១៩៥)*

**ភគវា ឯតទវោច អដ្ឋង្គសមន្នាគតោ ភិក្ខវេ ឧបោសថោ ឧបវុត្ថោ មហាប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោ ។** *ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។ល។*

ចន្ទោ ច សូរោ ច ឧភោ សុទស្សនា ឱភា-សយន្តា អនុយន្តិ យាវតា តមោនុទា តេ បន អន្តលិក្ខគា នភេ បភាសន្តិ ទិសា វិរោចនា ឯតស្មិំ យំ វិជ្ជតិ អន្តរេ ធនំ មុត្តា មណី វេឡុរិយញ្ច ភទ្ទកំ សិង្គី សុវណ្ណំ អថវាបិ កាញ្ចនំ យំ ជាតរូបំ ហាដកន្តិ

វុច្ចតិ អដ្ឋង្គុបេតស្ស ឧបោសថស្ស កលម្បិ តេ នានុ-
ភវន្តិ សោឡសឹ ចន្ទប្បភា តារគណាវ សព្វេ តស្មា
ហិ នារី ច នរោ ច សីលវា អដ្ឋង្គុបេតំ ឧបវស្សុ-
បោសថំ បុញ្ញានិ កត្វាន សុខុទ្រយានិ អនិន្ទិតា
សគ្គមុបេន្តិ ឋានន្តិ ។

*សភាវៈទាំងឡាយ ២ គឺ ព្រះចន្ទ្រ ១ ព្រះអាទិត្យ ១ ជាសភាវៈល្អមើល កាលបំភ្លឺលោក រមែងចរទៅអស់ទីត្រឹមណា ព្រះចន្ទ្រនិងព្រះអាទិត្យទាំងនេះ ដែលកំចាត់បង់នូវងងឹត ចរទៅក្នុងអាកាស ញ៉ាំងទិសឲ្យរុងរឿងភ្លឺច្បាស់ ក្នុងអាកាសអស់ទីត្រឹមនោះ ទ្រព្យណា មានក្នុងចន្លោះនេះ គឺ កែវមុក្តាក្តី កែវមណីក្តី កែវពិទូរ្យដ៏ល្អក្តី មាសឈ្មោះសិង្គីក្តី ឈ្មោះសុវណ្ណៈក្តី ឬមាសឈ្មោះកាញ្ចនក្តី ឈ្មោះជាតរូបក្តី ឈ្មោះហដកក្តី ទ្រព្យទាំងអម្បាលនោះ មិនដល់នូវចំណិតមួយ ក្នុងចំណែក ១៦ ៗ លើកនៃឧបោសថដែលប្រកបដោយអង្គ ៨ ប្រការឡើយ ដូចជាពួកផ្កាយទាំងអស់ មិនដល់នូវពន្លឺនៃព្រះចន្ទ្រ ហេតុដូច្នោះ ស្ត្រីក្តី បុរសក្តី ជាអ្នកមានសីល*

*គួរចាំរក្សានូវឧបោសថប្រកបដោយអង្គ ៨ ប្រការ ពួកជនដែលមិនមានគេនិន្ទា បំពេញនូវបុណ្យទាំងឡាយ ដែលមានសេចក្ដីសុខជាកម្រៃ រមែងចូលទៅកាន់ឋានសួគ៌បាន ។*

## ២.២១ អានិសង្សសីល

*នៅក្នុងវិនយបិដកមហាវគ្គ ទុតិយភាគ ៧ ទំព័រ ៣០៥ ព្រះមានព្រះភាគ ទ្រង់ត្រាស់អានិសង្ស ៥ ប្រការ នៃបុគ្គលមានសីល ឬ បរិបូរណ៍ដោយសីល ។*

១-ឥធ គហបតយោ សីលវា សីលសម្បន្នោ អប្បមាទាធិករណំ មហន្តំ ភោគក្ខន្ធំ អធិគច្ឆតិ : *ម្នាលគហបតីទាំងឡាយ បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលក្នុងលោកនេះ តែងបាននូវគំនរនៃសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្ដីមិនប្រមាទ ។*

២-សីលវតោ សីលសម្បន្នស្ស កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ : *បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលហើយ តែងមានកិត្តិស័ព្ទដ៏ពីរោះឮខ្ចរខ្ចាយទៅ ។*

៣-សីលវា សីលសម្បន្នោ យញ្ញទេវ បរិសំ ឧបសង្កមតិ យទិ ខត្តិយបរិសំ យទិ ព្រាហ្មណបរិសំ យទិ គហបតិបរិសំ យទិ សមណបរិសំ វិសារទោ ឧបសង្កមតិ អមង្កុភូតោ : *បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលហើយ (បើ) ចូលទៅកាន់បរិស័ទណា ទោះបីជាខត្តិយបរិស័ទក្តី ជាព្រាហ្មណបរិស័ទក្តី ជាគហបតិបរិស័ទក្តី ជាសមណបរិស័ទក្តី ក៏ក្លៀវក្លា មិនឱនមុខចុះ គឺជាមិនក្រអឹមក្រអៀន ហើយដើរចូលទៅ ។*

៤-សីលវា សីលសម្បន្នោ អសម្មូឡ្ហោ កាលំ ករោតិ : *បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលហើយ លុះវេលាទៀបស្លាប់ ក៏មិនវង្វេងស្មារតីឡើយ*

៥-សីលវា សីលសម្បន្នោ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបជ្ជតិ : *បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលហើយ លុះរំលាងខន្ធបន្ទាប់អំពីមរណៈ រមែងទៅកាន់មនុស្សលោក ឬទេវលោក ។*

ឥមេ ខោ គហបតយោ បញ្ច អានិសំសា សីលវតោ សីលសម្បទាយ : ម្នាលគហបតីទាំងឡាយ អានិសង្សទាំង ៥ ប្រការនេះឯង ជាអានិសង្សនៃបុគ្គលមានសីល ឬបរិបូរណ៍ដោយសីល ។

មិនត្រឹមតែប៉ុណ្ណោះឡើយ បុគ្គលដែលមានសីល រមែងបានជាទីស្រឡាញ់ពេញចិត្ត និងជាទីគោរព សរសើរនៃសព្រហ្មចារីផងគ្នាជាដើម ដរាបទៅទល់ត្រឹមបានដល់នូវព្រះនិព្វាន ដែលជាគ្រឿងក្សយនៃអាសវៈជាទីបំផុត សមដូចមានគាថាជាច្រើនបទ ដែលមានសម្ដែងនៅក្នុងគម្ពីរវិសុទ្ធិមគ្គថា ៖

សាសនេ កុលបុត្តានំ បតិដ្ឋា នត្ថិ យំ វិនា
អានិសំសបរិច្ឆេទំ តស្ស សីលស្ស កោ វទេ ។

ទីពឹងនៃកុលបុត្រទាំងឡាយក្នុងសាសនា មិនមានព្រោះវៀរនូវសីលណា នរណា គប្បីពោលនូវការកំណត់អានិសង្សនៃសីលនោះបាន ។

ន គង្គា យមុនា ចាបិ សរភូ វា សរស្សតី
និន្នគា ចាចិរវតី មហី ចាបិ មហានទី

សក្កុណាន្តិ វិសោធេតុំ តំ មលំ ឥធ ចាណិនំ
វិសោធយតិ សត្តានំ យំ វេ សីលជលំ មលំ។

*ស្ទឹងគង្គាក្តី យមុនាក្តី សរភូក្តី សរស្សតិក្តី អចិរវតីក្តី មហីក្តី សុទ្ធតែជាស្ទឹងយ៉ាងធំ ៗ ក៏មិនអាចដើម្បីនឹងជម្រះនូវមន្ទិលរបស់សត្វទាំងឡាយ ក្នុងលោកនេះបានឡើយ មានតែទឹក ពោលគឺសីលនេះឯងហើយ ទើបអាចជម្រះនូវមន្ទិលរបស់សត្វទាំងឡាយបាន ។*

ន តំ សជលទា វាតា ន ចាបិ ហរិចន្ទនំ
នេវ ហារា ន មណយោ ន ចន្ទកិរណង្កុរា
សមយន្តីធ សត្តានំ បរិឡាហំ សុរក្ខិតំ
យំ សមេតីទំ អរិយំ សីលំ អច្ចន្តសីតលំ ។

*ខ្យល់ទាំងឡាយ ដែលប្រកបដោយទឹកក្តី ខ្លឹមចន្ទន៍ក្រហមក្តី កែវមុក្តាហារទាំងឡាយក្តី កែវមណីទាំងឡាយក្តី រស្មីនៃព្រះចន្ទ្រដ៏ទន់ក្តី មិនអាចនឹងរម្ងាប់នូវសេចក្តីក្រហល់ក្រហាយរបស់សត្វទាំងឡាយក្នុងលោកនេះបានឡើយ មានតែសីលដ៏ប្រសើរ ដែលបុគ្គលរក្សាហើយដោយប្រពៃ ជាគុណជាតិត្រជាក់យ៉ាង*

*ក្រៃលែងនេះ ទើបអាចដើម្បីរម្ងាប់បាន ។*

សីលគន្ធសមោ គន្ធោ កុតោ ឆាម ភវិស្សតិ
យោ សមំ អនុវាតេ ច បដិវាតេ ច វាយតិ ។

*ក្លិនឯណាផ្សាយទៅស្មើ ក្នុងទីបណ្តោយខ្យល់ និងច្រាសខ្យល់ ក្លិននោះស្មើដោយក្លិនគឺសីលនឹងមានមកអំពីណា ។*

សគ្គារោហណសោបាណំ អញ្ញំ សីលសមំ កុតោ
ទ្វារំ វា បន និព្វាន- នគរស្ស បវេសនេ ។

*ជណ្តើរជាតិដទៃដែលជាជណ្តើរ សម្រាប់ឡើងទៅកាន់ស្ថានសួគ៌ ឬជាទ្វារសម្រាប់ញ៉ាំងជនឲ្យចូលទៅកាន់នគរ គឺនិព្វានឲ្យស្មើដោយសីល នឹងមានមកអំពីណា ។*

សោភន្តេវំ ន រាជានោ មុត្តាមណិវិភូសិតា
យថា សោភន្តិ យតិនោ សីលភូសនភូសិតា ។

*ព្រះរាជាទាំងឡាយ ដែលស្អិតស្អាងដោយកែវមុក្តា និងកែវមណី ក៏ទុកថាជាសមល្អមែនហើយ តែមិនសមល្អដូចព្រះយោគីទាំងឡាយ ដែលស្អិតស្អាងហើយ ដោយគ្រឿងសម្អាង ពោលគឺសីលនោះឡើយ ។*

អត្តានុវាទាទិភយំ វិទ្ធំសយតិ សព្វសោ
ជនេតិ កិត្តឹ ហាសញ្ច សីលំ សីលវតំ សទា ។

*សីលនៃបុគ្គលអ្នកមានសីលទាំងឡាយ រមែងកំចាត់នូវភ័យទាំងពួង មានអត្តានុវាទភ័យជាដើម ដោយសព្វគ្រប់ តែងញុំាងកិត្តិស័ព្ទនិងសេចក្តីរីករាយឲ្យកើតសព្វកាល ។*

គុណានំ មូលភូតស្ស ទោសានំ ពលឃាតិនោ
ឥតិ សីលស្ស វិញ្ញេយ្យំ អានិសំសកថាមុខំ ។

*ប្រធាននៃពាក្យពោល នូវអានិសង្សរបស់សីលដែលជាមូលនៃគុណទាំងឡាយ ជាគ្រឿងសម្លាប់នូវកម្លាំងនៃទោសទាំងឡាយ បណ្ឌិតគប្បីជ្រាបតាមន័យដែលបានពោលមកនេះចុះ ។ល។*

អច្ចន្តសន្តា បន យា អយំ និព្វានសម្បទា
សម្បន្នសីលស្ស មនោ តមេវ អនុធាវតិ ។

*និព្វានសម្បត្តិនោះហ្នឹងឯង ដែលមានសេចក្តីស្ងប់ ក្នុងទីបំផុតក្រៃពេក ចិត្តរបស់បុគ្គលមានសីលបរិបូណ៌ហើយ តែងស្ទុះទៅកាន់និព្វានសម្បត្តិនោះឯង ។*

*ក្នុងសារត្ថទីបនីដីកា មានសម្តែងពីសីលកថា ថា ៖*

សីលកថា នាម សីលំ នាមេតំ អវស្សយោ បតិដ្ឋា អារម្មណំ តាណំ លេណំ គតិ បរាយណំ ។ សីលំ នាមេតំ មម វំសោ ។ *ដែលឈ្មោះថា សីលកថា បានដល់ ពាក្យដែលទាក់ទងនឹងគុណរបស់សីល មានជាដើម យ៉ាងនេះថា ធម្មតាជាសីលនេះ ជាទីអាស្រ័យ ជាទីតាំង ជាអារម្មណ៍ ជាទីទប់ទល់ ជាទីការពារ ជាផ្លូវទៅ ជាទីទៅខាងមុខ, ឈ្មោះថា សីលនេះ ជាវង្សរបស់តថាគត ។*

*តថាគត បានបំពេញសីលទុកក្នុងអត្តភាព មិនមានទីបំផុត គឺក្នុងកាលដែលជាស្តេចសង្ខបាលនាគរាជ ក្នុងកាលជាស្តេចភូរិទត្តនាគរាជ ក្នុងកាលដែលជាស្តេចចម្បេយ្យនាគរាជ ក្នុងកាលដែលជាស្តេចដំរីសីលវរាជ ក្នុងកាលដែលជាស្តេចដំរីមាតុបោសកហត្ថី ក្នុងកាលដែលជាស្តេចដំរីឆទ្ទន្ត ។*

ឥធលោកបរលោកសម្បត្តីនញ្ហិ សីលសទិសោ អវស្សយោ សីលសទិសា បតិដ្ឋា អារម្មណំ តាណំ លេណំ គតិ បរាយណំ នត្ថិ, *ក៏ទីអាស្រ័យប្រាកដស្មើ*

*ដោយសីលនៃសម្បត្តិក្នុងលោកនេះ និង ក្នុងលោកខាងមុខ ទីតាំង អារម្មណ៍ ទីទប់ទល់ ទីការពារ ទីដើរទៅ ទីទៅក្នុងខាងមុខ ប្រាកដស្មើដោយសីលមិនមាន ។*

សីលាលង្ការសទិសោ អលង្ការោ នត្ថិ, *អលង្ការប្រាកដដូចជាគ្រឿងអលង្ការ គឺសីលមិនមាន,*

សីលបុប្ផសទិសំ បុប្ផំ នត្ថិ : *ផ្កាឈើ ប្រាកដដូចជាផ្កា គឺសីលមិនមាន,*

សីលគន្ធសទិសោ គន្ធោ នត្ថិ : *ក្លិនប្រាកដដូចជាក្លិន គឺសីលមិនមាន,*

សីលាលង្ការេន ហិ អលង្កតំ សីលកុសុមបិឡន្ធនំ សីលគន្ធានុលិត្តំ សទេវកោបិ លោកោ ឱលោកេន្តោ តិត្តិំ ន គច្ឆតិ : *ក៏លោកនេះ ព្រមទាំងទេវលោក សម្លឹងមើលបុគ្គលដែលប្រដាប់ដោយគ្រឿងប្រដាប់គឺសីល មានផ្កាឈើគឺសីលជាគ្រឿងលំអ ដែលក្លិនគឺសីលលាបហើយ រមែងមិនដល់ការឆ្អែត ។*

## ២.២២ សីលវត្ថុរគាថា

*(សុត្តន្តបិដក ខុទ្ទកនិកាយ លេខ៥៧ ទំព័រ២៨-២៩)*

សីលមេវិធ សិក្ខេថ អស្មិំ លោកេ សុសិក្ខិតំ

សីលំ ហិ សព្វសម្បត្តិំ ឧបនាមេតិ សេវិតំ ។

*បុគ្គលគប្បីសិក្សានូវសីល ឲ្យជាសីលដែលខ្លួនសិក្សាល្អហើយក្នុងលោកនេះ ព្រោះថាសីលដែលបុគ្គលសេពហើយ រមែងបង្អោនមកនូវសម្បត្តិទាំងពួង ។*

សីលំ រក្ខេយ្យ មេធាវី បត្ថយានោ តយោ សុខេ

បសំសំ វិត្តិលាភញ្ច បេច្ច សគ្គេ បមោទនំ ។

*ជនអ្នកមានប្រាជ្ញា កាលចង់បាននូវសេចក្តីសុខ ៣ យ៉ាង គឺសេចក្តីសរសើរ ១ ការបាននូវទ្រព្យ ១ កាលលះលោកនេះហើយ រីករាយក្នុងស្ថានសួគ៌ ១ គួររក្សាសីល។*

សីលវា ហិ ពហូ មិត្តេ សញ្ញមេនាធិគច្ឆតិ

ទុស្សីលោ បន មិត្តេហិ ធំសតេ បាបមាចរំ ។

*ពិតណាស់ បុគ្គលអ្នកមានសីល រមែងបាននូវមិត្តទាំងឡាយច្រើន ដោយការសង្រួម ចំណែកបុគ្គលទ្រុស្តសីល*

កាលប្រព្រឹត្តអាក្រក់ រមែងឃ្លាតចាកមិត្តទាំងឡាយ ។

អវណ្ណញ្ច អកិត្តិញ្ច ទុស្សីលោ លភតេ នរោ
វណ្ណំ កិត្តិំ បសំសញ្ច សទា លភតិ សីលវា ។

ជនទ្រុស្តសីលរមែងបានទូវទោសផង នូវដំណោះដំនៀលផង ឯជនអ្នកមានសីល រមែងបានទូវគុណផងនូវកិត្តិស័ព្ទផង នូវសេចក្តីសរសើរផង សព្វៗ កាល ។

អាទិ សីលំ បតិដ្ឋា ច កល្យាណានញ្ច មាតុកំ
បមុខំ សព្វធម្មានំ តស្មា សីលំ វិសោធយេ ។

សីលជាខាងដើម ជាទីតាំង ជាមេនៃកល្យាណធម៌ និងជាប្រធាននៃធម៌ទាំងពួង ព្រោះហេតុនោះ បុគ្គលគប្បីជម្រះសីល ។

វេលា ច សំវរំ សីលំ ចិត្តស្ស អភិហាសនំ
តិត្ថញ្ច សព្វពុទ្ធានំ តស្មា សីលំ វិសោធយេ ។

សីលជាច្រាំង ជាទំនប់ ជាគ្រឿងញ៉ាំងចិត្តឲ្យរីករាយ ទាំងជាកំពង់របស់ព្រះពុទ្ធគ្រប់ព្រះអង្គ ព្រោះហេតុនោះ បុគ្គលគប្បីជម្រះនូវសីល ។

សីលំ ពលំ អប្បដិមំ សីលំ អាវុធមុត្តមំ
សីលំ អាភរណំ សេដ្ឋំ សីលំ កវចមព្ភុតំ ។

*សីលជាកម្លាំងរកអ្វីប្រៀបផ្ទឹមមិនបាន សីលជាអាវុធដ៏ឧត្តម សីលជាគ្រឿងអាភរណៈដ៏ប្រសើរ សីលជាគ្រឿងក្រោះយ៉ាងអស្ចារ្យ ។*

សីលំ សេតុ មហេសក្ខោ សីលំ គន្ធោ អនុត្តរោ
សីលំ វិលេបនំ សេដ្ឋំ យេន វាតិ ទិសោ ទិសំ។

*សីល ជាស្ពានមានស័ក្តិធំ សីល ជាគ្រឿងក្រអូបដ៏ប្រសើរ សីល ជាគ្រឿងលាបដ៏ប្រសើរ តែងបក់ទៅសព្វៗទិស ។*

សីលំ សម្ពលមេវគ្គំ សីលំ ធាថេយ្យមុត្តមំ
សីលំ សេដ្ឋោ អតិវាហោ យេន វាតិ ទិសោ ទិសំ។

*សីល ជាកញ្ចប់បាយដ៏ប្រសើរ សីល ជាស្បៀងដ៏ឧត្តម សីល ជាវាហនៈដ៏ប្រសើរ សម្រាប់ទៅកាន់ទិសទាំងពួង ។*

ឥធេវ និន្ទំ លភតិ បេច្ចាធាយេ ច ទុម្មនោ
សព្វត្ថ ទុម្មនោ ពាលោ សីលេសុ អសមាហិតោ។

បុគ្គលពាល មានចិត្តអាក្រក់ក្នុងទីទាំងពួង មិនតាំងមាំក្នុងសីលទាំងឡាយ រមែងបាននូវសេចក្តីនិន្ទាក្នុងលោកនេះផង លុះលះលោកនេះទៅហើយ រមែងមានចិត្តជាទុក្ខក្នុងអបាយផង ។

ឥធេវ កិត្តឹ លភតិ បេច្ច សគ្គេ ច សុមនោ
សព្វត្ថ សុមនោ ធីរោ សីលេសុ សុសមាហិតោ ។

អ្នកប្រាជ្ញ មានចិត្តល្អ ក្នុងទីទាំងពួង តាំងមាំក្នុងសីលទាំងឡាយ រមែងបាននូវកិត្តិស័ព្ទក្នុងលោកនេះផង លុះលះលោកនេះទៅ រមែងមានចិត្តរីករាយក្នុងឋានសួគ៌ផង ។

សីលមេវ ឥធ អគ្គំ បញ្ញវា បន ឧត្តមោ
មនុស្សេសុ ច ទេវេសុ សីលបញ្ញាណតោ ជយន្តិ។

សីលជាកំពូលក្នុងលោកនេះ ចំណែកបុគ្គលមានប្រាជ្ញាក៏ឧត្តមដែរ ជ័យជំនះក្នុងមនុស្សលោក និងទេវលោក ព្រោះសីលនិងបញ្ញា ។

## ២.២៣ សីលវិមំសជាតក

ក្នុងក្រុងសាវត្ថី មានព្រាហ្មណ៍ម្នាក់ ឈ្មោះថា *សីលវិមំសកៈ* ជាអ្នកដល់នូវសរណៈ ៣ មានសីល ៥ មិនធុះធ្លាយ អាស្រ័យព្រះរាជាព្រះនាមកោសលចិញ្ចឹមជីវិត ។ ព្រះរាជាទ្រង់ធ្វើការរាប់អានដល់ព្រាហ្មណ៍នោះ ព្រមទាំងព្រាហ្មណ៍ឯទៀត ដោយទ្រង់ព្រះតម្រិះថា "ព្រាហ្មណ៍នេះ ជាអ្នកមានសីល" ក្នុងថ្ងៃមួយព្រាហ្មណ៍នោះគិតថា "ព្រះរាជាទ្រង់អាស្រ័យការដល់ព្រមដោយជាតិ គោត្រ ត្រកូល ប្រទេស និងសិល្បៈ របស់អាត្មាអញហើយ ទើបទ្រង់ធ្វើសេចក្ដីរាប់អាន ឬក៏ទ្រង់អាស្រ័យនូវការដល់ព្រមដោយសីល (របស់អាត្មាអញ) ទើបទ្រង់ធ្វើឬហ្ន៎ ? , អាត្មាអញនឹងសាកល្បងមើល" ដូច្នេះហើយ ក៏ទៅកាន់ទីបំរុងនៃព្រះរាជា កាលនឹង (ត្រឡប់)ទៅផ្ទះ មិនបានលាសោះឡើយ បានយកទ្រព្យមួយកហាបណៈ អំពីបន្ទះក្ដាររបស់ហិរញ្ញិកម្នាក់ទៅហើយ ។ ហិរញ្ញិកមិននិយាយពាក្យអ្វីៗ ឡើយ អង្គុយ(នៅស្ងៀម) ព្រោះសេចក្ដីគោរពចំពោះព្រាហ្មណ៍ ។ ក្នុងថ្ងៃទី២ ព្រាហ្មណ៍នោះ បានយកទ្រព្យ ២ កហាបណៈ ។ ហិរញ្ញិក ក៏បាន

អត់ទ្រាំយ៉ាងដូច្នេះដែរ ។ ក្នុងថ្ងៃទី ៣ ព្រាហ្មណ៍នោះ ក៏បានយកកហាបណៈ ១ ក្តាប់ដៃ ។ ហិរញ្ញិកក្រោធខឹង ហើយស្រែកប្រាប់ ៣ ដងថា "ខ្ញុំចាប់ចោរដែលប្លន់ទ្រព្យបានហើយ" ។ មនុស្សទាំងឡាយបាននាំគ្នាមកអំពីទីទុំះផង ទីនេះផង ពោលថា "ឥឡូវនេះ អ្នកធ្វើដូចជាអ្នកមានសីល ត្រាច់ទៅហើយ អស់កាលដ៏យូរ" ដូច្នេះហើយ ក៏ឲ្យការប្រហារ២-៣ដង ចងហើយបានសម្តែងដល់ព្រះរាជាហើយ ។ ព្រះរាជាទ្រង់មានព្រះវិប្បដិសារី ទ្រង់មានព្រះរាជាឱង្ការថា "នែព្រាហ្មណ៍ ព្រោះហេតុអ្វី ទើបអ្នកធ្វើកម្មនៃបុគ្គលអ្នកទ្រុស្តសីល យ៉ាងដូច្នេះ ? " ហើយទ្រង់ត្រាស់បញ្ជាថា "អ្នកទាំងឡាយចូរទៅ, ចូរធ្វើរាជអាជ្ញាដល់ព្រាហ្មណ៍នោះចុះ" ព្រាហ្មណ៍បានក្រាបទូលថា បពិត្រព្រះមហារាជ ទូលព្រះបង្គំមិនមែនជាចោរទេ, តាមពិត ទូលព្រះបង្គំបានធ្វើហើយយ៉ាងនេះ ព្រោះហេតុនេះ" ដូច្នេះ ហើយក្រាបទូលថា ឥឡូវនេះ ទូលព្រះបង្គំបានដឹងហើយ ដោយច្បាស់លាស់ថា ព្រះអង្គទ្រង់អាស្រ័យសីលប៉ុណ្ណោះ ទើបទ្រង់ធ្វើសេចក្តីរាប់អាន ដល់ទូលព្រះបង្គំ, មិនមែន ទ្រង់អាស្រ័យជាតិជាដើមធ្វើឡើយ ហើយបានក្រាប

ទូលថា "ពិតមែនដូច្នោះ ឥឡូវព្រះអង្គទ្រង់ត្រាស់បញ្ជាឲ្យធ្វើអាជ្ញាដល់ទូលព្រះបង្គំ, ដោយហេតុនេះ ទូលព្រះបង្គំនោះទើបដល់នូវការសន្និដ្ឋានថា ក្នុងលោកនេះ សីលប៉ុណ្ណោះប្រសើរបំផុត, សីលជាប្រធាន ដូច្នេះ, មួយទៀត ទូលព្រះបង្គំកាលធ្វើកម្មដែលសមគួរ ដល់សីលនេះ ស្ថិតនៅក្នុងផ្ទះបរិភោគនូវកិលេសទាំងឡាយ នឹងមិនអាចដើម្បីធ្វើបានឡើយ ដូច្នេះហើយ ក្រាបទូលសុំព្រះរាជាអនុញ្ញាតថា ក្នុងថ្ងៃនេះឯងទូលព្រះបង្គំនឹងបួស ក្នុងសំណាក់នៃព្រះសាស្ដា, បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ព្រះរាជទាននូវបព្វជ្ជា ដល់ទូលព្រះបង្គំផង ដូច្នេះហើយ ក៏បានទៅកាន់វត្តជេតពនសូមបព្វជ្ជានឹងព្រះសាស្ដា បានហើយនូវបព្វជ្ជានិងឧបសម្បទា មិនលះបង់កម្មដ្ឋានហើយ ចម្រើនវិបស្សនា បានសម្រេចហើយនូវព្រះអរហត្ត ។ ក៏ការវាយ ហើយចងនូវព្រាហ្មណ៍នោះឯណា, ការវាយហើយចងនោះ បណ្ឌិតគប្បីឃើញថា "ជាផលនៃអធិដ្ឋាន" ។

(រឿងព្រាហ្មណ៍មកហើយក្នុងអដ្ឋកថា សីលវិមំសជាតក ក្នុងនវម នៃឯកនិបាត) ។

## ៣_ភាវនាមយ:

ក្នុងអដ្ឋកថា-បរមត្ថទីបនី ថា : *ចេតនា របស់អ្នកពិចារណាឃើញច្បាស់នូវ ចក្ខុ សោត: ឃាន: ជិវ្ហា កាយ មន: ដោយ(ជារបស់)មិនទៀង ជាទុក្ខ ជាអនត្តា ដោយវិបស្សនាមគ្គដែលពោលហើយក្នុងបដិសម្ភិទា ១ ចេតនារបស់អ្នកពិចារណាឃើញច្បាស់នូវរូបទាំងឡាយ ។ល។ ធម៌ទាំងឡាយ ចក្ខុវិញ្ញាណ ។ល។ មនោវិញ្ញាណ ។ ចក្ខុសម្ផស្ស ។ល។ មនោសម្ផស្ស, ចក្ខុសម្ផស្សជា វេទនា ។ល។ មនោសម្ផស្ស-ជា វេទនា ។ រូបសញ្ញា ។ល។ ធម្មសញ្ញា ។ (និង) ជរាមរណ: ដោយជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ១ ឈានចេតនា ដែលប្រព្រឹត្តទៅហើយក្នុងអារម្មណ៍ ៣៨ ប្រការ មានបឋវីកសិណជាដើម ១ ចេតនាដែលប្រព្រឹត្តទៅហើយដោយអំណាចនៃការសន្សំ (បរិច្ចយ) និង មនសិការជាដើម ដែលមិនមានទោស ១ យ៉ាងណា អ្នកញ៉ាំងចេតនាទាំងអស់នោះ ឲ្យចម្រើនដោយបុញ្ញកិរិយាវត្ថុនេះ ព្រោះដូច្នោះ ទើបឈ្មោះថា បុញ្ញកិរិយាវត្ថុដែលសម្រេចដោយភាវនា តាមន័យដែលពោលហើយដូច្នេះឯង ។*

*(ម្យ៉ាងទៀត) ការឲ្យ (ទាន) ដោយផ្ដើមតាំងការពិចារណា (នាមរូប) ដោយការអស់ទៅ ដោយការសូន្យទៅ ដោយកម្ម បុញ្ញកិរិយាវត្ថុ ជា**ភាវនាមយៈ** ។*

ក្នុងបរមត្ថជោតិក ថា: **ភាវនា** *សម្ដែងវចនត្ថៈថា ៖*

**"កុសលធម្មេ ភាវេតិ ឧប្បាទេតិ វឌ្ឍេតីតិ = ភាវនា"** *ធម្មជាតិណា ធ្វើឲ្យកុសលដែលប្រសើរកើតឡើងជាគ្រាដំបូង ហើយធ្វើឲ្យចម្រើនឡើង ដូច្នេះ ធម្មជាតិនោះឈ្មោះថា **ភាវនា** បានដល់ មហាកុសលចិត្តុប្បាទ ដែលជាប់ទាក់ទងនឹងការចម្រើនសមថភាវនានិងវិបស្សនាភាវនា ដែលនៅជាបរិកម្មភាវនា និង ឧបចារភាវនា ។*

*ក្នុងវចនត្ថៈ នេះ បែកជា ២ ផ្នែក គឺ ៖*

**កុសលធម្មេ ភាវេតិ ឧប្បទេតិ** *រមែងធ្វើកុសលដែលប្រសើរកើតឡើងគ្រាដំបូង ១ ផ្នែក,*

**កុសលធម្មេ ភាវេតិ វឌ្ឍេតិ** *រមែងធ្វើកុសលដែលប្រសើរកើតឡើងច្រើនទៅក្រៃលែងឡើងៗ ១ ផ្នែក ។*

*វចនត្ថៈ ទាំង២ផ្នែកនេះ ផ្នែកទី១ សំដៅដល់កុសល-ចិត្តុប្បាទ ដែលកើតឡើង គ្រាដំបូងនៃការបដិបត្តិ ផ្នែកទី ២*

*សំដៅដល់ កុសលចិត្តុប្បាទ ដែលកើតឡើងជាប់តគ្នាក្នុងគ្រាក្រោយនៃការបដិបត្តិ ដែលនៅមិនទាន់ចូលដល់អប្បនា ។*

*__មួយទៀត__ ពាក្យថា **ភាវនា** ក្នុងបុញ្ញកិរិយាវត្ថុនោះ លោកសម្ដែងដល់រឿងមហាកុសល ដូច្នោះ អន្តធម៌ទើបបានដល់ មហាកុសលតែម្យ៉ាង ចំណែកពាក្យថា **ភាវនា** ក្នុងកម្មដ្ឋានសង្គហៈ បរិច្ឆេទទី ៩ នោះ លោកសម្ដែងដល់រឿងសមថៈ និង វិបស្សនា ដូច្នោះ អន្តធម៌ទើបបានដល់លោកិយនិងលោកុត្តរៈ កុសលទាំងអស់តាមសមគួរ ដូច្នោះដីកាចារ្យទើបពោលទុកថា ការសិក្សារៀនសូត្រ ព្រះធម៌វិន័យ ការអប់រំ ការនឹកគិត ពិចារណា គិតសញ្ជឹង ក្នុងគោលធម៌ផ្សេងៗក្ដី ការរៀន ការអប់រំ វិជ្ជាផ្សេងៗ ដែលមិនមានទោសទាំងនេះក្ដី សុទ្ធសឹងតែជាភាវនា ដែលជាចំណែកបុញ្ញកិរិយាវត្ថុទាំងអស់ ។*

## ៣.១ លក្ខណាជាដើមរបស់ភាវនាកុសល

*១-កុសលវឌ្ឍាបនលក្ខណា* មានការធ្វើឲ្យកុសលចម្រើនឡើង ជាលក្ខណៈ

*២-អកុសលបហានរសា* មានការលះបង់អកុសលជាកិច្ច

៣-សត្ថាចារេក្កមនបច្ចុប្បដ្ឋានា មានការចូលកាន់ផ្លូវបដិបត្តិ ដែលទាក់ទងជាមួយសតិរបស់នាមកាយ រូបកាយ ជាអាការប្រាកដ

៤-យោនិសោមនសិការបទដ្ឋានា មានយោនិសោ-មនសិការ គឺការពិចារណាដោយឧបាយ ជាហេតុជិត ។

## ៣.២ បដិក្ខេបធម៌ជាដើមរបស់ភាវនាកុសល

១-បដិក្ខេបធម្ម ធម៌ដែលត្រូវលះបង់ដោយភាវនា បានដល់ មោហៈ

២-អនុញ្ញាតធម្ម ធម៌ដែលបានទទួលអនុញ្ញាតអំពីភាវនាកុសលឲ្យកើត បានដល់ អមោហៈ

៣-ឧប្បាទេតព្វធម្ម ធម៌ដែលភាវនាកុសលធ្វើឲ្យកើតឡើង បានដល់ អរហត្តមគ្គ អរហត្តផល (ដោយឧក្កដ្ឋន័យ) ។

## ៤.អបចាយនមយៈ

ក្នុងបរមត្ថទីបនី អដ្ឋកថា : *បុញ្ញកិរិយាវត្ថុ ដែលសម្រេចដោយអបចាយនៈ (ការគោរព) គប្បីជ្រាបដោយអំណាចនៃការឃើញភិក្ខុចាស់ជាង ហើយក្រោកទទួល ទទួលបាត្រនិងចីវរ ថ្វាយបង្គំ និងឲ្យផ្លូវជាដើម ។*

នៅក្នុងបរមត្ថជោតិកៈ ***អបចាយន*** *សម្តែងវចនត្ថៈថា ៖*

"អបចាយន្តិ ឯតេនាតិ = អបចាយនំ" *ជនទាំងឡាយ រមែងធ្វើការគោរព ឱនលំទោន ដោយកុសលចេតនាណា ដូច្នោះ កុសលចេតនាដែលជាហេតុនៃការគោរព ឱន-លំទោននោះ ឈ្មោះថា* ***អបចាយនៈ*** *បានដល់ ចេតនាក្នុងមហាកុសលចិត្ត អធិប្បាយថា កាលបានជួបមាតាបិតា យាយតា គោរព ឬក្រាបថ្វាយបង្គំ ឱនក្បាល ឬចូលទៅ ទទួលវត្ថុផ្សេងៗ ដោយការជួយកាន់ ឬជួយទទួលរបស់មកពីលោក ដែលជាការធ្វើទៅដោយសេចក្តីបរិសុទ្ធិនៃចិត្ត មិនបានប្រាថ្នា ឬសង្ឃឹមយ៉ាងណា ក្នុងលាភ យស សក្ការៈ ទាំងនេះសុទ្ធតែជាអបចាយនៈទាំងអស់, ប្រសិនបើថា ការធ្វើនេះ មានសេចក្តី*

*សន្សើម ថានឹងបានលាភ យស សក្ការៈហើយ ការធ្វើយ៉ាង នេះនោះ មិនមែនជាអបចាយនៈ ដោយពិត តែជាអបចាយនៈ ដែលលាយដោយមាយាសាថេយ្យ ។*

## ៤.១ អបចាយនៈមាន ២ យ៉ាង

សាមញ្ញអបចាយន ១ វិសេសអបចាយន ១ ។

*ក្នុង ២ យ៉ាងនេះ ការសម្តែងសេចក្តីគោរព ឱនលំទោន ចំពោះមាតាបិតា យាយតា គ្រូអាចារ្យ ដោយសេចក្តីរលឹក នឹកថា យើងមាននាទីដែលនឹងត្រូវធ្វើការគោរព ឱនលំទោន ចំពោះលោកទាំងនេះ ព្រោះលោកជាញាតិអ្នកធំ និងគ្រូអាចារ្យ របស់យើងដូច្នេះ បានឈ្មោះថា សាមញ្ញអបចាយនៈ ។*

*ការសម្តែងសេចក្តីគោរពឱនលំទោន ក្នុងព្រះរតនត្រ័យ ដោយការរលឹកនឹកដល់ព្រះគុណផ្សេងៗ មាន**អរហំ** ជាដើម ដោយអំណាចនៃមហាកុសលចិត្ត ដែលប្រកបដោយសទ្ធា បញ្ញា ដោយថ្លែងវាចាថា **ពុទ្ធំ សរណំ គច្ឆាមិ** ជាដើម ដូច្នេះ បានឈ្មោះថា វិសេសអបចាយនៈ ។*

## ៤.២ បុគ្គលដែលគួរគោរពឱនលំទោន ៣ ប្រភេទ

១-គុណវុឌ្ឍិបុគ្គល ជាអ្នកចម្រើនដោយអំណាច
នៃសីលគុណ សមាធិគុណ បញ្ញាគុណ

២-វយវុឌ្ឍិបុគ្គល ជាអ្នកចម្រើនដោយអំណាចនៃអាយុ

៣-ជាតិវុឌ្ឍិបុគ្គល ជាអ្នកចម្រើនដោយអំណាច
នៃវង្សត្រកូល ។

ក្នុងបណ្តាវុឌ្ឍិទាំង ៣ ប្រភេទនេះ ការគោរពឱនលំទោនចំពោះគុណវុឌ្ឍិបុគ្គល និង វយវុឌ្ឍិបុគ្គល ទាំង ២ ប្រភេទប៉ុណ្ណោះ ទើបជាអបចាយនកុសលដោយពិតបាន, ចំណែកការគោរព ឱនលំទោនចំពោះជាតិវុឌ្ឍិបុគ្គលនោះ បើប្រព្រឹត្តទៅដោយអំណាចនៃលោភចិត្តុប្បាទ ទោសចិត្តុប្បាទ មោហ-ចិត្តុប្បាទ ក៏មិនជាកុសល យ៉ាងណា បើប្រព្រឹត្តទៅដោយអំណាចនៃមហាកុសលចិត្តុប្បាទ ក៏ជាអបចាយនកុសលដោយអនុលោមប៉ុណ្ណោះ ព្រោះជាការបដិបត្តិដោយមារយាទដែលល្អស្អាត តាមប្រវេណី និយមទូទៅ ។

វុឌ្ឍិទាំង ៣ ប្រភេទនេះ បុគ្គលខ្លះ ក៏ជាអ្នកចម្រើនគ្រប់ទាំង ៣ ប្រភេទ បានដល់ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ជាដើម,

បុគ្គលខ្លះ ក៏មានត្រឹមតែ ២ ប្រភេទ គឺ គុណវុឌ្ឍិ និងវយវុឌ្ឍិ បានដល់ ព្រះអរិយសង្ឃ អ្នកធំ ដែលមកអំពីត្រកូលសាមញ្ញ ឬ គុណវុឌ្ឍិ និង ជាតិវុឌ្ឍិ បានដល់ ព្រះរាហុលជាដើម ឬ វយវុឌ្ឍិ និង ជាតិវុឌ្ឍិ បានដល់ ព្រះបាទសុប្បពុទ្ធជាដើម, បុគ្គលខ្លះ ក៏ជាអ្នកធំណាមួយក្នុងវុឌ្ឍិ ៣ ប្រភេទនោះ ។

មួយទៀត អ្នកដែលជាគុណវុឌ្ឍិបុគ្គលដែលមានសីល សមាធិ បញ្ញា បើបានជួបជាមួយគ្នានឹងអ្នកដែលជាវយវុឌ្ឍិ-បុគ្គល ដែលមានអាយុច្រើនជាងខ្លួន ឬ ជាតិវុឌ្ឍិបុគ្គលដែលមានត្រកូលខ្ពស់ជាង ឬ តំណែងខ្ពស់ជាងយ៉ាងណាមួយ ឬ ទាំង ២ យ៉ាងហើយ ក៏មិនត្រូវធ្វើការគោរពដោយការក្រាប-ថ្វាយបង្គំ ត្រឹមតែសំពះក៏ល្មម សូម្បីថា អ្នកនោះជាបិតា មាតា យាយ តា គ្រូអាចារ្យ ក៏ដោយ បើលោកទាំងនោះ ជាមិច្ឆា-ទិដ្ឋិបុគ្គល មាននត្ថិកទិដ្ឋិជាដើម ទាំងសេចក្តីប្រព្រឹត្តិ ក៏អាក្រក់ជួរជាតិ ថោកទាបផងហើយ ក៏កាន់តែមិនចាំបាច់ត្រូវធ្វើការគោរពដោយការក្រាបថ្វាយបង្គំឡើយ យ៉ាងល្អបំផុតត្រឹមតែសំពះប៉ុណ្ណោះ ក៏ជាការប្រពៃ នេះព្រោះអ្នកដែលជាគុណវុឌ្ឍិ-បុគ្គលនោះ មានមុខដែលត្រូវគោរពចំពោះសីល សមាធិ

បញ្ញា ដែលមាននៅក្នុងសន្តានរបស់ខ្លួន ដែលជាគុណធម៌ខ្ពង់ខ្ពស់ជាង ល្អជាងលោក ហេតុនោះ ទើបមិនគួរនឹងធ្វើការក្រាបថ្វាយបង្គំ ព្រោះប្រសិនបើលោកទាំងនោះ មានសេចក្តីត្រេកអរចំពោះការក្រាបថ្វាយបង្គំ គ្រានោះផងហើយ ក៏នឹងកើតទោសដល់លោកទាំងក្នុងភពនេះ និងភពខាងមុខ ដែលប្រព្រឹត្តទៅតាមគោល(ច្បាប់) របស់ធម្មជាតិ សេចក្តីនេះបានមានប្រាកដច្បាស់ក្នុងរឿងចន្ទកុមារ ថា ក្នុងខណៈដែលព្រះ-ពោធិសត្វ ទ្រង់បានជួបជាមួយព្រះរាជបិតា នៅខាងក្រៅក្រុង ដោយបិតាព្រះអង្គ ត្រូវប្រជាជនធ្វើការនិរទេស ឲ្យចេញទៅនោះ ព្រះពោធិសត្វ ទ្រង់មិនបានធ្វើការក្រាបថ្វាយបង្គំ យ៉ាងណា ត្រឹមតែទ្រង់ធ្វើអញ្ជលី ព្រមជាមួយនឹងថ្លែងព្រះវាចាថា "**ចិរំ ជីវ សាមិ :** សូមព្រះអង្គ ចូរទ្រង់មានព្រះជន្មយឺនយូរ" ដោយអាការៈត្រឹមតែប៉ុណ្ណោះ ។

## ៤.៣ សេចក្តីគោរពនិងមិនគោរព

ភាវៈនៃបុគ្គលដែលធ្ងន់ទាំងឡាយ ឈ្មោះថា **គារវៈ** បានដល់ កិរិយា ធ្វើឲ្យធ្ងន់ក្នុងបុគ្គលដែលខ្លួនគោរព មានមាតាបិតាទាំងឡាយជាដើមនោះ ។

ព្រោះហេតុនោះ ក្នុងអដ្ឋកថា ទើបលោកពោលថា ៖

"កិរិយាធ្វើឲ្យធ្ងន់ គឺភាពជាអ្នកមានសេចក្តីគោរពតាមសមគួរក្នុងបុគ្គលទាំងឡាយ មានព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវ័ករបស់ព្រះតថាគត អាចារ្យ ឧបជ្ឈាយ៍ មាតា បិតា បងប្អូនប្រុស និងបងប្អូនស្រីជាដើម ដែលគួរដល់ការប្រកបដោយកិរិយាធ្វើឲ្យធ្ងន់ ឈ្មោះថា សេចក្តីគោរព" ។ សេចក្តីគោរពនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ជាមង្គល" ព្រោះជាហេតុនៃឥដ្ឋផល មានការបានទៅកាន់សុគតិភពជាដើម ។ ក៏ភាវៈនៃការមិនគោរពនោះ មិនមែនជាមង្គល គឺ ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយ ដោយការត្រាស់សម្តែងនូវភាវៈនៃសេចក្តីគោរពនោះ ជាមង្គល ។ មែនពិត សេចក្តីមិនគោរព គប្បីជ្រាបថា មិនមែនជាមង្គល ព្រោះជាហេតុនៃអនិដ្ឋផល មានការទៅកាន់ទុគ្គតិជាដើម ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់ត្រាស់សម្តែងធម៌ដល់សុភមាណព ទើបទ្រង់ត្រាស់ថា ៖

ម្នាលមាណព ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នករឹងត្អឹង មើលងាយ មិនសំពះបុគ្គលដែលគួរសំពះ មិនក្រោក

ទទួលបុគ្គលដែលគួរក្រោកទទួល មិនឲ្យអាសនៈ ដល់បុគ្គលដែលគួរដល់អាសនៈ មិនឲ្យផ្លូវ ដល់បុគ្គលដែលគួរដល់ផ្លូវ មិនធ្វើសក្ការៈ ដល់បុគ្គលដែលគួរដល់សក្ការៈ មិនធ្វើសេចក្តីគោរពដល់បុគ្គលដែលគួរធ្វើសេចក្តីគោរព មិនរាប់អានដល់បុគ្គលដែលគួររាប់អាន មិនបូជាដល់បុគ្គលដែលគួរបូជា ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះទំលាយរាងកាយបន្ទាប់ពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតសត្វតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក បើបុគ្គលនោះទំលាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ ទើបបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណាៗ រមែងជាអ្នកមានត្រកូលថោកទាប ។ ម្នាលមាណព បុគ្គលដែលរឹងត្អឹង មើលងាយ មិនសំពះបុគ្គលដែលគួរសំពះ ។បេ។ មិនបូជា ដល់បុគ្គលដែលគួរបូជា នេះឈ្មោះថា បដិបទាប្រព្រឹត្តទៅ ដើម្បីមានត្រកូលថោកទាប ។

ម្នាលមាណព មួយទៀត ស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនរឹងត្អឹង មិនមើលងាយ សំពះបុគ្គលដែលគួរ

សំពះ ក្រោកទទួលបុគ្គលដែលគួរក្រោកទទួល ឲ្យអាសនៈ ដល់បុគ្គលដែលគួរដល់អាសនៈ ឲ្យផ្លូវ ដល់បុគ្គលដែលគួរដល់ផ្លូវ ធ្វើសក្ការៈ ដល់បុគ្គលដែលគួរដល់សក្ការៈ ធ្វើសេចក្ដីគោរព ដល់បុគ្គលដែលគួរធ្វើសេចក្ដីគោរព រាប់អាន ដល់បុគ្គលដែលគួររាប់អាន បូជាដល់បុគ្គលដែលគួរបូជា ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទំលាយរាងកាយបន្ទាប់ពីសេចក្ដីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក បើបុគ្គលនោះ ទម្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ មិនទៅកើតក្នុងសុគតិសួគ៌ទេវលោកទេ ទើបបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណាៗ រមែងជាអ្នកមានត្រកូលខ្ពង់ខ្ពស់ ។ ម្នាលមាណព បុគ្គលដែលមិនរឹងត្អឹង មិនមើលងាយគេ សំពះបុគ្គលដែលគួរសំពះ ។ល។ បូជា ដល់បុគ្គលដែលគួរបូជា នេះឈ្មោះថា បដិបទាប្រព្រឹត្តទៅដើម្បីមានត្រកូលខ្ពង់ខ្ពស់ ។

ន័យក្នុងអដ្ឋកថា ចូឡកម្មវិភង្គសូត្រនោះថា ៖

បទថា **អភិវាទេតព្វំ** គឺ បុគ្គលដែលគួរដល់ការអភិវាទបានដល់ ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ឬព្រះអរិយសាវក ។ សូម្បី

បុគ្គលដែលគួរក្រោកទទួលជាដើម ក៏ន័យនេះដូចគ្នាដែរ ។

បទថា **សមត្តេន** ដែលខ្លួនបានបំពេញហើយ ។

បទថា **សមាទិន្នេន** គឺ ដែលខ្លួនកាន់ខ្ជាប់ហើយ គឺ ពាល់ត្រូវហើយ ។ បទថា **យទិទំ** មានសេចក្តីថា កម្ម គឺ ភាពជាអ្នករឹងត្អឹង មានមានះក្រៃលែងនេះឯណា បដិបទានេះ ។

*ដីកាចូឡកម្មវិភង្គសូត្រនោះថា ៖*

បទថា **សមត្តេន** គឺ ដែលអាច បានដល់ ដែលមានសមត្ថភាព ។ អធិប្បាយថា កម្មនោះ ជាកម្មដែលអាចដើម្បីនឹងឲ្យផល ដោយប្រការណា ព្រោះកម្មដែលខ្លួនបានធ្វើ គឺបានសន្សំទុកហើយ ដោយប្រការនោះ ។ ក៏កម្មប្រាកដដូច្នោះ ឈ្មោះថា មិនមានខ្វះខាត ដោយកិច្ចរបស់ខ្លួន ហេតុនោះ ទើបអដ្ឋកថាចារ្យពោលថា គឺ ខ្លួនបំពេញហើយ ។

ក្នុងបទថា **សមាទិន្នេន** នេះ ការកាន់ខ្ជាប់ គឺ ការពាល់ត្រូវដោយតណ្ហា និង ទិដ្ឋិ ឈ្មោះថា ការសមាទាន ព្រោះហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោលថា "ដែលខ្លួនកាន់ខ្ជាប់ គឺ ដែលខ្លួនពាល់ត្រូវហើយ ។

*ឈ្មោះថា បដិបទា ព្រោះវិគ្រោះថា "ជាគ្រឿងធ្វើដំណើរទៅកាន់សុគតិ ឬ ទុគ្គតិ នៃបុគ្គល" បានដល់ កម្ម ។*

*បុគ្គលដែលមិនរើសរសដោយបទបាលីថា ៖*

អត្តទ្វេតាសង្ខាតោ និវាតោ តុ យសាទិគុណប្បដិលាភ ហេតុតោ មង្គលំ : *បណ្ឌិតលោកពោលថា ចំណែកបុគ្គលប្រព្រឹត្តបន្ទាបខ្លួនពោលគឺ មិនរើសរស ជាហេតុបាននូវគុណានិងលាភ មានយសជាដើម ជាសេចក្តីចម្រើន ។*

## ៤.៤ គាថាសម្តែងអានិសង្សរបស់អបចាយនៈ

យេ វុឌ្ឍមបចាយន្តិ នរា ធម្មស្ស កោវិទា
ទិដ្ឋេ ធម្មេ ច បាសំសា សម្បរាយោ ច សុគ្គតី។

*ពួកជនដែលឈ្លាសក្នុងធម៌ កោតក្រែងចាស់ព្រឹទ្ធាចារ្យ រមែងបានសេចក្តីសរសើរ ក្នុងបច្ចុប្បន្នផង បានសុគតិក្នុងបរលោកផង ។*

អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ
ចត្តារោ ធម្មា វឌ្ឍន្តិ អាយុវណ្ណោ សុខំ ពលំ ។

ធម៌ គឺ ពរទាំងឡាយ ៤ ប្រការ គឺ អាយុ ១ ពណ៌សម្បុរកាយ ១ សេចក្តីសុខ ១ កំលាំង ១ រមែងចម្រើនអស់កាលជានិច្ច ដល់អ្នកដែលមានសេចក្តីឱនកាយថ្វាយបង្គំដល់ព្រះរតនត្រ័យ ជាប្រក្រតី និងអ្នកដែលមានសេចក្តីគោរពកោតក្រែង ដល់អ្នកដែលមានសេចក្តីចម្រើនដោយគុណមានសីលគុណជាដើម ឬ ដែលចម្រើនដោយវ័យ គឺ ចាស់ព្រឹទ្ធាចារ្យ ។

## អធិប្បាយអត្ថនៃគាថា

បទថា **អភិវាទនសីលិស្ស** គឺ អ្នកថ្វាយបង្គំជាប្រក្រតីបានដល់ អ្នកខ្វល់ខ្វាយកិច្ចគឺ ការថ្វាយបង្គំរឿយៗ ។

បទថា **វុឌ្ឍាបចាយិនោ** សេចក្តីថា ដល់គ្រហស្ថអ្នកឱនលំទោន ឬអ្នកបូជាជានិច្ច ដោយការក្រាបថ្វាយបង្គំ សូម្បីក្នុងភិក្ខុកំលោះ និងសាមណេរបួសក្នុងថ្ងៃនោះ, ក៏ឬដល់បព្វជិតអ្នកឱនលំទោន ឬអ្នកបូជាជានិច្ច ដោយការក្រាបថ្វាយបង្គំក្នុងអ្នក(បួស)ចាស់ជាងដោយបព្វជ្ជា ឬដោយឧបសម្បទា (ឬ) ក្នុងអ្នកចម្រើនដោយគុណ ។

*ពីរបទថា* **ចត្តាពេ ចម្មា** *សេចក្តីថា កាលអាយុចម្រើនរស់នៅ, អាយុនោះ រមែងចម្រើនអស់កាលប៉ុនណា, ធម៌ទាំងឡាយសូម្បីក្រៅនេះ ក៏ចម្រើនអស់កាលប៉ុណ្ណោះដូចគ្នា ។ ព្រោះថា អ្នកណាធ្វើកុសលដែលនៅអាយុ ៥០ ឆ្នាំ ឲ្យប្រព្រឹត្តទៅ, អន្តរាយនៃជីវិតរបស់អ្នកនោះ ដល់កើតឡើងសូម្បីក្នុងកាលមានអាយុ ២៥ ឆ្នាំ; អន្តរាយនោះ រមែងរម្ងាប់ទៅបានដោយភាពជាអ្នកក្រាបថ្វាយបង្គំជាប្រក្រតី ។ អ្នកនោះ រមែងតាំងនៅបានរហូតដល់អស់អាយុតែម្តង ។ សូម្បីវណ្ណៈជាដើមរបស់អ្នកនោះ រមែងចម្រើនព្រមទាំងអាយុនោះឯង ។*

*ន័យសូម្បីក្រៅពែងជាងនេះ ក៏យ៉ាងនេះឯង ។*

**អនន្តរាយេន បវត្តស្សាយុនោ វឌ្ឍនំ នាម ឆត្តិ** ។ *ក៏ឈ្មោះថា ការចម្រើននៃអាយុ ដែលប្រព្រឹត្តទៅដោយមិនមានអន្តរាយ មិនមានទេ ។*

## ៥~វេយ្យាវច្ចមយៈ

ក្នុងបរមត្ថទីបនី អដ្ឋកថា : *បុញ្ញកិរិយាវត្ថុ ដែលប្រកប ព្រមដោយការខ្វល់ខ្វាយ គប្បីជ្រាបដោយអំណាចនៃការ ធ្វើវត្តបដិបត្តិ ដល់ភិក្ខុចាស់ជាង ដោយអំណាចនៃការដែល ឃើញភិក្ខុចូលទៅក្នុងស្រុកដើម្បីបិណ្ឌបាត ទទួលបាត្រ (របស់លោក) ហើយ បញ្ចុះភិក្ខា សូម្បីក្នុងស្រុកឲ្យរៀបរយ នាំចូលទៅថ្វាយ និងដោយអំណាចនៃការប្រញាប់នាំយក បាត្រមកឲ្យជាដើម ដោយបានឮ (ពាក្យបង្គាប់)ថា ចូរទៅ នាំយកបាត្ររបស់ភិក្ខុទាំងឡាយមក ដូច្នេះ ។*

*<u>ក្នុងបរមត្ថជោតិកៈ</u> វេយ្យាវច្ច សម្តែងវចនត្ថៈថា ៖*

វិសេសេន អាវរន្តិ ឧស្សុក្កំ អាបជ្ជន្តីតិ ពយាវដា ពយាវដស្ស កម្មំ វេយ្យាវច្ចំ : *បុគ្គល ពួកណាមាន សេចក្តីព្យាយាមជាពិសេស ពោលគឺ ចូលដល់ ភាពជាអ្នកកង្វល់ចិត្ត យកចិត្តទុកដាក់ ដូច្នេះ បុគ្គលទាំងនោះ ឈ្មោះថា* **ព្យាវដៈ** *បានដល់ អ្នកចាត់ការ ឬអ្នកជួយឈឺឆ្អាល ក្នុងកិច្ចការផ្សេងៗ ការធ្វើរបស់បុគ្គលដែលមានសេចក្តី*

*ខ្វល់ខ្វាយ យកចិត្តទុកដាក់ជាពិសេស ឈ្មោះថា* ***វេយ្យាវច្ចៈ*** *បានដល់ ការជួយឈឺឆ្អាលក្នុងកិច្ចការដែលទាក់ទងនឹងបរិយត្តិ បដិបត្តិ ការបរិច្ចាគទាន ការឈឺថ្កាត់ មិនសប្បាយ ការជួយជួសជុល (សេនាសនៈ) ដូចដើមវិញ សម្អាតវត្តអារាម បូជនីយដ្ឋាន ជាដើម ។*

*តាមវចនត្ថនេះ សម្តែងដោយបុគ្គលាធិដ្ឋាន តែកាលនឹងសម្តែងដោយធម្មាធិដ្ឋានហើយ ក៏មានដូច្នេះ "* **តំ តំ កិច្ច-ករណេ ពយាវដស្ស ភាវោ វេយ្យាវច្ចំ** *: ធម៌ដែលជាហេតុធ្វើឲ្យបុគ្គលមានសេចក្តីកង្វល់ យកចិត្តទុកដាក់ក្នុងការធ្វើការងារគ្រប់យ៉ាង ឈ្មោះថា* ***វេយ្យាវច្ចៈ*** *បានដល់ ចេតនាដែលនៅក្នុងមហាកុសលចិត្តុប្បាទ ដែលធ្វើឲ្យបុគ្គលមានសេចក្តីព្យាយាម ខ្វល់ខ្វាយ យកចិត្តទុកដាក់ក្នុងការធ្វើការងារគ្រប់យ៉ាង ។*

*មួយទៀត ការជួយឈឺឆ្អាលធ្វើការងារផ្សេងៗ ដែលមិនមានទោសរបស់មាតាបិតា គ្រូ អាចារ្យ ញាតិ បងប្អូន មិត្រភក្តិ ដូចជាបុត្រធីតា ជួយមើលទ្រព្យសម្បត្តិ មាសប្រាក់ របូតការងារគ្រប់យ៉ាង មិនឲ្យលោកកង្វល់ចិត្តជាដើម ដូច្នេះ*

សូម្បីបើថា ជាការងាររផ្លូវលោកក៏ពិត តែក៏ចាត់ជាវេយ្យា-វច្ចកុសលទាំងអស់ ។

## ៥.១ បុព្វកម្មរបស់ឧត្តរមាណព

ក្នុងបាយាសិរាជញ្ញសូត្រ : ចំណែកខាងឧត្តរមាណព ជាអ្នកចាត់ចែង ក្នុងទានរបស់ស្តេចបាយាសិរាជញ្ញៈនុ៎ះ បានឲ្យទានដោយគោរព ឲ្យទានដោយដៃខ្លួនឯង ឲ្យទានដោយផ្ចិតផ្ចង់ ឲ្យទានដោយមិនបានបោះឲ្យ លុះបែកធ្លាយរាងកាយ បន្ទាប់អំពីមរណៈទៅ ក៏បានទៅកើតក្នុងឋានសុគតិសួគ៌ទេវលោក ជាមួយនឹងពួកទេវតាជាន់តាវត្តិង្ស ។

បញ្ជាក់ថា **ឧត្តរមាណព** នេះ ជាអ្នកខ្វល់ខ្វាយ ក្នុងទានរបស់ស្តេចបាយាសិរាជញ្ញៈនុ៎ះប៉ុណ្ណោះ ។ ក្នុងអដ្ឋកថាប្រាប់ថា **ឧត្តរមាណព** នោះ ឲ្យទានសូម្បីជាវត្ថុរបស់អ្នកដទៃ ក៏(ឲ្យទាន) ដោយគោរព ។

## ៥.២ បុព្វកម្មរបស់ព្រះរាជាចណ្ឌបជ្ជោត

ក៏ព្រះរាជា មានពាហនៈទាំង ៥ គឺ ៖

ដំរីញី ១ ឈ្មោះ **ភទ្ទវតី** ទៅបានមួយថ្ងៃ ៥០ យោជន៍ ។ ទាសឈ្មោះថា **កាកៈ** ទៅបាន ៦០ យោជន៍ ។ សេះ ២ គឺ **សេះចេលកណ្ឋិ** និង **មុញ្ចកេសិ** ទៅបាន ១០០ យោជន៍ ។ **ដំរីនាឡាគិរី** ទៅបាន ១២០ យោជន៍ (ក្នុងមួយថ្ងៃ) ។

បានឮមកថា ព្រះរាជាព្រះអង្គនោះ ក្នុងកាលព្រះពុទ្ធមិនទាន់បានទ្រង់ឧប្បត្តិឡើង បានជាអ្នកនៅបម្រើរបស់ឥស្សរជនម្នាក់ ។ តមកថ្ងៃមួយ កាលឥស្សរជននោះ ទៅក្រៅព្រះនគរ ងូតទឹកហើយមក, ព្រះបច្ចេកពុទ្ធអង្គមួយ ចូលទៅកាន់ព្រះនគរ ដើម្បីបិណ្ឌបាត មិនបានភិក្ខាឡើយត្រឹមតែមួយដុំ ព្រោះអ្នកក្រុងទាំងអស់ត្រូវមារបណ្តាលចិត្ត មានបាត្រតាមដែលលាងទុកហើយ (ទទេ) ចេញទៅ ។ លំដាប់នោះ មារចូលទៅរកព្រះបច្ចេកពុទ្ធនោះ ដោយភេទដែលមិនមានអ្នកណាស្គាល់ហើយ សួរលោកក្នុងខណៈដែលលោក(មក)ដល់ទ្វារព្រះនគរថា “លោកម្ចាស់ លោកបានអ្វីៗ ខ្លះទេ” ? ព្រះបច្ចេកពុទ្ធ ឆ្លើយថា “ក៏អ្នកឯងធ្វើអាការគឺ ដែលមិនបានដល់យើងហើយមិនមែនឬ” ? ។

បើដូច្នោះ សូមលោកម្ចាស់ត្រឡប់ចូលទៅទៀតចុះ, គ្រានេះខ្ញុំនឹងមិនធ្វើ ។

ព្រះបច្ចេកពុទ្ធ : យើងនឹងមិនត្រឡប់ទៅវិញទៀតទេ ។

ក៏បើព្រះបច្ចេកពុទ្ធនោះ គប្បីត្រឡប់ទៅសោត មារនោះនឹងគប្បីជ្រែកចូលក្នុងសរីរៈរបស់អ្នកក្រុងទាំងអស់ ហើយទះដៃធ្វើការសើចចំអកទៀត, កាលព្រះបច្ចេកពុទ្ធមិនត្រឡប់ មារក៏បាត់ទៅក្នុងទីនោះឯង ។ ខណៈនោះ ឥស្សរជននោះល្មមឃើញព្រះបច្ចេកពុទ្ធ ដែលមកនៅដោយទាំងបាត្រតាមដែលលាងទុក (ទទេ) ហើយ ទើបថ្វាយបង្គំ ហើយសួរថា "លោកម្ចាស់ លោកបានអ្វីៗ ខ្លះទេ" ? លោកឆ្លើយថា "អ្នកមានអាយុ អាត្មាត្រាច់ទៅហើយ ចេញមកហើយ" ។ គេគិតថា "លោកម្ចាស់ មិនតបពាក្យដែលយើងសួរ នឹងពោលពាក្យដទៃ, លោកគង់នឹងនៅមិនទាន់បានអ្វីៗ" ។ ក្នុងវេលានោះ គាត់ក្រឡេកមើលបាត្ររបស់លោក ឃើញបាត្រទទេ ក៏ជាអ្នកក្បៀវក្លា តែមិនអាចទទួលបាត្រ ព្រោះមិនទាន់ដឹងថា កត្តក្នុងផ្ទះរបស់ខ្លួនសម្រេចហើយ ឬមិនទាន់សម្រេច ទើបពោលថា "លោកម្ចាស់ សូមលោកម្ចាស់ ចូរនៅចាំបន្តិច" ដូច្នេះហើយ ក៏ទៅកាន់ផ្ទះដោយ

*ហ័ស សួរថា "កត្តសម្រាប់យើងសម្រេចហើយឬ" ? កាលអ្នកបម្រើឆ្លើយថា "សម្រេចហើយ" ទើបពោលនឹងអ្នកបម្រើនោះថា "បា អ្នកដទៃដែលមានសេចក្តីរហ័សដែលបរិបូណ៌ជាងអ្នកមិនមាន, ដោយការស្ទុះទៅដ៏រហ័ស អ្នកឯងចូលទៅដល់លោកម្ចាស់នោះ ពោលថា "លោកម្ចាស់ សូមលោកចូរឲ្យបាត្រ, ហើយទទួលបាត្រមកដោយរហ័ស" ។ គេស្ទុះទៅដោយពាក្យបន្ទាប់តែមួយប៉ុណ្ណោះ ទទួលបាត្រនាំមកហើយ ។ សុម្បីឥស្សរជន ធ្វើបាត្រឲ្យពេញដោយភោជនរបស់ខ្លួន ហើយពោលថា "អ្នកចូរប្រញាប់ទៅ ថ្វាយបាត្រនេះដល់លោកម្ចាស់ យើងនឹងឲ្យចំណែកបុណ្យ អំពីទាននេះ ដល់អ្នកឯង" ។ គេទទួលបាត្រនោះ ហើយទៅដោយលឿន(រហ័ស) ថ្វាយបាត្រដល់ព្រះបច្ចេកពុទ្ធ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយពោលថា "លោកម្ចាស់ដ៏ចម្រើន វេលាចូលទៅជិតហើយ, ខ្ញុំទៅនិងមកដោយការស្ទុះទៅដ៏រហ័សក្រៃលែង, ដោយផលនៃការស្ទុះទៅរបស់ខ្ញុំនេះ សូមពាហនៈទាំងឡាយ ៥ ដែលអាចនឹងទៅបាន ៥០ យោជន៍ ៦០ យោជន៍ ១០០ យោជន៍ ១២០ យោជន៍ ចូរកើតឡើងដល់ខ្ញុំ, មួយទៀត រាងកាយរបស់ខ្ញុំដែលមកនិងទៅ*

ត្រូវពន្លឺនៃព្រះអាទិត្យជុតពេលហើយ, ដោយផលនៃការដែលរាំងកាយត្រូវពន្លឺនៃព្រះអាទិត្យជុតពេលនោះរបស់ខ្ញុំ សូមអាផ្វារបស់ខ្ញុំ ចូរផ្សាយទៅដូចនឹងពន្លឺនៃព្រះអាទិត្យ ក្នុងទីដែលកើតហើយនិងកើតហើយ; ចំណែកបុណ្យក្នុងព្រោះបិណ្ឌបាតនេះដែលអ្នកជាម្ចាស់(ឥស្សរជន) ឲ្យហើយដល់ខ្ញុំ, ដោយផលដែលហូរចេញនៃចំណែកបុណ្យនោះ សូមខ្ញុំចូរជាអ្នកមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយ" ។ ព្រះបច្ចេកពុទ្ធពោលថា "សូមសេចក្តីប្រាថ្នាដែលអ្នកតាំងទុកនេះ ចូរសម្រេច" ហើយបានធ្វើអនុមោទនាថា ៖

ឥច្ឆិតំ បត្ថិតំ តុយ្ហំ សព្វមេវ សមិជ្ឈតុ
សព្វេ បូរេន្តុ សង្កប្បា ចន្ទោ បន្នរសោ យថា។
ឥច្ឆិតំ បត្ថិតំ តុយ្ហំ ខិប្បមេវ សមិជ្ឈតុ
សព្វេ បូរេន្តុ សង្កប្បា មណិជោតិរសោ យថា។

វត្ថុដែលត្រូវការហើយ ប្រាថ្នាហើយ ចូរសម្រេចដល់អ្នកឲ្យបានឆាប់រហ័ស, សូមសេចក្តីត្រិះរិះទាំងពួង ចូរពេញដូចព្រះចន្ទ្រ ក្នុងថ្ងៃ ១៥ កើត ។ វត្ថុដែលត្រូវការហើយប្រាថ្នាហើយ ចូរសម្រេចដល់អ្នកឲ្យបានឆាប់រហ័ស, សូម

តម្រិះត្រូវទាំងពួង ចូរពេញដល់អ្នក ដូចកែវមណី ឈ្មោះថាជោតិរសៈ ។

បានឮថា គាថា ២ នេះឯង ឈ្មោះថា គាថាអនុមោទនារបស់ព្រះបច្ចេកពុទ្ធទាំងឡាយ ។ រតនៈគឺកែវមណី ដែលឲ្យវត្ថុដែលប្រាថ្នាទាំងពួង ហៅថា “កែវមណីជោតិរស” ក្នុងគាថានោះ ។ នេះជាបុព្វចរិតនៃបុរសទទួលប្រើនោះ ។ គេបានជាព្រះបាទចណ្ឌបជ្ជោត ក្នុងឥឡូវនេះ ។ និងដោយផលដែលហូរចេញនៃកម្មនោះ ពាហនៈទាំង ៥ នេះ ទើបកើតឡើង ។

## ៦. បត្តិទានមយៈ

**បត្តិទាន** សម្តែងវចនត្ថថា "បត្តព្វាតិ បត្តិ បត្តិយា ទានំ បត្តិទានំ" ធម្មជាតិណា ដែលអ្នកធ្វើបានដល់ហើយ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **បត្តិ** បានដល់ ទាន សីល ភាវនា ដែលកើតឡើងហើយ ក្នុងសន្តានរបស់ខ្លួន ការឲ្យចំណែកបុណ្យដែលខ្លួនបានមក ឈ្មោះថា **បត្តិទាន** បានដល់ ការឧទ្ទិសចំណែកបុណ្យឲ្យដល់មាតាបិតា គ្រូអាចារ្យ ញាតិ បង ប្អូន រហូតសព្វសត្វទាំងពួងដែលស្លាប់ទៅហើយ ។

តាមវចនត្ថនេះ ជាការសម្តែងដោយបុគ្គលាធិដ្ឋាន តែកាលនឹងសម្តែងដោយធម្មាធិដ្ឋានហើយ ក៏មានដូច្នេះ "**បត្តឹ ទេន្តិ ឯតេនាតិ បត្តិទានំ** : អ្នកចិត្តបុណ្យទាំងឡាយរមែងឲ្យចំណែកបុណ្យ ដែលខ្លួនបានមក ដល់អ្នកដែលវិលាងខន្ធស្លាប់ទៅកាន់បរលោកហើយ ឬអ្នកដែលនៅមានជីវិតរស់នៅ ដោយធម្មជាតិនោះ ដូច្នោះ ធម្មជាតិ ដែលជាហេតុនៃការឲ្យនោះ ឈ្មោះថា **បត្តិទាន** បានដល់ ចេតនាដែលនៅក្នុងមហាកុសលចិត្តុប្បាទ ដែលកើតឡើង ក្នុងខណៈដែលតាំងចិត្តឧទ្ទិសចំណែកបុណ្យ ។

*សួរថា ការឧទ្ទិសចំណែកបុណ្យ ឲ្យដល់បុគ្គលដទៃដូច្នោះហើយ បុណ្យនោះនឹងកាត់បន្ថយចុះទៅឬទេ ?*

*ឆ្លើយថា មិនកាត់បន្ថយចុះឡើយ យ៉ាងណា មានតែនឹងត្រឡប់បង្កើនឡើង បន្ថែមឡើងទៀត ដូច្នោះ ក៏ព្រោះថាការឲ្យនូវបុណ្យនោះ ផ្សេងគ្នាពីការឲ្យវត្ថុដែលមាន ដែលពោលថា មានតែនឹងបង្កើនឡើង ថែមឡើងទៅនោះ ពាក្យនេះឧបមាហាក់បីដូចការអុចទៀនបន្ថែមឡើង គឺបុគ្គលដុតទៀនទុក ១ ដើម សូម្បីបើថា នាំទៀនដទៃៗមកអុចតមានចំនួនច្រើនរយ ច្រើនពាន់ដើមក៏ដោយ ពន្លឺភ្លឺច្បាស់ដែលមាននៅក្នុងទីនោះជាមួយទៀនដើមដំបូង ក៏មិនបានអស់ទៅដោយប្រការណា មានតែបានទទួលពន្លឺភ្លឺច្បាស់បន្ថែមឡើងពីពន្លឺទៀនទាំងនោះជាទ្វេគុណ យ៉ាងណា ការឧទ្ទិសចំណែកបុណ្យឲ្យដល់បុគ្គលដទៃ ក៏រមែងជួយធ្វើឲ្យកុសលដែលខ្លួនបានមក មានអំណាចច្រើនក្រៃលែងៗឡើងទៅគ្រប់កាលដែលធ្វើការឧទ្ទិសឲ្យ ដូច្នោះ ។*

*ម្យ៉ាងទៀត ការចែកបុណ្យកុសលឲ្យដល់អ្នកដទៃ គឺជាការប្រដៅចិត្តមួយផ្នែក ដើម្បីកុំឲ្យចិត្តគិតបានអ្វីៗ តែខ្លួន*

៦៨ ត្រូវបេះបែងចែករបស់ប្រសើរឲ្យអ្នកដទៃ ទូន្មានចិត្តឲ្យបេះអើពើក្នុងអំពើល្អ ដោយយកចិត្តទុកដាក់ ការជូនបុណ្យ គឺជូនដោយចិត្តមេត្តា ដោយចិត្តទន់ភ្លន់ ជូនដើម្បីឲ្យអ្នកដទៃបានបុណ្យពិតៗ ព្រោះអនុមោទនា ។

# ៧.បត្តានុមោទនាមយៈ

ក្នុងអដ្ឋកថា បរមត្ថទីបនី ថា : *បុញ្ញកិរិយាវត្ថុ គឺការអនុមោទនា (បុណ្យ) គប្បីជ្រាបដោយអំណាចនៃការអនុ-មោទនាចំណែកបុណ្យ ដែលអ្នកដទៃឲ្យហើយ ឬបុណ្យដែលអ្នកដទៃធ្វើហើយទាំងអស់ថា សាធុ (ល្អហើយ) ។*

បរមត្ថជោតិកៈ ***បត្តានុមោទនា*** *សម្តែងវចនត្ថៈថា ៖*

"បត្តិយា អនុមោទនំ = បត្តានុមោទនំ" *ការឃើញល្អ ធ្វើតាមឬទទួលត្រេកអរតាម ដោយសេចក្តីពេញចិត្តនូវចំណែកបុណ្យ ដែលគេឧទ្ទិសមកឲ្យ ឈ្មោះថា* ***បត្តានុមោទនៈ*** *បានដល់ ការត្រេកអរទទួលចំណែកបុណ្យដែលគេឧទ្ទិសមកឲ្យ ។*

ពាក្យថា “**បត្តិ**” ក្នុងបត្តិទាននោះ ជាទាន សីល ភាវនា ដែលខ្លួនព្យាយាមកសាងឲ្យកើតឡើងហើយ ឧទ្ទិសឲ្យដល់បុគ្គលដទៃ, ចំណែកពាក្យថា “**បត្តិ**” នៅក្នុងបត្តានុមោទនានោះ បានដល់ កុសលដែលគេឧទ្ទិសឲ្យនោះ បានមកដល់ខ្លួនហើយ ដោយផ្លូវវាចានិងអក្សរ ដូច្នោះ ទើបសម្ដែងវចនត្ថៈន័យមួយទៀតថា "ទាបីយតីតិ បត្តិ" កុសលដែលអ្នកដទៃគប្បីឧទ្ទិសឲ្យ ដូច្នោះ ឈ្មោះថា **បត្តិ**, "បត្តឹ អនុមោទន្តិ **សាធុការំ** ទទន្តិ ឯតេនាតិ បត្តានុមោទនំ" ជនទាំងឡាយ រមែងត្រេកអរនូវបុណ្យកុសលដែលគេឧទ្ទិសមកឲ្យដោយការថ្លែងវាចាថា **សាធុ** ដោយចេតនានោះ ដូច្នោះ ចេតនានោះ ឈ្មោះថា **បត្តានុមោទនៈ** បានដល់ មហាកុសល-ចេតនា ដែលទាក់ទងជាមួយការអនុមោទនា ។

កាលពិចារណា មើលតាមគោលវចនត្ថៈដែលសម្ដែងហើយនេះ ក៏គប្បីឃើញបានថា ចេតនានៅក្នុងមហាកុសលសោមនស្សជួងណាមួយនោះពិតៗ ជាបត្តានុមោទនាកុសលយ៉ាងបរិបូរណ៍ ចំណែកចេតនានៅក្នុងមហាកុសលឧបេក្ខាជួងណាមួយនោះ ជាបត្តានុមោទនាកុសលមិនបរិបូរណ៍ ព្រោះ

ថា ចិត្តក្នុងខណៈនោះ ខ្វះបីតិសោមនស្ស ចំពោះបុណ្យកុសលដែលគេឧទ្ទិសមកឲ្យ ត្រឹមតែធ្វើឲ្យថ្លែងវាចាថា សាធុ សាធុ (ល្អហើយៗ) តាមការសារបស់ខ្លួនប៉ុណ្ណោះ ដូច្នោះការអនុមោទនាដែលជាបត្តានុមោទនាកុសល យ៉ាងបរិបូរណ៍ត្រូវមានចិត្តប្រកបដោយបីតិសោមនស្ស បើក្រៃលែងជាញាណសម្បយុត្តសោមនស្សផងហើយ ក៏ជាបត្តានុនោទនាកុសលយ៉ាងល្អក្រៃលែង ។

## ៧.១ ការអនុមោទនាបុណ្យដែលមិនឈ្មោះថា បត្តានុមោទនាដោយត្រង់

ការអនុមោទនាចំណែកបុណ្យ ដែលមិនឈ្មោះថាបត្តានុមោទនា ដោយត្រង់នោះ គឺ កាលបានឃើញគេកំពុងធ្វើបុណ្យ គឺការបរិច្ចាគទាន រក្សាសីល ចម្រើនភាវនា ឬបានឃើញពាក្យចារិកឈ្មោះម្ចាស់របស់ ដែលជាប់នៅក្នុងវត្ថុដែលកសាងថ្វាយ(សង្ឃជាដើម) ក៏កើតបីតិសោមនស្សផង ដោយហេតុដែលគេមិនបានពោលប្រាប់ ឬឧទ្ទិសចំណែកបុណ្យនោះឲ្យទេ ការដែលបីតិសោមនស្សចំពោះការងារដែលល្អរបស់

បុគ្គលដទៃយ៉ាងនេះនោះ នឹងថ្លែងវាចាថា សាធុៗ ឬថា ល្អណាស់ ក៏ដោយ ឬមិនបានថ្លែងវាចាក៏ដោយ មិនបាន ឈ្មោះថា **បត្តានុមោទនា** ដោយត្រង់ ត្រឹមតែជាអនុលោម ប៉ុណ្ណោះ, សម្រាប់ការអនុមោទនាចំណែកបុណ្យ ដែលបាន ឈ្មោះថា ជាបត្តានុមោទនាកុសលពិតនោះ បានដល់ បុណ្យ កុសល ដែលអ្នកធ្វើបានព្យាយាមកសាងឡើង ហើយនាំមក ពោលប្រាប់ ឬ ឧទ្ទិសឲ្យ ការអនុមោទនាចំណែកបុណ្យ ដែលម្ចាស់របស់ពោលប្រាប់ ឬ ឧទ្ទិសឲ្យ ដូច្នេះ ទើបបាន ឈ្មោះថា បត្តានុមោទនកុសល ដោយត្រង់ ។

## ៧.២ ចំណែកបុណ្យដែលគេឧទ្ទិសឲ្យ ២ ប្រការ

១-ឧទ្ទិស្សិកបត្តិ ចំណែកបុណ្យដែលគេឧទ្ទិសឲ្យ ដោយចំពោះ

២-អនុទ្ទិស្សិកបត្តិ ចំណែកបុណ្យដែលគេឧទ្ទិសឲ្យ មិនចំពោះ

ការបែកបទតាមបាលីវេយ្យាករណ៍ដូច្នេះ ៖

**ឧទ្ទិស្ស + ឥក + បត្តិ = ឧទ្ទិស្សិកបត្តិ ,**

ឧទ្ទិស្ស = ការចំពោះ, ឥក = មាន, បត្តិ = កុសល ដែលគេផ្សាយឲ្យ, កាលរួមបទទាំង ៣ នេះ ចូលគ្នាហើយ ក៏ប្រែថា កុសលដែលគេផ្សាយឲ្យដោយមានការចំពោះ ។

ន + ឧទ្ទិស្ស + ឥក + បត្តិ = អនុទ្ទិស្សិកបត្តិ,

ន = មិន, ឧទ្ទិស្ស = ការចំពោះ, ឥក = មាន, បត្តិ = កុសលដែលគេផ្សាយឲ្យ, កាលរួមបទទាំង ៤ នេះ ចូលគ្នាហើយ ក៏ប្រែថា កុសលដែលគេផ្សាយឲ្យដោយមិនមានការចំពោះ ។

ការបែងចែកបុណ្យកុសលទាំង ២ ប្រការនេះ អ្នកដែលបានទទួលចំណែកបុណ្យប្រភេទដែលជាឧទ្ទិស្សិកបត្តិ កាលបានថ្លែងវាចាថា សាធុៗ ហើយ ក៏បានទទួលផលមួយរំពេច ដូចជាពួកប្រេតដែលជាញាតិ របស់ព្រះបាទពិម្ពិសារ (តាំងតែអំពី ៩២ កប្បមុន) កាលព្រះបាទពិម្ពិសារ បានកសាងវត្តវេឡុវនារាម ថ្វាយចំពោះព្រះសម្មាសម្ពុទ្ធ ព្រះមហាក្សត្រមិនបានបែងចែកចំណែកបុណ្យ ដោយចំពោះឲ្យដល់ពួកប្រេតទាំងនោះឡើយ ត្រឹមតែទ្រង់ផ្សាយទៅ ដោយមិនចំពោះប៉ុណ្ណោះ ដូច្នោះពួកប្រេតទាំងនោះ ទើបបាននាំគ្នាបញ្ចេញ

សំឡេងស្រែកយំ សុំចំពោះព្រះមហាក្សត្រ លុះព្រឹកស្អែកឡើង ព្រះមហាក្សត្រ ក៏ប្រញាប់ស្តេចទៅគាល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ក្រាបទូលសួរដល់រឿងដែលបានជួបប្រទះមកនោះ ចំពោះព្រះសម្មាសម្ពុទ្ធ ។

ព្រះអង្គទើបសម្តែងប្រាប់ថា ជាសំឡេងរបស់ប្រេតដែលជាញាតិ មកស្រែកសុំចំណែកបុណ្យ ព្រោះព្រះអង្គមិនបានឧទ្ទិសចំណែកបុណ្យទាំងពួង ដែលទ្រង់បំពេញឲ្យដល់គេដោយចំពោះឡើយ គេទាំងនោះ បានតាំងចិត្តរងចាំដើម្បីនឹងបានទទួលចំណែកបុណ្យ អំពីព្រះអង្គ មកអស់រយៈពេលយូរលង់ហើយ ។ ដូច្នោះ ព្រះបាទពិម្ពិសារ ទើបទ្រង់បានចាត់ការធ្វើបុណ្យឡើងថ្មីទៀតជាគ្រាទី ២ ហើយ ទ្រង់បានចែកចំណែកបុណ្យនោះ ឲ្យដល់ប្រេតទាំងនោះ ដោយចំពោះចំណែកពួកប្រេតទាំងឡាយ កាលបានទទួលចំណែកបុណ្យពីព្រះបាទពិម្ពិសារ ដែលទ្រង់ចែកឲ្យដោយចំពោះហើយ ទើបនាំគ្នាបញ្ចេញវាចាថា សាធុៗៗ ផលបុណ្យ ក៏ប្រាកដកើតឡើងមួយរំពេច ដោយបានទទួលអាហារមកបរិភោគសម្រាលសេចក្តីស្រេកឃ្លាន ដែលលំបាកមកអស់រយៈពេល

ជាយូរលង់ (ទើបតែបានបរិភោគក្នុងខណៈនោះឯង ។ នេះជាផលដែលបានទទួលដោយប្រាកដជាក់ អំពីការចែកចំណែកបុណ្យដោយចំពោះ ។

សម្រាប់អ្នកដែលបានទទួលចំណែកបុណ្យ ប្រភេទដែលជាអនុទ្ទិស្សិកបត្តិនោះ មិនបានទទួលផលប្រាកដជាក់ក្នុងមួយរំពេច ដូចអ្នកដែលបានទទួលចំណែកបុណ្យ ប្រភេទឧទ្ទិស្សិកបត្តិនោះទេ តែទោះជាយ៉ាងណាក៏ដោយ អានិសង្សនៃការអនុមោទនា ចំណែកបុណ្យប្រភេទអនុទ្ទិស្សិកបត្តិ របស់ពួកប្រេតទាំងឡាយ ក៏មិនសាបសូន្យទៅទេ, ចំពោះការទទួលចំណែកបុណ្យប្រភេទដែលជាអនុទ្ទិស្សិកបត្តិ វេលាណា វេលានោះ ការអនុមោទនាចំណែកបុណ្យប្រភេទដែលជាអនុទ្ទិស្សិ-កបត្តិនេះ ក៏ចូលរួមជួយឧបត្ថម្ភ ការអនុមោទនាប្រភេទដែលជាឧទ្ទិស្សិកបត្តិ ឲ្យមានកម្លាំងខ្លាំងឡើងក្នុងខណៈនោះ ។

តាមដែលពោលមកហើយនេះ សំដៅដល់អ្នកដែលបានស្លាប់ទៅហើយ ក៏បានទៅកាន់កំណើតដែលជាបរទត្តូ-បជីវិកប្រេតមួយពួក វិនិបាតអសុរនិងវេមានិកប្រេត ដែលជាពួកទេវតាជាន់ទាប ក្នុងចាតុម្មហារាជិកាភូមិមួយទៀតប៉ុណ្ណោះ

សម្រាប់ក្នុងពួកមនុស្សផងគ្នានេះ មានការអនុមោទនាចំណែកបុណ្យ ប្រភេទដែលជាឧទ្ទិស្សិកបត្តិ ឬអនុទ្ទិស្សិកបត្តិដូចគ្នា តែផលដែលបានទទួលនោះ មិនមែនជារបស់របរ មាស ប្រាក់ អាហារ បរិភោគ ទីនៅអាស្រ័យ ដូចគ្នានឹងពួកប្រេត ដែលបានទទួលនោះទេ ត្រឹមតែបានទទួលផល គឺមានចិត្តសុខសប្បាយ មិនក្តៅក្រហាយ មុខមាត់ស្រស់បស់មិនស្រអាប់ប៉ុណ្ណោះ (នឹងត្រូវទទួលផលជាសេចក្តីសុខ ក្នុងបរលោក ឬក្នុងបច្ចុប្បន្នក៏មាន) ។

## ៧.៣ វិធីចែកបុណ្យប្រភេទឧទ្ទិស្សិកបត្តិ

សម្រាប់វិធីចែកបុណ្យ ប្រភេទឧទ្ទិស្សិកបត្តិ មានវិធីចែកដូច្នេះ ថា "ឥទំ មេ បុញ្ញំ មាតាបិតុអាចរិយ-ញាតិមិត្តសម្ពហានំ ទេមិ : សូមឧទ្ទិស្សការធ្វើបុណ្យដែលទាក់ទងនឹងទាន សីល ភាវនា របស់ខ្ញុំម្ចាស់នេះ ឲ្យដល់មាតាបិតា គ្រូ អាចារ្យ ញាតិ មិត្ត ដែលស្លាប់ទៅហើយ ឬដែលនៅមានជីវិតនោះផង ។

## ៧.៤ វិធីចែកបុណ្យប្រភេទអនុទ្ទិស្សិកបត្តិ

សម្រាប់វិធីចែកបុណ្យប្រភេទអនុទ្ទិស្សិកបត្តិ មានវិធីចែកដូច្នេះថា "ឥទំ មេ បុញ្ញំ សព្វសត្តានំ ទេមិ : សូមឧទ្ទិស្សការធ្វើបុណ្យដែលទាក់ទងនឹងទាន សីល ភាវនា របស់ខ្ញុំម្ចាស់នេះ ឲ្យដល់សព្វសត្វទាំងពួងទាំងឡាយ ។

ចេតនាជាហេតុអនុមោទនា សូម្បីរបស់ពួកប្រេតទាំងឡាយ រមែងជាគុណជាតិឲ្យផលក្នុងខណៈនោះបាន, មិនបាច់ពោលថ្វីដល់ចេតនាដែលជាហេតុអនុមោទនា របស់មនុស្សឡើយ ។

ក្នុងសេចក្តីនេះ មានរឿងទាំងនេះ (ជាឧទាហរណ៍) ។

## ៧.៥ រឿងឧបាសកម្នាក់

បានឮមកថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ មានឧបាសកម្នាក់ ជាសោតាបន្ន បានចុះទូកជាមួយនឹងកុដុម្ពីកជាងកាត់សក់ម្នាក់ ។ ក្នុងថ្ងៃទី ៧ នាវា ក៏បានគៀងនៅត្រង់កណ្តាលនៃសមុទ្រ ។ ជនទាំងពីរនាក់នោះឯង ដេកលើបន្ទះ

ក្តារមួយហើយ ក៏ទៅដល់កោះមួយ បណ្តាជនទាំងពីរនាក់នោះ ជាងកាត់សក់ សម្លាប់សត្វទាំងឡាយហើយ អាំងស៊ីឲ្យដល់ឧបាសកខ្លះ ឧបាសក ពោលថា "ខ្ញុំគ្រប់គ្រាន់ហើយ" ដូច្នោះ មិនបរិភោគ ហើយគិតថា "ក្នុងទីនេះ ក្រៅពីត្រៃសរណៈចេញហើយ ទីពឹងដទៃរបស់អាត្មាអញ មិនមានឡើយ" ។ កាលបើឧបាសកនោះ រលឹកនូវគុណនៃព្រះរតនត្រ័យយ៉ាងនេះ, ស្តេចនាគរាជ ក៏កើតឡើងហើយក្នុងកោះនោះ និម្មិតសរីរៈរបស់ខ្លួន ធ្វើជាទូកយ៉ាងធំពេញដោយរតន ៧ ប្រការ ។

សមុទ្រទេវតា បានជាអ្នកកាច់ចង្កូតទូក ឋិតនៅលើទូកស្រែកប្រកាសថា "បុគ្គលអ្នកទៅកាន់ជម្ពូទ្វីប មានដែរឬទេ ?"

ឧបាសក ប្រាប់ថា "យើងទាំងឡាយនឹងទៅ" កាលបើទេវតាពោលថា "ចូរអ្នកឡើងទូកចុះ" ដូច្នេះ កំពុងតែឡើងទូកបានហៅជាងកាត់សក់ "ឲ្យឡើងទូកផង" ។ ទេវតាពោលថា "បុគ្គលនោះមិនមានគុណ គឺ សីល និងមារយាទឡើយ ព្រោះហេតុនោះ បុគ្គលនោះ ជាអ្នកមិនគួរដើម្បីនឹងចុះទូកនេះទេ" ។ ឧបាសកពោលថា "ហេតុនោះ ចូរស្មេសសិនចុះ ខ្ញុំនឹងឲ្យនូវចំណែកបុណ្យអំពីទាន ដែលខ្លួនខ្ញុំបានឲ្យហើយ ពីសីលដែល

ខ្ញុំបានរក្សាហើយ និងអំពីការនាដែលខ្ញុំអប់រំហើយ ដល់បុរសនុ៎ះ”, ជាងកាត់សក់ពោលថា “ខ្ញុំសូមអនុមោទនា” ។ ក្នុងពេលនោះ ទេវតាឲ្យបុរសនោះឋិតនៅលើទូក ហើយបាន អុំទូកនោះ សំដៅទៅទីក្រុងពារាណសី ញុំាងទ្រព្យឲ្យតាំងនៅ ក្នុងផ្ទះនៃជនទាំងពីរនាក់នោះស្រេចហើយ ក៏បានត្រឡប់ទៅ កាន់វិមានរបស់ខ្លួនវិញ ។

(អដ្ឋកថា សីលានិសង្សជាកត ក្នុងចតុត្ថវគ្គ ទុកនិបាត)

## ៧.៦ រឿងសង្ខព្រាហ្មណ៍

ក្នុងអតីតកាល ទីក្រុងពារាណសី មានឈ្មោះថា មោលិនី ។ ក្នុងកាលនោះ ព្រះពោធិសត្វបានជាព្រាហ្មណ៍ នាមថា **សង្ខ** ក្នុងទីក្រុងមោលិនី ទៅដើម្បីលក់ដូរតាមទូក បានជួបនឹងព្រះបច្ចេកពុទ្ធជាម្ចាស់មួយព្រះអង្គ ក្នុងចន្លោះផ្លូវ លោកកំពុងតែជាន់នូវផែនដីដ៏ក្តៅធំ ដូចជារងើកភ្លើង ព្រោះ ខ្យល់និងកំដៅថ្ងៃដ៏ក្តៅពន្លឹក និមន្តមក មានចិត្តត្រេកអរថា “ស្រែបុណ្យ របស់អាត្មាអញមកដល់ហើយ” ទើបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គពាក់ស្បែកព្រះបាទនេះ

ហើយបាំងឆត្រ និមន្តទៅ" ដូច្នេះហើយ ក៏ប្រគេនឆត្រ និង ស្បែកព្រះបាទ ហើយទៅកាន់កំពង់ ហើយចុះទូក ។ ក្នុងថ្ងៃ ទី៧ នាវាបានគៀងហើយ ព្រះពោធិសត្វបាននាំបុរសជា ឧបដ្ឋាកម្នាក់ទៅ យកប្រេងលាបពេញទាំងសរីរៈហើយ បរិភោគ លំអិតជុំស្ករ ជាមួយនឹងទឹកដោះរាវ តាមត្រូវការ ហើយ ឲ្យបុរសឧបដ្ឋាកបរិភោគផងហើយ ឡើងកាន់កំពូលនៃ សសរក្តោងជាមួយនឹងបុរសឧបដ្ឋាកនោះ លោតផ្លោះឡើង ធ្លាក់ទៅក្នុងទីបំផុតប្រមាណ ១ ឧសភ ប្រារព្ធដើម្បីនឹងឆ្លង (សមុទ្រ) ។ កាលបើឧបាសកនោះ កំពុងតែឆ្លង (សមុទ្រ) នោះឯង ៧ ថ្ងៃ កន្លងទៅហើយ ។ គ្រានោះ នាងទេវធីតា ឈ្មោះថា **មណីមេខលា** ដែលថែរក្សានូវសមុទ្រ ប្រាថ្នា នឹងជួយស្រង់ព្រះពោធិសត្វ ទើបនិម្មិតនាវាសម្រេចដោយ រតនៈ ពេញទៅដោយរតនៈ ៧ ប្រការ លើកពរ ព្រះពោធិសត្វនោះដាក់លើនាវា មិនឲ្យក្រឡេក មើលបុរស ជាឧបដ្ឋាកឡើយ ។ ព្រះពោធិសត្វ បានឲ្យចំណែកបុណ្យ អំពីកល្យាណកម្ម ដែលខ្លួនបានធ្វើហើយដល់ឧបដ្ឋាកនោះ ។ ឧបដ្ឋាកនោះ អនុមោទនាហើយនូវចំណែកបុណ្យនោះ ។ គ្រា

*នោះ ទេវតាបានឲ្យឧបដ្ឋាកនោះឋិតនៅលើនាវា នាំនាវានោះ ឆ្ពោះទៅកាន់ទីក្រុងមោលិនី ញុំាងទ្រព្យឲ្យតាំងនៅលើផ្ទះ របស់ព្រះពោធិសត្វហើយ ក៏បានវិលទៅកាន់វិមាន របស់ខ្លួនវិញភ្លាម ។*

*(រឿងនេះ លោកពោលហើយក្នុងអដ្ឋកថា*
*សង្ខព្រាហ្មណ៍ជាតក ក្នុងទសកនិបាត)*

*ព្រោះហេតុដូច្នោះ ចេតនាជាហេតុអនុមោទនា រមែងជាគុណជាតិឲ្យផលក្នុងខណៈនោះបាន ។*

## ៧.៧ វិហារវិមាន

*(ព្រះអនុរុទ្ធត្ថេរសួរថា) ម្នាលទេវធីតា នាងមានសម្បុរដ៏រុងរឿង ។ល។ ដូចផ្កាយព្រឹក កាលដែលនាងកំពុងរាំនោះ សំឡេងទិព្វទាំងឡាយ គួរស្តាប់ គួររីករាយនៃចិត្ត រមែងលាន់ឮអំពីអវយវៈតូចធំដោយសព្វគ្រប់ កាលដែលនាងកំពុងរាំនោះ ក្លិនទិព្វទាំងឡាយ មានក្លិនក្រអូប ជាទីរីករាយនៃចិត្ត រមែងផ្សាយចេញអំពីអវយវៈតូចធំ ដោយសព្វគ្រប់ កាលនាងងាកកាយ គ្រឿងប្រដាប់ទាំងឡាយឮដ៏ផ្ទួនសក់ ក៏ឮសូរគឹកកង ដូចតូរ្យតន្ត្រីប្រកប*

ដោយអង្គ ៥ គ្រឿងប្រដាប់ត្រចៀក ត្រូវខ្យល់បក់មកប៉ះ ក៏កម្រើក ដោយខ្យល់ ឮសូរគឹកកង ដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ផ្កាកម្រងណា ឮដ៏សិរ្យៈរបស់នាង មានក្លិនក្រអូប ជាទីរីករាយនៃចិត្ត (ក្លិនផ្កាកម្រងនោះ) រមែងផ្សាយទៅសព្វទិស ដូចដើមឱទ្បោក នាងតែងជំក្លិនក្រអូបនោះ តែងឃើញរូប ដែលមិនមែនជារបស់មនុស្ស ម្នាលទេវតា អាត្មាសួរហើយ នាងចូរប្រាប់នេះជាផលនៃកម្មអ្វី ។

(ទេវតាឆ្លើយថា) បពិត្រព្រះអនុរុទ្ធដ៏ចម្រើន (នាងវិសាខា) ជាសំឡាញ់របស់ខ្ញុំ បានឲ្យជាងធ្វើមហាវិហារ ទៀបក្រុងសាវត្ថី ឧទ្ទិសចំពោះសង្ឃ ខ្ញុំជ្រះថ្លា រីករាយ ចំពោះវិហារនោះ ព្រោះឃើញនូវផ្ទះគឺវិហារ ជាទីស្រឡាញ់នោះ ទើបវិមានដែលខ្ញុំបានហើយ **ដោយអនុមោទនា** ដ៏បរិសុទ្ធនោះឯង ជាវត្ថុអស្ចារ្យ គួររមិលមើល ក៏ខ្ពស់ទៅឮដ៏អាកាស អស់ ១៦ យោជន៍ជុំវិញ ដោយបុញ្ញរិទ្ធិនៃខ្ញុំ ផ្ទះកំពូល ជាលំនៅរបស់ខ្ញុំ ដូចគេចែកដោយចំណែកស្មើគ្នា រុងរឿងភ្លឺទូទៅ អស់ ១០០ យោជន៍ជុំវិញ ឯស្រះបោក្ខរណីទាំងឡាយរបស់ខ្ញុំ ក្នុងទីនេះ ដែលពួកត្រីទិព្វនៅអាស្រ័យហើយ មានទឹករងថ្លា ក្រាលដោយខ្សាច់មាស ដេរដាសដោយឈូកផ្សេងៗ ឆ្លុកដោយឈូកសទាំងឡាយ មានក្លិនក្រអូប ជាទីគាប់ចិត្ត ដែលខ្យល់បក់

ផ្សាយទៅ ដើមព្រីង ខ្នុរ ត្នោត ដូង ព្រៃ និងឈើផ្សេងៗ ទាំងឡាយ ដុះជិតលំនៅខាងក្នុង មិនបាច់ដាំឡើយ (វិមាននោះ) សឹងវង់ដោយតូរ្យតន្ត្រីផ្សេងៗ គឹកកងដោយពួកស្រីអប្សរ ទោះជនណាឃើញខ្ញុំ ក្នុងការយល់សប្តិ ជននោះឯង គង់ត្រេកអរ វិមានបែបនេះ ជាទីអស្ចារ្យ គួររមិលមើល ភ្លឺព្រោងព្រាត ដោយសព្វគ្រប់ កើតឡើងដោយបុញ្ញកម្មទាំងឡាយរបស់ខ្ញុំ បុគ្គលគួរធ្វើនូវបុណ្យទាំងឡាយ ។

(ព្រះអនុរុទ្ធត្ថេរសួរថា) វិមានដែលនាងបានហើយ **ដោយអនុមោទនា** ដ៏បរិសុទ្ធនោះឯង ជាទីអស្ចារ្យ គួររមិលមើលម្យ៉ាងទៀត នារីណា បានឲ្យនូវទាន នាងចូរប្រាប់នូវគតិរបស់នារីនោះ តើទៅកើតក្នុងទីណា ។

(ទេវតាឆ្លើយថា) បពិត្រលោកដ៏ចម្រើន ស្រីសំឡាញ់របស់ខ្ញុំណា បានឲ្យជាងធ្វើមហាវិហារដើម្បីសង្ឃ ស្រីសំឡាញ់នោះ (គឺនាងវិសាខា) ជាស្រីមានធម៌ ដឹងច្បាស់ បានឲ្យទានហើយបានទៅកើតក្នុងទេវលោក ជាន់និម្មានរតី បានជាបជាបតីនៃទេវរាជឈ្មោះសុនិម្មិត លោកម្ចាស់សួររកនូវនារីណាថា នារីនោះទៅកើតក្នុងទីណា ផលនៃកម្មរបស់នារីនោះ មិនគប្បីគិតឡើយ ។

*បពិត្រលោកដ៏ចម្រើន ខ្ញុំបានដោះស្រាយ តាមសេចក្តីពិតមិនប្រែប្រួល ព្រោះហេតុនោះ លោកម្ចាស់ចូរបបួលពួកជនដទៃថា អ្នកទាំងឡាយ ចូរត្រេកអរឲ្យទានចំពោះសង្ឃផង អ្នកទាំងឡាយ ចូរមានចិត្តជ្រះថ្លា ស្តាប់ធម៌ផង ការបានអត្តភាពជាមនុស្សដែលគេកម្របានដោយងាយ អ្នកទាំងឡាយ ក៏បានហើយ ព្រះពុទ្ធ មានសំឡេងដូចព្រហ្ម មានព្រះចម្មាដូចមាស ជាអធិបតីក្នុងផ្លូវ បានសម្តែងនូវទានជាផ្លូវណា ទក្ខិណាទាន (ដែលបុគ្គលឲ្យហើយ) ចំពោះសង្ឃណា ជាទានមានផលច្រើន អ្នកទាំងឡាយចូរត្រេកអរឲ្យទានទាំងឡាយ(នោះ)ចំពោះសង្ឃ (នោះ)ចុះ ។ល។*

*(ចាកសុត្តន្តបិដក ភាគ៥៥ ទំព័រ៩១)*

## ៧.៨ រឿងប្រេតជាមាតានៃព្រះសារីបុត្ត

*ព្រះសាស្តា កាលទ្រង់ប្រថាប់នៅវត្តវេឡុវ័នមហាវិហារ ទ្រង់ប្រារព្ធនាងប្រេតមាតារបស់ព្រះសារីបុត្តត្ថេរ ដោយជាតិទី ៥ អំពីបច្ចុប្បន្នជាតិនេះ ទើបត្រាស់គាថានេះ មានពាក្យចាប់ផ្តើម ថា នគ្គា ទុព្វណ្ណរូបាសិ ដូច្នេះ ។*

ថ្ងៃមួយ ព្រះសារីបុត្រ ព្រះមហាមោគ្គល្លាន ព្រះអនុរុទ្ធ និងព្រះកប្បិន បាននៅក្នុងព្រៃមួយកន្លែង មិនឆ្ងាយពីក្រុងរាជគ្រឹះ ។ ក៏សម័យនោះឯង ក្នុងក្រុងពារាណសី មានព្រាហ្មណ៍ម្នាក់ ជាអ្នកមាំមួន មានទ្រព្យច្រើន មានភោគៈច្រើន ដូចជាអណ្ដូងទីផឹកស៊ីរបស់សមណព្រាហ្មណ៍ មនុស្សកំព្រា អ្នកធ្វើដំណើរ វណិពក និងយាចក បានឲ្យវត្ថុមានបាយ ទឹក សំពត់ និងទីដេកជាដើម និងកាលនឹងឲ្យ រមែងបដិបត្តិតាមសេចក្ដីពេញចិត្តគ្រប់យ៉ាង តាមលំដាប់របស់ការឲ្យ មានទឹកលាងជើង និងសំពត់ជូតជើងជាដើម តាមកាលនិងតាមសេចក្ដីសមរម្យ ដល់អ្នកដែលមកដល់ហើយៗ ។ ក្នុងវេលាមុនអាហារ បានអង្គាសភិក្ខុទាំងឡាយដោយបាយនិងទឹកជាដើម ដោយគោរព ។ លោកកាលនឹងទៅប្រទេសដទៃ ទើបពោលនឹងភរិយាថា "នាងដ៏ចម្រើន នាងកុំធ្វើទានវិធីនេះ តាមដែលបញ្ញត្តិឲ្យសាបសូន្យឡើយ ចូលទៅតាំងទុកដោយគោរព" ។ ភរិយាទទួលពាក្យហើយ លុះស្វាមីជៀសចេញទៅប៉ុណ្ណោះ ក៏គាត់ផ្ដាច់វិធីដែលបញ្ញត្តិទុកដើម្បីភិក្ខុទាំងឡាយជាលំដាប់ដំបូង តែកាលអ្នកដំណើរចូលទៅដើម្បីនៅអាស្រ័យ ក៏សម្ដែងសាលាចាស់ដែលចោល

ទុកខាងក្រោយផ្ទះ ដោយពាក្យថា “ពួកលោកចូរនៅក្នុងសាលានេះ” ។ កាលអ្នកដំណើរមកក្នុងទីនោះ ដើម្បីត្រូវការបាយ និងទឹកជាដើម ទើបពោលថា “ចូរស៊ីគូថ (លាមក) ផឹកមូត្រ (ទឹកនោម) ផឹកលោហិត (ឈាម) ស៊ីខួរបស់មាតាលោក” ហើយទើបបញ្ចុះឈ្មោះវត្ថុដែលមិនស្អាត គួរខ្ពើម ហើយ (ស្អោះទឹកមាត់) ពោលរឹងរូះ ។

សម័យតមក នាងធ្វើកាលកិរិយាហើយ ដែលអានុភាពកម្មបោះទៅ កើតក្នុងកំណើតប្រេត សោយទុក្ខដែលសមរម្យដល់វិចីទុច្ចរិតរបស់ខ្លួន ត្រឡប់រលឹកដល់សេចក្តីសម្ព័ន្ធគ្នា ក្នុងជាតិមុន មានសេចក្តីប្រាថ្នានឹងមកកាន់សំណាក់របស់ព្រះសារីបុត្ត ទើបដល់ទ្វារវិហារ ។ ទេវតាដែលស្ថិតនៅត្រង់ទ្វារវិហាររបស់ព្រះសារីបុត្តនោះ ហាម(មិនឲ្យ)ចូលវិហារ ។ បានឮថា នាងប្រេតនោះ ធ្លាប់ជាមាតារបស់ព្រះថេរៈ ក្នុងជាតិទី ៥ អំពីបច្ចុប្បន្នជាតិនេះ ។ ព្រោះដូច្នោះ នាងទើបពោលយ៉ាងនេះថា ខ្ញុំជាមាតារបស់លោកម្ចាស់សារីបុត្តត្ថេរ ក្នុងជាតិទី ៥ អំពីបច្ចុប្បន្នជាតិ សូមលោកចូរឲ្យខ្ញុំចូលទ្វារ ដើម្បីឃើញព្រះថេរៈ ។ ទេវតាបានស្តាប់ដូចនោះ ទើបអនុញ្ញាតឲ្យនាងចូលទៅ នាង

គ្រាចូលទៅហើយបានឈរក្នុងទីបំផុតទីចង្រ្កម សម្តែងខ្លួនដល់ព្រះថេរៈ ។ ព្រះថេរៈគ្រាបានឃើញនាងប្រេតនោះ ជាអ្នកមានចិត្តដែលសេចក្តីករុណាជាស់តឿន ទើបសួរដោយគាថាថា ៖

ម្នាលស្រីស្គម មានឆ្អឹងជំនីរគោម នាងជាស្រីអាក្រាត មានរូប មានសម្បុរអាក្រក់ក្រៃពេក មានខ្លួនស្គាំងស្គម មានខ្លួនរវាមដោយសរសៃ នាងជាអ្វីមកឈរនៅទីនេះ ។

នាងប្រេតនោះ ត្រូវព្រះថេរៈសួរ កាលនឹងឲ្យពាក្យតប ទើបបានពោលគាថា ៥ គាថា សេចក្តីថា ៖

អំពីមុនខ្ញុំជាមាតាបង្កើតរបស់លោក ក្នុងជាតិទាំងឡាយដទៃៗ មកកើតក្នុងកំណើតនៃប្រេត ពេញប្រៀបដោយសេចក្តីស្រេកឃ្លាន បរិភោគទឹកមាត់ ដែលគេស្តោះចោល ទឹកសម្បោរ ស្ទស្ទ ខ្ទាញ់រាវ (នៃសាកសព) ដែលគេដុត និងឈាមនៃស្រីទាំងឡាយដែលសម្រាលកូន និងឈាមនៃដំបៅនិងច្រមុះ និងក្បាលដាច់ មានសេចក្តីស្រេកឃ្លានគ្របសង្កត់ ខ្ញុំបរិភោគនូវខ្ទុះ និងឈាមដែលជាប់នឹងសរីរៈនៃស្រីនិងបុរស នូវខ្ទុះនិងឈាម នៃបសុសត្វ និងមនុស្សទាំងឡាយ ខ្ញុំមិនមានទីពឹង មិនមានទីលំនៅ ដេកតែលើទីស្មសាន ដូចគ្រែ លោកម្ចាស់ជាបុត្ត

សូមលោកម្ចាស់ឲ្យទានដើម្បីខ្ញុំ លុះឲ្យហើយ ចូរឧទ្ទិសផល ដល់ខ្ញុំ គិតធ្វើដូចម្តេចហ្ន៎ ឲ្យខ្ញុំគប្បីបានរួចអំពីការបរិភោគ នូវខ្ទុះនិងឈាម ។

ព្រះសារីបុត្តត្ថេរ បានស្តាប់ដូចនោះហើយ ក្នុងថ្ងៃទីពីរ ទើបហៅព្រះថេរៈ ៣ រូប មានព្រះមហាមោគ្គល្លានត្ថេរជាដើម មក ព្រមដោយព្រះថេរៈទាំងនោះ ត្រាច់ទៅបិណ្ឌបាតក្នុងក្រុង រាជគ្រឹះ បានទៅដល់ព្រះរាជនិវេសន៍របស់ព្រះបាទពិម្ពិសារ ។ ព្រះរាជាឃើញព្រះថេរៈហើយ ទើបសួរដល់ហេតុនៃការមកថា លោកម្ចាស់ លោកមកដើម្បីប្រយោជន៍អ្វី ? ព្រះមហាមោគ្គ-ល្លាន ទើបបានទូលរឿងនោះចំពោះព្រះរាជា ព្រះរាជាត្រាស់ថា ញោមដឹងហើយ ហើយទើបលះព្រះថេរៈ បង្គាប់ឲ្យហៅអមាត្យ អ្នកសម្រេចរាជការ ទ្រង់បញ្ជាថា អ្នកចូរសាងកុដិ ៤ ខ្នង ក្នុងទី នេះ ដែលបរិបូរណ៍ដោយម្លប់និងទឹក ដ៏វិចិត្រ មិនឆ្ងាយពីក្រុង និងក្នុងខាងក្នុងព្រះរាជវាំង ឲ្យបែងចែកជា ៣ ចំណែក ដោយ មានសេចក្តីពិសេស ត្រឹមតែល្មមហើយឲ្យទទួលកុដិ ៤ ខ្នង ។ និងព្រះអង្គឯង ក៏បានស្តេចទៅក្នុងទីនោះ ទ្រង់បានធ្វើព្រះរាជ-ករណីយកិច្ចដែលគួរធ្វើ ។ កាលកុដិសម្រេចហើយ ទើបឲ្យ

ត្រៀមពលីកម្មទាំងអស់ ចូលទៅតម្កល់បាយទឹក និងសំពត់ជាដើម និងគ្រឿងបរិក្ខារគ្រប់យ៉ាង ដែលសមគួរដល់ភិក្ខុសង្ឃ ដែលមកពីទិសទាំង ៤ មានព្រះពុទ្ធជាប្រធាន ហើយប្រគល់ថ្វាយវត្ថុទាំងអស់នោះ ចំពោះព្រះសារីបុត្តត្ថេរ ។ លំដាប់នោះ ព្រះថេរៈ បានថ្វាយវត្ថុទាំងអស់នោះ ចំពោះភិក្ខុសង្ឃដែលមកពីទិសទាំង ៤ មានព្រះពុទ្ធជាប្រធាន ឧទ្ទិសដល់នាងប្រេតនោះ ។ នាងប្រេតនោះ បានអនុមោទនាចំណែកបុណ្យនោះហើយ កើតក្នុងទេវលោក ជាអ្នកព្រមដោយវត្ថុដែលគួរប្រាថ្នាគ្រប់យ៉ាងក្នុងថ្ងៃតមក ក៏បានចូលទៅរកព្រះមហាមោគ្គល្លានត្ថេរ ថ្វាយបង្គំហើយឈរ ។ ព្រះថេរៈសាកសួរនាងប្រេតនោះ ។ នាងប្រេតនោះ បានពោលហេតុដែលខ្លួនចូលដល់ភាពជាប្រេត និងចូលដល់ភាពជាទេវតាទៀត។ ដោយហេតុនោះ លោកទើបពោលថា៖

ព្រះអគ្គសាវក មាននាមថា ឧបតិស្សៈ លុះបានស្តាប់ពាក្យនៃនាងប្រេត ជាមាតាហើយ មានចិត្តប្រកបដោយករុណា បានហៅព្រះមោគ្គល្លាន ១ ព្រះអនុរុទ្ធ ១ ព្រះកប្បិន ១ ឲ្យធ្វើនូវកុដិទាំងឡាយ ៤ ខ្នង ហើយវេរកុដិផង ឲ្យបាយនិងទឹកផង ចំពោះព្រះសង្ឃដែលមកអំពីទិសទាំង ៤ ហើយឧទ្ទិសទក្ខិណា-

ទាន ដល់មាតា ។ វិបាកក៏កើតឡើងក្នុងលំដាប់ដែលឧទ្ទិសហើយ ភោជនាហារ ទឹកផឹក និងសំពត់ (ក៏កើតឡើង) នេះជាផល នៃទក្ខិណាទាន លំដាប់នោះ (ស្រីនោះ មានរាងកាយ) ស្អាត មានសំពត់ស្លៀកពាក់ស្អាតបាត ទ្រទ្រង់នូវសំពត់ដ៏ឧត្តមជាងសំពត់ដែលកើតក្នុងដែនកាសី មានគ្រឿងវត្ថាករណៈដ៏វិចិត្រ បានចូលទៅរកព្រះកោលិតៈ ។

លំដាប់នោះ ព្រះមហាមោគ្គល្លាន សួរនាងប្រេតនោះថា៖

ម្នាលនាងទេវធីតា នាងមានសម្បុរល្អ មកឈរនៅ (ទីនេះ) ភ្លឺស្វាងទូទៅសព្វទិសទាំងឡាយ ដូចជាផ្កាយព្រឹក ឯសម្បុរប្រាជកដូច្នោះ កើតឡើងដល់នាង ដោយហេតុដូចម្តេច ផលនៃសុចរិត សម្រេចដល់នាងក្នុងទីនេះ ដោយហេតុដូចម្តេច បានជាភោគៈណានីមួយ ដែលជាទីពេញចិត្ត កើតឡើងដល់នាង ។

ម្នាលនាងទេវធីតា មានអានុភាពច្រើន យើងសូមសួរនាង នាងកាលកើតជាមនុស្ស តើបានធ្វើបុណ្យដូចម្តេច នាងជាទេវធីតា មានអានុភាពភ្លឺផ្លេកយ៉ាងនេះ ទាំងសម្បុរនាង ក៏ភ្លឺសព្វទិស ដោយបុញ្ញកម្មដូចម្តេច ។

*លំដាប់នោះ នាងប្រេតទើបតបដោយន័យមានជាដើមថា អំពីមុន ខ្ញុំជាមាតារបស់ព្រះសារីបុត្ត ។ ពាក្យដែលនៅសល់ មានន័យដូចពោលហើយនុ៎ះឯង ។*

*លំដាប់នោះ ព្រះមហាមោគ្គល្លានត្ថេរ បានក្រាបទូល រឿងនោះ ចំពោះព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុហើយ ទ្រង់សម្តែងធម៌ដល់ បរិស័ទដែលចូលដល់ព្រមហើយ ។ ទេសនានោះ បានមាន ប្រយោជន៍ដល់មហាជន ដូច្នោះឯង ។*

*ចប់ រឿងប្រេត ជាមាតានៃព្រះសារីបុត្ត ។*

*(ចាកអដ្ឋកថា បរមត្ថទីបនី)*

## ៧.៩ ការអនុមោទនាបុណ្យជាការប្រដៅចិត្តមួយផ្នែក

*ការអនុមោទនានូវបុណ្យកុសល ដែលអ្នកដទៃបានធ្វើ ឬបានជូន ក៏ជាការប្រដៅចិត្តមួយផ្នែក កុំឲ្យចិត្តរឹងរូស ប្រកាន់ ទិដ្ឋិ មានះលើកកំពស់ខ្លួន តែធ្វើឲ្យចិត្តទន់ភ្លន់ ស្ងប់ស្ងាត់ កំចាត់ការប្រកាន់ខ្លួន ឃើញបុណ្យកុសល ជាធំជាងទ្រព្យ សម្បត្តិ មាសប្រាក់ ក្នុងលោក ប្រដៅទូន្មានចិត្តឲ្យស្គាល់តម្លៃ*

នៃសេចក្ដីល្អ ចេះជ្រះថ្លាក្នុងបុណ្យកុសល របស់អ្នកដទៃ ឃើញអ្នកដទៃ មានសេចក្ដីល្អផ្សេងៗថា ជាអ្នកមានគុណ គឺមានគុណចំពោះខ្លួនយើងផង ចំពោះអ្នកដទៃច្រើនផង ចំពោះសាសនាផង កាលដែលអ្នកដទៃនោះ ជាអ្នកមានសទ្ធា មានសីល មានចាគៈជាដើម ត្រូវទូន្មានចិត្តឲ្យចេះដឹងគុណអ្នកដទៃ កុំបំភ្លេច កុំលុបបំបាត់ចោលនូវគុណ គឺសេចក្ដីល្អរបស់អ្នកដទៃ ព្រោះហេតុនោះ ចិត្តត្រូវតែយល់ដល់អំពើល្អគ្រប់យ៉ាង ដោយមិនប្រកាន់ឫកពាចើងម៉ើង ឆ្មើងឆ្មៃ មើលងាយ ឬឌឹងក្រោធជាមួយអ្នកដទៃឡើយ មនុស្សល្អម្នាក់ អាចឲ្យការរស់នៅ និងសេចក្ដីសុខដល់អ្នកដទៃច្រើននាក់ណាស់ក្នុងមួយថ្ងៃៗ ដូច្នេះ គួរប្រមូលមនុស្សល្អទាំងនោះ ឲ្យមកជាខ្លួនយើងតែម្នាក់ ដោយការអនុមោទនាជ្រះថ្លា ត្រេកអរនូវអំពើល្អ ដែលអ្នកដទៃមាន ជួនកាលអំពើល្អនោះ យើងមិនអាចធ្វើបានផង តើគួររីងរូស ឌឹងប្រកែកឈ្លោះ ឬក៏ត្រូវប្រដៅចិត្តឲ្យស្ងួត ហើយជ្រះថ្លាទទួលយកនូវបុណ្យ ដោយការអនុមោទនាវិញ ? ម្យ៉ាងវិញទៀត បើយើងសំឡឹងមើលគុណ គឺ សេចក្ដីល្អរបស់អ្នកដទៃ ហើយឲ្យតម្លៃយ៉ាងថ្លៃពិតៗ

រមែងកំចាត់នូវចិត្តអាក្រក់របស់យើង មានការមើលងាយអ្នកដទៃ ដោយអាងទ្រព្យសម្បត្តិ វង្សត្រកូលជាដើមទៀតផង ។

## ៨.ធម្មស្សវនមយៈ

ធម្មស្សវន សម្តែងវចនត្ថៈថា ៖

"ធម្មំ សុណន្តិ ឯតេនាតិ ធម្មស្សវនំ" ជនទាំងឡាយ រមែងស្តាប់ធម៌ដោយធម្មជាតិនោះ ដូច្នោះ ធម្មជាតិដែលជាហេតុនៃការស្តាប់នោះ ឈ្មោះថា **ធម្មស្សវនៈ** បានដល់ចេតនានៅក្នុងមហាកុសលចិត្តុប្បាទ ដែលមានយោនិសោ-មនសិការៈជាប្រធាន ។

មួយទៀត ការស្តាប់ធម៌នេះ ក៏មាន ២ ប្រការ គឺ ការស្តាប់ធម៌ ដែលអ្នកស្តាប់បានប្រារព្ធឡើងខាងក្នុងចិត្តថា កាលយើងបានស្តាប់ធម៌រឿយៗហើយ ជនទាំងឡាយនឹងដឹងថា យើងជាអ្នកមានសទ្ធា ក៏នាំគ្នាសរសើរ ឃើញថា យើងនេះជាអ្នកមានចិត្តគំនិតល្អ មានសទ្ធាពិត ការស្តាប់ធម៌យ៉ាងនេះ

រមែងមានផល មានអានិសង្សតិច ។ សម្រាប់ការស្តាប់ធម៌ដែលមានការប្រារព្ធក្នុងចិត្តថា ការស្តាប់ធម៌នោះ ជាសេចក្តីល្អ ធ្វើឲ្យចិត្តទន់ភ្លន់ ប្រាថ្នាប្រយោជន៍ មានយោនិសោមនសិការថា នេះជាឧបាយឲ្យបានបំពេញប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ ពិតប្រាកដ នេះជាបុញ្ញកិរិយាវត្ថុដែលសម្រេចដោយការស្តាប់ធម៌, នាំឲ្យមានសតិបញ្ញា ដឹងបាប ដឹងបុណ្យ គុណទោស ប្រយោជន៍ មិនមែនប្រយោជន៍ ធ្វើឲ្យចិត្តសប្បាយរីករាយ ថ្លាបរិសុទ្ធ មានចេតនាករុណាចំពោះអ្នកសម្តែង អ្នកបង្រៀន បោះបង់ចោលនូវការទម្លាប់ដែលជាទោស មិនមែនប្រយោជន៍ចេញបាន ការស្តាប់ធម៌ដែលមានការប្រារព្ធយ៉ាងនេះ ជាការស្តាប់ដែលមានផលច្រើន មានអានិសង្សច្រើន ចាត់ជាធម្មស្សវនកុសលយ៉ាងពិតប្រាកដ សមដូចព្រះមហាពុទ្ធឃោសាចារ្យ សម្តែងទុកក្នុងអដ្ឋសាលិនីអដ្ឋកថាថា ៖

"ឯកោ សុណន្តោ ឥតិ មំ សទ្ធោតិ ជានិស្សន្តីតិ សុណាតិ, តំ ន មហប្ផលំ ។ ឯកោ ឯវំ មេ មហប្ផលំ ភវិស្សតីតិ ហិតផរណេន មុទុចិត្តេន ធម្មំ

សុណាតិ, ឥទំ សវនមយំ បុញ្ញកិរិយាវត្ថុ នាម" ។ អ្នកណាមួយស្ដាប់ធម៌ ដោយប្រារព្ធថា ជនទាំងឡាយ រមែងចូលចិត្តចំពោះយើងថា យើងនេះពេញចិត្តការស្ដាប់ធម៌ ជាអ្នកមានសទ្ធាពិត ការស្ដាប់ធម៌ដែលមានការប្រារព្ធដូច្នេះ រមែងមានផលតិច ។ អ្នកណាមួយស្ដាប់ធម៌ ដោយប្រារព្ធថា "ការស្ដាប់ធម៌នេះ នឹងមានផលច្រើន មានអានិសង្សច្រើនដល់យើង និងជាប្រយោជន៍ដ៏ធំទូលាយដល់យើង ចិត្តគំនិតយើងក៏ទន់ភ្លន់ មានចេតនាទូលាយ ឬមានចិត្តល្អចំពោះអ្នកសម្ដែង ការស្ដាប់ធម៌ ដែលមានការប្រារព្ធព្រមដោយអាការរបស់ចិត្ត ក៏ដូច្នេះ ការស្ដាប់ធម៌យ៉ាងនេះ បានឈ្មោះថាបុញ្ញកិរិយាវត្ថុ ដែលជាធម្មស្សវនមយៈ ពិតមែន ។

## ៨.១ ការស្ដាប់ធម៌តាមកាលជាមង្គល

បទបាលីថា កាលេន ធម្មស្សវនំ ការស្ដាប់នូវធម៌តាមកាលជាមង្គលដ៏ឧត្ដម ព្រោះបាលីថា ៖

កាលេន ធម្មស្សវនំ នាម យស្មឹ កាលេ ឧទ្ធច្ចសហគតំ ចិត្តំ ហោតិ កាមវិតក្កាទីនំ វា

អញ្ញតរេន អភិក្កន្តំ តស្មិំ កាលេ តេសំ វិនោទនត្ថំ ធម្មស្សវនំ : *ការស្តាប់នូវធម៌តាមកាល ដើម្បីប្រយោជន៍ដល់កិរិយាបន្ទោបង់នូវកាមវិតក្កៈទាំងឡាយនោះ ចិត្តដែលប្រព្រឹត្តទៅមួយអន្លើដោយសេចក្តីរាយមាយ មានក្នុងកាលឯណា ដែលវិតក្កៈទាំងឡាយ មានកាមវិតក្កៈជាដើមណាមួយគ្របសង្កត់ហើយ ក្នុងកាលនោះ បានស្តាប់ធម៌ក្នុងកាលនឹងបន្ទោបង់នូវកាមវិតក្កៈជាដើមបាន ឈ្មោះថា* កាលេន ធម្មស្សវនំ ។

*បទបាលីថា* កាមប្បដិសំយុត្តោ វិតក្កោ កាម-វិតក្កោ : *សេចក្តីត្រិះរិះប្រកបព្រមចំពោះហើយដោយកាម ឈ្មោះថា កាមវិតក្កៈ,* ព្យាបាទប្បដិសំយុត្តោ វិតក្កោ ព្យាបាទវិតក្កោ *សេចក្តីត្រិះរិះប្រកបព្រមចំពោះហើយដោយព្យាបាទ ឈ្មោះថា ព្យាបាទវិតក្កៈ,* វិហឹសាបដិសំយុត្តោ វិតក្កោ វិហឹសាវិតក្កោ : *វិតក្កៈគឺសេចក្តីត្រិះរិះប្រកបដោយសេចក្តីបៀតបៀនសត្វ ឈ្មោះថា វិហឹសាវិតក្កៈ ។*

*ក្នុងពាក្យនេះថា* កាមប្បដិសំយុត្ត *កាមទាំងឡាយ ២*

យ៉ាងគឺ វត្ថុកាម ១ កិលេសកាម ១ ។ បណ្តាកាមទាំង ២ យ៉ាងនោះ គប្បីប្រកបសេចក្តីថា សេចក្តីត្រិះរិះដែលប្រកបព្រមដោយកាមទាំងឡាយ ដោយអំណាចកិរិយាធ្វើឲ្យជាអារម្មណ៍ ក្នុងផ្នែកនៃវត្ថុកាម (បាត់ជាវត្ថុកាមវិតក្ក), ប៉ុន្តែក្នុងផ្នែកនៃកិលេសកាម សេចក្តីត្រិះរិះដែលប្រកបព្រមដោយកាមដោយអំណាចការមកជួបប្រទះ (បាត់ជាកិលេសកាមវិតក្ក) ។

ព្រោះហេតុនោះហើយ បានជាព្រះសព្វញ្ញុពុទ្ធ ទ្រង់ត្រាស់បង្គាប់ឲ្យស្តាប់ធម៌តាមកាល ជាហេតុមិនឲ្យធ្លុះធ្លាយសិក្ខាបទណាមួយផង ធ្វើចិត្តឲ្យឡើងកាន់អរិយធម៌ដ៏ប្រសើរផង ។

ការស្តាប់ធម៌តាមកាល គឺ បញ្ចមី អដ្ឋមី ចាតុទ្ទសី បុណ្ណមីជាដើម ។ មួយទៀត បុគ្គលចូលទៅរកកល្យាណមិត្រទាំងឡាយ ហើយអាចដើម្បីនឹងស្តាប់ធម៌ ដែលបន្ទោបង់ការសង្ស័យរបស់ខ្លួនចេញបាន ក្នុងកាលណា, ការស្តាប់ធម៌សូម្បីក្នុងកាលនោះ គប្បីជ្រាបថា **ការស្តាប់ធម៌តាមកាល** ។

ចំណែកក្នុងអដ្ឋកថា គិលានសូត្រ ក្នុងតិកានិបាត អង្គុត្តរនិកាយ លោកពោលថា "ការសម្តែងធម៌ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតហើយ ១ ខែ ៨ ដង" ។

*ឈ្មោះថា វារៈ ៨ ក្នុងអដ្ឋកថាគិលានសូត្រនោះ បានដល់ ថ្ងៃនៃបកតិឧបោសថ ៨ ថ្ងៃ គឺ ក្នុងជុណ្ហបក្ខ (ខាងខ្នើត) ៤ ថ្ងៃ គឺ ថ្ងៃទី ៥ ថ្ងៃទី ៨ ថ្ងៃទី ១៤ ថ្ងៃទី ១៥, ឯក្នុងកាឡបក្ខ (ខាងរនោច) ក៏ដូច្នោះដែរ គឺ ថ្ងៃទី ៥ ថ្ងៃទី ៨ ថ្ងៃទី ១៤ ថ្ងៃខែដាច់ ។*

* សួរថា តិថីទី ៥ មិនបានមកក្នុងបាលីទាំងពួង មិនមែនឬ ? ។ ឆ្លើយថា ពិតមែន ។ តែតិថីទី ៥ នោះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយ បានតាំងទុកហើយ ។*

*ព្រោះហេតុនោះ ការស្តាប់ធម៌ សូម្បីក្នុងថ្ងៃទាំងឡាយ ៨ នៃខែ ក៏ឈ្មោះថា ការស្តាប់ធម៌តាមកាល ដូច្នេះ ។*

*ការស្តាប់ធម៌តាមកាលនុ៎ះឯង ជាមង្គលដ៏ប្រសើរ ព្រោះហេតុនៃកិរិយាបាននូវគុណដ៏វិសេស មានប្រការផ្សេងៗ មានលះបង់នូវនីវរណៈផង បាននូវអានិសង្ស ៤ យ៉ាងផង ឲ្យបានសម្រេចកិរិយាអស់ទៅនៃអាសវៈកិលេសជាដើមផង ។*

*សមដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យណា ព្រះអរិយសាវក ធ្វើខ្លួនឲ្យប្រកបដោយប្រយោជន៍ ធ្វើទុកក្នុងចិត្ត កំណត់ដោយ*

ចិត្តទាំងពួង ផ្ទៀងសោតៈចាំស្តាប់ធម៌, ក្នុងសម័យនោះ នីវរណៈធម៌ទាំង ៥ រមែងមិនមានដល់ព្រះអរិយសាវកនេះ, ក្នុងសម័យនោះពោជ្ឈង្គ ៧ រមែងដល់នូវការចម្រើនពេញបរិបូរណ៍ ។

ព្រះពុទ្ធជាម្ចាស់សម្តែងទុកក្នុងចតុក្កង្គុត្តរ បញ្ចមវគ្គឈ្មោះសោតានុគតសូត្រថា សោតានុគតានំ ភិក្ខវេ ធម្មានំ វចសា បរិចិតានំ ម្នាលភិក្ខុទាំងឡាយ គឺភិក្ខុសន្សំហើយដោយពាក្យនៃធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅតាមផ្លូវញាណនៃត្រចៀក មនសានុបេក្ខិតានំ គឺភិក្ខុមើលហើយដោយចិត្តចាក់ធ្លុះចំពោះដោយបញ្ញា គឺ ទិដ្ឋិដ៏ល្អ ។

## ៨.២ អានិសង្សទាំងឡាយ ៤ ប្រការ នៃធម៌ដែលចូលទៅកាន់ត្រចៀករឿយៗ

(សុត្តន្តបិដក អង្គុត្តរនិកាយ លេខ១៤៣ ទំព័រ១០៧)

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ រៀននូវធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ធម៌ទាំងនោះ ជាសភាវៈចូលទៅកាន់

ត្រចៀករឿយៗនៃភិក្ខុនោះ ដែលបានចាំស្ទាត់រត់មាត់ ចូលចិត្ត ច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិបាន ។ ភិក្ខុនោះ ភ្លេចស្មារតី ធ្វើមរណកាលទៅ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ ចំណែកធម៌ទាំងឡាយ រមែងប្រាកដច្បាស់ដល់ភិក្ខុនោះ ដែលមានសេចក្តីសុខក្នុងទេវនិកាយនោះ ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិ ឈ្មោះថា ជាការយឺតយូរ [៦] ឯសត្វនោះ វេលាដល់នូវគុណវិសេស ក៏ឆាប់រហ័សជាងសតិនោះ ។

ម្នាលភិក្ខុទាំងឡាយ នេះ ជាអានិសង្សទី១ នៃធម៌ដែលចូលទៅកាន់ត្រចៀករឿយៗ ដែលបានចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិបាន រមែងកើតប្រាកដ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុរៀននូវធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ធម៌ទាំងនោះ ជាសភាវៈ ចូលទៅកាន់ត្រចៀករឿយៗនៃភិក្ខុនោះ ដែលបានចាំស្ទាត់រត់មាត់ ចូលចិត្ត

[៦] ស្មារតីដែលកើតឡើងមួយភ្លេច ទុកជាយឺតយូរ ឯសត្វដែលមានអានិសង្សធម៌ក្នុងខ្លួន វេលានឹងសម្រេចមគ្គផលបាន ឆាប់ជាងស្មារតីមួយភ្លេតនោះឯង ។

ច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិបាន ។ ភិក្ខុនោះភ្លេចស្មារតី ធ្វើមរណកាលទៅ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ ចំណែកនៃធម៌ទាំងឡាយ រមែងមិនសូវប្រាកដច្បាស់ដល់ភិក្ខុនោះ ដែលមានសេចក្ដីសុខក្នុងទេវនិកាយនោះ ។ ប៉ុន្តែ ជាអ្នកមានឫទ្ធិ ដល់នូវសេចក្ដីស្ទាត់ជំនាញខាងផ្លូវចិត្ត សម្ដែងធម៌ដល់ទេវបរិស័ទបាន ។ ទេវតានោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញ បានប្រព្រឹត្តព្រហ្មចរិយៈអំពីមុន ក្នុងធម្មវិន័យណា នេះគឺធម្មវិន័យនោះឯង ។

ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិ ឈ្មោះថាជាការយឺតយូរ សត្វនោះដល់នូវគុណវិសេស ក៏ឆាប់រហ័សជាងសតិនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសជាអ្នកឈ្លាសវៃ ខាងសំឡេងស្គរ បុរសនោះ ដើរទៅកាន់ផ្លូវឆ្ងាយបានឮសំឡេងស្គរ បុរសនោះ ក៏មិនមានសេចក្ដីសង្ស័យ ឬងឿងឆ្ងល់នឹងសំឡេងស្គរនោះថា សំឡេងស្គរមែន ឬមិនមែនសំឡេងស្គរទេ ដូច្នេះឡើយ បុរសនោះ គប្បីដល់នូវសេចក្ដីចូលចិត្តថា សំឡេងស្គរ ដោយពិត មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុរៀននូវធម៌ ក៏មានឧបមេយ្យដូច្នោះដែរ

ៗបេៗ ជាអ្នកដល់នូវគុណវិសេសឆាប់រហ័ស ។ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ២ នៃធម៌ដែលចូលទៅកាន់ត្រចៀករឿយៗ ដែលបុគ្គលចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិ រមែងកើតប្រាកដ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុរៀននូវធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ធម៌ទាំងនោះ ជាសភាវៈ ចូលទៅកាន់ត្រចៀករឿយៗនៃភិក្ខុនោះ ដែលបានចាំស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ ចាក់ធ្លុះដោយទិដ្ឋិបាន ។ ភិក្ខុនោះ ភ្លេចស្មារតីធ្វើមរណកាលទៅ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ ចំណែកនៃធម៌ទាំងឡាយ មិនប្រាកដច្បាស់ដល់ភិក្ខុនោះ ដែលមានសេចក្ដីសុខក្នុងទេវនិកាយនោះឡើយ ទាំងមិនមែនជាភិក្ខុមានឫទ្ធិ ដល់នូវសេចក្ដីស្ទាត់ជំនាញខាងផ្លូវចិត្ត ហើយសម្ដែងធម៌ដល់បរិស័ទបានឡើយ ។

គ្រាន់តែថា ទេវបុត្តអាចសម្ដែងធម៌ ដល់បរិស័ទបានប៉ុណ្ណោះ ។ ទេវបុត្តនោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញបានប្រព្រឹត្តព្រហ្មចរិយៈអំពីមុន ក្នុងធម្មវិន័យណានេះ គឺ

ធម្មវិន័យនោះឯង ។

ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិ ឈ្មោះថា ជាការយឺតយូរ សត្វនោះដល់នូវគុណវិសេស ក៏ឆាប់រហ័ស ជាងសតិនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុរសជាអ្នក ឈ្លាសវៃ នឹងសំឡេងស័ង្ខ បុរសនោះ ដើរទៅកាន់ផ្លូវឆ្ងាយ បានឮសំឡេងស័ង្ខ បុរសនោះ ក៏មិនមានសេចក្តីសង្ស័យ ឬ ងឿងឆ្ងល់នឹងសំឡេងស័ង្ខនោះថា សំឡេងស័ង្ខមែន ឬមិនមែន សំឡេងស័ង្ខទេ បុរសនោះ គប្បីដល់នូវសេចក្តីចូលចិត្តថា ជាសំឡេងស័ង្ខដោយពិត មានឧបមាយ៉ាងណា ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុរៀននូវធម៌ ក៏មានឧបមេយ្យដូច្នោះដែរ ។បេ។ ជាអ្នកដល់នូវគុណវិសេសឆាប់រហ័ស ។

ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ៣ នៃធម៌ដែល ចូលទៅកាន់ត្រចៀករឿយៗ ដែលបុគ្គលចាំស្ទាត់រត់មាត់ចូល ចិត្តច្បាស់លាស់ចាក់ធ្លុះដោយទិដ្ឋិ រមែងកើតប្រាកដ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុរៀននូវធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទានៈ ឥតិវុត្តកៈ ជាតកៈ អព្ភុតធម្មៈ វេទល្លៈ ធម៌ទាំងនោះ ជាសភាវៈចូលទៅកាន់

ត្រចៀករឿយៗនៃភិក្ខុនោះ ដែលបានចាំស្ទាត់រត់មាត់ចូលចិត្ត ច្បាស់លាស់ចាក់ធ្លុះដោយទិដ្ឋិ ។ ភិក្ខុនោះ ក៏ភ្លេចស្មារតីធ្វើមរណកាលទៅ រមែងចូលទៅកាន់ទេវនិកាយណាមួយ ។ ចំណែកនៃធម៌ទាំងឡាយ មិនប្រាកដច្បាស់ដល់ភិក្ខុនោះ ដែលមានសេចក្ដីសុខក្នុងទេវនិកាយនោះ ទាំងមិនមែនជាភិក្ខុមានឫទ្ធិដល់នូវសេចក្ដីស្ទាត់ជំនាញខាងផ្លូវចិត្ត ហើយសម្ដែងធម៌ដល់បរិស័ទបានឡើយ ។

ទាំងមិនមែនជាទេវបុត្ត អាចសម្ដែងធម៌ដល់ទេវបរិស័ទបានទេ ។ តែថា បើមានឱបបាតិកសត្វ រំលឹកនូវឱបបាតិកសត្វថា ម្នាលគ្នាយើង ពួកយើងបានប្រព្រឹត្តព្រហ្មចរិយៈអំពីមុនក្នុងធម្មវិន័យណា អ្នករលឹកបាននូវធម្មវិន័យនោះដែរឬ ។ ទេវបុត្តនោះ ក៏និយាយយ៉ាងនេះថា ម្នាលគ្នាយើង យើងរលឹកបាន ម្នាលគ្នាយើង យើងរលឹកបាន ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃសតិ ឈ្មោះថា ជាការយឺតយូរ សត្វនោះដល់នូវគុណវិសេស ក៏ឆាប់រហ័សជាងសតិនោះ ។

ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចសម្លាញ់ពីរនាក់ លេងអាចម៍ដីជាមួយគ្នា សម្លាញ់ទាំងពីរនាក់នោះ មកជួបគ្នាក្នុង

ទីណាមួយៗ សម្លាញ់ម្នាក់ក៏និយាយទៅនឹងសម្លាញ់ម្នាក់នោះ យ៉ាងនេះថា នែសម្លាញ់ ឯងរលឹកបាននូវហេតុនេះទេ ។ សម្លាញ់នោះ គប្បីតបយ៉ាងនេះថា នែសម្លាញ់ អញរលឹក បាន នែសម្លាញ់ អញរលឹកបាន មានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ ភិក្ខុរៀននូវធម៌ ក៏មានឧបមេយ្យដូច្នោះដែរ ។បេ។ ជាអ្នកដល់នូវគុណវិសេសឆាប់រហ័ស ។

ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សទី ៤ នៃធម៌ដែលចូលទៅកាន់ត្រចៀករឿយៗ ដែលបុគ្គលចាំស្ទាត់រត់មាត់ចូលចិត្តច្បាស់លាស់ចាក់ធ្លុះដោយទិដ្ឋិ រមែងកើតប្រាកដ ។

ម្នាលភិក្ខុទាំងឡាយ អានិសង្សទាំង ៤ នេះ នៃធម៌ដែលចូលទៅកាន់ត្រចៀករឿយៗ ដែលបុគ្គលចាំស្ទាត់រត់មាត់ចូលចិត្តច្បាស់លាស់ចាក់ធ្លុះដោយទិដ្ឋិ រមែងកើតប្រាកដ ។

## អដ្ឋកថាសោតានុគតសូត្រ

បទថា សោតានុគតានំ មានសេចក្ដីថា ដែលភិក្ខុផ្ទៀងសោតប្បសាទចុះហើយ កំណត់ដោយសោតៈ គឺញាណ ។

ពីរបទថា **អានិសំសា** **ចាដិកង្ខា** មានសេចក្ដីថា គុណានិសង្សដែលភិក្ខុនោះ គប្បីសង្ឃឹមបាន ។

ពីរបទថា ធម្មំ បរិយាបុណាតិ មានសេចក្តីថា រមែងសិក្សាធម៌ដែលជាបែបផែន ជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តា មានអង្គ ៩ មានសុត្តៈ គេយ្យៈ ជាដើម ។

បទថា សោតានុគតា បានដល់ ទៅតាមត្រចៀក គឺចូលកាន់ត្រចៀក ។ បទថា មនសានុបេក្ខិតា ប្រែថា ត្រួតមើលដោយចិត្ត ។

ពាក្យថា ចាក់ធ្លុះដោយបញ្ញា បទបាលីថា ទិដ្ឋិយា សុប្បដិវិទ្ធាតិ អត្ថតោ ច ការណតោ ច បញ្ញាយ សុដ្ឋុ បដិវិទ្ធា បច្ចក្ខីកតា : គឺបុគ្គលចាក់ធ្លុះដោយប្រពៃ គឺបុគ្គលធ្វើឲ្យជាក់ច្បាស់ហើយដោយបញ្ញា តាមអត្ថផង តាមហេតុផង ឈ្មោះថា ទិដ្ឋិយា សុប្បដិវិទ្ធា ។

ពាក្យថា មុដ្ឋស្សតិ កាលំ កុរុមានោ នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហើយ ព្រោះភាវៈជាអ្នកមិនមានសតិជាគ្រឿងនឹករលឹកនូវព្រះពុទ្ធវចនៈ ក៏ទេដែរ, តែព្រះអង្គទ្រង់ត្រាស់សំដៅយកកាលកិរិយារបស់បុថុជ្ជន ។ មែនពិត បុថុជ្ជនឈ្មោះថា ជាអ្នកភ្លេចភ្លាំងសតិ ធ្វើមរណកាល ។

បទថា ឧបបជ្ជតិ មានសេចក្ដីថា ស្ថិតនៅក្នុងសីល ដ៏បរិសុទ្ធ រមែងទៅកើតនៅក្នុងទេវលោក ។

បទថា ធម្មបទាបិលបន្តិ មានសេចក្ដីថា ធម៌គឺ ពុទ្ធវចនៈឯណា ដែលភ្លេចភ្លាំងដោយការទន្ទេញ គឺមិនបាន ចាំរត់មាត់ក្នុងកាលមុន របស់ភិក្ខុអ្នកមានសេចក្ដីសុខ ជាអ្នក កើតហើយក្នុងភពជាទីបំផុត, ធម៌ គឺពុទ្ធវចនៈទាំងអស់នោះ រមែងប្រាកដច្បាស់ គឺ រមែងជាក់ច្បាស់ បានដល់ ប្រាកដ យ៉ាងច្បាស់លាស់ ដូចជាស្រមោលក្នុងកញ្ចក់ដ៏ភ្លឺថ្លា ។

ពាក្យថា ទន្ធោ ភិក្ខវេ សតុប្បាទោ មានសេចក្ដីថា ការកើតឡើងនៃសតិ ជាគ្រឿងរលឹកដល់ព្រះពុទ្ធវចនៈនោះឯង យឺតយូរ គឺធូន់ ។ ពាក្យថា អថ សោ សត្តោ ខិប្បំយេវ វិសេសគាមី ហោតិ មានសេចក្ដីថា រមែងជាអ្នកទៅដល់ ព្រះនិព្វាន ។ ពាក្យថា ឥទ្ធិមា ចេតោវសិប្បត្តោ មានសេចក្ដី ថា ព្រះខីណាស្រពអ្នកដល់ព្រមដោយឫទ្ធិ ដល់នូវភាពជាអ្នក ស្ទាត់ជំនាញនៃចិត្ត ។ល។

ការស្តាប់ធម៌ រមែងជាហេតុឲ្យបានសម្រេចនូវអានិសង្ស ៤ ប្រការ ដោយប្រការដូច្នោះ ។ ក៏ជនទាំងឡាយ លុះបានស្តាប់ធម៌ហើយ ក៏សម្រេចធម៌ជាទីអស់ទៅនៃអាសវៈ គណនាត្រាប់ពុំបាន ។ ព្រោះហេតុនោះ អ្នកណាមួយ ក៏មិនគួរជាអ្នកខ្ជិលស្តាប់ធម៌ឡើយ ។

## ៨.៣ ធម្មស្សវនកថា កុក្កុដីវត្ថុ

មានសេចក្តីដំណាលថា ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះ-នាមថា **កកុសន្ធ** មានមេមាន់មួយ នៅជិតអាសនៈសាលា ។

មេមាន់នោះ បានស្តាប់នូវសំឡេងសូធ្យព្រះធម៌ របស់ភិក្ខុអ្នកចម្រើនវិបស្សនាមួយអង្គ កំពុងតែស្វាធ្យាយនូវវិបស្សនាកម្មដ្ឋាន ទើបកំណត់យកនិមិត្តក្នុងសំឡេងថា "**ធម្មោ ឯសោ** នុ៎ះជាធម៌" ដូច្នេះ ត្រូវសត្វក្លែង ១ សម្លាប់ច្យុតហើយ បានកើតជារាជធីតា ព្រះនាមថា **ឧព្វរី** បួសហើយក្នុងសំណាក់នៃនាងបរិព្វាជិកាទាំងឡាយ ។ ក្នុងកាលក្រោយមក នាងចូលទៅកាន់វច្ចកុដិ ឃើញហ្វូងដង្កូវ ហើយក៏បានញ៉ាំងបុឡុវកសញ្ញាឲ្យកើតឡើង បានសម្រេចបឋមឈានហើយ

លុះច្យុតចាកអត្តភាពនោះ ទៅកើតក្នុងព្រហ្មលោក, ច្យុតចាកព្រហ្មលោកនោះហើយ ក៏បានកើតក្នុងត្រកូលសេដ្ឋី, មិនយូរប៉ុន្មាន ក៏បានច្យុតិ ហើយទៅកើតជាកូនជ្រូកញី ក្នុងនគររាជគ្រឹះ ក្នុងពុទ្ធុប្បាទនេះ ។

ព្រះសាស្តា ទ្រង់ទតព្រះនេត្រឃើញសត្វជ្រូកញីនោះហើយ ទ្រង់ធ្វើនូវការញញឹម ត្រូវព្រះមហាអានន្ទ ក្រាបទូលសួរហើយ ទ្រង់ត្រាស់សម្តែងរឿងរ៉ាវទាំងអស់ ទ្រង់ត្រាស់សម្តែងនូវគាថា ក្នុងតណ្ហាវគ្គនៃធម្មបទថា "យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ ..." ដូច្នេះជាដើម ។

ចំណែកមេជ្រូកនោះ ច្យុតអំពីអត្តភាពនោះហើយ កើតជារាជធីតាក្នុងសុវណ្ណភូមិ ច្យុតអំពីនោះហើយ បានទៅកើតក្នុងស្រុកឈ្មោះវនវាសី, ច្យុតអំពីនោះហើយ បានទៅកើតក្នុងក្រុងពារាណសី, ច្យុតអំពីនោះហើយ បានទៅកើតជាធីតារបស់អ្នកលក់សេះ ក្បែរកំពង់ឈ្មោះសុប្បារកៈ, ច្យុតអំពីនោះហើយ បានទៅកើតជាធីតារបស់នាយនាវា ក្បែរកំពង់ឈ្មោះកាវីរ, ទី ១០ ច្យុតអំពីនោះហើយ បានទៅកើតជាធីតា នៃឥស្សរជន ក្នុងអនុរាធបុរី, ច្យុតអំពីនោះហើយ បានទៅកើត

ជាធីតារបស់សុមនកុដុម្ពិក៍ ឈ្មោះថា **នាងសុមនា** ក្នុងស្រុកកេក្កន្តគ្រាមក្នុងទិសទក្សិណ នៃអនុរាធបុរីនុ៎ះឯង ។

នាងសុមនា បានកើត ១២ ជាតិ តាំងពីអត្តភាពជាមេមាន់ រហូតដល់មានអត្តភាពជាធីតារបស់កុដុម្ពិក៍ ដោយប្រការដូច្នេះ ។ ក្នុងកាលក្រោយមក នាងទៅកាន់ផ្ទះរបស់មហាមាត្យ ឈ្មោះថា **លកុណ្ឌកអតិអម្ពរៈ** នៃព្រះរាជាទ្រង់ព្រះនាមទុដ្ឋគាមិណី ។ ក្នុងគ្រានោះ ព្រះមហាអតុលត្ថេរៈនៅក្នុងកោដិបព្វតមហាវិហារ និមន្តទៅបិណ្ឌបាតក្នុងស្រុកនោះ ឃើញនាងហើយ ហៅភិក្ខុទាំងឡាយ មកប្រាប់ថា "ម្នាលលោកដ៏មានអាយុ កូនជ្រូកមេ កើតហើយបានដល់នូវភាពជាភរិយារបស់មហាអមាត្យ, រឿងនោះអស្ចារ្យមែនហ្ន៎ !" នាងបានស្តាប់ពាក្យនោះ ដឹងនូវអត្តភាពក្នុងអតីតៈ របស់ខ្លួនបានដោយញាណជាគ្រឿងរលឹកជាតិ ក៏កើតសេចក្តីសង្វេគតក់ស្លុត បានសុំស្វាមីបួសក្នុងសំណាក់នៃពួកនាងភិក្ខុនី បានស្តាប់សតិប្បដ្ឋានសូត្រ ក្នុងតិស្សមហាវិហារហើយ បានសម្រេចជាសោតាបន្ន ក្នុងកាលក្រោយមក បានស្តាប់នូវអាសីវិសូបមសូត្រ ក្នុងកល្លកមហាវិហារ ក៏បានសម្រេច

នូវព្រះអរហត្ត ។

**ឯវំ ធម្មស្សវនំ សម្មាភាវិតំ អរហត្តំ ចាបេតិ** បុគ្គលស្តាប់ធម៌ គឺចម្រើនដោយប្រពៃ ញុំាងបុគ្គលនោះឲ្យបានសម្រេចព្រះអរហត្តយ៉ាងនេះ តែងអស់ទៅនូវអាសវៈតាមលំដាប់ ។ (មង្គលត្ថទីបនី ៤, ៤៨-៨២)

## ៩_ធម្មទេសនាមយៈ

***ធម្មទេសនា*** *មានវចនត្ថៈថា ៖*

**ធម្មំ ទេសេន្តិ ឯតាយាតិ = ធម្មទេសនា :** ជនទាំងឡាយ រមែងសម្តែង រមែងបង្រៀនធម៌ ដោយធម្មជាតិនោះ ដូច្នោះ ធម្មជាតិដែលជាហេតុនៃការសម្តែង បង្រៀនធម៌ឈ្មោះថា ធម្មទេសនា, បានដល់ ចេតនានៅក្នុងមហាកុសល-ចិត្តុប្បាទ ដែលមានយោនិសោមនសិការជាប្រធាន ។

ការបង្រៀន ការសម្តែងវិជ្ជាអាជីពផ្សេងៗ ដែលមិនមានទោស ក៏ចាត់ជាធម្មទេសនាកុសលបានដូចគ្នា ដូច្នោះ

លោកវិភាវិនីដីកាចារ្យ ទើបបានសម្ដែងទុកថា **និរវជ្ជវិជ្ជាទិ-ឧបនិស្សយចេតនាបិ ឯត្ថេវ សង្គហំ គច្ឆតិ** : ចេតនាដែលជាហេតុនៃការចង្អុលបង្ហាញណែនាំវិជ្ជាផ្សេងៗ ដែលមិនមានទោស ក៏សង្គ្រោះចូលក្នុងធម្មទេសនា នេះ បានដូចគ្នា ។

## ៩.១ អានិសង្សធម្មទេសនាកុសល

បរមត្ថទីបនី អដ្ឋកថាខុទ្ទកនិកាយ ឥតិវុត្តកៈ ថា ភិក្ខុកាលមិនប្រាថ្នាការស្គាល់ជំនាញក្នុងធម៌ដើម្បីខ្លួន សម្ដែងធម៌ដល់អ្នកដទៃ ដោយអធ្យាស្រ័យពេញទៅដោយការអនុគ្រោះនេះឈ្មោះថា បុញ្ញកិរិយាវត្ថុ សម្រេចដោយការសម្ដែងធម៌ ។ តែថា កាលដែលភិក្ខុមួយរូបតាំងសេចក្ដីប្រាថ្នាទុកថា ជនទាំងឡាយនឹងដឹងថា យើងជាធម្មកថិកដោយវិធីយ៉ាងនេះ ហើយអាស្រ័យលាភសក្ការៈ និងសេចក្ដីសរសើរ (សិលោក) សម្ដែងធម៌មិនមានផលច្រើនឡើយ ។

ចំណែកក្នុងបរមត្ថជោតិកៈ ថា ៖

**ធម្មទេសនា** ដែលមានអានិសង្សច្រើននោះ គឺ អ្នកសម្ដែងធម៌ ដោយចិត្តបរិសុទ្ធ ពោលគឺ មិនប្រាថ្នាលាភ

សក្ការៈ យស សេចក្ដីសរសើរទេ ប្រាថ្នាតែ ឲ្យអ្នកស្ដាប់បានទទួលប្រយោជន៍តែប៉ុណ្ណោះ ការសម្ដែងធម៌យ៉ាងនេះ ចាត់ជាធម្មទេសនាកុសលពិត និង មានអានិសង្សច្រើន ។

ធម្មទេសនា ដែលមានអានិសង្សតិចនោះ គឺ អ្នកសម្ដែងធម៌ ដោយចិត្តមិនបរិសុទ្ធ រវល់តែប្រាថ្នានៅក្នុងរឿងលាភ សក្ការៈ យស សេចក្ដីសរសើរ ទាំងចិត្តក៏គិតដើម្បីឲ្យជនទាំងឡាយបានដឹងថា ខ្លួននេះជាព្រះធម្មកថិក គ្រូអាចារ្យ ការសម្ដែងធម៌យ៉ាងនេះ ចាត់ជាធម្មទេសនាកុសល ដែលមិនពិត មិនត្រឹមត្រូវ និងមានអានិសង្ស ក៏តិច ។

មួយទៀត អ្នកដែលសម្ដែងធម៌ ដោយចិត្តដែលមិនបរិសុទ្ធនេះ កាលកំពុងសម្ដែង ប្រសិនបើមានចិត្តបរិសុទ្ធកើតឡើងបានមួយខណៈៗ ពោលគឺ មិនប្រាថ្នាលាភ សក្ការៈ យស សេចក្ដីសរសើរទេ ប្រាថ្នាតែឲ្យអ្នកស្ដាប់បានទទួលប្រយោជន៍តែប៉ុណ្ណោះ ដូច្នោះ ការសម្ដែងធម៌ក្នុងខណៈនោះ ក៏ជាធម្មទេសនាកុសលពិត ត្រឹមត្រូវ និងមានអានិសង្សបានដូចគ្នា ។

ដូចដែលព្រះមហាពុទ្ធឃោសាចារ្យ បានសម្តែងទុក ក្នុងអដ្ឋសាលិនី អដ្ឋកថា ថា ៖

ឯកោ ឯវំ មំ ធម្មកថិកោតិ ជានិស្សន្តីតិ ឥច្ឆាយ ឋត្វា លាភគរុកោ ហុត្វា ទេសេតិ, តំ ន មហប្ផលំ អ្នកណាមួយសម្តែងធម៌ដោយចិត្តមិនបរិសុទ្ធ ដោយប្រាថ្នាក្នុងចិត្តថា ជនទាំងឡាយនឹងបានដឹងយើងនេះ ជាធម្មកថិកទាំងប្រាថ្នាក្នុងលាភ ការសម្តែងធម៌យ៉ាងនេះ រមែងមានផលមានអានិសង្សតិចមិនច្រើន ។

"ឯកោ អត្តនោ បគុណំ ធម្មំ អប្បច្ចាសីសមានោ វិមុត្តាយតនសីសេន បរេសំ ទេសេតិ ឥទំ ទេសនាមយំ បុញ្ញកិរិយាវត្ថុ នាម" អ្នកណាមួយសម្តែងធម៌ដល់ជនទាំងឡាយ ដោយសេចក្តីដឹង សេចក្តីជំនាញរបស់ខ្លួន ដោយមិនមានការប្រាថ្នាក្នុងលាភយ៉ាងណាទេ ប្រាថ្នាតែនឹងឲ្យសម្រេចអរហត្តផលតែម្យ៉ាង ការសម្តែងធម៌យ៉ាងនេះ បានឈ្មោះថា បុញ្ញកិរិយាវត្ថុ ដែលសម្រេចដោយធម្មទេសនាកុសល ។

## ៩.២ ធម្មទាន

*ដោយបទបាលីថា* "ឥធេកច្ចោ អមតប្បត្តិប្បដិបទំ កាថេត្វា ទេតិ ឥទំ ធម្មទានំ នាម ។ *បុគ្គលខ្លះក្នុងលោកនេះ សម្តែងប្រាប់នូវបដិបទា ជាហេតុដល់នូវព្រះនិព្វាន ឈ្មោះថា* **អមតៈ** *តែងឲ្យនូវទាននេះ ឈ្មោះថា ធម្មទាន* "អមតប្បត្តិហេតុភូតំ សម្មាបដិបទំ" *នូវបដិបទាដោយប្រពៃ ជាហេតុឲ្យកើតឡើងនៃកិរិយាដល់នូវព្រះនិព្វាន ឈ្មោះថា* **អមតៈ** *ជាឈ្មោះ ធម្មទាន ។*

"ឥធេកច្ចោ ឥមេ ធម្មា កុសលា ឥមេ ធម្មា អកុសលា" *បុគ្គលពួកខ្លះក្នុងសាសនានេះ បែងចែកធម៌ជាកុសល និង អកុសល ប្រាប់ថា ធម៌ទាំងឡាយនេះ ជាកុសល ធម៌ទាំងឡាយនេះ ជាអកុសល ឈ្មោះថា ធម្មទាន ។*

ឥមេ ធម្មា សាវជ្ជា *ធម៌ទាំងឡាយនេះ ប្រព្រឹត្តទៅមានទោស,* ឥមេ ធម្មា អនវជ្ជា *ធម៌ទាំងឡាយនេះ ប្រព្រឹត្តទៅមិនមានទោស,* ឥមេ វិញ្ញុគរហិតា *ធម៌ទាំងឡាយនេះ គឺ បណ្ឌិតគប្បីតិះដៀល,* ឥមេ វិញ្ញុប្បសត្ថា

*ធម៌ទាំងឡាយនេះ គឺ បណ្ឌិតគប្បីសរសើរ, ឥធំ សិទ្ធប្បត្តំ ធម្មទានំ នាម ធម្មទាននេះ ឈ្មោះថា ជាកំពូល,*

"ឥធ លោកបរលោកទុក្ខក្ខយសុខាវហានស្ស បន សម្មាសម្ពុទ្ធប្បវេទិតស្ស ធម្មស្ស បរេសំ ហិតកាមតាយ ទេសនា ធម្មទានំ" *ចំណែកទេសនានូវធម៌គឺ ព្រះសម្មា-សម្ពុទ្ធ ត្រាស់ដឹងហើយ ជាហេតុនាំមកនូវប្រយោជន៍ និងសេចក្ដីសុខ ជាគ្រឿងអស់ទៅនៃទុក្ខ ក្នុងលោកនេះផង ក្នុងលោកខាងមុខនោះផង ដល់ខ្លួនផង ដល់អ្នកដទៃផង សមដូចគាថា ដែលព្រះអង្គទ្រង់សម្ដែងចំពោះសក្កទេវរាជ ជាស្ដេចនៃទេវតា ។*

**សព្វទានំ ធម្មទានំ ជិនាតិ សព្វរសំ ធម្មរសោ ជិនាតិ**

**សព្វរតឹ ធម្មរតិ ជិនាតិ តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ ។**

*ធម្មទានឈ្នះទានទាំងពួង, ធម្មរស ឈ្នះរសទាំងពួង,*

*សេចក្ដីត្រេកអរក្នុងធម៌ ឈ្នះសេចក្ដីត្រេកអរទាំងពួង*

*កិរិយាអស់ទៅនៃតណ្ហា ឈ្នះទុក្ខទាំងពួង ។*

**អដ្ឋកថាធម្មបទថា** : *បទថា សព្វទានំ ជាដើម សេចក្តីថា "ក៏ប្រសិនបើ បុគ្គលគប្បីថ្វាយត្រៃចីវរ ដល់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះខីណាស្រពទាំងឡាយ ដែលបានគង់ជាប់ៗគ្នា ក្នុងផ្ទៃចក្រវាឡ រហូតដល់ព្រហ្មលោក ។ ឯកិរិយាអនុមោទនា ដែលព្រះពុទ្ធជាដើមទ្រង់បានធ្វើហើយ ដែលប្រកបដោយព្រះគាថា មានបាទ ៤ ក្នុងសមាគមនោះឯងប្រសើរបំផុត ។ ព្រោះថា ទាននោះ រមែងមិនដល់នូវតម្លៃនូវចំណែកទី ១៦ នៃព្រះគាថានោះទេ ។ ការសម្តែងក្តី ការប្រាប់ក្តី ការបង្រៀន ការស្តាប់ក្តី នូវធម៌ ជាធម្មជាតិមានផលច្រើនយ៉ាង ដូច្នេះ ។*

*មួយទៀត បុគ្គលឯណាមួយឲ្យគេធ្វើការស្តាប់ធម៌នោះ, អានិសង្សដ៏ច្រើន រមែងមានដល់បុគ្គលនោះពិត ។ ធម្មទានដែលព្រះពុទ្ធជាដើម ទ្រង់បានឲ្យប្រព្រឹត្តទៅហើយ សូម្បីដោយអំណាចអនុមោទនា ដោយហោចទៅ ដោយព្រះគាថាប្រកបដោយ ៤ បាទប៉ុណ្ណោះ ជាធម្មជាតិដ៏ប្រសើរបំផុតជាងទាន ដែលទាយកញុំាងបាត្រឲ្យពេញដោយបិណ្ឌបាត ដ៏*

ប្រណីត ហើយប្រគេនដល់បរិស័ទអ្នកប្រាកដដូច្នោះឯង សូម្បីជាងភេសជ្ជទាន ដែលទាយកញ៉ាំងបាត្រឲ្យពេញ ដោយទឹកដោះរាវថ្លា និង ប្រេងជាដើមហើយប្រគេន សូម្បីជាងសេនាសនទាន ដែលទាយកញ៉ាំងបុគ្គលឲ្យសាងព្រះវិហារទាំងឡាយ ដូចព្រះមហាវិហារ និងប្រាសាទទាំងឡាយ ដូចជាលោហប្រាសាទ រាប់ច្រើនសែនខ្ទង់ជាអនេក ហើយប្រគេន សូម្បីជាងបរិច្ចាគ ដែលអនាថបិណ្ឌិកសេដ្ឋី ជាដើម ប្រារព្ធព្រះវិហារទាំងឡាយធ្វើហើយ ។ ពោះហេតុអ្វី ? ព្រោះថាបុគ្គលទាំងឡាយ កាលនឹងធ្វើបុណ្យដូច្នោះ ត្រូវតែស្ដាប់ធម៌ហើយប៉ុណ្ណោះ ទើបធ្វើបាន, មិនបានស្ដាប់ហើយ ក៏ធ្វើមិនបានទេ ។ ក៏ប្រសិនបើសត្វទាំងនេះ មិនគប្បីស្ដាប់ធម៌ទេ, ក៏មិនគប្បីប្រគេន សូម្បីនូវបបរត្រឹមតែមួយវែក សូម្បីនូវបាយត្រឹមតែមួយវែកដែរ, ហេតុនេះ ធម្មទាននោះឯង ទើបប្រសើរបំផុតជាងទានទាំងពួង ។ ម្យ៉ាងទៀត លើកលែងតែព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធទាំងឡាយចេញហើយ សូម្បីព្រះ-សាវ័កទាំងឡាយ មានព្រះសារីបុត្តជាដើម ជាអ្នកប្រកបដោយបញ្ញា ដែលអាចដើម្បីនឹងរាប់តំណក់ទឹកភ្លៀងទាំងឡាយបាន

កាលបើភ្លៀងកំពុងធ្លាក់ រហូតដល់កប្បទាំងអស់ ក៏មិនអាចនឹងសម្រេចសោតាបត្តិផលជាដើម ដោយធម្មតារបស់ខ្លួនបានឡើយ, លុះត្រាតែស្តាប់ធម៌ដែលព្រះអស្សជិត្ថេរៈ ជាដើមសម្តែងហើយ ទើបធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលបាន, និង ធ្វើឲ្យជាក់ច្បាស់នូវសាវកបារមីញាណ ដោយព្រះធម៌-ទេសនារបស់ព្រះសាស្តា, បពិត្រមហារាជ ព្រោះហេតុនេះឯង ធម្មទានទុំះឯង ទើបជាទានដ៏ប្រសើរបំផុត ។ ព្រោះហេតុនោះព្រះសាស្តាទើបត្រាស់ថា "សព្វទានំ ធម្មទានំ ជិនាតិ : ធម្មទាន រមែងឈ្នះនូវទានទាំងពួង" ដូច្នេះជាដើម ។

ពាក្យថា សព្វរសំ ធម្មរសោ ជិនាតិ រសនៃធម្មឈ្នះជាងរសទាំងពួង ដោយបទបាលីថា យោ បនេស សត្តតឹសពោធិបក្ខិយធម្មសង្ខាតោច នវលោកុត្តរធម្ម-សង្ខាតោច ធម្មរសោ អយមេវ សព្វរសានំ សេដ្ឋោ ។ ចំណែករសឯណា ពោលគឺធម៌ជាចំណែកនៃបញ្ញា ជាគ្រឿងត្រាស់ដឹងដ៏ក្រៃលែង មាន ៣៧ ប្រការផង ពោលគឺធម៌ជាគ្រឿងឆ្លងចាកលោក ៩ ប្រការផង ធម្មរសនេះឯង ប្រសើរ

ជាងរសទាំងពួង ទើបឲ្យឈ្មោះថា រសរបស់ធម៌ ។

បទដីកាថា ធម្មរសោតិ សទ្ធម្មសន្និចយំ បីតិប្បាមោជ្ជំ កិរិយារីករាយនឹងការនៃខ្លួនជាអ្នកក្រេបផឹក គឺបុគ្គលអាស្រ័យនូវព្រះសទ្ធម្មឲ្យឈ្មោះថា រសរបស់ធម៌ដូច្នេះ ។

បទបាលីថា សព្វរតឹ ធម្មរតិ ជិនាតិ សេចក្តីត្រេកអរក្នុងធម៌ ឈ្នះសេចក្តីត្រេកអរទាំងពួង ។

មានបទវិគ្គហថា ធម្មរតីតិ សមថវិបស្សនាធម្មេ អភិរតិ បុគ្គលត្រេកអរចំពោះក្នុងសមថ និងវិបស្សនាធម៌ទាំងឡាយ ឲ្យឈ្មោះថា **ធម្មរតិ** ដូច្នេះ ឈ្មោះថា ត្រេកអរ ។

តណ្ហក្ខយោ បន តណ្ហក្ខយន្តេ ឧប្បន្នំ អរហត្តំ តំ សកលស្សាបិ វដ្ដទុក្ខស្ស អភិភវនតោ សព្វសេដ្ឋមេវ ។ ចំណែកខាងព្រះអរហត្ត ដែលកើតឡើងក្នុងទីបំផុតនៃធម៌ជាគ្រឿងអស់ទៅនៃតណ្ហា ឈ្មោះថា ធម៌ជាគ្រឿងអស់ទៅនៃតណ្ហា ព្រះអរហត្តនោះ ឈ្មោះថា ប្រសើរបំផុតជាងធម៌ទាំងពួង ព្រោះគ្របសង្កត់នូវវដ្ដទុក្ខមែនទាំងអស់ ។

ពាក្យថា **អស់តណ្ហា ឈ្នះទុក្ខទាំងពួង** ចំណែកព្រះអរហត្ត ដែលកើតឡើងក្នុងទីបំផុតនៃធម៌ ជាគ្រឿងអស់ទៅនៃតណ្ហា ព្រោះថា ប្រសើរបំផុតជាងធម៌ទាំងពួង អាចគ្របសង្កត់នូវវដ្តទុក្ខបាន បានជាឈ្មោះថា តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ, ឈ្មោះថា **លាភគរុ** ជាអ្នកជូន់ក្នុងលាភ មកពីតណ្ហាប៉ះពាល់ អ្នកមិនជូន់ដោយលាភ សូម្បីសម្តែងធម៌ មានចិត្តទន់ផ្សាយផលប្រយោជន៍ មែនពិត តែងនឹកបំណងឲ្យអ្នកដទៃបេះចាំនូវពុទ្ធវចនស្អាត់ជំនាញរបស់ខ្លួន ឈ្មោះថា ទេសនាមយបុណ្យ សម្រេចមកពីទេសនា ។

ប្រាថ្នាមិនឲ្យសាបសូន្យ អង្គរបស់ព្រះពុទ្ធសាសនា ដែលប្រកបដោយអង្គទាំង ៩ ផង ។

ភិក្ខុសម្តែងដោយពិស្តារនូវសច្ចៈទាំង ៤ ប្រការ ដែលប្រកបដោយអត្ថនិងព្យញ្ជនៈ ។

ពាក្យថា **ធម៌** បទវិគ្គហៈថា ធម្មន្តិ ចតុស្សច្ចធម្មំ ទេសេតិ ភិក្ខុអង្គណា សម្តែងនូវសច្ចធម៌ ៤ ឈ្មោះថា សម្តែងធម៌ ឬឈ្មោះថា ធម៌ ។

អត្ថប្បដិសំវេទិនោតិ បាលិអត្ថំ អាជានន្តស្ស ភិក្ខុអង្គឯណា កាលដឹងប្រាកដនូវអត្ថនៃបាលី ឈ្មោះថា ដឹងចំពោះនូវអត្ថ ។ ធម្មប្បដិសំវេទិនោតិ បាលី អាជានន្តស្ស ភិក្ខុអង្គឯណា កាលដឹងនូវបាលី ឈ្មោះថា ដឹងចំពោះនូវធម៌ ។ បាមោជ្ជន្តិ តរុណាបីតិ គឺ បីតិនៅខ្ចីនៅទន់ ឈ្មោះថា បាមោជ្ជៈ ។ បីតីតិ តុដ្ឋាការភូតោ ពលវប្បីតិ, បីតិដ៏មានកម្លាំងជាអាការៈនៃសេចក្តីត្រេកអរកើតឡើង ឈ្មោះថា បីតិ ។ កាយោតិ នាមកាយោ វិនាមកាយ ឈ្មោះថា កាយ ។ បស្សម្ភតីតិ បដិប្បស្សម្ភតិ នាមកាយស្ងប់រម្ងាប់ឲ្យ ឈ្មោះថា បស្សម្ភតិ ។ សុខំ វេទេតីតិ សុខំ បដិលភតិ ភិក្ខុបានចំពោះនូវសេចក្តីសុខ ឈ្មោះថា សោយនូវសេចក្តីសុខ ។ សមាធិយតីតិ អរហត្ត ផលសមាធិនា សមាធិយតិ ចិត្តតម្កល់មាំ ដោយកិរិយាតម្កល់មាំ គឺ អរហត្តផល ឈ្មោះថា **សមាធិយតិ** ។ ព្រោះបុគ្គលនេះការស្តាប់នូវធម៌នោះ ដឹងនូវឈាននិងវិបស្សនា មគ្គផល ក្នុងទីដែលមកហើយ បីតិកើតឡើងបុគ្គលនោះ កាលមិនថយចុះ ក្នុងចន្លោះនៃបីតិនោះ

ជាអ្នកដែលប្រកបដោយឧបចារកម្មដ្ឋាន ហើយញុំាងវិបស្សនាឲ្យចម្រើនឡើង ហើយសម្រេចនូវព្រះអរហត្ត, ចិត្តំ សមាធិយតិ គឺចិត្តតម្កល់មាំ សំដៅយកព្រះអរហត្តនោះ ។ វិមុត្តាយតនន្តិ វិមុច្ចនការណំ ហេតុនៃកិរិយារួចស្រឡះ ឈ្មោះថា **វិមុត្តាយតន** ។

បាមោជ្ជកើតឡើង គឺ មានសេចក្តីរីករាយ ជាលក្ខណៈ, រំពឹងនូវធម៌នោះ ដ៏សមគួរហើយ ប្រព្រឹត្តល្អដោយកាយ វាចា មនោ របស់ខ្លួន ដល់នូវសោមនស្ស ។ ពាក្យថា បីតិ ដ៏មានកម្លាំង គឺ រម្ងាប់កាយនិងចិត្ត ។ កាលបើនាមកាយរម្ងាប់ហើយ រូបកាយក៏ស្ងប់រម្ងាប់ដែរ ។ ពាក្យថា **បានចំពោះនូវសេចក្តីសុខ** គឺ ចេតសិកនៅប្រឡូកប្រឡំ អាចដើម្បីជាបច្ច័យតម្កល់មាំនៃចិត្ត ។ ពាក្យថា **តម្កល់មាំ** សំដៅយកអនុត្តរសមាធិ ជាឈ្មោះអរហត្តផលសមាធិ ។

ពាក្យថា **រួចផុតអាយតនៈ** បទបាលីថា វិមុត្តិយា វដ្ដទុក្ខតោ វិមុច្ចនស្ស អាយតនំ ការណំ វិមុត្តាយតនំ អាយតនៈជាហេតុនៃកិរិយារួចចាកវដ្ដទុក្ខ ឈ្មោះថា **វិមុត្តា-**

យតនៈ ឬ វិមុច្ចនការណ៍ កិរិយាស្ដាប់ធម៌ក្ដី ឲ្យនូវអភ័យទានក្ដី ចាត់ចូលក្នុងធម្មទានដែរ ។

## ៩.៣ ធម្មកថិកអ្នកសម្ដែងធម៌មាន ៥ យ៉ាង

១-ធម្មំ ទេសេន្តេនបិ ហិតផរណមុទុចិត្តេនេវ ភវិតព្វំ ន លាភ គរុកេន : ចំណែកធម្មកថិកអ្នកសម្ដែងធម៌ គប្បីមានចិត្តទន់ភ្លន់ ផ្សាយនូវប្រយោជន៍ធម្មទាន មិនធ្ងន់ចិត្តដោយលាភ ។

២-លាភគរុកស្ស ហិ ធម្មទានំ ន មហប្ផលំ ព្រោះថា ធម្មទានរបស់បុគ្គលអ្នកធ្ងន់ដោយលាភ ជាធម្មទានមិនមានផលច្រើន

៣-ឥច្ឆាយ ឋត្វា លាភគរុកោ ហុត្វា ទេសេតិ តំ ន មហប្ផលំ : បុគ្គលអ្នកសម្ដែងធម៌ ជាអ្នកគោរពលាភ ឋិតនៅក្នុងឥច្ឆា ធម្មទាននេះ មិនមានផលច្រើន ។

៤-ឯកោ អត្តនោ បគុណធម្មំ អប្បច្ចាសីស-មានោ បរេសំ ទេសេតិ ឥទំ ទេសនាមយំ បុញ្ញកិរិយាវត្ថុ នាម : ធម្មកថិកអង្គណាមួយ មិនមាន

*ទឹកបំណាំងនូវលាភសក្ការៈ តែងសម្ដែងនូវធម៌ ដល់ជនទាំងឡាយដទៃឲ្យស្គាល់នូវគុណៈរបស់ខ្លួនថា ធម្មទាននេះ ជាបុញ្ញ-កិរិយាវត្ថុ សម្រេចអំពីទេសនាមយៈ*

*៥-តំ ឆ មហាប្ផលំ តណ្ហាយ បរាមដ្ឋត្តា ធម្មទាននេះ មិនមានផលច្រើន ព្រោះមានតណ្ហាប៉ះពាល់ហើយ ។*

## ៩.៤ គាថាក្នុងភិន្នកសូត្រ

*ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ៖*

អន្នទោ ពលទោ ហោតិ វត្ថទោ ហោតិ វណ្ណទោ
យានទោ សុខទោ ហោតិ ទីបទោ ហោតិ ចក្ខុទោ។
សោ ច សព្វទទោ ហោតិ
យោ ទទាតិ ឧបស្សយំ
អមតន្ទទោ ច សោ ហោតិ
យោ ធម្មមនុសាសតិ ។

*បុគ្គលឲ្យបាយ ឈ្មោះថា ឲ្យកម្លាំង ឲ្យសំពត់ ឈ្មោះថា ឲ្យពណ៌សម្បុរ ឲ្យយានជំនិះ ឈ្មោះថា ឲ្យសេចក្ដីសុខ*

ឲ្យប្រទីប ឈ្មោះថាឲ្យចក្ខុ ។ មួយទៀត បុគ្គលណា ឲ្យទីនៅអាស្រ័យ បុគ្គលនោះឈ្មោះថា ឲ្យវត្ថុគ្រប់យ៉ាង បុគ្គលណាប្រៀនប្រដៅធម៌ បុគ្គលនោះឈ្មោះថា **ឲ្យព្រះនិព្វាន** ។

**អដ្ឋកថា ពន្យល់ថា :**

បទថា អមតន្ទទោ ច សោ ហោតិ អធិប្បាយថា កាលបុគ្គលញ៉ាំងបិណ្ឌបាត ឲ្យពេញដោយភោជនដ៏ប្រណីត ហើយថ្វាយ ឈ្មោះថា ឲ្យសេចក្តីមិនស្លាប់ ។

បទថា យោ ធម្មមនុសាសតិ អធិប្បាយថា បុគ្គលណា រមែងទូន្មានធម៌ រមែងប្រាប់អដ្ឋកថា រមែងបង្រៀនបាលី រមែងដោះស្រាយបញ្ហាដែលសួរហើយ រមែងប្រាប់កម្មដ្ឋាន រមែងធ្វើធម្មស្សវនៈ សូម្បីទាំងអស់នេះ ឈ្មោះថា រមែងទូន្មានធម៌ ។ មួយទៀត ការឲ្យធម៌នេះប៉ុណ្ណោះ បណ្ឌិតគប្បីជ្រាបថា ប្រសើរជាងការឲ្យទាំងអស់ សេចក្តីនេះ សមពិតដូចដែលទ្រង់ត្រាស់ទុកថា "សព្វទានំ ធម្មទានំ ជិនាតិ ។លៗ តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ" ដូច្នេះ ។

# ១០_ទិដ្ឋុជុកម្ម

បរមត្ថទីបនី អដ្ឋកថាខុទ្ទកនិកាយ ថា : ការដែលទិដ្ឋិដំណើរទៅត្រង់ ឈ្មោះថា ការឃើញត្រង់ (ទិដ្ឋិជុកម្ម) ពាក្យថា **ទិដ្ឋិជុកតំ** នេះ ជាឈ្មោះរបស់សម្មាទស្សនៈ ដែលប្រព្រឹត្តទៅហើយដោយន័យមានជាដើមថា ទានដែលឲ្យហើយមានផល ។ ព្រោះថា ការឃើញត្រង់នេះ សូម្បីជាញាណវិប្បយុត្ត ក្នុងចំណែកខាងដើម ឬខាងក្រោយ តែក្នុងវេលាធ្វើការឃើញឲ្យត្រង់ហើយ ក៏ជាញាណសម្បយុត្តនោះឯង ។

តែអាចារ្យពួកមួយពោលថា **ទស្សនៈ** គឺ ការឃើញដោយអំណាចនៃការដឹងច្បាស់ និងការដឹងជាក់ ១ វិញ្ញាណដែលជាកុសល ១ កម្មស្សកតាញាណជាដើម ១ ជាសម្មាទស្សនៈ ។ បណ្ដាធម៌ ៣ យ៉ាង មានទស្សនៈជាដើមនោះ សូម្បីក្នុងកាលញាណនៅមិនទាន់កើតឡើង ក៏មានការសង្គ្រោះហេតុដែលសមគួរដល់ហេតុ ជាគ្រឿងរឭកដល់បុណ្យដែលខ្លួនបានធ្វើទុកហើយ ចូលជាមួយវិញ្ញាណដែលជាកុសលបាន។ មានការសង្គ្រោះចូលជាមួយកម្មស្សកតាញាណ គឺ ការឃើញ

*ប្រពៃ តាមផ្លូវរបស់កម្មបាន ។ តែការឃើញត្រង់ក្រៅនេះ មានការកំណត់ធម៌ទាំងពួង ជាលក្ខណៈ ។ ព្រោះថា ការធ្វើបុណ្យយ៉ាងណានីមួយ បុណ្យនោះក៏មានផលច្រើន ព្រោះហេតុដែលទិដ្ឋិទាំងឡាយត្រង់នោះឯង ។*

ក្នុងបរមត្ថជោតិកៈ *មានសម្ដែងវចនត្ថៈរបស់* ***ទិដ្ឋុជុកម្ម*** *ថា* "ទិដ្ឋិយា ឧជុករណំ ទិដ្ឋុជុកម្មំ" *ការធ្វើសេចក្ដីឃើញឲ្យត្រង់ ឈ្មោះថា* ***ទិដ្ឋុជុកម្ម****, បានដល់ កម្មស្សកតាញាណ ព្រមដោយកុសលចេតនា, ពាក្យថា “****ទិដ្ឋុជុកម្ម****” នេះជាឈ្មោះរបស់កម្មស្សកតាញាណ ដូចដែលព្រះអានន្ទត្ថេរបានសម្ដែងទុកក្នុងកាមាវចរកុសល បទមូលដីកាថា ៖*

"កម្មស្សកតាញាណំ ទិដ្ឋុជុកម្មំ" ***កម្មស្សកតាញាណ*** *គឺបញ្ញាដែលដឹងថា សត្វទាំងឡាយមានសិទ្ធិ ឬសេចក្ដីសម្រេចក្នុងការធ្វើរបស់ខ្លួន ទាំងដែលជាផ្នែកល្អ និងមិនល្អ ទាំងអស់គ្នា ចំណែកទ្រព្យសម្បត្តិ មាស ប្រាក់ មាតាបិតា ស្វាមី ភរិយា បុត្រធីតាទាំងនេះ មិនមែនជាសិទ្ធិរបស់សត្វទាំងឡាយនោះ ដោយពិត ព្រោះមិនបានជាប់តាម*

សត្វទាំងឡាយទៅក្នុងភពដទៃបាន (សូម្បី) ក្នុងភពនេះ ក៏នៅមានសិទ្ធិមិនជាក់លាក់ ឬ មិនប្រាកដទៀតផង ព្រោះនៅមានភ័យផ្សេងៗ មកដណ្ដើមយកទៅបាន សេចក្ដីឃើញដូច្នេះ បានឈ្មោះថា **ទិដ្ឋុជុកម្ម** ។

តែក្នុងប្រភេទកម្មចតុក្កនេះ បានសម្ដែងដល់ចេតនាផ្សេងៗ ដែលជាតួកម្ម ដូច្នោះ ចេតនាចេតសិក ដែលកើតព្រមជាមួយកម្មស្សកតាញាណនោះ ក៏បានឈ្មោះថា "ទិដ្ឋុជុកម្ម" ផង ពិតមែន កម្មស្សកតាញាណដែលកើតឡើង ដោយវៀរចាកពីចេតនាចេតសិកនោះ រមែងមិនមាន ដូច្នោះ កាលបានពោលកម្មស្សកតាញាណ ដែលជាតួទិដ្ឋុជុកម្មហើយ ក៏ជាការដែលថា បានពោលដល់ចេតនាចេតសិកផង នេះប្រព្រឹត្តទៅតាមអវិនាភាវន័យ គឺ ន័យពោលដល់វត្ថុមួយហើយ ក៏រមែងឲ្យសម្រេចដល់វត្ថុមួយទៀត ព្រោះវៀរចាកពីកម្ម មិនបាន ។

**កម្មស្សកតាញាណ មានវចនត្ថៈថា ៖**

"កម្មំ សកំ យេសន្តិ កម្មស្សកា" កម្មជាកម្មសិទ្ធិរបស់ខ្លួន មានដល់សត្វទាំងឡាយ ដូច្នោះ សត្វទាំង

ឡាយទើបបានឈ្មោះ ថាកម្មស្សកៈ បានដល់ សត្វទាំងឡាយ "កម្មស្សកានំ ភាវោ កម្មស្សកតា" ការរស់នៅនៃសត្វទាំងឡាយ ដែលមានកម្ម ជាកម្មសិទ្ធិរបស់ខ្លួន ឈ្មោះថា កម្មស្សកតា បានដល់ ការរស់នៅរបស់សត្វ ឈ្មោះថា កម្មស្សកតាញាណ បានដល់ បញ្ញា ។

*សម្តែងវចនត្ថៈ ន័យមួយទៀតថា ៖*

"អត្តនោ បច្ចយេហិ ឧជុំ ករិយតីតិ ឧជុកម្មំ" "ទិដ្ឋិ ឯវ ឧជុកម្មំ ទិដ្ឋុជុកម្មំ" ធម្មជាតិណា ត្រូវបច្ច័យរបស់ខ្លួនធ្វើឲ្យត្រង់ ដូច្នោះ ធម៌ដែលត្រូវធ្វើឲ្យត្រង់ ឈ្មោះថា **ឧជុកម្ម** ការឃើញ គឺបញ្ញានេះពិតៗ ជាធម្មជាតិត្រូវធ្វើឲ្យត្រង់ ឈ្មោះថា ទិដ្ឋុជុកម្ម, ពាក្យថា "**ទិដ្ឋិ**" ក្នុងទីនេះសំដៅដល់បញ្ញា គឺធម្មជាតិដែលដឹងតាមសេចក្តីពិត បានដល់ **កម្មស្សកតាញាណ** "អត្តនោ បច្ចយេហិ" ធម៌ដែលជាបច្ច័យរបស់ខ្លួន សំដៅសេចក្តីថា ធម៌ដែលជាបច្ច័យរបស់កម្មស្សកតាញាណនោះឯង ។

## ១០.១ បច្ច័យនៃកម្មស្សកតាញ្ញាណ ៣

ធម៌ជាបច្ច័យដល់កម្មស្សកតាញ្ញាណ មាន ៣ ប្រការគឺ

**១-សុតមយបញ្ញា** បញ្ញាដែលកើតអំពីការសិក្សា រៀនសូត្រ ជាហេតុ ជាបច្ច័យឲ្យកើតកម្មស្សកតាញ្ញាណ

**២-ចិន្តាមយបញ្ញា** បញ្ញាដែលកើតអំពីការគិតនឹកពិចារណា ក្នុងការរស់នៅរបស់សត្វទាំងឡាយ ដោយការមានរោគ មិនមានរោគ សេចក្តីឆ្លាត សេចក្តីល្ងង់ សុខ ទុក្ខ អាយុវែង អាយុខ្លី ទាល់ក្រ មានទ្រព្យសម្បត្តិច្រើន ទាំងនេះជាដើម ជាហេតុ ជាបច្ច័យនាំឲ្យកើតកម្មស្សកតាញ្ញាណ

**៣-ភាវនាមយបញ្ញា** បញ្ញាដែលកើតអំពីការចម្រើនវិបស្សនា ជាហេតុ ជាបច្ច័យឲ្យកើតកម្មស្សកតាញ្ញាណ ។

ក្នុងវចនត្ថៈ ទី ២ នេះ បញ្ញាចែកចេញជា ២ យ៉ាង គឺ

បញ្ញាដែលជាហេតុ ១ បញ្ញាដែលជាផល ១ ។

បញ្ញាដែលជាហេតុ ក៏បានដល់ បញ្ញាទាំង ៣ ខាងដើមនេះ, ចំណែកបញ្ញាដែលជាផលនោះ ក៏បានដល់ កម្មស្សកតា-ញ្ញាណ ហេតុនេះពិត សូម្បីជនទាំងឡាយ នឹងលះសក្កាយទិដ្ឋិ (សេចក្តីប្រកាន់ភ្ជាប់ក្នុងខន្ធ ៥ ថា ជាតួខ្លួន) មិនបានក៏ពិត តែ

កាលមានការឃើញត្រង់នៅក្នុងទសវត្ថុកសម្មាទិដ្ឋិ ១០ ប្រការ ហើយ ក៏បានឈ្មោះថា មានកម្មស្សកតាញាណដែលសម្រេចជាទិដ្ឋុជុកម្មកុសលកើតឡើង ។

## ១០.២ សម្មាទិដ្ឋិ ១០ ប្រការ

គំនិតដែលយល់ត្រូវតាមគន្លងធម៌ ហៅថា សម្មាទិដ្ឋិ សម្មាទិដ្ឋិ មាន ១០ នោះ គឺ ៖

១-អត្ថិ ទិន្នំ យល់ថា ទានដែលបុគ្គលឲ្យហើយ មានផល

២-អត្ថិ យិដ្ឋំ យល់ថា ការបូជាធំ មានផល

៣-អត្ថិ ហុតំ យល់ថា ការបូជាតូច មានផល

៤-អត្ថិ សុកតទុក្កតានំ កម្មានំ ផលំ វិបាកោ យល់ថា ផលវិបាកនៃកុសលាកុសលកម្ម ដែលបុគ្គលធ្វើល្អនិងអាក្រក់មាន

៥-អត្ថិ អយំ លោកោ យល់ថា លោកនេះ មាន

៦-អត្ថិ បរោ លោកោ យល់ថា លោកខាងមុខ មាន

៧-អត្ថិ មាតា យល់ថា មាតា មានគុណ

៨-អត្ថិ បិតា យល់ថា បិតា មានគុណ

៩-អត្ថិ សត្តា ឱបបាតិកា យល់ថា សត្វទាំងឡាយ ជា

ឱបបាតិក កំណើតមាន

១០- *អត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ* : យល់ថា សមណព្រាហ្មណ៍ទាំងឡាយ ក្នុងលោកនេះ ជាអ្នកប្រព្រឹត្តល្អ ប្រតិបត្តិត្រឹមត្រូវ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ដោយប្រាជ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយសម្តែងប្រាប់ មាន ។

ដូច្នោះ គ្រហស្ថ ឬ បព្វជិតទាំងឡាយ ខ្លួនមានសេចក្តីដឹងក្នុងវិជ្ជាផ្លូវលោក ឬ មិនមានសេចក្តីដឹងក៏ដោយ បើសេចក្តីយើញរបស់ខ្លួន នៅមិនទាន់ត្រឹមត្រូវតាមគោលរបស់ទស-វត្ថុកសម្មាទិដ្ឋិ ១០ ប្រការហើយ ក៏ជាការសមគួរយ៉ាងក្រៃលែង នឹងត្រូវព្យាយាមធ្វើការអប់រំ សិក្សារៀនសូត្រក្នុងផ្នែកបរិយត្តិ ឬបដិបត្តិដែលត្រឹមត្រូវ ដើម្បីបានកែតម្រង់ដោះស្រាយសេចក្តីឃើញរបស់ខ្លួនឲ្យបរិបូរណ៍ ត្រឹមត្រូវតាមគោលរបស់ទសវត្ថុកសម្មាទិដ្ឋិ ដែលសម្តែងហើយនោះ ព្រោះអ្នកដែលមាន (សេចក្តីយល់ឃើញ) ត្រឹមត្រូវតាមគោលរបស់ទសវត្ថុកសម្មាទិដ្ឋិយ៉ាងបរិបូរណ៍ អ្នកនោះមិនបាត់បង់

ទីដែលកើតមកជាមនុស្ស ជួបព្រះពុទ្ធសាសនា សមជាមួយការដែលបានឈ្មោះថា ជាពុទ្ធសាសនិកជន ដ៏ពិតប្រាកដ ដែលជាផលកម្រៃ មិនខាតទុន និងជាទីទុកដាក់ចិត្ត មានចិត្តសប្បាយរីករាយដល់ការប្រព្រឹត្តទៅ ក្នុងបរលោករបស់ខ្លួនបានទៀតផង ។

មួយទៀត អ្នកដែលមានសេចក្តីឃើញតាមគោលរបស់ទសវត្ថុកសម្មាទិដ្ឋិ ល្អគ្រប់ប្រការហើយនោះ ក៏ឈ្មោះថា កម្មស្សកតាញាណ បានកើតឡើងហើយដល់អ្នកនោះ ដូច្នោះការបរិច្ចាគទាន រក្សាសីល ចម្រើនភាវនារបស់អ្នកនោះ ក៏រមែងមានអានិសង្សច្រើន រកអ្វីប្រៀបមិនបាន, ប្រៀបដូចជាការបណ្តុះគ្រាប់ពោធិ៍ ដុះជាពោធិ៍ធំឡើង ផុយគ្នានឹងទានសីល ភាវនារបស់អ្នកដែលមិនមាន កម្មស្សកតាញាណ រមែងមានអានិសង្សតិច ប្រៀបដូចដើមពោធិ៍ធំ ឲ្យផលកើតជាគ្រាប់ពោធិ៍ ក៏ដូច្នោះឯង ដូច្នោះ ព្រះមហាពុទ្ធឃោសាចារ្យ ទើបពោលពណ៌នាគុណរបស់កម្មស្សកតាញាណ ទុកក្នុងចតុក្កនិទ្ទេសវណ្ណនា សម្មោហវិនោទនី អដ្ឋកថាថា "ឥមស្មឹ កម្មស្សកតាញាណេ ឋត្វា ពាហុំ ទានំ ទត្វា សីលំ

បូរេត្វា ឧឡោរសិ សមាធិយិត្វា សុខេន សុខំ សម្បត្តិយា សម្បត្តឹ អនុភវិត្វា និព្វានំ បត្វានំ គណនបរិច្ឆេទោ នត្ថិ" ។

*ការកំណត់រាប់ចំនួនរបស់បុគ្គល ចូលកាន់ព្រះនិព្វាន ក្រោយពីបានសោយសេចក្ដីសុខ ក្នុងសម្បត្តិក្រៃលែងៗឡើង ទៅជាលំដាប់ជាប់ៗ គ្នា ដោយអាស្រ័យការតាំងនៅក្នុងកម្មស្សកតាញាណល្អយ៉ាងនោះហើយ បានធ្វើបុណ្យច្រើនគ្រាសង្រួមរវាំងក្នុងសីល ៥ មិនឲ្យសីលដាច់ សមាទានឧបោសថសីលទាំងនេះនោះ រមែងមិនមាន ។*

## ១០.៣ អង្គធម៌របស់ទិដ្ឋធម្មវេទនីយកម្ម ក្នុងខណៈទាំង ៣ របស់ចេតនា

*ទី១-ទិដ្ឋជុកម្ម ក្នុងខណៈដែលជាបុព្វចេតនា បានដល់ មហាកុសលចិត្ត ៨*

*ទី២-ទិដ្ឋជុកម្ម ក្នុងខណៈដែលជាមុញ្ចនចេតនា បានដល់ មហាកុសលញាណសម្បយុត្តចិត្ត ៤*

*ទី៣-ទិដ្ឋជុកម្ម ក្នុងខណៈដែលជាអបរចេតនា*

បានដល់ មហាកុសលចិត្ត ៨ ។

## សេចក្តីអធិប្បាយ

អ្នកដែលមានសេចក្តីឃើញ នៅមិនទាន់ត្រឹមត្រូវចំពោះព្រះពុទ្ធសាសនា ក្នុងរឿងផ្សេងៗ មានការស្លាប់ ការកើត ភូមិជាទីសោយសេចក្តីទុក្ខ មាននរក ប្រេត អសុរកាយ, ភូមិជាទីសោយសេចក្តីសុខ មានសួគ៌ ៦ ជាន់ជាដើម, មនុស្សស្លាប់ហើយកើតជាសត្វតិរច្ឆាន ក៏មាន ជាមនុស្សទៀត ក៏មាន សត្វតិរច្ឆានស្លាប់ហើយ កើតជាមនុស្ស ក៏មាន ជាសត្វតិរច្ឆានទៀត ក៏មាន, កាលខាងក្រោយមក ភ្ញាក់រលឹកដឹងខ្លួនថា ការគិត ការយល់ឃើញរបស់ខ្លួន មិនត្រឹមត្រូវចំពោះព្រះពុទ្ធសាសនា ដូច្នោះ ខ្លួនគួរនឹងធ្វើការសិក្សារៀនសូត្រចំពោះការប្រព្រឹត្តិទៅនៃចិត្ត និងរូបរាងកាយ ដើម្បីនឹងបានការអប់រំការគិតឃើញរបស់ខ្លួនឲ្យត្រឹមត្រូវចំពោះព្រះពុទ្ធសាសនា កាលដែលមកភ្ញាក់រលឹកដឹងខ្លួនបានដូច្នេះ ជាទិដ្ឋុជុកម្ម ក្នុងខណៈដែលជា បុព្វចេតនា ។

កាលគិតឃើញយល់ចូលចិត្ត ដូច្នេះហើយ ក៏ចាប់ផ្ដើមធ្វើការសិក្សារៀនសូត្រ ចំពោះការប្រព្រឹត្តិទៅរបស់វត្ថុដែលមានជីវិតនិងមិនមានជីវិត ក្នុងធម៌ដែលជាគោលទាក់ទងនឹងរឿងនេះ ដោយចំពោះការសិក្សា បានចម្រើនឡើងត្រឹមណា ការយល់ដឹង ការឃើញ ក៏ចម្រើនឡើងទៅតាមលំដាប់ រហូតបានទទួលការយល់ដឹង សេចក្ដីឃើញយ៉ាងច្បាស់ជាក់ស្ដែងក្នុងរឿងការស្លាប់ ការកើត នរក សួគ៌ ជាដើមទាំងនោះថាមានមែន ប៉ុនណា បានយ៉ាងល្អ ការឃើញច្បាស់យ៉ាងនេះពិតជាទិដ្ឋុជុកម្ម ក្នុងខណៈដែលជា **មុញ្ចនចេតនា** ។

ខាងក្រោយពីបានទទួលសេចក្ដីឃើញចូលចិត្ត ឃើញត្រឹមត្រូវ ដោយការសិក្សារៀនសូត្រយ៉ាងល្អហើយ ក៏មកពិចារណាចំពោះសេចក្ដីប្រព្រឹត្តិទៅរបស់ខ្លួនថា កាលមុននេះយើងមានសេចក្ដីយល់ឃើញខុសច្រើនប្រការ ឥឡូវនេះ យើងបានធ្វើការយល់ឃើញរបស់យើងឲ្យល្អ ឲ្យត្រឹមត្រូវ ចំពោះពាក្យអប់រំក្នុងព្រះពុទ្ធសាសនាបានយ៉ាងល្អហើយ ការពិចារណាដូច្នេះឯង ជាទិដ្ឋុជុកម្មក្នុងខណៈដែលជា **អបរចេតនា**, ដោយហេតុនោះ ព្រះមហាពុទ្ធឃោសាចារ្យ ទើបបានសម្ដែង

*ទុកក្នុងបុញ្ញកិរិយាវត្ថាទិកថា អដ្ឋសាលិនី អដ្ឋកថា ថា ៖*

១-"ទិដ្ឋឹ ឧជុកំ ករិស្សាមីតិ ចិន្តេន្តោបិ តេសំយេវ អដ្ឋន្នំ អញ្ញតរេន ចិន្តេតិ" *អ្នកដែលមានការគិតថា យើងនឹងធ្វើសេចក្តីយល់ឃើញរបស់យើង ឲ្យត្រឹមត្រូវ តាមព្រះពុទ្ធសាសនា ការគិតយ៉ាងនេះ ក៏គិតដោយមហាកុសលចិត្ត ៨ ដួង ណាមួយ (ទិដ្ឋុជុកម្មក្នុងខណៈដែលជាបុព្វចេតនា) ។*

២-"ទិដ្ឋឹ ឧជុកំ ករោន្តិ បន ចតុន្នំ ញាណសម្បយុត្តានំ អញ្ញតរេន ករោតិ" *ចំណែកអ្នកដែលធ្វើសេចក្តីយល់ឃើញរបស់ខ្លួន ឲ្យត្រឹមត្រូវដោយការសិក្សាព្រះបរិយត្តិ ឬបដិបត្តិនោះ ជាការធ្វើដោយមហាកុសលញាណសម្បយុត្តចិត្ត ៤ ដួង ណាមួយនោះឯង (ទិដ្ឋុជុកម្មក្នុងខណៈដែលជាមុញ្ចនចេតនា) ។*

៣-"ទិដ្ឋឹ មេ ឧជុកា កតាតិ បច្ចវេក្ខតោ អដ្ឋន្នំ អញ្ញតរេន បច្ចវេក្ខតិ" *អ្នកដែលមានការពិចារណា ក្នុងសេចក្តីយល់ឃើញរបស់ខ្លួនថា យើងបានធ្វើ*

សេចក្ដីយល់ឃើញរបស់ខ្លួនឲ្យត្រឹមត្រូវល្អហើយ ការពិចារណារបស់អ្នកនេះ ជាការពិចារណា ដោយមហាកុសលចិត្ត ៨ ដួងណាមួយនោះ (ទិដ្ឋុជុកម្មក្នុងខណៈដែលជាអបរចេតនា) ។

## ១០.៤ សរុបបុញ្ញកិរិយាវត្ថុ ៧ ប្រការ ចូលក្នុងទាន សីល ភាវនា

បរមត្ថទីបនី អដ្ឋកថា : *បណ្ដាបុញ្ញកិរិយាវត្ថុ ៧ យ៉ាងនោះ បត្តិទានមយៈ និង អនុមោទនាមយៈ ពីរយ៉ាងនេះ សង្គ្រោះចូលក្នុងទានកុសល ឈ្មោះថា* ***ទានមយៈ*** *។*

*អបចាយនៈ និងវេយ្យាវច្ចៈ ពីរយ៉ាងនេះ សង្គ្រោះចូលក្នុងសីលកុសល ឈ្មោះថា* ***សីលមយៈ*** *។*

*ធម្មទេសនា (ការសម្ដែងធម៌) ធម្មស្សវន (ការស្ដាប់ធម៌) និង ទិដ្ឋុជុកម្ម (ការឃើញត្រង់) បីយ៉ាងនេះ សង្គ្រោះចូលក្នុងភាវនាកុសល ឈ្មោះថា* ***ភាវនាមយៈ*** *។*

*(ម្យ៉ាងទៀត) ទិដ្ឋុជុកម្ម សង្គ្រោះចូលក្នុងបុញ្ញកិរិយាវត្ថុទាំង ៣ យ៉ាង ។*

ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុនេះ មាន ៣ យ៉ាង, ៣ យ៉ាងតើដូចម្ដេច ? គឺ ទានមយបុញ្ញកិរិយាវត្ថុ ១ សីលមយបុញ្ញកិរិយាវត្ថុ ១ ភាវនាមយបុញ្ញកិរិយាវត្ថុ ១ ដូច្នេះ ។

ក៏ក្នុងអធិការនេះ បុញ្ញកិរិយាវត្ថុទាំង ៣ យ៉ាង មានការប្រព្រឹត្តទៅដោយអំណាចនៃកុសលចេតនា ដែលជាកាមាវចរ ៨ ដួង ។ ឧបមាថា កាលបុគ្គលសម្ដែងធម៌ ដែលស្ទាត់ជំនាញ ក៏មិនទើកដល់អនុសន្ធិឡើយ ធម៌ពួកខ្លះ ក៏វៀរទៅបានយ៉ាងណា កាលព្រះយោគាវចរប្រកបរឿយៗ នូវសមថភាវនានិងវិបស្សនាភាវនាដែលជំនាញ មនសិការដោយចិត្តដែលជាញាណវិប្បយុត្ត ក៏ប្រព្រឹត្តទៅបានក្នុងចន្លោះៗ (តែ) ទាំងអស់នោះ ជាបុញ្ញកិរិយាវត្ថុដែលសម្រេចដោយចេតនាម្យ៉ាងដោយអំណាចនៃកុសលចេតនាដែលជាមហគ្គតៈ មិនជាបុញ្ញកិរិយាវត្ថុក្រៅនេះទេ (ទានមយៈ សីលមយៈ) ។

## ១០.៥ អធិប្បាយធម៌ជាបដិបក្ខនឹងទានជាដើម

ក្នុងបរមត្ថជោតិកៈ ពោលទុកថា បណ្ដាបុញ្ញកិរិយាវត្ថុទាំងឡាយនេះ **ទានកុសល** ជាបដិបក្ខនឹងឥស្សា គឺ សេចក្ដីមិនពេញចិត្តក្នុងសម្បត្តិ ឬគុណ សេចក្ដីល្អរបស់អ្នកដទៃ និងជាបដិបក្ខនឹងមច្ឆរិយៈ ដែលមានសេចក្ដីស្រឡាញ់ទ្រព្យ-សម្បត្តិ ឬគុណ សេចក្ដីល្អរបស់ខ្លួន ដូច្នោះ អ្នកដែលធ្វើការបរិច្ចាគទាន ទើបចាំបាច់ត្រូវយកឈ្នះឥស្សា មច្ឆរិយៈ ឲ្យបានជាមុនសិន ការបរិច្ចាគទាន ទើបសម្រេចបាន ដែលពោលដូច្នេះ ក៏ព្រោះថា បើនៅមានឥស្សាដរាបណា ក៏នឹងធ្វើឲ្យកើតសេចក្ដីមិនពេញចិត្ត ក្នុងការដែលទ្រព្យសម្បត្តិរបស់ខ្លួនដែលត្រូវអស់ទៅ កាលបើដូច្នេះ ការបរិច្ចាគទាន ក៏សម្រេចមិនបានដូច្នោះ ទានកុសលនេះ ទើបជាបដិបក្ខចំពោះឥស្សា មច្ឆរិយៈទាំង ២ ដូច្នោះ ការបរិច្ចាគទាន សម្រេចបានក្នុងខណៈណាខណៈនោះ ក៏បានឈ្មោះថា ការបង្ក្រាបឥស្សា មច្ឆរិយៈ ទាំង ២ នេះ បានមួយខណៈ ។

ចំណែកការកើតឡើងរបស់**បត្តិទាន** និង **បត្តានុមោទនា** ទាំង ២ នេះ ក៏ដូចគ្នានឹងទានកុសលនោះឯង ពោលគឺ បើអ្នក

ណាទៅមានឥស្សា អ្នកនោះ ក៏នឹងកើតការមិនពេញចិត្តក្នុងការដែលបុគ្គលដទៃបានទទួលអំពីខ្លួន ដោយងាយស្រួល មិនមានការលំបាក បើទៅមានមច្ឆរិយៈ ក៏នឹងកើតការមិនពេញចិត្តក្នុងការបែងចែកកុសលឲ្យដល់បុគ្គលដទៃ កាលជាដូច្នេះ បត្តិទានកុសល ក៏សម្រេចមិនបាន ដូច្នោះ បត្តិទាន-កុសល សម្រេចក្នុងខណៈណា ខណៈនោះ ក៏បានឈ្មោះថាធ្វើការបង្ក្រាបឥស្សា មច្ឆរិយៈ បានមួយខណៈ ។

ក្នុងរវាងបត្តានុមោទនៈ ជាមួយនឹងឥស្សា មច្ឆរិយៈនោះសោត ក៏ដូចគ្នា ពោលគឺ បើទៅមានចិត្តឥស្សា ក៏នឹងកើតសេចក្តីមិនពេញចិត្តក្នុងការបរិច្ចាគទាន រក្សាសីល ចម្រើនភាវនារបស់អ្នកដទៃ ហើយមិនតែប៉ុណ្ណោះ នៅត្រឡប់ឃើញថា ជាការអួតអាង កាលដូច្នេះ ចិត្តគិតនឹងគោរពទទួល (អនុមោទនា) ចំណែកបុណ្យដែលគេចែកឲ្យ ក៏កើតឡើងមិនបាន បើទៅមានមច្ឆរិយៈ ក៏មានតែសេចក្តីហួងហែងក្នុងទ្រព្យសម្បត្តិរបស់ខ្លួន នឹងធ្វើតាមអ្នកដែលគេចែកបុណ្យឲ្យនោះក៏ធ្វើមិនបាន ដូច្នោះ ទើបមិនពេញចិត្ត ទទួលការចែកចំណែកបុណ្យក្នុងការបរិច្ចាគទាន ដែលគេបានចែកឲ្យ បើកាលបែង

បែកបុណ្យនោះ ទាក់ទងនឹងសីលភាវនាហើយ ខ្លួនឯងក៏មិនទាន់លះបង់សេចក្ដីសប្បាយ ត្រេកត្រអាល ឬភ្លើតភ្លើនក្នុងអារម្មណ៍ផ្សេងៗ មករក្សាសីល ចម្រើនភាវនាដូចគ្នា ជាមួយគេក៏ធ្វើមិនបាន ដោយហេតុនេះឯង ទើបមិនមានសេចក្ដីត្រេកអរចំពោះការបែងចែកចំណែកបុណ្យនោះៗ ដូច្នោះ កាលបត្តានុមោទនាកុសល សម្រេចក្នុងខណៈណា ខណៈនោះក៏បានឈ្មោះថា ធ្វើការបង្ក្រាបឥស្សា មច្ឆរិយៈ បានមួយខណៈ ដូច្នោះ បត្តិទាន និងបត្តានុមោទនៈ ទាំង ២ នេះ ទើបមានសភាព ដូចគ្នានឹងទានកុសល ដោយសេចក្ដីជាបដិបក្ខ នឹងឥស្សាមច្ឆរិយៈ អាស្រ័យហេតុនេះឯង លោកទើបចាត់ជាបត្តានុមោទនៈ ចូលក្នុងទានមយកុសល ។

មួយទៀត ការបែងចែកចំណែកបុណ្យនោះ អ្នកធ្វើការបែងចែក រមែងបានកុសលគ្រប់ទាំងបីយ៉ាង ក៏មាន ពីរយ៉ាងក៏មាន មួយយ៉ាងក៏មាន ស្រេចតែការចែកចំណែកបុណ្យដែលទាក់ទងនឹងកុសលនោះៗ សម្រាប់អ្នកអនុមោទនាចំណែកបុណ្យពីគេនោះ បានតែទានមយកុលសម្ប៉ាង មិនថាអ្នកចែកឲ្យគ្រប់ទាំង ៣ ឬ ២-១ ក៏ដោយ ។

*មានអធិប្បាយថា* ៖

*១-អ្នកបរិច្ចាគទាន រក្សាសីល ចម្រើនភាវនា ហើយចែកចំណែកបុណ្យក្តី ឬរក្សាសីល ចម្រើនភាវនា ហើយចែកចំណែកបុណ្យក្តី អ្នកដែលធ្វើការចែកចំណែកបុណ្យនោះ រមែងបានកុសលគ្រប់ទាំង ៣ ប្រការ គឺ សម្រេចទានកុសល សម្រេចសីលកុសល សម្រេចភាវនាកុសល ។*

*២-អ្នកបរិច្ចាគទាន រក្សាសីល ហើយចែកចំណែកបុណ្យក្តី ឬ អ្នកដែលរក្សាសីល ហើយចែកចំណែកបុណ្យក្តី រមែងបានកុសលគ្រប់ទាំង ២ យ៉ាង គឺ សម្រេចទានកុសល សម្រេចសីលកុសល ។*

*៣-អ្នកបរិច្ចាគទាន ចម្រើនភាវនា ហើយចែកចំណែកបុណ្យក្តី ឬ ចម្រើនភាវនា ហើយចែកចំណែកបុណ្យក្តី រមែងបានកុសលគ្រប់ទាំង ២ ប្រការ គឺ ទានមយកុសល ភាវនាមយកុសល ។*

*៤-អ្នកបរិច្ចាគទាន ហើយចែកចំណែកបុណ្យក្តី រមែងបានទានកុសលម្យ៉ាង ។ ដូច្នេះ ក៏ព្រោះថា ការចែកចំណែកបុណ្យក្តី ការអនុមោទនាបុណ្យក្តី ចូលក្នុងទានមយកុសលតែម្យ៉ាង ។*

*អបចាយនៈ វេយ្យាវច្ចៈ ទាំង ២ នេះ ជាចារិត្តសីល គឺការប្រព្រឹត្តិល្អរបស់គ្រហស្ថ និង បព្វជិត ដែលជាសប្បុរសដែលមានសេចក្ដីចេះដឹងក្នុងព្រះពុទ្ធសាសនា យ៉ាងល្អ ហេតុនោះ លោកទើបចាត់ចូលសីលមយកុសល ។*

*ធម្មស្សវន ធម្មទេសនា ទិដ្ឋុជុកម្ម ទាំង ៣ នេះ ជាការងារដែលធ្វើឲ្យកុសលធម៌ ចម្រើនក្រៃលែងៗឡើង ដូចគ្នាការចម្រើនសមថវិបស្សនា ហេតុនោះ លោកទើបចាត់ចូលក្នុងភាវនាមយកុសល ។*

## **១០.៦ ការសង្គ្រោះធម្មទេសនានិងទិដ្ឋុជុកម្ម នំយមួយទៀត តាមអដ្ឋកថា អធិប្បាយពុទ្ធភាសិត**

*ការសម្ដែងធម៌ ការបង្រៀនធម៌ ទាំងនេះ សង្គ្រោះចូលក្នុងទានមយកុសល ក៏បាន ដូចដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ទេសនាថា "**សព្វទានំ ធម្មទានំ ជិនាតិ** : ធម្មទាន ឈ្នះអស់ទានទាំងពួង" ។ ចំណែកទិដ្ឋុជុកម្មនោះ ព្រះមហាពុទ្ធឃោសាចារ្យ បានសម្ដែងទុកក្នុងសង្គីតសូត្រ នៃបាដិកវគ្គអដ្ឋកថាថា "**ទិដ្ឋុជុកម្មំ សព្វេសំ និយមលក្ខណំ**" "ទិដ្ឋុជុកម្មនេះ ជាគ្រឿងកំណត់នៃសេចក្ដីបរិបូរណ៍របស់បុញ្ញកិរិយាវត្ថុ*

ទាំងពួង” មានន័យថា ទិដ្ឋុជុកម្មនេះ សង្គ្រោះចូលទៅក្នុងទានមយៈ សីលមយៈ ភាវនាមយកុសលបានទាំងអស់នោះឯង ដែលលោកពោលដូច្នេះនោះ ក៏ព្រោះទិដ្ឋុជុកម្មនេះ ប្រៀបដូចអ្នកកាប់ចង្កូតទូក ដែលចាំបាច់ត្រូវតែជ្រើសរើសយកកន្លែងទូកឲ្យរត់ត្រង់ ដូច្នោះ ។ ប្រសិនបើខ្វះអ្នកកាប់ចង្កូតទូកហើយ ទូកក៏នឹងរត់ត្រង់ទៅមិនបាន សេចក្តីនេះយ៉ាងណា អ្នកដែលធ្វើការបរិច្ចាគទាន រក្សាសីល ចម្រើនភាវនា បើមិនមានទិដ្ឋុជុកម្មប្រកបផងហើយ ការបញ្ចេញផលរបស់ទាន សីល ភាវនាទាំងនេះ ក៏មិនបរិបូរណ៍ មានការខ្វះខាត មិនពេញលេញ មិនត្រូវគ្នាជាមួយសេចក្តីប្រាថ្នារបស់ខ្លួន ពោលគឺកាលកើតជាមនុស្ស ទេវតា ក៏ឲ្យកើតជាមនុស្សទេវតាជាន់ទាប មានអវយវៈខ្វះខាត ឬស្ងួមិ្បមានអវយវៈគ្រប់គ្រាន់ ក៏ជាអ្នកល្ងង់ខ្លៅ បញ្ញាតិច និងបានទទួលសេចក្តីក្តៅក្រហាយ មិនជាសុខ ក្នុងទ្រព្យសម្បត្តិជារឿយៗ កុសលរបស់បុគ្គលទាំងនេះ កាលពោលដោយអង្គធម៌ ក៏បានដល់ទ្វិហេតុក កុសលឱមកៈ ។

*សម្រាប់កុសលរបស់អ្នកមានទិដ្ឋុជុកម្ម ចូលប្រកបផង នោះ រមែងបញ្ចេញផលមហាសាល តាមសេចក្ដីប្រាថ្នារបស់ខ្លួន ពោលគឺ កាលទឹងកើតជាមនុស្ស ទេវតា ក៏កើតជាមនុស្ស ទេវតាដែលល្អ មានអវយវៈបរិបូរណ៍គ្រប់គ្រាន់ល្អ ស្អាត មានសតិបញ្ញា ឆ្លាតវាងវៃ បានទទួលសេចក្ដីសុខកាយ សប្បាយចិត្ត ក្នុងទ្រព្យសម្បត្តិជានិច្ច កុសលរបស់បុគ្គលទាំងនេះ កាលពោលដោយអដ្ឋធម៌ហើយ បានដល់* ***តិហេតុកកុសលឧក្កដ្ឋ*** *ឬថ្នាក់ទាបចុះមក ក៏បានដល់* ***តិហេតុកកុសលឱមក*** *។*

**។ ចប់ ។**

# ១១_និធិកណ្ឌសូត្រ

និធឹ និធេតិ បុរិសោ គម្ភីរេ ឱទកន្តិកេ[៧]
អត្ថេ កិច្ចេ សមុប្បន្នេ អត្ថាយ មេ ភវិស្សតិ
រាជតោ វា ទុរុត្តស្ស ចោរតោ បីឡិតស្ស វា
ឥណស្ស វា បមោក្ខាយ ទុព្ភិក្ខេ អាបទាសុ វា
ឯតទត្ថាយ លោកស្មឹ និធិ នាម និធិយ្យតិ ។

*បុរសកប់កំណប់ទ្រព្យទុកក្នុងទីជ្រៅ ជាទីបំផុតនៃទឹក ដោយគិតថា កាលបើកិច្ចដែលត្រូវការ កើតឡើងហើយ ទ្រព្យនេះនឹងបានជាប្រយោជន៍ដល់អាត្មាអញ ដែលត្រូវពួកបច្ចាមិត្តពោលបង្កាច់ នឹងបានដោះខ្លួនចេញពីស្តេច ឬត្រូវចោរបៀតបៀន នឹងបានដោះខ្លួនចេញពីចោរ នឹងបានដោះបំណុល ឬក្នុងពេលទុរភិក្ស ឬក៏ក្នុងកាលអន្តរាយទាំងឡាយ ជម្មតាកំណប់ដែលគេកប់ទុកក្នុងលោក ដើម្បីប្រយោជន៍នេះឯង ។*

តាវស្សុ និហិតោ សន្តោ គម្ភីរេ ឱទកន្តិកេ

---

៧ ឱ. ឧទកន្តិកេ ។ អដ្ឋកថាយំ ព្យុទិសោយេវ ហោតិ ។

ន សព្វោ សព្វទាយេវ[៨] តស្ស តំ ឧបកប្បតិ
និធិ វា ឋានា ចវតិ សញ្ញា វាស្ស វិមុយ្ហតិ
នាគា វា អបនាមេន្តិ យក្ខា វាបិ រហន្តិ នំ
អប្បិយា វាបិ ទាយាទា ឧទ្ធរន្តិ អបស្សតោ
យទា បុញ្ញក្ខយោ ហោតិ សព្វមេតំ វិនស្សតិ ។

*កំណប់ដែលបុគ្គលកប់ក្នុងទីជ្រៅ មានទីបំផុតទល់នឹងទឹកដល់ម៉្លោះ កំណប់ទ្រព្យទាំងអស់នោះ ក៏មិនសម្រេចដល់បុគ្គលនោះសព្វកាលទេ ដ្បិតថា កំណប់ទ្រព្យរមែងឃ្លាតទៅចាកទីខ្លះ សេចក្ដីចំណាំរបស់បុគ្គលនោះ រមែងវង្វេងទៅខ្លះ នាគទាំងឡាយ រមែងនាំជញ្ជូនទៅខ្លះ ពុំនោះសោត ពួកយក្ស នាំយកទ្រព្យនោះទៅខ្លះ អ្នកទទួលមត៌ក ដែលមិនជាទីស្រឡាញ់ រមែងគាស់យកនូវកំណប់ទ្រព្យនោះ កាលខ្លួនមិនឃើញខ្លះ ខ្លួនអស់បុណ្យទៅវេលាណា កំណប់ទាំងអស់នោះ រមែងវិនាសបាត់បង់ទៅក្នុងវេលានោះ ។*

យស្ស ទានេន សីលេន សញ្ញមេន[៩] ទមេន ច

---

៨ ឱ.ម. ឯវំ ។ ៩ ឱ.ម. សំយមេន ។

និធិ សុនិហិតោ ហោតិ ឥត្ថិយា បុរិសស្ស វា
ចេតិយម្ហិ ច[១០] សង្ឃេ វា បុគ្គលេ អតិថីសុ វា
មាតរិ បិតរិ វាបិ[១១] អថោ ជេដ្ឋម្ហិ ភាតរិ
ឯសោ និធិ សុនិហិតោ អជេយ្យោ អនុគាមិកោ
បហាយ គមនីយេសុ ឯតំ អាទាយ គច្ឆតិ
អសាធារណមញ្ញេសំ អចោរហរណោ[១២] និធិ ។

*កំណប់ទ្រព្យដែលស្ត្រី ឬ បុរសណា បានកប់ទុកល្អហើយ ដោយទាន សីល ដោយការសង្រួម និងដោយការទូន្មានខ្លួន ក្នុងចេតិយ ក្នុងសង្ឃ ក្នុងបុគ្គល ក្នុងពួកភ្ញៀវ ឬមួយក្នុងមាតា ក្នុងបិតា ឬថា ក្នុងបងប្រុស-ស្រី ដែលជាច្បង កំណប់ទ្រព្យនុ៎ះ ចាត់ជាកំណប់ទ្រព្យដែលកប់ទុកប្រពៃហើយ នរណាៗ មិនគប្បីផ្ចាញ់បានជាកំណប់ទ្រព្យ ដែលជាប់តាមខ្លួនទៅ កាលភោគៈទាំងឡាយដែលខ្លួនត្រូវលះបង់ហើយទៅ ខ្លួនរមែងកាន់យកនូវកំណប់ទ្រព្យ គឺបុណ្យនុ៎ះទៅ កំណប់ទ្រព្យ គឺ*

១០ ឱ. វ ។ ១១ ម. ចាបិ ។ ១២ ឱ.ម. អចោរាហរណោ ។

បុណ្យ មិនទួទៅដល់ពួកជនដទៃ ជារបស់ដែលចោរលួចទៅមិនបាន ។

កយិរាថ ធីរោ បុញ្ញានិ យោ និធិ អនុគាមិកោ
ឯស ទេវមនុស្សានំ សព្វកាមទទោ និធិ
យំ យំ ទេវាភិបត្ថេន្តិ សព្វមេតេន លព្ភតិ ។

កំណាប់ទ្រព្យ គឺ បុណ្យណា ជាប់តាមខ្លួនទៅបាន អ្នកប្រាជ្ញ គួរធ្វើនូវកំណាប់ទ្រព្យ គឺបុណ្យនោះ កំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដល់ទេវតានិងមនុស្សទាំងឡាយ ពួកទេវតានិងមនុស្សទាំងឡាយ ប្រាថ្នាណាស់នូវផលណាៗ ផលទាំងពួងនោះៗ រមែងបានដោយកំណាប់ទ្រព្យ គឺ បុណ្យនុ៎ះ ។

សុវណ្ណតា សុសរតា សុសណ្ឋានំ សុរូបតា
អាធិបច្ចំ[១៣] បរិវារោ សព្វមេតេន លព្ភតិ ។

ភាពជាអ្នកមានពណ៌សម្បុរផូរផង់ មានសំឡេងពីរោះ ទ្រង់ទ្រាយល្អ រូបល្អ ជាអធិបតី មានយសបរិវារ ផលទាំងអស់ រមែងបានដោយកំណាប់ទ្រព្យ គឺបុណ្យនុ៎ះ ។

---

១៣ ឱ.ម. អធិបច្ចំ ។

បទេសរជ្ជំ ឥស្សរិយំ ចក្កវត្តិសុខំ បិយំ
ទេវរជ្ជម្បិ ទិព្វេសុ សព្វមេតេន លព្ភតិ ។

*ភាពជាស្តេចប្រទេសរាជ ឥស្សរិយយស សេចក្តីសុខរបស់ស្តេចចក្រពត្តិ ជាទីស្រឡាញ់ ភាពជាស្តេចនៃទេវតា ក្នុងទេពនិកាយទាំងឡាយ ផលទាំងអស់ រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។*

មានុស្សិកា ច សម្បត្តិ ទេវលោកេ ច យា រតិ
យា ច និព្វានសម្បត្តិ សព្វមេតេន លព្ភតិ ។

*សម្បត្តិជារបស់មនុស្សណាផង សេចក្តីត្រេកអរ ក្នុងទេវលោកណាផង សម្បត្តិ គឺព្រះនិព្វានណាផង សម្បត្តិទាំងអស់ រមែងបានដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។*

មិត្តសម្បទមាគម្ម យោនិសោ វេ បយុញ្ជតោ
វិជ្ជាវិមុត្តិវសីភាវោ សព្វមេតេន លព្ភតិ ។

*ភាពនៃបុគ្គល កាលអាស្រ័យមិត្តសម្បទា បើប្រកបសេចក្តីព្យាយាម ដោយឧបាយដែលត្រូវ ជាអ្នកស្ទាត់ក្នុងវិជ្ជា និងវិមុត្តិ ឥដ្ឋផលទាំងអស់ បានដោយកំណប់ទ្រព្យ គឺបុណ្យនោះ ។*

បដិសម្ភិទា វិមោក្ខា[14] ច យា ច សាវកបារមី
បច្ចេកពោធិ ពុទ្ធភូមិ សព្វមេតេន លព្ភតិ ។

*បដិសម្ភិទា វិមោក្ខ សាវកបារមីញាណ បច្ចេកពោធិ-ញាណ និងពុទ្ធភូមិណាៗ ឥដ្ឋផលទាំងអស់ រមែងបាន ដោយកំណប់ទ្រព្យ គឺបុណ្យនុ៎ះ ។*

ឯវំ មហត្ថិកា[15] ឯសា យទិទំ បុញ្ញសម្បទា
តស្មា ធីរា បសំសន្តិ បណ្ឌិតា កតបុញ្ញតន្តិ ។

*បុញ្ញសម្បទានេះ ឲ្យសម្រេចប្រយោជន៍ដ៏ធំ ដោយប្រការដូច្នេះ ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ជាធីរជន ទើបសរសើរនូវភាពនៃបុគ្គល ជាអ្នកមានបុណ្យធ្វើទុកហើយ ។*

**ចប់ និធិកណ្ឌសូត្រ ៦**

*(ចាកសុត្តន្តបិដក ភាគ ៥២ ទំព័រ ១៥-១៨)*

---

[14] ម. វិមោក្ខោ ។ [15] ម. មហិទ្ធិកា ។

## អដ្ឋកថា

***និធិ*** *(កំណប់ទ្រព្យ) នោះមាន ៤ យ៉ាង គឺ* ***ថាវរនិធិ ជង្គមនិធិ អង្គសមនិធិ អនុគាមិកនិធិ*** *។*

*បណ្ដានិធិ ៤ នោះ ទ្រព្យដែលជាប់ផែនដីក្ដី ទ្រព្យដែលតាំងនៅក្នុងអាកាសក្ដី ប្រាក់ក្ដី មាសក្ដី ស្រែក្ដី ទីដីក្ដី, ឬក៏ទ្រព្យបែបនោះសូម្បីដទៃណា ដែលវៀរចាកការឃ្លាតចាកទីដោយខ្លួនឯង ឈ្មោះថា* ***ថាវរៈ*** *(មាំមួន) ទ្រព្យនេះឈ្មោះថា* ***ថាវរនិធិ*** *។ ទាសី ទាសៈ ដំរី គោ សេះ លា ពពែ កែះ មាន់ជ្រូក, ឬក៏ថា ទ្រព្យបែបនោះសូម្បីដទៃណា ដែលប្រកបដោយការឃ្លាតចាកទីបានដោយខ្លួនឯង ឈ្មោះថា ជង្គមៈ (ដើរទៅបាន) ទ្រព្យនេះឈ្មោះថា* ***ជង្គមនិធិ*** *។ ពហុសច្ចៈ (ភាពជាពហុស្សូត) ដែលជាប្រភពកើតការងារ ប្រភពកើតសិល្បៈទីតាំងនៃវិជ្ជា, ក៏ឬថា ពហុសច្ចៈបែបនោះ សូម្បីដទៃណា ដែលសិក្សាហើយសិក្សាទៀត ជំនាញជាប់ខ្លួន ដូចជាអវយវៈធំតូចឈ្មោះថា* ***អង្គសមៈ*** *(ស្មើដោយអវយវៈ) ទ្រព្យនេះឈ្មោះថា* ***អង្គសមនិធិ*** *។ បុណ្យដែលសម្រេចដោយទាន ដែលសម្រេចដោយសីល ដែលសម្រេចដោយភាវនា ដែលសម្រេចដោយ*

*ការស្តាប់ធម៌ ដែលសម្រេចដោយការសម្តែងធម៌, ក៏ឬថា បុណ្យបែបនោះ សូម្បីដទៃណា តាមឲ្យផលដែលគួរប្រាថ្នា ហាក់ដូចជាប់តាមទៅក្នុងទីនោះៗ ឈ្មោះថា* **អនុគាមិកៈ** *(ជាប់តាមទៅបាន), ទ្រព្យនេះ ឈ្មោះថា* **អនុគាមិកនិធិ** ។

**គម្ពីរដែលជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ**

១-ព្រះត្រៃបិដក

២-អដ្ឋកថា សមន្តប្បាសាទិកា

៣-អដ្ឋកថា សុមង្គលវិលាសិនី

៤-អដ្ឋកថា មនោរថបូរណី

៥-អដ្ឋកថា បរមត្ថជោតិកា

៦-ធម្មបទដ្ឋកថា

៧-អដ្ឋកថា បរមត្ថទីបនី

៨-បរមត្ថជោតិកៈ មង្គលត្ថទីបនី

៩-វិសុទ្ធិមគ្គ (សីលនិទ្ទេស)

អក្ខរាវិរុទ្ធ សរសេរតាមវចនានុក្រមខ្មែរ របស់សម្តេច

ព្រះសង្ឃរាជ ជោតញ្ញាណោ **ជួន-ណាត** ។